# សង្កេតការណ៍

## ២៩

## ជំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



ប្រជាជនកម្ពុជាចូលរួមអបអរសាទរខួបជ័យជម្នះលើរបបខ្មែរក្រហមនៅខេត្តសៀមរាប នាដើមទសវត្សរ៍៨០
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org
ខែតុលា-វិច្ឆិកា ឆ្នាំ២០១៣

# មាតិកា

ខែតុលា-វិច្ឆិកា ឆ្នាំ២០១៣



សេចក្តីសន្និដ្ឋានបិទបញ្ចប់សំណុំរឿង០០២/០១
៣ ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
១៣ ដោយសហព្រះរាជអាជ្ញា
៣២ ដោយក្រុមមេធាវីការពារក្តី នួន ជា
៥៨ ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន

ក្រុមសង្ខេតការណ៍ ៖
លឹម ជ័យទ័ត្ត, ឌី សុជាតា,
ចាន ប្រាថ្នា, និង ទួន ឡៃហុល

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ វ៉ាន់ថាន់ ពៅដារ៉ា

ខៀវ សំផន (ជួរមុខខាងស្តាំ) កំពុងនាំគណៈប្រតិភូ ភូមា ដឹកនាំដោយប្រធានាធិបតី នេ វិន ទស្សនកិច្ចប្រាសាទអង្គរវត្ត ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្ដីពីការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០១ : ការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

### ថ្ងៃទី១៦-៣១ ខែតុលា ឆ្នាំ២០១៣

## *សេចក្ដីផ្ដើម*

ចន្លោះចាប់ពីថ្ងៃទី១៦ និង៣១ ខែតុលា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា បានបើកសវនាការចំនួន១០ថ្ងៃ ទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០១ ។ បើយោងតាមប្រធានអង្គជំនុំជម្រះសាលាដំបូង លោកចៅក្រម និល ណុន ការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នេះធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការចំនួន ២១២ ថ្ងៃ ដើម្បីស្ដាប់ការពិភាក្សាសួរដេញដោលរបស់ភាគីទាំងអស់លើសក្ខីកម្មរបស់សាក្សី ៥៧រូប អ្នកជំនាញ ៣រូប និងដើមបណ្ដឹងរដ្ឋប្បវេណី ៣២រូប ។ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការសរុបចំនួន ២២២ថ្ងៃលើសំណុំរឿង០០២/០១ ។

នៅក្នុងសវនាការស្ដីពីការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ឱកាសជូនភាគីទាំងអស់ ដើម្បីអាចធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយទៅតាមការកំណត់រៀងៗខ្លួន ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ដល់ឱកាសឲ្យធ្វើសេចក្ដីសន្និដ្ឋានមុនភាគីផ្សេងៗ ក្នុងរយៈពេលមួយថ្ងៃពេញ ។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដោតសំខាន់លើបញ្ហាទូទៅនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការបង្ហាញឧក្រិដ្ឋកម្ម ទាំងនោះ និងការទទួលខុសត្រូវរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ សហព្រះរាជអាជ្ញា មានពេលវេលាចំនួនបីថ្ងៃក្នុងការធ្វើសេចក្ដី



យោធាខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សន្និដ្ឋានរបស់ខ្លួនដោយផ្ដោតសំខាន់លើចំណុចមួយចំនួនពាក់ព័ន្ធនឹងភស្តុតាងស្ដីពីបទឧក្រិដ្ឋជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ ដែនការឧក្រិដ្ឋពាក់ព័ន្ធនឹងការសម្លាប់ទាហាន និងមន្ត្រីសាធារណៈរដ្ឋខ្មែរ និងបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ, តួនាទី និងអត្តចរិករបស់ជនជាប់ចោទនៅមុនក្នុងអំឡុងពេលនិងក្រោយ ឆ្នាំ១៩៧៥, ការសន្និដ្ឋានស្ដីពីការ និងការចូលរួមសំខាន់នៅក្នុងផែនការសហឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវការរៀបចំផែនការទទួលខុសត្រូវ និងការជម្រុញ និងការញុះញង់ឲ្យមានប្រព្រឹត្តឧក្រិដ្ឋកម្ម ព្រមទាំងការខកខានការទប់ស្កាត់ឧក្រិដ្ឋកម្មក្នុងនាមជាថ្នាក់លើ ឬការដាក់ទោសជនដែដល់ និងការកំណត់ទោស ។ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលរួមគ្នាចំនួនមួយថ្ងៃទៀត ដើម្បីឆ្លើយតបនឹងមេធាវីការពារក្ដី ។ ចំណែកឯមេធាវីការពារក្ដីទាំងពីរក្រុមវិញ គឺមានឱកាសធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០១ ចំនួន៤ថ្ងៃ ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ទទួលបានពេលវេលាមួយថ្ងៃសម្រាប់ធ្វើសេចក្ដីថ្លែងការណ៍នៅថ្ងៃចុងក្រោយ ។ ក្រុមមេធាវីការពារក្ដី នួន ជា បានលើកឡើងដោយសង្កត់ធ្ងន់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់កូនក្ដីខ្លួន ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងការឆ្លើយតបទៅនឹងការសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការសម្លាប់អតីតមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងទី២ ។ ជនជាប់ចោទ នួន ជា ផ្ទាល់បានធ្វើសេចក្ដីថ្លែងការណ៍នៅថ្ងៃចុងក្រោយនៃសវនាការនេះ ដោយឆ្លើយតបស្ទើរតែគ្រប់ចំណុចចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងលើកឡើងថា កិច្ចដំណើរការជំនុំជម្រះ គឺពុំមានភាពយុត្តិធម៌នោះទេ ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានធ្វើសេចក្ដីសន្និដ្ឋានដោយផ្ដោតសំខាន់លើវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង និងលើកឡើងពីអត្តចរិក និងតួនាទីរបស់ ខៀវ សំផន ហើយឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការជម្លៀសប្រជាជន ការចោទប្រកាន់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម និងការសម្លាប់អតីតមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ ជនជាប់ចោទ ខៀវ សំផន ក៏បានធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងមូលហេតុដែលមិនឆ្លើយតបសំណួររបស់ភាគីនាពេលកន្លងមក ។ គួរបញ្ជាក់ថា នៅក្នុងសវនាការនេះ ភាគីទាំងអស់បានដាក់បង្ហាញឯកសារភស្តុតាងរួមមាន ឯកសារដកស្រង់អត្ថបទ រូបភាព វីដេអូខ្លីៗ និងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីគាំទ្រអំណះអំណាងរៀងៗខ្លួន ។



យោធាខ្មែរក្រហមចូលឆែកឆេរលំនៅដ្ឋាន ក្នុងទីក្រុងភ្នំពេញក្រោយពេលប្រជាជនត្រូវជម្លៀសចេញពីទីក្រុង
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សេចក្តីសន្និដ្ឋានបិទបញ្ចប់សំណុំរឿង០០២/០១ ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់សំណុំរឿង០០២/០១ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល១ថ្ងៃពេញ ដើម្បីសន្និដ្ឋានអំពីអង្គហេតុដែលត្រូវចោទប្រកាន់ នួន ជា និង ខៀវ សំផន និងការទាមទារសំណងជាស្ថាពរ ។ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើងតាមលំដាប់លំដោយ ពីមេធាវី ពេជ អង្គ, ហុង គឹមសួន, សំ សុគង់, ទី ស្រ៊ីនណា, គ្រីស្ទីន ម៉ាទីណូ និង អេលីហ្សាបេិត ស៊ីម៉ូណូហ្វត ។

## ១) អង្គហេតុដែលត្រូវចោទប្រកាន់ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្ម

ជាកិច្ចផ្តើមដំបូង មេធាវី ពេជ អង្គ លើកឡើងអំពីបញ្ហាទូទៅនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ មេធាវី ពេជ អង្គ បានអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីយ៉ាងសំខាន់នៅគ្រប់កិច្ច ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ហើយតួនាទីនេះគប្បីដាក់បញ្ចូលនៅសាលក្រមរបស់តុលាការដោយឈរលើមូលដ្ឋានចំនួនបីចំណុចដូចខាងក្រោម ៖

ទី១) ជាប្រវត្តិសាស្រ្ត ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មដែលមានលក្ខណៈធំធេង និងធ្ងន់ធ្ងរ ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះសេចក្តី ហើយត្រូវបានទទួលស្គាល់ជាភាគីពេញសិទ្ធិដូចសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីដែរ ដែលកត្តានេះពុំធ្លាប់មានសម្រាប់តុលាការអន្តរជាតិផ្សេងៗទៀតនោះទេ ។

ទី២) ភស្តុតាងដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីមានសារៈសំខាន់ និងអាចជឿជាក់បាន ។ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥៧៤រូបដែលរួមបញ្ចូលទាំងព័ត៌មានផ្សេងៗទៀត ត្រូវបានទទួលធ្វើជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម និងការថ្លែងទុក្ខសោកដែលជាផលប៉ះពាល់ដោយសារឧក្រិដ្ឋកម្ម និងគោលនយោបាយទាំង៥របស់បក្សកុម្មុយនីស្តកម្ពុជា ។ សក្ខីកម្មទាំងនោះបានបង្ហាញពីទិដ្ឋភាពរួមនៃឧក្រិដ្ឋកម្ម ដែលមានលក្ខណៈជាប្រព័ន្ធ និងវាយប្រហារជាទូទៅមកលើប្រជាជនកម្ពុជា?

ទី៣) តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានសារៈសំខាន់ក្នុងការផ្សះផ្សាជាតិ ។ ការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការឈឺចាប់ និងផលប៉ះពាល់ដែលកើតចេញពីបទឧក្រិដ្ឋកម្មទាំងនោះ អាចធ្វើឲ្យតុលាការស្វែងរកយុត្តិធម៌ជូនដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗទៀត ដែលរង់ចាំយុត្តិធម៌អស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ សក្ខីកម្ម និងកំណត់ហេតុផ្សេងៗទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃខ្ពស់ ដែលអាចឲ្យអង្គជំនុំជម្រះជឿជាក់បានក្នុងការចោទប្រកាន់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញការពិតនូវអ្វី ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអាចជួយឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការសម្រេចសេចក្តីលើសំណុំរឿង ០០២/០១ ។

បន្ទាប់ពីមេធាវី ពេជ អង្គ បញ្ចប់បទអន្តរាគមន៍ខាងលើ មេធាវី ហុង គឹមសួន បានបន្តធ្វើសេចក្តីសន្និដ្ឋាន ដោយលើកឡើងអំពីគោលបំណងនៃសហឧក្រិដ្ឋកម្មរួម ការជម្លៀសប្រជាជនសហករណ៍ និងការដ្ឋានធ្វើការ និងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ដែលជាធាតុផ្សំនៃគោលនយោបាយទាំង៥របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ២) គោលបំណងនៃសហឧក្រិដ្ឋកម្មរួម

មេធាវី ហុង គឹមសួន បានលើកឡើងថា គោលបំណងរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺអនុវត្តបដិវត្តសង្គមនិយម

នៅប្រទេសកម្ពុជាឲ្យបានឆាប់រហ័សតាមរយៈពាក្យស្លោក"មហាលោតផ្លោះ មហាអស្ចារ្យ" ។ ដើម្បីសម្រេចគោលបំណងនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពុំបានគិតអំពីសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋឡើយ ហើយបានបង្កើតគោលនយោបាយចំនួន ៥ ៖ ទី១) ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនផ្សេងៗពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ។ ទី២) ការបង្កើតសហករណ៍ និងការដ្ឋានលើកទំនប់ជីកប្រឡាយ ។ ទី៣) ការអប់រំ និងការកសាងធាតុអាក្រក់ ការសម្លាប់ ឬកម្ទេចខ្មាំងខាងក្នុង និងខាងក្រៅជួរបក្សទាំងអស់ ។ ទី៤) ការផ្តោតសំខាន់ទៅលើក្រុមមនុស្សជាក់លាក់ ជាពិសេសប្រជាជនថ្មី ឬប្រជាជន ១៧ មេសា ជនជាតិចាម វៀតណាម ព្រះសង្ឃ អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ។ ទី៥) បទបញ្ញត្តិបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍តាមរយៈការចាប់ដៃ ។

មេធាវី ហុង គីមសួន បានអះអាងថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មិនត្រឹមតែចង់ឲ្យបដិវត្តន៍របស់ខ្លួនលឿនរហ័សជាងបដិវត្តន៍ម៉ៅនិយមនោះទេ គឺថែមទាំងចង់ឲ្យសង្គមកម្ពុជាយកគំរូតាមវណ្ណៈកសិករ និងកម្មករដែលកត្តាទាំងនេះធ្វើឲ្យសង្គមកម្ពុជាត្រូវបានបំផ្លាញចោល ។ តាមការអះអាងខាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនលើសលុប បានបង្ហាញអំពីវត្តមាននៃគោលនយោបាយទាំង៥ ដែលជាគោលបំណងនៃសហឧក្រិដ្ឋកម្មរួមរបស់បក្សកុម្មុយនីស្តកម្ពុជា ។

### ក) ការជម្លៀសប្រជាជនដោយបង្ខំ

មេធាវី ហុង គីមសួន បានលើកឡើងថា ប្រជាជនត្រូវបានជម្លៀសដោយបង្ខំឲ្យចេញពីទីក្រុង និងទីប្រជុំជនផ្សេងទៀតពីកន្លែងមួយទៅកន្លែងមួយទៀត ។ គោលបំណងនៃការជម្លៀសនេះ ដើម្បីធានាថា សហករណ៍ និងការដ្ឋានត្រូវបានផ្គត់ផ្គង់កម្លាំងពលកម្មគ្រប់គ្រាន់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការបង្កបង្កើតផល នៅតាមមូលដ្ឋាន ដើម្បីសម្រេចបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ ។ ដើម្បីសម្រេចគោលបំណងនេះ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់ និងហួសកម្លាំង ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានគោលបំណងកែទម្រង់ប្រជាជនកម្ពុជាឲ្យចូលក្នុងវណ្ណៈកសិករទាំងមូល និងដើម្បីគ្រប់គ្រងទីក្រុងឲ្យមានប្រសិទ្ធិភាពជៀសវាងខ្មាំងលាក់ខ្លួននៅក្នុងទីក្រុង ។ ការជម្លៀសប្រជាជន ដោយបង្ខំត្រូវបានបក្សកុម្មុយនីស្តកម្ពុជាអនុវត្តតាំងពីមុនឆ្នាំ១៩៧៥ ហើយបន្តរហូតដល់ឆ្នាំ១៩៧៧ ។ ប្រជាជនដែលត្រូវបានជម្លៀស ពុំត្រូវបានបក្សជូនដំណឹងជាមុនឡើយ ឬមានការជូនដំណឹងបន្តិចបន្តួចតែប៉ុណ្ណោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានផ្តល់សក្ខីកម្មថា អ្នកដែលបដិសេធមិនចេញពីផ្ទះត្រូវយោធាខ្មែរក្រហមគំរាមបាញ់សម្លាប់ចោល ។ មេធាវីបញ្ជាក់ថា ការជម្លៀសដោយបង្ខំត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានការជម្លៀសនៅខេត្តកំពង់ចាម ក្រុងខុដុង្គ កំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី ស្វាយរៀង និងខេត្តកណ្តាល ។ បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ បក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមអនុវត្តគោលនយោបាយរបស់ខ្លួនដោយជម្លៀសប្រជាជនទាំងអស់ចេញពីក្រុងយកទៅធ្វើការនៅតាមសហករណ៍ និងការដ្ឋានផ្សេងៗនៅតាមមូលដ្ឋាន ។

តាមការលើកឡើងរបស់មេធាវី ហុង គីមសួន ការជម្លៀសប្រជាជនត្រូវបានបែងចែកជាពីរដំណាក់កាលធំៗ ។ ដំណាក់កាលទី១ ៖ ជាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសនៅខេត្តបាត់ដំបង ក្រុងកំពង់សោម កំពង់ស្ពឺ ពោធិ៍សាត់ កណ្តាល កំពត សៀមរាប និងតាកែវ ដែលត្រូវបានធ្វើភ្លាមៗបន្ទាប់ពីការជម្លៀសនៅភ្នំពេញ ។ ប្រជាជនត្រូវបានណែនាំមិនឲ្យយកទ្រព្យសម្បត្តិតាមខ្លួនច្រើនឡើយ ។ដំណាក់កាលទី២ ៖ ខ្មែរក្រហមជម្លៀសប្រជាជនពីភូមិភាគកណ្តាល ភូមិភាគឧត្តរចាស់ ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ទៅភូមិភាគពាយ័ព្យ និងប៉ែកខាងជើងនៃប្រទេស ។ មេធាវីបានអះអាងថា ការជម្លៀសទាំងនោះត្រូវបានធ្វើក្នុងលក្ខខណ្ឌអមនុស្សធម៌ ។ ប្រជាជនត្រូវធ្វើដំណើរជាច្រើនថ្ងៃដោយថ្មើរជើង គ្មានការដឹកជញ្ជូន គ្មានម្ហូបអាហារ គ្មានថ្នាំសង្កូវ ពោលគឺពុំមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាឡើយ ដែលជាហេតុធ្វើឲ្យប្រជាជនស្លាប់ជាច្រើននៅក្នុងអំឡុងពេលជម្លៀសនោះ ។

មេធាវី ហុង គីមសួន បានអះអាងទៀតថា ប្រជាជន ១៧ មេសា ជាកម្មវត្ថុ ឬជាគោលដៅនៃការជម្លៀសដោយបង្ខំ ។ ក្រោ

ពីនេះ ក្រុមជាក់លាក់មួយចំនួន ដូចជា អ្នកជាប់និន្នាការទៅនឹងរបប លន់ នល់ ប្រជាជនខ្មែរក្រោម ព្រះសង្ឃ ។ល។ ក៏ត្រូវបានកំណត់មុខសញ្ញាដើម្បីជម្លៀសដែរ ។ ផលប៉ះពាល់នៃការជម្លៀសនេះ បានបណ្តាលឲ្យមានការបាត់បង់ជីវិតទ្រព្យសម្បត្តិ បែកបាក់គ្រួសារ ការវាយដំធ្វើបាប និងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ មេធាវី ហុង គីមសួន បានអះអាងថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានដឹង និងបានចូលរួមក្នុងការបង្កើត និងអនុវត្តគោលនយោបាយនៃការជម្លៀសទាំងនោះ ។ ជាក់ស្តែង នួន ជា បានទទួលស្គាល់ថា ពិតជាមានផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប្រាកដមែន ។ ខៀវ សំផន និង អៀង សារី ធ្លាប់បានចូលរួមកិច្ចប្រជុំជាមួយ ប៉ុល ពត ដើម្បីពិភាក្សាអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។

### ១) សហករណ៍ និងការដ្ឋានធ្វើការងារ

មេធាវី ហុង គីមសួន បានបញ្ជាក់ថា សហករណ៍ និងការដ្ឋាន ត្រូវបានបង្កើតឡើងដើម្បីអនុវត្ត គោលនយោបាយរបស់បក្ស ។ បក្សកុម្មុយនីស្តកម្ពុជាមានគោលបំណងសំខាន់ៗចំនួន៣ ។ ទី១) បក្សកុម្មុយនីស្តកម្ពុជាមានបំណងកសាងសង្គមដោយផ្អែកលើ សមូហភាព បំបាត់វិស័យឯកជន និងបំផ្លាញរចនាសម្ព័ន្ធសង្គម ។ ទី២) ដើម្បីផ្តល់នូវម្ហូបអាហារ និងការប្រើប្រាស់ក្នុងស្រុក និងនាំចេញ ។ បក្សមានបំណងបង្កើតសហករណ៍កម្រិតខ្ពស់ និងបង្កបង្កើនផលស្រូវឲ្យបាន៣តោនក្នុងមួយហិកតា ។ ភាពជាមនុស្សត្រូវបានបាត់បង់ដោយសារប្រជាជនត្រូវបានដាក់ឲ្យធ្វើការជាទម្ងន់ ទ្រព្យសម្បត្តិឯកជន ត្រូវបានលុបបំបាត់ សេរីភាពធ្វើដំណើរត្រូវបានហាមឃាត់ ។ ប្រជាជនត្រូវបានបែងចែកជា៣ប្រភេទ រួមមាន ប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម និងប្រជាជនបញ្ញើដែលជាប្រជាជនថ្មី ។ ប្រជាជនថ្មីត្រូវបានកំណត់ ថាជាសត្រូវ ជាចក្រពត្តិ និងមូលធននិយម ដែលកេងប្រវ័ញ្ចលើប្រជាកសិករ ។ ទី៣) ដើម្បីត្រួតពិនិត្យសង្គម និងកែទម្រង់សតិអារម្មណ៍ប្រជាជន ។ មេធាវី ហុង គីមសួន បានលើកឡើងថា ប្រជាជនត្រូវបានដាក់នៅក្នុងសហករណ៍ដើម្បីតាមដានការអនុវត្តការងារ និងចូលរួមកិច្ចប្រជុំស្វ័យទិតៀនជាប្រចាំ ។ លើសពីនេះទៀត ប្រជាជនទាំងនោះត្រូវបានតម្រូវឲ្យសរសេរជីវប្រវត្តិ ដើម្បីជាមធ្យោបាយក្នុងការកំណត់ខ្មាំង ។ ប្រជាជនជាច្រើន ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ដោយរងការចោទប្រកាន់ ថាជាខ្មាំង ។


ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងបន្ទប់សវនាការ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មេធាវី ហុង គឹមសួន បានអះអាងថា នួន ជា និង ខៀវ សំផន ជាអ្នកបង្កើតគោលនយោបាយបង្កើតសហករណ៍ និងពិនិត្យមើលការអនុវត្តគោលនយោបាយនេះ តាមរយៈការចុះទៅពិនិត្យមើលសហករណ៍ និងតំបន់ធ្វើការយ៉ាងទៀងទាត់ ។

### គ) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

មេធាវី ហុង គឹមសួន បានលើកឡើងថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចេញបទបញ្ជាឲ្យប្រជាជនរៀបអាពាហ៍ពិពាហ៍ដោយចាប់ដៃគ្នាទៅវិញទៅមក ដែលខុសពីឆន្ទៈរបស់ខ្លួនក្នុងការជ្រើសរើសគូស្រករ ។ គោលនយោបាយនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើនចំនួនប្រជាជនដើម្បីធ្វើការជូនអង្គការ ។ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា រូបគាត់ត្រូវបានបង្ខំឲ្យរៀបការ ។ ប្រជាជនចាមត្រូវបានបង្ខំឲ្យរៀបការជាមួយជនជាតិខ្មែរ ទោះបីមានការហាមឃាត់តាមប្រពៃណីសាសនាក៏ដោយ ។

មេធាវី ហុង គឹមសួន អះអាងថា គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវបានអនុវត្តនៅទូទាំងប្រទេស ។ គោលនយោបាយនេះផ្ទុយទៅនឹងឆន្ទៈរបស់ប្រជាជនក្នុងការជ្រើសរើសគូស្រករ ។ អ្នកដែលជំទាស់ទៅនឹងការចាប់ឲ្យរៀបអាពាហ៍ពិពាហ៍នឹងទទួលរងទារុណកម្ម ។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានផ្តល់សក្ខីកម្មថា រូបគាត់ត្រូវបានចាប់ឃុំខ្លួននៅគុកកោះខ្យង ដោយសារបានបដិសេធនូវសំណើសុំរៀបអាពាហ៍ពិពាហ៍របស់យោធាខ្មែរក្រហមម្នាក់ ។ គូស្រករដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវបានគេលួចតាមដាន ដើម្បីឲ្យប្រាកដថាអ្នកទាំងនោះពិតជាបានរួមដំណេកជាមួយគ្នា ពោលគឺដើម្បីធានាថា ចំនួនប្រជាជននឹងត្រូវបានបង្កើន ។ មេធាវី ហុង គឹមសួន បានលើកឡើងថា គោលនយោបាយនេះបានធ្វើឲ្យប៉ះពាល់ដល់បុរស និងស្ត្រី ជាពិសេសទៅលើជនជាតិភាគតិច និងចាមជាដើម ។ ជាលទ្ធផលគូស្រករទាំងនោះបានរស់នៅជាមួយគ្នាក្នុងស្ថានភាពភ័យខ្លាច ព្រោះមិនធ្លាប់ស្គាល់ចិត្តគ្នាពីមុន ។

### ឃ) មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស

ទាក់ទងនឹងមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សផ្សេងៗទៀត មេធាវី សំ សុគង់ បានលើកឡើងថា គោលនយោបាយនេះត្រូវបានបង្កើតឡើងដើម្បីធានាចំពោះគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវគោរពយ៉ាងតឹងរឹងបំផុត ។ ការបង្កើតមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស គឺដើម្បីអប់រំឡើងវិញចំពោះអ្នកដែលមានសមាសភាពមិនល្អ រកមើលសត្រូវ វាយតម្លៃខ្មាំង វិភាគលើខ្មាំង ចាប់ខ្មាំង និងកម្ទេចខ្មាំង ពោលគឺធ្វើយ៉ាងណាដើម្បីការពារបដិវត្តន៍ ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានណែនាំអំពីរបៀបនៃការកំណត់ខ្មាំង និងការអនុវត្តរបស់ខ្មាំង ។ ខ្មាំងដែលចាប់ខ្លួនបាន ត្រូវបានឃុំខ្លួន សួរចម្លើយ និងធ្វើទារុណកម្ម ។

មេធាវី សំ សុគង់ បានអះអាងថា នួន ជា និង ខៀវ សំផន បានចូលរួមបង្កើត និងអនុវត្តយ៉ាងស៊ីជម្រៅចំពោះគោលនយោបាយនេះ ។ ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំ និងធ្វើសេចក្តីថ្លែងការណ៍ជាច្រើនទាក់ទងនឹងការសម្លាប់ខ្មាំង ។ ចំណែក នួន ជា ក្នុងនាម ជាប្រធានសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា បានធ្វើសេចក្តីសម្រេចជាច្រើនពាក់ព័ន្ធនឹងការសម្លាប់មនុស្ស ។

### ង) ការប្រព្រឹត្តទៅលើក្រុមមនុស្សដែលជាគោលដៅជាក់លាក់

យោងតាមសក្ខីកម្មរបស់អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ មេធាវី សំ សុគង់ បានអះអាងថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគ្រប់ជាន់ថ្នាក់បានណែនាំកម្មាភិបាលថ្នាក់ក្រោមឲ្យធ្វើការកំណត់អតីត ទាហាន មន្ត្រី និងអ្នកជាប់ពាក់ព័ន្ធទៅនឹងរបប លន់ នល់ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានចាត់ថ្នាក់ អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ និងព្រះសង្ឃជាក្រុមពិសេសដែលត្រូវលុបបំបាត់ចោល ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបញ្ជាក់ថា អ្នកជាប់ពាក់ព័ន្ធនឹងរបបសាធារណៈរដ្ឋខ្មែរត្រូវបានចាត់ទុកថាជាខ្មាំង និងត្រូវចាប់ខ្លួន ។ មេធាវី សំ សុគង់ បានអះអាងទៀតថា ការបង្គាប់ឲ្យកំណត់ក្រុមមនុស្សជាក់លាក់នេះ ខ្មែរក្រហមមានគោលបំណងបោសសម្អាតអតីតមន្ត្រីនៃរបបសាធារណៈរដ្ឋខ្មែរ ដើម្បីធានាថាបក្សកុម្មុយនីស្តកម្ពុជានឹងមិនព្រមប្រឈមមុខជាមួយអ្នកតស៊ូប្រឆាំងនឹងបដិវត្តន៍ ។ អតីតទាហាន និងមន្ត្រីរបប លន់ នល់

ត្រូវបានខ្មែរក្រហមបោកបញ្ឆោតឲ្យធ្វើប្រវត្តិរូប បន្ទាប់មកត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។ ក្រៅពីនេះ ប្រជាជនខ្មែរក្រោមក៏ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាកំណត់ថា ជាខ្មាំងដែលត្រូវកម្ទេចចោល ។ ខ្មែរក្រហមយល់ឃើញថា ប្រជាជនទាំងនោះជាអតីតទាហាន លន់ នល់ ឬធ្លាប់ចូលរួមជាមួយរបបសាធារណៈរដ្ឋខ្មែរ ។ ម្យ៉ាងវិញទៀត ប្រជាជនទាំងនោះមានប្រភពមកពីដែនដីសណ្តរទន្លេមេគង្គដែលជាផ្នែកមួយនៃក្រុមនយោបាយជាតិសាសន៍ និងជនជាតិវៀតណាម ។ ប្រជាជនទាំងនោះត្រូវបានខ្មែរក្រហមលាបពណ៌ថា ជាចារកម្មរបស់វៀតណាម ឬខ្លួនជាខ្មែរ ប៉ុន្តែមានគំនិតជាយួន ។ ក្រៅពីក្រុមទាំងនេះ ខ្មែរក្រហមក៏បានកំណត់មុខសញ្ញាដែរចំពោះក្រុមជនជាតិភាគតិច និងចាម ។ ទំនៀមទម្លាប់ប្រពៃណីជំនឿសាសនារបស់ក្រុមទាំងនេះ ត្រូវបានលុបបំបាត់ចោល ។

មេធាវី សំ សុគង់ អះអាងថា នៅខែមេសា ឆ្នាំ១៩៧៧ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចេញបញ្ជាឲ្យចាប់ខ្លួនជនជាតិវៀតណាម និងប្រជាជនខ្មែរក្រោមទាំងអស់ដែលនិយាយភាសាវៀតណាម ឬកើតនៅប្រទេសវៀតណាម ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ប៉ុល ពត, នួន ជា និង សុន សេន បើក កិច្ចប្រជុំសម្ងាត់មួយដោយមាន ខៀវ សំផន ជាអ្នកធ្វើកំណត់ហេតុកិច្ចប្រជុំ ។ កិច្ចប្រជុំនេះបានសម្រេច ឲ្យមានការបោសសម្អាតកម្មាភិបាលនៅភូមិភាគបូព៌ា រួមមាន សោ ភឹម ជាលេខាភូមិភាគ និងកម្មាភិបាលផ្សេងៗទៀតនៅក្នុងភូមិភាគនោះ ។

### ៣) ការជម្លៀសប្រជាជន

#### ក) ការជម្លៀសប្រជាជននៅដំណាក់កាលទី១

ទាក់ទងនឹងអង្គហេតុនៃការជម្លៀសប្រជាជនដំណាក់កាលទី១ មេធាវី ទី ស្រ៊ីណា បានលើកឡើងថា ការជម្លៀសប្រជាជននៅដំណាក់កាលទី១ ត្រូវបានគិតចាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសជាបន្តបន្ទាប់រហូតដល់មុនខែកញ្ញា ឆ្នាំ១៩៧៥ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមការចូលដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ហើយបានជម្លៀសប្រជាជនជាង ២លាននាក់ចេញពីទីក្រុង ។ ក្នុងអំឡុងពេលជម្លៀសយោធាខ្មែរក្រហម បានគំរាមកំហែងប្រជាជនឲ្យចេញពីផ្ទះ និងបាញ់សម្លាប់ប្រសិនបើមានអ្នកជំទាស់មិនព្រមចេញ ។ នៅពេលជម្លៀសនោះដែរយោធាខ្មែរក្រហមបានស្រាវជ្រាវរកអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដើម្បីសម្លាប់ចោល ។ តាមការស្រាវជ្រាវរបស់សាស្ត្រាចារ្យ បើន ឃៀរនិន បានបញ្ជាក់ថា មន្ត្រីនៃរបប លន់ នល់ និងប្រជាជនស៊ីវិលប្រមាណ១ម៉ឺននាក់ ត្រូវបានសម្លាប់ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ។ ប្រជាជនជាច្រើនទៀត បានទទួលរងគ្រោះដោយសារបាត់បង់សមាជិកគ្រួសារ ទ្រព្យសម្បត្តិ និងកើតមានជំងឺភ័យខ្លាច និងតក់ស្លុតជាខ្លាំង ។

ឆ្លើយតបនឹងការអះអាងរបស់ក្រុមមេធាវីការពារក្តីដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះស្បៀង និងបញ្ហាសន្តិសុខសម្រាប់ប្រជាជននៅក្នុងទីក្រុងនោះ មេធាវី ទី ស្រ៊ីណា បញ្ជាក់ថា ជាការអះអាងមិនត្រឹមត្រូវ ។ មេធាវីទី ស្រ៊ីណា បញ្ជាក់ថា នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជីវភាពរបស់ប្រជាជននៅក្នុងទីក្រុងភ្នំពេញនៅមានភាពល្អប្រសើរនៅឡើយ ហើយស្បៀងអាហារត្រូវបានផ្គត់ផ្គង់គ្រប់គ្រាន់ ។ បន្ថែមលើនេះមេធាវីបានយោងទៅលើសក្ខីកម្មរបស់សាក្សី ស៊ីតនី ឆាន់ប៊ឺត ដែលថា ខ្មែរក្រហមបានព្យាយាមទប់ស្កាត់ការដឹកជញ្ជូនស្បៀងមកពីវៀតណាមខាងត្បូងមកឲ្យប្រជាជននៅទីក្រុងភ្នំពេញ ។ ចុងក្រោយមេធាវីបានលើកឡើងថា ទោះបីជាមានការខ្វះខាតស្បៀងក្តី ក៏ពុំចាំបាច់ធ្វើការជម្លៀសក្នុងសភាពទាន់ហន់ ដែលធ្វើឲ្យប្រជាជនស្លាប់ជាច្រើនយ៉ាងនេះដែរ ។ ម្យ៉ាងវិញទៀត ប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញពេលទៅដល់មូលដ្ឋានក៏ពុំទទួលបានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំបក្សក្នុងការផ្តល់ស្បៀងឡើយ ។ ទាក់ទងនឹងបញ្ហាសន្តិសុខដែលមេធាវីការពារក្តី និង នួន ជា លើកឡើងថា អាចកើតចេញពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនោះ មេធាវី ទី ស្រ៊ីណា អះអាងថា គឺគ្រាន់តែជាល្បិចបោកបញ្ឆោតឲ្យប្រជាជនចាកចេញពីក្រុងភ្នំពេញឲ្យបានលឿនតែប៉ុណ្ណោះ ។ សាក្សីជាច្រើន ដែលក្នុងនោះមានទាំងអតីតកម្មាភិបាលយោធា បានផ្តល់សក្ខីកម្មថា ពុំមានសញ្ញាណណាមួយដែលអាចកំណត់ថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាទៀតឡើយ ។

មេធាវីអន្តរជាតិ គ្រីស៊ីន ម៉ាទីណូ បានបន្ថែមថា ការជម្លៀស

ប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ ជាការធ្វើឲ្យប្រជាជនក្លាយជាទាសករ ។ ការជម្លៀសទាំងនេះ កើតចេញពីការបញ្ជារបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយសារពុំមានកម្មាភិបាលថ្នាក់ក្រោមណាម្នាក់ហានសម្រេចឲ្យជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំយ៉ាងនេះទេ ។ មេធាវីលើកឡើងថា នួន ជា និង ខៀវ សំផន បានទៅទស្សនានៅតាមសហករណ៍ និងការដ្ឋានធ្វើការងារជាច្រើនលើក ហើយពុំដែលខ្វល់ពីការរស់នៅភាពអត់ឃ្លានរបស់ប្រជាជនឡើយ ។

### ៣) ការជម្លៀសប្រជាជននៅដំណាក់កាលទី២

ទាក់ទងនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊េត ស៊ីម៉ូណូហ្វត អះអាងថា ជាការបន្តអនុវត្តផែនការខក្រិដ្ឋកម្មភាពរឹងរូស និងភាពគ្មានប្រណីរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចបញ្ជូនប្រជាជនរាប់សែននាក់ ដែលភាគច្រើនជាប្រជាជនថ្មី ទៅភូមិភាគពាយ័ព្យទោះបីដឹងថា នៅភូមិភាគនេះ មានការខ្វះខាតស្បៀងក៏ដោយ ។ ប្រជាជនត្រូវបានដឹកជញ្ជូន និងឲ្យធ្វើការដូចគោក្របី ។ ប្រជាជនត្រូវបានគេបោកបញ្ឆោតថាទៅកន្លែងដែលសំបូរស្រូវអង្ករសម្រាប់បរិភោគ ។ នៅពេលទៅដល់ប្រជាជនម្នាក់ៗមានការខកចិត្តដោយសារគាត់ត្រូវបានបញ្ជូនទៅក្នុងព្រៃ ដើម្បីកាប់ឆ្ការធ្វើស្រែចម្ការ ។ លក្ខខណ្ឌរស់នៅកាន់តែលំបាកដោយសារពុំមានម្ហូបអាហារ និងទឹកសម្រាប់បរិភោគគ្រប់គ្រាន់ ពុំមានជម្រក និងត្រូវធ្វើការជាទម្ងន់ ។ ចុងក្រោយមេធាវីអះអាងថា ការផ្តល់លក្ខខណ្ឌរស់នៅបែបនេះ ពុំមានហេតុផលអ្វីក្រៅពីចង់សម្លាប់ប្រជាជនថ្មីទាំងនោះឡើយ ។

### ៤) ការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

មេធាវី ស៊ីម៉ូណូហ្វត អះអាងថា ការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ជាការអនុវត្តផែនការខក្រិដ្ឋរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ទាំងមុន និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទូទាំងប្រទេស ។ ការសម្លាប់នៅទួលពោធិ៍ជ្រៃគឺជាផ្នែកមួយនៃការសម្លាប់ទាំងនោះ ។ ទាហាន លន់ នល់ បានទទួលរងការនូវការបោកបញ្ឆោត ហើយត្រូវបានប្រមូលយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ។ មេធាវីអះអាងទៀតថា នួន ជា និង ខៀវ សំផន បានចូលរួមជាមួយ ប៉ុល ពត ក្នុងការបង្កើតផែនការខក្រិដ្ឋទាំងនេះ ។

### ៥) ការសន្និដ្ឋានតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅក្រុមមេធាវីការពារក្តី

ឆ្លើយតបនឹងការលើកឡើងជាច្រើនដងរបស់មេធាវី គង់



ប្រជាជនត្រឡប់ទៅលំនៅដ្ឋានវិញ

សំអុន ដែលថា ខៀវ សំផន ជាសុភាពបុរស មានសុចរិត មិនអាត្មានិយម និងជាមនុស្សគិតពីផលប្រយោជន៍របស់ជាតិជាធំ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី អះអាងថា គឺជាការលើកឡើងមិនត្រឹមត្រូវ ។ មេធាវី ម៉ុច សុវណ្ណារី បានបញ្ជាក់ថា មានភស្តុតាងជាច្រើនដែលអាចបញ្ជាក់ថា ខៀវ សំផន ពុំមានបុគ្គលិកលក្ខណៈបែបនេះឡើយ ។ ជាបឋមមេធាវីបានផ្តល់ការបញ្ជាក់ និងចោទជាសំណួរថា «បញ្ញវន្តជាច្រើន ត្រូវបានថ្នាក់ដឹកនាំខ្មែរក្រហមហៅឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ដោយកុហកថាមកកសាងជាតិ ។ តែតាមពិតពួកគេត្រូវបានយកទៅកសាង ហើយសម្លាប់ចោលនៅមន្ទីរស-២១ ។ សំណួរសួរថា

តើហេតុអ្វីបានជាបញ្ហាជនឈ្មោះ ខៀវ សំផន ម្នាក់នេះត្រូវបានគេទុកឲ្យរស់នៅ ហើយបំពេញតួនាទីកំពូលនៃថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យទៅវិញ? ហើយអ្វីបានជាបញ្ហាជនរូបនេះមិនត្រូវបានយកទៅកសាង ឬក៏កម្ទេចចោលដូចបញ្ហាជនឯទៀត?» ។ មេធាវីលើកឡើងថា ខៀវ សំផន ត្រូវបានតែងតាំងឲ្យកាន់មុខដំណែងសំខាន់ៗ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយ



ក្រោយរបបខ្មែរក្រហមដួលរលំ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មេដឹកនាំបក្សកុម្មុយនីស្តដទៃទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានថ្លែងអបអរសាទរជាច្រើនដងចំពោះមហាជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយ ខៀវ សំផន នៅតែបន្តគាំទ្រ ប៉ុល ពត និងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជារបបនេះដួលរលំក៏ដោយ ។ នៅចុងបញ្ចប់នៃការឆ្លើយតបទៅនឹងបុគ្គលិកលក្ខណៈរបស់ ខៀវ សំផន មេធាវី ម៉ុច សុវណ្ណារី បានផ្តល់ការកត់សម្គាល់ថា «...ខ្ញុំសូមរំឭក លោក ខៀវ សំផន ថាមនុស្សធម៌ គឺជារឿងដែលអ្នកដឹកនាំគ្រប់រូបត្រូវគិតហើយពិចារណា ហើយជាអត្ថិភាពសំខាន់នៅក្នុងការដែលគេដឹកនាំប្រជាជនប្រទេសជាតិរបស់គេ ។ ខ្ញុំនិយាយនៅទីនេះ ពីមនុស្សធម៌ មិនមែនពីនយោបាយ ឬមនោគមន៍វិជ្ជា ។ ប្រជាជនគឺជាមនុស្សដែលថ្នាក់ដឹកនាំនីមួយៗត្រូវយកចិត្តទុកដាក់ ហើយថែរក្សា ។ ពួកគេមិនមែនជាកម្មវត្ថុនៃសង្គ្រាម ដែលភាគីនៃសង្គ្រាមត្រូវដណ្តើមយកឲ្យខានតែបាន មិនថាត្រូវលះបង់ជីវិតដ៏មានតម្លៃរបស់ពួកគេកម្រិតណានោះទេ ។ លក្ខណៈជាអ្នកដឹកនាំល្អ ដែលស្រឡាញ់ជាតិ ដូចដែលពួកលោកតែងតែអះអាងនៅចំពោះមុខសវនាការ និងចំពោះមុខជនរងគ្រោះនៃរបបខ្មែរក្រហម និងប្រជាជនខ្មែរជំនាន់ក្រោយ ពិតជាមិនអាចហាមឧត្តមគតិរបស់លោកឲ្យទទួលខុសត្រូវនូវហេតុការណ៍ជាក់ស្តែងដែរថា ក្រោមការដឹកនាំរបស់ពួកលោក ប្រទេសនេះបានក្លាយជាវាលពិឃាត បានបន្សល់ទុកនូវស្នាមងងឹតក្នុងប្រវត្តិសាស្ត្រសម្រាប់ប្រជាជនខ្មែរជំនាន់ក្រោយ ។ ខ្ញុំជឿថា ឧត្តមគតិ និងសម្បជញ្ញៈជាជនស្នេហាជាតិ នឹងហាមលោកមិនឲ្យលោកធ្វើជាមុខមាត់ដ៏សង្ហានៃរបបកម្ពុជាប្រជាធិបតេយ្យ នៅលើឆាកអន្តរជាតិ និងនៅចំពោះមុខប្រជាជនខ្មែរជំនាន់នោះ ជំនាន់នេះ និងជំនាន់តទៅទៀតនោះទេ» ។

ទាក់ទងនឹងភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី និងសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ម៉ុច សុវណ្ណារី បានអះអាងថា ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានបកស្រាយមិនត្រូវទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ អង្គជំនុំជម្រះមិនដែលបានធានាដល់ក្រុមមេធាវីការពារក្តីថា ឯកសារទាំងនោះមិនអាចជឿជាក់បាន ឬអាចជឿជាក់បានតិចតួចនោះឡើយ ។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា កំណត់ហេតុផ្តល់សក្ខីកម្មអំពីបញ្ហានានា (ក្រៅពីអំពើ ឬអាកប្បកិរិយារបស់ជនជាប់ចោទ) អាចត្រូវបានចាត់ទុកថាមានការជាប់ពាក់ព័ន្ធ គួរឲ្យជឿជាក់បាន ។ មេធាវី ម៉ុច សុវណ្ណារី លើកឡើងទៀតថា សេចក្តីថ្លែងការណ៍ (ថ្លែងទុក្ខសោក) របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយបានគាំទ្រទៅនឹងភស្តុតាងផ្សេងៗទៀត ដែលបង្ហាញពីអត្ថិភាពនៃអំពើឧក្រិដ្ឋកម្ម ក្រុមមេធាវីការពារក្តី នួន ជា ពុំបានធ្វើការប្រឆាំងជាក់លាក់ណាមួយឡើយ ។

មេធាវី ម៉ុច សុវណ្ណារី បានរិះគន់ចំពោះវិធីសាស្ត្ររបស់ក្រុម

មេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន ក្នុងការដកស្រង់សក្ខីកម្មមកធ្វើជាអំណះអំណាង ។ មេធាវី ម៉ុច សុវណ្ណារី បញ្ជាក់ថា ក្រុមមេធាវីការពារក្ដី ខៀវ សំផន មិនបានដកស្រង់សក្ខីកម្មឲ្យបានពេញលេញ ហើយធ្វើការបកស្រាយមិនត្រឹមត្រូវ និងត្រូវតាមបរិបទនៃសក្ខីកម្មទាំងនោះឡើយ ។ សក្ខីកម្មដែលមេធាវីការពារក្ដីបានដកស្រង់នោះរួមមាន សក្ខីកម្មសាក្សី ប៉ុងសូដ៍, ស៊ីវ ហេដឌ័រ, នួន ហ៊ិន ជាដើម ហើយបានបដិសេធដោយមិនត្រឹមត្រូវចំពោះសក្ខីកម្មរបស់សាស្ត្រាចារ្យ ហ៊ីលីព ហ្សូត និង សាក្សី ភី ភួន ។

## ៦) ការទាមទារសំណង

បន្ទាប់ពីបញ្ចប់ការធ្វើសេចក្ដីសន្និដ្ឋានអំពីអង្គហេតុដែលត្រូវចោទប្រកាន់ និងផលប៉ះពាល់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយសារអំពើឧក្រិដ្ឋទាំងនោះ មេធាវី ពេជ អង្គ បានលើកឡើងអំពីគម្រោងសំណងចំនួន១៣ ដែលត្រូវបានបែងចែកជា៣ជំពូកដូចខាងក្រោម៖

### ជំពូកទី១ : ស្ដីពីការរំឭក និងការគោរពវិញ្ញាណក្ខន្ធ

គម្រោងទី១) ការបង្កើតទិវាជាតិនៃការចងចាំ : មេធាវីស្នើឲ្យបង្កើតឲ្យមានថ្ងៃចងចាំជាផ្លូវការ ដែលជាថ្ងៃសម្រាកមួយផ្សេងពីថ្ងៃឈប់ដែលមាននាពេលបច្ចុប្បន្ន ។ ថ្ងៃនោះ អាចជាថ្ងៃ១៧ មេសា ឬ ២០ឧសភា ឬថ្ងៃ៣០មីនា ។ គោលបំណងនៃការបង្កើតថ្ងៃនេះ គឺដើម្បីរំឭក និងស្ដារកិត្តិយសដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ព្រមទាំងសម្រាប់អប់រំដល់អ្នកជំនាន់ក្រោយ ។ មេធាវីបញ្ជាក់ថា គម្រោងនេះទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលកម្ពុជារួចហើយ ។

គម្រោងទី២) កសាងស្តូបសម្រាប់រំឭកជាសាធារណៈ : ស្តូបនេះនឹងត្រូវប្រើសម្រាប់តំកល់អដ្ឋិធាតុរបស់ជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជនទូទៅ អុជធូបគោរពវិញ្ញាណក្ខន្ធអ្នកទាំងនោះ ។ មេធាវីបញ្ជាក់ថា គម្រោងនេះពុំទាន់ទទួលបានការធានាផ្ដល់ថវិកានៅឡើយ ។

គម្រោងទី៣) ការកសាងបូជនីយដ្ឋានរំឭកចំពោះជនរងគ្រោះ : គម្រោងនេះមានគោលដៅរំឭកឡើងវិញអំពីព្រឹត្តិការណ៍ជាក់ស្ដែងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទីតាំងដែលត្រូវសាងសង់ និងតម្កល់រូបចម្លាក់ គឺនៅទល់មុខស្ថានទូតបារាំង ត្រង់រង្វង់មូលជិតស្ពានជ្រោយចង្វារ ។ គម្រោងនេះអនុវត្តដោយសិល្បៈករម្នាក់ឈ្មោះ សេរ៉ា និងទទួលបានការគាំទ្រថវិកាដោយរដ្ឋាភិបាលបារាំង និងបុគ្គលផ្សេងៗទៀត ។

គម្រោងទី៤) ការសាងសង់ស្តូបរំឭកដល់ជនរងគ្រោះខ្មែរក្រហមសម្រាប់ប្រជាជនខ្មែរនៅប្រទេសបារាំង : ស្តូបនេះនឹងត្រូវបានសាងសង់សម្រាប់ប្រជាជនដែលរស់នៅប្រទេសបារាំងធ្វើការគោរពវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ គម្រោងនេះមានការចូលអនុវត្តពីសមាគមចំនួនបី រួមមាន សមាគមជនរងគ្រោះនៃអំពើពូជប្រល័យសាសន៍នៃរបបខ្មែរក្រហម សមាគមរំឭកដល់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម និងសម្ព័ន្ធអន្តរជាតិនៃសិទ្ធិមនុស្ស ។ បច្ចុប្បន្នគម្រោងនេះទទួលបានការឯកភាពជាគោលការណ៍រួចហើយពីសាលាក្រុងប៉ារីស ។ ទោះបីជាយ៉ាងណា គម្រោងនេះកំពុងស្ថិតនៅដំណាក់កាលស្វែងរកថវិកានៅឡើយ ។

### ជំពូកទី២ : ពាក់ព័ន្ធនឹងការស្ដារនីតិសម្បទា

ជំពូកនេះបានបែងចែកជាពីរគម្រោង គឺគម្រោងចងក្រងសក្ខីកម្ម និងគម្រោងស្ដីពីក្រុមជួយខ្លួនឯង ។ គម្រោងទាំងពីរនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្តដល់ជនរងគ្រោះពីអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ គម្រោងនេះទទួលបន្ទុកអនុវត្ត ដោយអង្គការចិត្តសាស្ត្រសង្គម អន្តរវប្បធម៌ ដែលមានរយៈពេល១៦ខែ ដោយទទួលថវិកាមួយផ្នែកពីរដ្ឋាភិបាល អាល្លឺម៉ង់ និងសប្បុរសជនមួយចំនួនទៀត ។

### ជំពូកទី៣ : ស្ដីពីការចងក្រងឯកសារ និង ការអប់រំ

នៅក្នុងជំពូកនេះ រួមមានគម្រោងចងក្រងឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហម និងការដាក់តាំងពិព័រណ៍ ។ គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ ដែលត្រូវធ្វើនៅសារមន្ទីរចំនួន៥ ដោយទទួលបានថវិកាពីរដ្ឋាភិបាលអាល្លឺម៉ង់ ។ គម្រោងនេះអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនឹងធ្វើការយ៉ាងជិតស្និតជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ហើយទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជារួចហើយ ។

គម្រោងទី៨) ការតាំងពិព័រណ៍ចល័ត ៖ គម្រោងនេះបង្កើតឡើងក្នុងគោលបំណងតាំងពិព័រណ៍ និងចងក្រងឯកសារអំពីបទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីការជម្លៀសដោយបង្ខំ និងព្យសនកម្មផ្សេងៗដែលគាត់បានទទួលរងនៅក្នុងរបបខ្មែរក្រហម ។ គម្រោងនេះនឹងទទួលបន្ទុកអនុវត្ត ដោយអង្គការករុណា និងអង្គការយុវសន្តិភាព ។ គម្រោងនេះទទួលបានថវិកាពីក្រសួងការបរទេសអាល្លឺម៉ង់ ចំនួន១០ម៉ឺនអឺរ៉ូ និងអនុវត្តក្នុងរយៈពេល ១២ខែ ។

គម្រោងទី៩) ការតាក់តែងជំពូកជាក់លាក់អំពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ។ មេធាវី ពេជ អង្គ ស្នើសុំដាក់ជំពូកនេះនៅក្នុងសៀវភៅបណ្ដុះបណ្ដាលគ្រូបង្រៀនផ្នែកប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបន្ទុករៀបចំ និងបណ្ដុះបណ្ដាលដល់គ្រូបង្រៀនប្រវត្តិសាស្ត្រអំពីជំពូកនេះ ។

គម្រោងទី១០) ការកសាងមជ្ឈមណ្ឌលសិក្សាសន្តិភាព ។ គម្រោងនេះមានគោលដៅបង្កើត ជាទីកន្លែងមួយសម្រាប់ជាការចងក្រង ការផ្សព្វផ្សាយបណ្ដុះបណ្ដាល ការពិភាក្សា ការអប់រំ និងជាការរំឭក ។ អង្គការយុវសន្តិភាពជាអ្នកទទួលបន្ទុកអនុវត្តគម្រោងនេះ ដោយសហការជាមួយសមាគមផ្សេងៗទៀត ។ មជ្ឈមណ្ឌលនេះនឹងត្រូវសាងសង់នៅស្រុកសំរោង ខេត្តបាត់ដំបង ដែលជាអតីតកន្លែងសម្លាប់មនុស្សរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

គម្រោងទី១១) ការបោះពុម្ពផ្សាយកូនសៀវភៅស្ដីអំពីដំណើរការនៃសំណុំរឿង០០២/០១ ។ តាមការបញ្ជាក់របស់មេធាវី ពេជ អង្គ សៀវភៅនេះនឹងត្រូវបោះជាភាសាសាមញ្ញបំផុតដែលអាចធ្វើឲ្យសាធារណជនទូទៅបានយល់អំពីកិច្ចដំណើរការជំនុំជម្រះក្ដីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ គម្រោងនេះទទួលបន្ទុកអនុវត្តដោយអង្គការគណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា "ច្រាក់" (CHRAC) ដោយទទួលបានការផ្ដល់ថវិកាពីអង្គការសហប្រតិបត្តិការអាល្លឺម៉ង់ ។

គម្រោងទី១២) ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប ។ មេធាវីស្នើឲ្យផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញជាអ្នកអនុវត្តគម្រោងនេះ ដោយបោះពុម្ព និងចែកចាយសាលក្រមទាំងមូល និងសាលក្រមសង្ខេបនៃសំណុំរឿង០០២/០១ ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី សាធារណជន និងអ្នកវិជ្ជាជីវៈច្បាប់ផ្សេងៗ ។ តាមការបញ្ជាក់របស់មេធាវី ពេជ អង្គ ថវិកាដែលត្រូវបោះពុម្ពផ្សាយសាលក្រមនេះមានចំនួនតិចជាងការបោះពុម្ពសាលក្រមនៃសំណុំរឿង០០១ ។

គម្រោងទី១៣) ការផ្សាយឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនៅគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ ។ មេធាវី ពេជ អង្គ បញ្ជាក់ថា ការដាក់ឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីទៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះ ដើម្បីបង្ហាញអំពីការចូលរួម និងលើកតម្លៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការរបស់តុលាការ ។ ការផ្សាយនេះមានរួមបញ្ចូលទាំងឈ្មោះជាភាសាខ្មែរ អក្សរឡាតាំង លេខដើមបណ្ដឹងរដ្ឋប្បវេណីដែលចេញដោយអង្គភាពគាំពារជនរងគ្រោះ និងធាតុចាំបាច់ផ្សេងទៀត ដែលងាយស្រួលក្នុងការស្វែងរកឈ្មោះ ។

បន្ទាប់ពីបញ្ចប់ការលើកឡើងនូវគម្រោងទាំង១៣ ខាងលើ សហមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើទាំង ៨ ដូចខាងក្រោម ៖

*ទី១) ទទួលស្គាល់ជាផ្លូវការនូវការខូចខាត ដែលបានទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណីថា ជាផលវិបាកនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទ និងត្រូវផ្ដន្ទាទោស ។*

*ទី២) ជាចម្បង បង្ហាញឲ្យបុគ្គលដែលត្រូវបានប្រកាសថា មានពិរុទ្ធភាពឲ្យជួសជុលសំណងដែល ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងការខូចខាត ។ ក្នុងករណីពិរុទ្ធជនទាំងនោះក្រីក្រពុំមានលទ្ធភាពសង ស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចថា សំណងនឹងត្រូវអនុវត្ត និងផ្ដល់ថវិកាដោយតតិយជន ។*

*ទី៣) ជាបន្ទាប់បន្សំ ស្នើសុំឲ្យអង្គជំនុំជម្រះទទួលឯកភាពតាមការស្នើសុំរបស់អង្គជំនុំជម្រះឲ្យអនុវត្តបែបបទ អនុវត្តយោងតាមវិធាន ២៣ស្ទួន៤(៣)(ខ) ។*

*ទី៤) ទទួលស្គាល់គម្រោងនីមួយៗ ដែលបានរៀបរាប់ខាងលើថាជាសំណង ។ ទោះជាស្ថានភាពថវិការបស់គម្រោងទាំង*

នោះយ៉ាងណាក៏ដោយ ឬក៏យ៉ាងហោចណាស់ទទួលស្គាល់គម្រោងទាំងនោះ ឲ្យស្មើទៅនឹងទំហំថវិកានៃគម្រោងនេះ ដោយអញ្ជើញអង្គការទទួលបន្ទុកអនុវត្តគម្រោងឲ្យអនុវត្តសម ស្របទៅនឹងចំនួនថវិកា ។

ទី៥) ពិចារណាលើព័ត៌មានស្តីពីស្ថានភាពថវិការបស់គម្រោងទាំងឡាយ ដែលបានរៀបរាប់ខាងលើ ដែលដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពផ្តល់ជូននៅពេលការពិភាក្សារបស់ចៅក្រម ។

ទី៦) ទទួលនូវអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់ជូននៅពេលពិភាក្សារបស់ចៅក្រម លើព័ត៌មានទាំងអស់នេះ ដើម្បីឲ្យពួកគាត់អាចទទួលបានសំណងប្រកបដោយអត្ថន័យ ។

ទី៧) សម្រេចថា គម្រោងណាមួយ ដែលត្រូវបានកម្រិតត្រឹមរយៈពេលណាមួយរហូតមកដល់ពេលនេះដោយមូលហេតុថវិកាត្រូវតែបានចាត់ទុកជាសំណងមួយលើសពីរយៈពេលនេះ នៅពេលដែលទទួលបានថវិកាបន្ថែម ។

ទី៨) លើកទឹកចិត្តអាជ្ញាធរជាតិ សហគមន៍អន្តរជាតិ និងម្ចាស់ជំនួយនានាឲ្យបង្ហាញពីសាមគ្គី ភាពរបស់ពួកគេក្នុងការសម្រេចឲ្យបាននូវវិធានការសំណងដែលនឹងត្រូវទទួលស្គាល់ ។


ប្រជាជនកំពុងស្វែងរកទីកន្លែងមានសុវត្ថិភាព (បណ្ណសារ : មជ្ឈមណ្ឌលឯកសា

# សេចក្តីថ្លែងការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយសហព្រះរាជអាជ្ញា

បន្ទាប់ពីភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ សហព្រះរាជអាជ្ញាជាតិ ជា លាង បានចាប់ផ្តើមថ្លែងសេចក្តីសន្និដ្ឋានបញ្ចប់សំណុំរឿង០០២/០១ ។ នៅក្នុងសវនាការបិទបញ្ចប់សេចក្តីសន្និដ្ឋាន ចោទប្រកាន់ក្នុងរយៈពេល៤ថ្ងៃនេះ ភាគីសហព្រះរាជអាជ្ញាបានដាក់បញ្ចាំងខ្សែវីដេអូខ្លីៗ រូបភាព ការដកស្រង់អត្ថបទ និងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ។ សហព្រះរាជអាជ្ញា បានផ្តោតសំខាន់លើចំណុចមួយចំនួនដូចជាភស្តុតាងពាក់ព័ន្ធនឹងបទឧក្រិដ្ឋជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ និងផែនការឈានទៅរកឧក្រិដ្ឋកម្ម ផែនការឧក្រិដ្ឋពាក់ព័ន្ធនឹងការសម្លាប់ទាហាន និងមន្ត្រីរបបសាធារណៈរដ្ឋខ្មែរនិងបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ ការសន្និដ្ឋានពីការទទួលខុសត្រូវនិងការចូលរួមសំខាន់នៅក្នុងផែនការសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវការរៀបចំផែនការការទទួលខុសត្រូវ និងការជម្រុញ និងការញុះញង់ឲ្យមានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ព្រមទាំងការខកខានទប់ស្កាត់ឧក្រិដ្ឋកម្មក្នុងនាមជាថ្នាក់លើ ឬការដាក់ទោសចារីដែលដល់ និងការកំណត់ទោស ។


រកម្ពុជា)

គួរកត់សម្គាល់ថា មានការអាក់រអួលផ្នែកបច្ចេកទេសសម្លេងអស់រយៈពេល៣០នាទី នៅពេលដែលភាគីសហព្រះរាជអាជ្ញាចាប់ផ្តើមអានសេចក្តីសន្និដ្ឋាន បិទនៅក្នុងសំណុំរឿង០០២/០១ នៅព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ ។

អង្គជំនុំជម្រះបានរំឭកដល់ភាគីមិនអនុញ្ញាតឲ្យប្រើឈ្មោះសាក្សីដែលពុំទាន់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះឡើយ ។ ឈ្មោះរបស់សាក្សីទាំងនោះត្រូវប្រើលេខកូដ ដែលផ្តល់ដោយតុលាការជំនួសវិញ ។

នៅក្នុងសេចក្តីផ្តើមរបស់ខ្លួនសហព្រះរាជអាជ្ញាបានលើកឡើងពីការជំនុំជម្រះក្តីនេះ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ចំពោះបទឧក្រិដ្ឋដែលធ្វើឲ្យមនុស្សទូទាំងសកលលោកភិតភ័យ តក់ស្លុតហើយព្រះរាជអាជ្ញាបានដាក់បង្ហាញភស្តុតាង ដែលបញ្ជាក់ពីតួនាទីរបស់ នួន ជា និង ខៀវ សំផន នៅក្នុងអង្គការឧក្រិដ្ឋមួយដែលបានធ្វើទុកបុកម្នេញ និងកាប់សម្លាប់ប្រជាជនឯងរាប់លាននាក់ដែលសុទ្ធតែជាជនស៊ីវិលស្លូតត្រង់ ស្ត្រី កុមារ មនុស្សចាស់ និងអ្នកទន់ខ្សោយ និងអ្នករងគ្រោះ ។ សហព្រះរាជអាជ្ញាជាតិបានបន្តលើកឡើងពីការទទួលរងគ្រោះរបស់ប្រជាជនកម្ពុជាទៀតថា សូម្បីតែមកដល់ពេលបច្ចុប្បន្ននេះ ក៏ក្រុមគ្រួសារខ្មែររាប់មិនអស់កំពុងតែរែក

អម្រែកមួយយ៉ាងធ្ងន់ ដែលបន្សល់ទុកពីរបបខ្មែរក្រហម ដែលរួមមានការបង្អត់បាយ ការធ្វើទារុណកម្ម ការបាត់បង់អ្នកជាទីស្រលាញ់ ដែលពួកខ្មែរក្រហមបានសម្លាប់ ឬដែលបាត់ខ្លួន ។ ប្រជាជនខ្មែរទាំងមូលបានរងទុក្ខខ្លោចផ្សា ដោយសារការបាត់បង់ឱកាសសិក្សា និងការអភិវឌ្ឍន៍ ដោយសារតែប្រជាជនខ្មែរមួយជំនាន់ ដែលបានរៀនសូត្រចេះដឹង និងមានជំនាញខ្ពស់ស្ទើរតែទាំងអស់ ត្រូវបានបោសសម្អាត សម្លាប់ចោល ឬបង្ខំឲ្យភៀសខ្លួនចេញពីប្រទេសកម្ពុជា ។ សហព្រះរាជអាជ្ញាបានបន្តទៀតថា ការជម្រះក្តីនេះមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ហើយថែមទាំងសំខាន់



នីកូឡាស គុំចាន់ ជាសហព្រះរាជអាជ្ញាអន្តរជាតិដែលចូលកាន់តំណែងនៅឆ្នាំ២០១៤ ជំនួស អេនឌ្រូ ខេលី
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាប់ពិភពលោកទាំងមូលផងដែរដោយសារវាបង្ហាញឲ្យឃើញថាបទឧក្រិដ្ឋ ដែលមានលក្ខណៈធំធេង និងធ្ងន់ធ្ងរ ដូច្នេះ គឺពិតជាមិនអាចបំភ្លេចបាន និងត្រូវតែផ្តន្ទាទោស ។ សហព្រះរាជអាជ្ញាបានបញ្ជាក់អំពីវិសាលភាពនៃបទចោទថា អង្គជំនុំជម្រះនៅក្នុងដំណាក់កាលនេះ ពិនិត្យមើលតែមួយផ្នែកនៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះនៃបទឧក្រិដ្ឋមួយចំនួនទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសិនតែប៉ុណ្ណោះ ។ ការពិនិត្យមើលលើកដំបូង ដែលផ្តោតលើតែបទឧក្រិដ្ឋជម្លៀសប្រជាជន ដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជន នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបទឧក្រិដ្ឋពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ពីជនបទទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យនៅឆ្នាំ១៩៧៥ និង១៩៧៦ ព្រមទាំងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃយ៉ាងរង្គាលនៅខែមេសា ឆ្នាំ១៩៧៥ ។ ភស្តុតាង ដែលសហព្រះរាជអាជ្ញាបានដាក់បង្ហាញកើតចេញពីផលប៉ះពាល់នៃគោលនយោបាយឧក្រិដ្ឋ និងការបន្តអនុវត្តផែនការឧក្រិដ្ឋទាំងនៅមុន និងនៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សហព្រះរាជអាជ្ញាបានបន្ថែម ទៀតថា នួន ជា និង ខៀវ សំផន ព្រមទាំងជនដទៃទៀត ដែលជាមេដឹកនាំខ្ពស់បំផុតនៃរបបនោះបានបង្កើត និងអនុវត្តផែនការ និងគោលនយោបាយ ដោយបានដឹងថាបទឧក្រិដ្ឋទាំងនេះនឹងកើតមានឡើងជាយថាហេតុ ។

## ១) ភស្តុតាងពាក់ព័ន្ធនឹងបទឧក្រិដ្ឋជម្លៀសប្រជាជនដំណាក់កាលទី១ និង២ និងផែនការឈានទៅរកឧក្រិដ្ឋកម្ម

ហេតុការណ៍ទាំងឡាយដែលកើតឡើងនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពុំមែនជាផែនការដាច់ដោយឡែក និងកើតឡើងដោយពុំដឹងខ្លួននោះទេ ។ ហេតុការណ៍នេះបានកើតឡើងបន្តដោយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីជម្លៀសប្រជាជនចេញពីទីប្រជុំជន ដែលបក្សនេះបានកាន់កាប់ក្នុងគោលបំណងដើម្បីឲ្យប្រជាជនរស់នៅទីប្រជុំជនទាំងនោះក្លាយជាទាសករ និងដើម្បីកាប់សម្លាប់សមាជិកនៃរបបសាធារណរដ្ឋខ្មែរ និងបុគ្គលផ្សេងទៀត ដែលគេចាត់ទុកថាជាខ្មាំង ។

ភស្តុតាងដែលបានបង្ហាញពីអំពើទាំងនេះនៅចុងទសវត្សរ៍ទី៦០ និងដើមទសវត្សរ៍ទី៧០ នឹងជាភស្តុតាងសំខាន់ ។ មូលហេតុសំខាន់ ដោយសារវាបានបង្ហាញឲ្យឃើញនូវហេតុការណ៍នាខែមេសា ឆ្នាំ១៩៧៥ ដែលជាហេតុការណ៍មួយផ្នែកបង្ហាញឲ្យឃើញនូវការកើតឡើងជាហូហែរនៃអំពើហិង្សា ភាពសាហាវយង់ឃ្នង និងការជិះជាន់ ដែលជនជាប់ចោទបានបង្កើតឡើងជាយូរមកហើយ ។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា នៅពេលប្រជុំសម្រេចពីការជម្លៀសប្រជាជន ជនជាប់ចោទបានដឹងជាមុនថាឧក្រិដ្ឋកម្មនឹងកើតមានឡើង ។ ជនជាប់ចោទបានដឹងពីការធ្វើបាបប្រជាជនយ៉ាងធ្ងន់ធ្ងរ ព្រោះជាក់ស្តែងពួកគេបានចាត់ទុកប្រជាជនទាំងនោះថាជាជនសង្ស័យ និងត្រូវចាត់ទុកថាជាខ្មាំង ជាពិសេស

អ្នកដែលមកពីទីក្រុងអ្នកដែលទទួលការអប់រំខ្ពស់ អ្នកដែលជាប់ខ្សែនៅបរទេស សមាជិកនៃក្រុមជាតិពន្ធុ ជនជាតិភាគតិច អ្នកដែលកាន់សាសនា និងជាពិសេសអ្នកដែលធ្លាប់ជាប់និន្នាការជាមួយរបបចាស់ ។ បុគ្គលទាំងឡាយដែលត្រូវមើលឃើញថា ប្រឆាំងនឹងត្រូវប្រឈមនឹងទុក្ខទោស និងសេចក្តីស្លាប់ ។ អំពើហឹង្សានេះ បានបង្ហាញឲ្យឃើញនូវរបៀបឡើងកាន់អំណាច របៀបអនុវត្តអំណាច និងរបៀបដែលពួកគេព្យាយាមយកអំណាចទាំងនោះ មកអនុវត្តលើបុគ្គលទាំងឡាយនៅក្រៅជួរ ។ អំពើហឹង្សាទាំងនេះ កើតឡើងពីការតស៊ូវណ្ណៈរបស់បក្សប្រឆាំងនឹងខ្មាំងរបស់ខ្មែរក្រហម ដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៦០ ។ នៅក្នុងសេចក្តីណែនាំរបស់បក្សដែលមានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្តបានបញ្ជាក់ថា នៅក្នុងមហាសន្និបាតលើកទី១ នាខែកញ្ញា ឆ្នាំ១៩៦០ រួមមាន ប៉ុល ពត, នួន ជា និង អៀង សារី បានសម្រេចថា នៅក្នុងសង្គមកម្ពុជា កសិករ និងម្ចាស់ដី មានទំនាស់ស្លាប់រស់នឹងគ្នា ។ ហឹង្សាបដិវត្តនេះជាចំណុចចាប់ផ្តើមមួយហៅថា បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ។ ទស្សនៈអំពីទំនាស់ស្លាប់រស់ មានអានុភាពខ្លាំងក្លា និងស្ថិតស្ថេររហូតមក ដែលជាគោលការណ៍អនុវត្តជាក់ស្តែង ហើយពុំមានអ្វីអាចសម្របសម្រួលបាន ។ សហព្រះរាជអាជ្ញា បានលើកយកករណីរបស់ ឌុច ដែលទទួលខុសត្រូវលើមរណៈភាពប្រជាជននៅមន្ទីរស-២១ ប្រមាណជាង១២០០០នាក់ ដែលមជ្ឈិមបក្សចាត់ទុកថាជាខ្មាំង ។ ឌុច ជាបុគ្គលដែលអាចពន្យល់បានអំពីទំនាស់ស្លាប់រស់នោះ ។ ប្រជាជនរាប់រយពាន់នាក់បានស្លាប់ ដោយសារលទ្ធផលសម្រេចប្រើប្រាស់ហឹង្សាបដិវត្តន៍ តាំងពីមុនខែមេសា ឆ្នាំ១៩៧៥មកម្ល៉េះ ។ ដើម្បីអនុវត្តហឹង្សាប្រដាប់អាវុធប្រឆាំងនឹងខ្មាំងរបស់ពួកគេ មេដឹកនាំបក្សបានបង្កើតកងការពារសម្ងាត់ចាប់ពីឆ្នាំ១៩៦១មក ។ ក្រោយមក កងឈ្លបប្រដាប់អាវុធទាំងនេះ បានក្លាយជាកងទ័ពខ្មែរក្រហម ។ នៅក្នុងសៀវភៅបោះពុម្ពផ្សាយក្នុងឆ្នាំ ២០០៤ របស់ ខៀវ សំផន បានទទួលស្គាល់ថា នៅទសវត្សឆ្នាំ៦០ កងទាំងនេះមានមុខងារដូចជា ការកាប់សម្លាប់ប្រជាជន ដែលចាប់បាននៅក្រោយពេលមកលួចលបស្តាប់ ឬតាមដានការប្រជុំរបស់បក្ស ។ ការកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ពុំបានកម្រិតត្រឹមតែស៊ុយការពារខ្លួន ឬការសម្លាប់នៅក្នុងភ្លើងសង្គ្រាមប៉ុណ្ណោះទេ ។ កម្មាភិបាលបក្ស និងកងឈ្លបបានប្រហារជីវិតពួកទាហាន ដែលពួកគេចាប់ខ្លួនបានចាប់តាំងពីដើមដំបូងបំផុតនៃចលនាបះបោរនៃចលនាបក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងរបបសម្តេចព្រះ នរោត្តម សីហនុ ក្នុងឆ្នាំ១៩៦៨មកម្ល៉េះ ។ នៅឆ្នាំ១៩៧១ ការប្រើប្រាស់ការបំភិតបំភ័យរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងអ្នកដែលគេយល់ថា ជាភ្នាក់ងាររបស់ខ្មាំង និងគិញបានក្លាយជាប្រព័ន្ធ ។ សហព្រះរាជអាជ្ញា បានលើកយកភស្តុតាងមួយចំនួនដែលផ្តល់សក្ខីកម្មដោយសាក្សី ហ៊ុលីព ស្សុត និងសាក្សី កាំង ហ្គេចអ៊ាវ ហៅ ឌុច ដើម្បីគាំទ្រការលើកឡើងរបស់ខ្លួន ។ ឌុច បានចាត់ចែងមន្ទីរម-១៣ ចាប់តាំងពីខែកក្កដា ឆ្នាំ១៩៧១ ដល់ខែមេសា ឆ្នាំ១៩៧៥ ។ នៅក្នុងសក្ខីកម្ម ឌុច បានរៀបរាប់អំពីរបៀបដែលខ្មែរក្រហមបានបញ្ជូនប្រជាជនដែលសង្ស័យថា ជាគិញ មកកាន់មន្ទីរសន្តិសុខម-១៣ ដើម្បីសួរចម្លើយ និងសម្លាប់ចោល ដោយគោរពតាមគោលនយោបាយរបស់បក្ស ។ ឌុច បំពេញការងារនេះនៅក្រោមការត្រួតត្រាផ្ទាល់របស់ វន វេត ដែលជាលេខាភូមិភាគពិសេស ហើយសហការីរបស់ វន វេត មាន នួន ជា និងខៀវ សំផន ជាសមាជិកគណៈកម្មាការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ ប្រភេទខ្មាំងដែលត្រូវបញ្ជូនទៅ ម-១៣ ដើម្បីសួរចម្លើយ និងសម្លាប់ចោលរួមមាន ទាហាន លន់ នល់ កម្មាភិបាលដែលបញ្ជូនទៅរៀននៅវៀតណាម និងអ្នកនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ។ សហព្រះរាជអាជ្ញាបានចង្អុលបង្ហាញថា សក្ខីកម្មរបស់ ឌុច ពិតជាអាចទុកចិត្តបាន ដោយហេតុថា ឌុច ជាមនុស្សដែលមានការចងចាំលម្អិត ហើយគេអាចមើលឃើញថា ឌុច គ្មានចេតនាភូតកុហក ឬបញ្ចេញបញ្ចូលនោះឡើយ ។ នៅក្នុងដំណាក់កាលផ្តល់សក្ខីកម្ម ឌុច ត្រូវអង្គជំនុំជម្រះតុលាការកំពូលផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតរួចទៅហើយ ដោយសារការទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម និងសម្លាប់ប្រជាជននៅមន្ទីរសន្តិសុខ ស-២១ និង ម-១៣ ។

ព្រះរាជអាជ្ញា បានបន្តលើកឡើងទៀតថា ការជម្លៀសប្រជាជនឲ្យចេញពីទីក្រុងនានាដោយបង្ខំ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ធ្វើឡើងទៅតាមការសម្រេចរបស់ នួន ជា និង ខៀវ សំផន គឺជាមធ្យោបាយតែមួយគត់ ដើម្បីផ្តួលរំលំវណ្ណៈអ្នកទីក្រុង

និងបំបែកបំបាក់ខ្សែខ្មាំងនៅតាមទីក្រុង ។ ការកំណត់អត្តសញ្ញាណខ្មាំងគឺជាការកម្ទេចខ្មាំង ដោយប្រើប្រាស់អំពើហិង្សាលើប្រជាជនស៊ីវិល ដែលត្រូវបានបង្ខំឲ្យរស់នៅតាមសហករណ៍ខ្មែរក្រហម ។ សហករណ៍បង្កើតឡើងនៅឆ្នាំ១៩៧១ ក្រោយមកនៅឆ្នាំ១៩៧២ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានសមូហភាវូនីយកម្មដោយបង្ខំ ដែលប្រជាជនត្រូវបង្ខំឲ្យធ្វើការរួមគ្នា ហូបចុករួមគ្នា ដោយពុំមានកម្មសិទ្ធិឯកជន ។ នៅខែឧសភា ឆ្នាំ១៩៧៣ បក្សបានដាក់ប្រជាជនឲ្យរស់នៅក្នុងសហករណ៍កម្រិតខ្ពស់ ដែលប្រជាជនត្រូវបានជិះជាន់កាន់តែធ្ងន់ធ្ងរមួយកម្រិត ទៀត ។ ខៀវ សំផន បានទទួលស្គាល់នៅក្នុងបទសម្ភាសន៍កាលពីពេលថ្មីៗថា ប្រជាជនកម្ពុជា ត្រូវបង្ខំឲ្យចូលរួមក្នុងសហករណ៍ ។ ដំបូងប្រសិនបើមិនបង្ខំ ពុំមានអ្នកណាចូលរួមដោយស្ម័គ្រចិត្តនោះទេ ។ ព្រះរាជអាជ្ញាច្រានចោលការលើកឡើងរបស់មេធាវីការពារក្តីកន្លងមកដែលថា ការបង្កើតសហករណ៍ គឺជាផ្នែកនៃកម្មវិធីស្របច្បាប់ ដើម្បីដោះស្រាយភាពមិនស្មើគ្នានៅក្នុងសង្គម និងការកេងប្រវ័ញ្ចកសិករពីវណ្ណៈជិះជាន់នោះថា ជាការមិនត្រឹមត្រូវ ។ ការច្រានចោលនេះ សហព្រះរាជអាជ្ញា បានផ្អែកលើការពិនិត្យលើរបៀបប្រព្រឹត្តនៃសហករណ៍ទាំងនោះ ដែលមានសភាពផ្ទុយពីការលើកឡើងរបស់មេធាវីការពារជនជាប់ចោទ ។ ឆ្លងតាមសេចក្តីសម្រេចរបស់គណៈកម្មាការមជ្ឈិមនៅក្នុងខែឧសភា ឆ្នាំ១៩៧២ ការដាក់ឲ្យទៅជាសមូហភាពត្រូវបានអនុវត្តដោយបង្ខំ ។ ចាប់តាំងពីពេលនោះមក ការប្រឆាំងនឹងកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់រំដោះមានន័យថា ជាការស្លាប់ ។ គោលបំណងពិតប្រាកដនៃការបង្កើតសហករណ៍ គឺដើម្បីរក្សាអំណាចរបស់អ្នកដឹកនាំបក្សតាមរយៈការដាក់ប្រជាជនឲ្យទៅជាទាសករ ។ សហករណ៍ត្រូវប្រើប្រាស់ជាឧបករណ៍ ដើម្បីវាយប្រហារ និងកម្ទេចខ្មាំងទាំងនៅទីជនបទ ទាំងនៅទីក្រុង ។

### ក) ចេតនាឧក្រិដ្ឋរបស់ជនជាប់ចោទស្តីពីការអនុវត្តការជម្លៀសប្រជាជនដោយបង្ខំ

សហព្រះរាជអាជ្ញាជាតិ បានព្យាយាមលើកឡើងពីភាពស៊ីសង្វាក់គ្នានៃភស្តុតាងអំពើឧក្រិដ្ឋ និងដើមហេតុនៅមុនឆ្នាំ១៩៧៥ ពោលគឺចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ ដែលជាគន្លឹះសំខាន់នាំឲ្យមានការជម្លៀសប្រជាជនដោយបង្ខំ ។ អំពើឧក្រិដ្ឋនេះ ត្រូវរៀបចំឡើងដើម្បីកាត់ផ្តាច់កុំឲ្យកម្លាំងរដ្ឋាភិបាល សាធារណរដ្ឋខ្មែរមានមូលដ្ឋានគាំទ្រ និងផ្លាស់ប្តូរទីលំនៅដោយបង្ខំដល់ប្រជាជនដែលត្រូវជម្លៀសទៅកាន់សហករណ៍ជនបទនៅក្នុងតំបន់រំដោះ ។ តំបន់រំដោះគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា ដោយការដាក់ប្រជាជនទាំងនោះឲ្យទៅជាទាសករ និងប្រើប្រាស់ជាមូលដ្ឋានផលិតកម្មសម្រាប់បម្រើបដិវត្តន៍ ។ ការជម្លៀសក៏បានធ្វើឡើងរួមជាមួយនឹងការសម្លាប់ដែរ ដែលជាអំពើឧក្រិដ្ឋប្រឆាំងនឹងប្រជាជនរាប់ពាន់នាក់ ដោយប្រព្រឹត្តឡើងក្នុងលក្ខណៈរៀបចំនិងសម្របសម្រួលគ្នា ក្រោមការបញ្ជាពីថ្នាក់កំពូលបំផុតរបស់បក្ស ។ ព្រះរាជអាជ្ញាក៏បានបញ្ជាក់ទៀតថា ការឈឺចាប់ខ្លោចផ្សាររបស់ប្រជាជន ដែលកើតចេញពីការជម្លៀសបក្សពុំបានលើកយកមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយម្តងណាឡើយ ។ ការឈឺចាប់ធ្ងន់ធ្ងរ ដែលកើតលើប្រជាជនស៊ីវិលនៅក្នុងអំឡុងពេលជម្លៀសមុនឆ្នាំ១៩៧៥ បានបង្ហាញតាមរយៈសក្ខីកម្មរបស់សាក្សីជាច្រើនរូបនៅចំពោះមុខអង្គជំនុំជម្រះ ។ ដោយផ្អែកលើសក្ខីកម្មរបស់សាក្សី ដេវីដ ឆេនដ្ល័រ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងក្រសែភ្នែកបក្សកុម្មុយនីស្តកម្ពុជា ប្រជាជននៅក្នុងក្រុងបានក្លាយជាខ្មាំងដោយសារនយោបាយ ។ ចំណែកសាក្សី ឈូក រីន មេបញ្ជាការខ្មែរក្រហមប្រចាំភូមិភាគនិរតី បានបញ្ជាក់ថា ក្នុងនាមជាយោធាម្នាក់ ឈូក រីន បានដឹងច្បាស់តាំងពី មុនឆ្នាំ១៩៧៥ ថាអ្នករស់នៅក្នុងទីក្រុងសុទ្ធតែជាខ្មាំង ។ សហព្រះរាជអាជ្ញាបានបន្តថា បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំឲ្យមានការជម្លៀសប្រជាជននៅទីតាំងមួយចំនួន ដូចជានៅឧត្តុង្គ និងនៅខេត្តកំពង់ចាមមុនពេលជម្លៀសនៅទីក្រុងភ្នំពេញ ។ ការជម្លៀសក្រុងឧត្តុង្គដោយបង្ខំ បានក្លាយជាគំរូ ដែលមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចថា នឹងធ្វើដូចគ្នានៅទីក្រុងភ្នំពេញ ។

សហព្រះរាជអាជ្ញាជាតិ បានគូសបញ្ជាក់ពីការចូលរួមរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅក្នុងការប្រជុំមជ្ឈិមបក្សទាំងពីរលើកនៅខែមិថុនា ឆ្នាំ១៩៧៤និង ខែមេសា ឆ្នាំ១៩៧៥ ។ ការប្រជុំស្តីពីការសម្រេចរបស់មេដឹកនាំលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំក្រោយថ្ងៃជ័យជម្នះ ។ ព្រះរាជ

អាជ្ញាបានទាញយកភស្តុតាង ដែលជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តស្តីពីការថ្លែងសន្ទរកថារបស់មេដឹកនាំខ្មែរក្រហម ។ ប៉ុល ពត, នួន ជា និង ខៀវ សំផន បានបង្ហាញពីគោលបំណងនៃការជម្លៀសប្រជាជនចេញពីទីក្រុង ដែលផ្តោតទៅលើការលុបបំបាត់ខ្មាំងរួមមាន សេ.អ៊ី.អា, កា.ហ្សេ.បេ, ភ្នាក់ងារវៀតណាម និងនាយទុនសក្តិភូមិជាដើម ។ សមាជិកនៃអតីតរបបសាធារណៈរដ្ឋខ្មែរត្រូវបានកំណត់ជាមុខសញ្ញាសម្រាប់កម្ទេចភ្លាមៗ ។ ប្រជាជនដែលនៅសល់ត្រូវរងការគាបសង្កត់ និងដាក់ឃុំឃាំងនៅក្នុងសហករណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ។ ពួកគេជាច្រើនត្រូវសម្លាប់ចោល ហើយអ្នកដែលនៅសល់ត្រូវទទួលរងការបំពានធ្វើបាបលើរូបរាងកាយ និងផ្លូវចិត្ត រួមមានដូចជា ការបង្ខំឲ្យសរសេរប្រវត្តិរូប ដើម្បីអាចកំណត់អត្តសញ្ញាណនិងកម្ទេចចោល អ្នកដែលនៅសល់ពីរបបសាធារណរដ្ឋ, ការបំបែកចេញពីគ្រួសាររបស់គេ ដោយបង្ខំឲ្យធ្វើការងារប្រើកម្លាំងធ្ងន់ៗ, ការទទួលរបបអាហារមិនគ្រប់គ្រាន់ និងការបដិសេធសិទ្ធិចិញ្ចឹមជីវិត ឬស្វែងរកអាហារបរិភោគ, ការទទួលរងនូវការគំរាមកំហែង, ទារុណកម្ម, ការជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ និងចុងក្រោយត្រូវសម្លាប់ចោល ។

### ខ) វិបត្តិមនុស្សធម៌បង្ករឡើងនៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

សហព្រះរាជអាជ្ញា បានលើកឡើងពីភស្តុតាង ដើម្បីច្រានចោលការអះអាងដោយក្រុមមេធាវីការពារក្តីដែលលើកឡើងថាការជម្លៀសធ្វើឡើងដើម្បីផ្តល់ម្ហូបអាហារ និងដើម្បីឆ្លើយតបវិបត្តិផ្នែកមនុស្សធម៌ ។ ភស្តុតាងបង្ហាញថា នៅក្នុងរយៈពេលប៉ុន្មានខែមុនបែកភ្នំពេញ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មានចេតនាបង្ករឲ្យមានវិបត្តិមនុស្សធម៌នៅក្នុងទីក្រុង ដោយការឡោមព័ទ្ធក្រុងនេះ បិទផ្លូវផ្គត់ផ្គង់អាហារ និងបរិក្ខារពេទ្យកាប់សម្លាប់ជនស៊ីវិលនៅពេលបាញ់ផ្លោងវាយសម្រុកចូលតំបន់ប្រជាជនរស់នៅនិងបំភិតបំភ័យប្រជាជននៅក្នុងទីក្រុងទាំងមូល ។ សហព្រះរាជអាជ្ញាបន្តថា សកម្មភាពនេះ ធ្វើឡើងផ្ទុយពីចេតនារបស់ជនជាប់ចោទដែលថា ខ្លួនមានបំណងជៀសវាង ឬកាត់បន្ថយការឈឺចាប់ខ្លោចផ្សានោះ ។ ប៉ុន្តែ វាបែរជាបង្ហាញឲ្យឃើញថា ការពិតជនជាប់ចោទមានចេតនាផ្ទុយស្រលះទៅវិញ ។ សហព្រះរាជអាជ្ញាបានលើកយកសក្ខីកម្ម និងកំណត់ហេតុប្រចាំថ្ងៃរបស់សាក្សី ស៊ីដនីស្កែនប៊ើក ដែលថា ពួកខ្មែរក្រហមវាយប្រហារលើក្បួនរថយន្តដែលកំពុងដឹកម្ហូបអាហារ និងប្រេងឥន្ធនៈពីប្រទេសវៀតណាមខាងត្បូងមកតាមទន្លេមេគង្គលើ ដើម្បីចែកចាយទៅដល់ទីក្រុងភ្នំពេញ ។ ការវាយប្រហារនេះ ដើម្បីធ្វើឲ្យទីក្រុងភ្នំពេញដាច់ខ្យល់ស្លាប់ ។ រដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរ (លន់ នល់) បានស្នើសុំឲ្យមានការចរចា ជាមួយខ្មែរក្រហមដើម្បីបញ្ឈប់សង្គ្រាមដោយសន្តិវិធី ប៉ុន្តែការព្យាយាមនេះត្រូវបដិសេធ ដោយបក្សកុម្មុយនីស្តកម្ពុជាជាច្រើនលើក ។ សហព្រះរាជអាជ្ញាបានលើកយកសក្ខីកម្មរបស់សាក្សី ហ្វីលីព ស្សត ស្តីពីការផ្លោងគ្រាប់បែករបស់ខ្មែរក្រហមមកលើតំបន់ដែលមានប្រជាជនរស់នៅច្រើន ដោយមិនរើសមុខ មិនដឹងទិសតំបន់ ។ ប្រជាជននៅតាមជាយក្រុងទទួលរងគ្រោះច្រើនជាងគេ ។ ខ្មែរក្រហមយល់ថា ការផ្លោងទាំងនោះពុំមានចោទជាបញ្ហានោះទេ ដោយសារប្រជាជនទាំងនោះរស់នៅជាមួយ លន់ នល់ ពុំព្រមជ្រើសរើសចូលរួមបដិវត្តជាមួយខ្មែរក្រហម ។ ភស្តុតាងបង្ហាញពីចេតនារបស់ជនជាប់ចោទ ក្នុងការដឹកនាំនិងជំរុញឲ្យមានការសម្លាប់រង្គាលមកលើជនស៊ីវិល ដែលរស់នៅទីក្រុង ។ ភស្តុតាងក៏បង្ហាញពីសេចក្តីឈឺចាប់ដ៏ធំធេង ដែលជនជាប់ចោទបង្កឡើងដោយបានដឹងជាមុន និងប្រកបដោយចេតនា ក្នុងរយៈពេលប៉ុន្មានខែមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៥ ។ ជនជាប់ចោទ ពិតជាមានការទទួលខុសត្រូវទាំងស្រុងចំពោះស្ថានភាពអមនុស្សធម៌ដ៏ធ្ងន់ធ្ងរនៅទីក្រុងភ្នំពេញ ។ សហព្រះរាជអាជ្ញា បានលើកយកសក្ខីកម្មរបស់សាក្សី ស៊ីដនីស្កែនប៊ើក និង អាល់ រ៉ុកូហ្វ ទាក់ទងនឹងការកំណត់មុខសញ្ញា និងការបែងចែកមន្ត្រីសាធារណរដ្ឋខ្មែរក្នុងរយៈពេលតែប៉ុន្មានម៉ោងក្រោយពេលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ និងបុគ្គលសំខាន់ៗមួយចំនួននៅក្រសួងព័ត៌មាន ។ ខ្មែរក្រហមបានឲ្យបុគ្គលទាំងនោះបែងចែកជាបីក្រុម គឺទាហាន អ្នកនយោបាយ និងប្រជាជនស៊ីវិល ។ សហព្រះរាជអាជ្ញា បានបង្ហាញរូបថតមួយសន្លឹកនៃព្រឹត្តិការណ៍នៅក្នុងក្រសួងព័ត៌មានដែលថតដោយលោក អាល់ រ៉ុកូហ្វ ។ សហព្រះរាជអាជ្ញាបានបន្តដោយយោងទៅលើសក្ខីកម្មរបស់

សាក្សីមួយចំនួន ដែលបានផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះថា ឧត្តមសេនីយ៍ ថាច់ សារី, ស៊ីរិមតៈ, ឡុង បូរ៉េត (អតីតនាយករដ្ឋមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ), លន់ នន់ (ប្អូនរបស់ លន់ នល់), មន្ត្រីសាធារណរដ្ឋខ្មែរដទៃទៀតដែលបានបង្ហាញខ្លួននៅក្រសួងព័ត៌មាន និងឧត្តមសេនីយ៍៩៤រូបទៀត ត្រូវសម្លាប់ចោល ។

### គ) ខ្មែរក្រហមប្រើលេះ និងការបង្ខំ ដើម្បីជម្លៀសប្រជាជន

បន្ទាប់មកសហព្រះរាជអាជ្ញា បានលើកឡើងពីការបង្ខិតបង្ខំឲ្យប្រជាជននៅទីក្រុងភ្នំពេញ ចាកចេញពីលំនៅដ្ឋានរបស់ខ្លួនដោយតក់ក្រហល់ ។ សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបបានបញ្ជាក់ពីភាពដាច់ខាតរបស់យោធាខ្មែរក្រហម ក្នុងការជំរុញឲ្យប្រជាជនចាកចេញពីទីក្រុងភ្លាម ។ សហព្រះរាជអាជ្ញា បានដកស្រង់សក្ខីកម្មរបស់សាក្សី ស៊ីដនី ស្កែនបើកទាក់ទងនឹងចំណុចនេះថា "ក្រុមពួកទាហានខ្មាំងបានគ្រវីកាំភ្លើងខ្លី និងកាំភ្លើងវែង អ្នកខ្លះស្រែកគំហក និងអ្នកខ្លះប្រើឧបករណ៍ផ្ទុំបំពងសំឡេង ។ ពួកគេបញ្ជាឲ្យប្រជាជនចេញពីលំនៅដ្ឋានជាបន្ទាន់ ។ ពួកខ្មាំងបានបាញ់ឡើងកំហែញប្រជាជន" ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ បានជម្រាបជូនអង្គជំនុំជម្រះថា "ប្រសិនបើយើងមិនព្រមចាកចេញ ពួកគេច្បាស់ជាចាត់ទុកពួកយើងថាជាជនក្បត់ ជាពួកចក្រពត្តិ និងជាអ្នកបម្រើរបបចាស់ និងច្បាស់ជាយកយើងទៅសម្លាប់ចោលអស់បាត់ទៅហើយ" ។ សក្ខីកម្មជាច្រើន ដែលសហព្រះរាជអាជ្ញាបានដកស្រង់ ដើម្បីបង្ហាញជូនអង្គជំនុំជម្រះអំពីការបង្ខំប្រជាជនឲ្យចេញពីលំនៅដ្ឋានរបស់ខ្លួនមានដូចជា ស៊ុំ ជា, ប៉ូឌីណា, យឹម សុវណ្ណ, អូន ដល្លី, ឆេង អេងលី, បេ សុដានី, ចៅ នី, ម៉ុម សំអឿន, យិន វំដួល និង ពេជ ស្រីផល ។ សហព្រះរាជអាជ្ញាបានបន្តថា ពួកខ្មែរក្រហមបានបណ្តេញប្រជាជនចេញពីទីក្រុងឲ្យអស់ភ្លាមៗ ទោះបីជាតាមមធ្យោបាយណាក៏ដោយ ។ ប្រជាជននៅទីក្រុងទាំងអស់ត្រូវតែចាកចេញដោយគ្មានការលើកលែង គ្មានក្តីសណ្តោសប្រោសមេត្តា ឬអាណិតអាសូរអ្វីទាំងអស់ ។ សហព្រះរាជអាជ្ញាបន្តថា ភស្តុតាងបានបង្ហាញថាទាហានខ្មែរក្រហមសម្លាប់អ្នកទីក្រុងភ្នំពេញណា ដែលយឺតយ៉ាវក្នុងការអនុវត្តបញ្ជារបស់ពួកគេ ។ រាល់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តលើប្រជាជន ដែលខ្មែរក្រហមជម្លៀសមានជាអាទិ៍ ការប្រព្រឹត្តដោយអមនុស្សធម៌ ការធ្វើទារុណកម្ម ការសម្លាប់រង្គាលជាបន្តបន្ទាប់ គឺជាផ្នែកពាក់ព័ន្ធមួយនៃផែនការឧក្រិដ្ឋរួម ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ បទឧក្រិដ្ឋទាំងនេះ កើតចេញដោយផ្ទាល់ និងភ្លាមៗនៃការបញ្ជា ដែលចេញដោយមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា និងមានភាពស៊ីសង្វាក់គ្នានឹងអ្វីដែលពួកខ្មែរក្រហមបានប្រព្រឹត្តនៅពេលក្រោយមកទៀត ។ យោធាខ្មែរក្រហមត្រូវបណ្តុះបណ្តាល និងបញ្ចូលមនោគមន៍វិជ្ជា ដើម្បីគិតថាមនុស្សទីក្រុង គឺសុទ្ធតែជាខ្មាំងរបស់ពួកគេ ។ អតីតយោធាខ្មែរក្រហម គង់ គីម បានលើកឡើងថា គ្មានច្បាប់ ឬបទបញ្ជាណាមួយហាមយើងមិនឲ្យបាញ់មនុស្សនោះ ទេ ។ ជនជាប់ចោទ ខៀវ សំផន បានអះអាងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា ការជម្លៀសដោយបង្ខំមានមូលហេតុត្រឹមត្រូវ ដោយសារមានការគម្រាមកំហែងពីការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកកាំង ។ នេះជាការភូតភរដែលខ្មែរក្រហមប្រើដើម្បីបោកប្រាស់ប្រជាជនឲ្យចេញពីទីក្រុង ព្រមទាំងមានចេតនាគិតទុកជាមុន ដែលត្រូវរៀបចំឡើងដើម្បីឲ្យប្រជាជនអនុវត្តតាមឲ្យបានកាន់តែទូលំទូលាយ និងបង្កលក្ខណៈកាន់តែងាយស្រួលសម្រាប់កងទ័ពបក្សកុម្មុយនីស្តកម្ពុជាក្នុងការបញ្ចប់បេសកកម្មរបស់ខ្លួន ។

### ឃ) អំពើអមនុស្សធម៌

ប្រជាជនកម្ពុជាដែលរស់នៅក្នុងទីក្រុងភ្នំពេញ បានក្លាយជាទាសករ និងអ្នកទោសរបស់យោធាខ្មែរក្រហមប្រដាប់ដោយអាវុធហើយអមដំណើរពួកគាត់ទៅកាន់ទីកន្លែងដែលខ្លួនពុំធ្លាប់ស្គាល់ ។ប្រជាជនដែលត្រូវជម្លៀសរួមមានបុរស ស្ត្រី កុមារ ចាស់ជរា ជនពិការ អ្នកជិះរទេះ និងអ្នកជំងឺ ។ អ្នកទាំងនេះ ភាគច្រើនធ្វើដំណើរដោយថ្មើរជើង អូសរទេះ បណ្តើរកង់ ខ្លះអូសរទេះដឹកឥវ៉ាន់ ខ្លះដឹកសមាជិកគ្រួសារដែលមានជំងឺ អ្នកខ្លះត្រូវទុកចោលរថយន្តដែលអស់សាំង ឬត្រូវខ្មែរក្រហមរឹបអូស ។ ស្ថានភាព ដែលបានប្រព្រឹត្តមកលើជនដែលត្រូវជម្លៀសមានភាពឈឺចាប់យ៉ាងខ្លាំង ដូចជា ការធ្វើដំណើរយឺតៗកណ្តាលថ្ងៃក្តៅនៅក្នុងរដូវក្តៅបំផុតប្រចាំឆ្នាំ បណ្តាលឲ្យមានការឈឺចាប់ពេញរាងកាយ ដោយគ្មានជំរក គ្មានទឹក គ្មានចំណីអាហារ និងគ្មានជំនួយថ្នាំសង្កូវទាល់តែសោះ ។ អ្នកទាំងនោះត្រូវខ្មែរក្រហមដកហូត សិទ្ធិសេរី

ភាព ប្រឈមមុខនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញ ហើយមានអ្នកខ្លះត្រូវស្លាប់ដោយ សារទ្រាំទ្រនឹងស្ថានភាពដ៏លំបាកនេះពុំបាន ។ ដោយផ្អែកលើសក្ខីកម្មរបស់លោក មាស សារ៉ាន់ បានឲ្យដឹងថា បុគ្គលិកពេទ្យត្រូវបញ្ជាឲ្យចេញ និងទុកអ្នករបួសចោល ។ អ្នកជំងឺរាប់រយនាក់ត្រូវបោះបង់ចោលក្នុងនោះមានកុមារអាយុ៨ឆ្នាំដែលធ្លាយពោះ និងចេញពោះវៀនមកក្រៅ ។ កុមារីនោះបានទាញអាវរបស់លោក មាស សារ៉ាន់ និងសុំអង្វរឲ្យបីយកនាងទៅជាមួយផង ប៉ុន្តែគាត់ត្រូវចាកចេញ ។ រូបភាពលំបាកវេទនាជាច្រើននៅក្នុងពេលជម្លៀស ដែលត្រូវលើកឡើងនៅក្នុងសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ រួមមានការសម្រាលកូននៅតាមផ្លូវ ការព្រាត់ប្រាសកូនចៅ បើទោះបីជាមានការសុំអង្វរយោធាខ្មែរក្រហមដើម្បីស្វែងរកសមាជិកគ្រួសារ ក៏ពួកគេមិនអនុញ្ញាតដែរ ។

## ង) ការជម្លៀសដំណាក់កាលទី២

សហព្រះរាជអាជ្ញាបន្តធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការជម្លៀសលើកទី២ ដោយផ្តោតលើការលើកឡើងរបស់សាក្សីជំនាញ ហ៊ីលីព ស្ងត ដែលថាការបញ្ជូនប្រជាជនរាប់លាននាក់ហើយដូនដំណើរក្នុងរយៈពេលប៉ុន្មានម៉ោង គឺជាការរុញច្រានប្រជាជនឲ្យធ្លាក់ក្នុងគ្រោះមហន្តរាយ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា នៅខែកញ្ញា ឆ្នាំ១៩៧៥ ការជម្លៀសប្រជាជនប្រមាណកន្លះលាននាក់ទៅភូមិភាគពាយ័ព្យ ដោយថ្នាក់ដឹកនាំមជ្ឈិមដឹងច្បាស់ជាមុនថា ប្រជាជនមិនអាចទ្រាំទ្ររស់នៅក្នុងស្ថានភាពដ៏លំបាកបានទេ ។ ដោយសារនៅភូមិភាគពាយ័ព្យភាគច្រើនសុទ្ធតែព្រៃ ហើយប្រជាជនថ្មីពុំមានបទពិសោធ និងសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មនោះទេ ។

សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានបន្តលើកឡើងពីឧក្រិដ្ឋកម្ម ដែលកើតចេញពីការជម្លៀសដំណាក់កាលទី២ ដោយបង្ហាញថា វាកើតចេញពីលទ្ធផលនៃផែនការឧក្រិដ្ឋរៀបចំដោយ ខៀវ សំផន, នួន ជា រួមជាមួយនឹងសមាជិកផ្សេងទៀតនៃមជ្ឈិមបក្ស ។ ព្រះរាជអាជ្ញាបានបន្តទៀតថា វាមានភាពដូចគ្នានឹងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដែលកើតឡើងដោយសារការរៀបចំទុកជាមុនយ៉ាងហ្មត់ចត់ ដើម្បីធ្វើទុកបុកម្នេញ និងកាប់



ប្រជាជនត្រឡប់ទៅលំនៅដ្ឋានវិញក្រោយរបបខ្មែរក្រហមដួលរលំ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្លាប់អតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ និងទាហាន ដោយការលើកទឹកចិត្តឲ្យកងកម្មាភិបាលប្រព្រឹត្តដោយមេដឹកនាំទាំងនោះ ។ នៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ខៀវ សំផន បានផ្សព្វផ្សាយនូវសេចក្តីសម្រេចរបស់សន្និបាតជាតិលើកទី២ថា ចាំបាច់ដាច់ខាត ត្រូវសម្លាប់ជនក្បត់ទាំង៧រូបរបស់របបសាធារណៈរដ្ឋខ្មែរ ។ ខៀវ សំផន ពុំធ្លាប់បដិសេធការផ្សព្វផ្សាយនេះទេ ដែលវាជាការបញ្ជាក់យ៉ាងច្បាស់ពីពិរុទ្ធភាព និងការទទួលខុសត្រូវរបស់ខៀវ សំផន ចំពោះការកាប់សម្លាប់នេះ ។ នួន ជា បានបញ្ជាក់ប្រាប់ថេត សម្បត្តិ ដែលជាអ្នកការសែតដ៏គួរឲ្យទុកចិត្តម្នាក់ថា “គោលនយោបាយគឺកម្ទេច” ។ នួន ជា បានទទួលស្គាល់អំពីការសម្លាប់មនុស្ស ដែលត្រូវចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ការទទួលខុសត្រូវនេះធ្វើឡើងដោយគ្មានសម្ពាធ ដោយម៉ឺងម៉ាត់ ដោយប្រាកដប្រជា គ្មានការសោកស្តាយ និងដោយគ្មានវិប្បដិសារី ។ វាបង្ហាញយ៉ាងច្បាស់តាមរយៈសេចក្តីថ្លែងការណ៍ និងចម្លើយរបស់ នួន ជា ដែលនៅតែជឿជាក់ថា ការកាប់សម្លាប់នៅក្រៅប្រព័ន្ធតុលាការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានហេតុផលត្រឹមត្រូវ ហើយចាំបាច់ត្រូវតែធ្វើ ។ អៀង សារី ជាសមាជិកអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា និងជាអ្នកធ្វើការងារជាមួយ នួន ជា បានទទួលស្គាល់ថា “បញ្ជាឲ្យកាប់សម្លាប់មន្ត្រី លន់ នល់ ចេញមកពីមេដឹកនាំមជ្ឈិមបក្ស ហើយទំហំនៃបញ្ជាកាប់សម្លាប់នោះ មិនមែនត្រឹមតែជួរដឹកនាំសាធារណៈខ្មែរប៉ុណ្ណោះទេ ។ បញ្ជាឲ្យកាប់សម្លាប់មន្ត្រី លន់ នល់ បានពង្រីករហូត ដោយរួមបញ្ចូលអ្នករដ្ឋការថ្នាក់ទាប និងកម្មាភិបាលយោធា” ។ អៀង សារី បានធ្វើសេចក្តីប្រកាស ដែលនិយាយពីអាទិភាពនៃគោលនយោបាយក្នុងការកំណត់គោលដៅ និងកាប់សម្លាប់ទាហានថ្នាក់ទាបនិងអ្នករដ្ឋការនៃរបបសាធារណៈរដ្ឋខ្មែរក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ អៀង សារី បានពន្យល់នូវហេតុផលនៅពីក្រោយការសម្លាប់ ដែលត្រូវបានរៀបចំជាឈុតលើទាហានសាធារណៈរដ្ឋខ្មែរ និងមន្ត្រីទាំងនោះ ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ការសម្លាប់ទាំងនេះ កើតឡើងក្នុងមធ្យោបាយ និងវិធីស្រដៀងគ្នានៅតាមទីតាំងភូមិសាស្ត្រធំៗ ស្របជាមួយនឹងគោលនយោបាយមុនៗរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ ។

សហព្រះរាជអាជ្ញា បានបែងចែកការសម្លាប់អតីតមន្ត្រីសាធារណរដ្ឋនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ជាពីរក្រុម ។ ទីមួយ មន្ត្រីដែលត្រូវខ្មែរក្រហមសម្លាប់នៅក្នុងទីក្រុងភ្នំពេញពេលជម្លៀស, នៅក្នុងពេលធ្វើដំណើរ ឬនៅពេលទៅដល់គោលដៅថ្មីរបស់ពួកគេ ក្រោយពេលពួកគេត្រូវបានបង្ខំចេញពីទីក្រុងភ្នំពេញ ។ ក្រុមទីពីរការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅក្រៅទីក្រុងភ្នំពេញ និងអ្នកដែលពុំមែនជាកម្មវត្ថុនៃការបញ្ជូនដោយការបង្ខំពីទីក្រុងភ្នំពេញ ។ យោងតាមដីការបស់សហព្រះរាជអាជ្ញា ការកាប់សម្លាប់ក្រុមទាំងពីរប្រភេទនេះ បង្ហាញអំពីអត្ថិភាពនៃគោលនយោបាយក្នុងការកាប់សម្លាប់អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ចាប់ពីថ្ងៃទី១៧ខែមេសាឆ្នាំ១៩៧៥ ។ ការកាប់សម្លាប់ក្រុមទាំងពីរនេះ បានកើតឡើងក្នុងពេលជម្លៀសប្រជាជន ដែលអ្នកទាំងនេះគឺជាបុគ្គលិកសាធារណរដ្ឋខ្មែរ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ទៀតថា ការកាប់សម្លាប់ទាំងនេះគឺជាផ្នែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជនជាប់ចោទកំពុងតែប្រឈមមុខនឹងការជំនុំជម្រះ ។ សហព្រះរាជអាជ្ញាបានលើកឡើងពីភស្តុតាង ដែលជាសក្ខីកម្មរបស់សាក្សីមួយ ចំនួនទាក់ទងនឹងការមើលឃើញនូវការកាប់សម្លាប់ទាហាន លន់ នល់ ដែលសាក្សីបានឃើញ ។ ផ្អែកតាមបទពិសោធរបស់ជនភៀសខ្លួន ដែលលោក ប៉ុងសូដ៍ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថា កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាមានបំណងកម្ទេចប្រជាជនទាំងអស់ ដែលបម្រើការងារឲ្យរបប លន់ នល់ ដែលពួកគាត់ត្រូវចាត់ទុកថាជាពួកក្បត់ ។ លោក ហ្វីលីព ស្សុត បានបញ្ជាក់ដោយផ្អែកលើការស្រាវជ្រាវនៅក្នុងសៀវភៅរបស់គាត់ថា សណ្ឋាគារមនោរម្យត្រូវបានប្រើប្រាស់ជាទីតាំង ដើម្បីប្រមូលផ្តុំមន្ត្រីសាធារណរដ្ឋខ្មែរជាន់ខ្ពស់ ដើម្បីយកទៅសម្លាប់ចោល ។ សាក្សី ហ្វីលីព ស្សុត បានបន្ថែមទៀតថា នាយករដ្ឋមន្ត្រី ឡុង បូរ៉េត, លន់ នន់ និងអ្នករដ្ឋការជាន់ខ្ពស់ផ្សេងទៀតត្រូវបានគេយកចេញទៅសម្លាប់ចោលនៅកន្លែងកីឡា មិនឆ្ងាយពីទីស្តីការក្រសួងពត៌មាន ដែលជាកន្លែងឃុំខ្លួនអ្នកទាំងនោះ ។ ប៉ុន្មានថ្ងៃក្រោយមក អ្នកនយោបាយ មន្ត្រីជាន់ខ្ពស់ ប៉ូលីស និងនាយទាហានប្រមាណ៧០០-៨០០នាក់ ត្រូវបាន

សម្លាប់ចោល ។ សហព្រះរាជអាជ្ញាបានបង្ហាញពីសក្ខីកម្មរបស់សាក្សី ស៊ុំ ជា ដែលជាអតីតទាហានខ្មែរក្រហមនៅភូមិភាគឧត្តរ ស្តីពីការកាប់សម្លាប់ ។ ទាហានខ្លះត្រូវយកទៅសម្លាប់នៅព្រៃក្តៅ ហើយគេបានរោទិ៍ម៉ាស៊ីនឡាន ដើម្បីឲ្យមានសម្លេងថ្លង់ ។ វិធីសម្លាប់មានលក្ខណៈឃោរឃៅបំផុត ដោយប្រើចប ដែកគោលទេះ និងដំបងឫស្សី ។ សាក្សី ប៉ៃ ជុយជីពសែ បាននិយាយថា មិនមែនតែបុរសទេដែលត្រូវសម្លាប់ ប៉ុន្តែគ្រួសារទាំងមូលក៏ត្រូវសម្លាប់ដែរ ។ សាក្សីបានបង្ហាញលម្អិតពីការដឹកប្រជាជនយកទៅសម្លាប់ ហើយមានមន្ត្រី និងទាហាន លន់ នល់ មួយចំនួនត្រូវសម្លាប់ចោលភ្លាមៗ ដោយពុំបានដឹកទៅមន្ទីរសន្តិសុខនោះទេ ។ សហព្រះរាជអាជ្ញា បានធ្វើការសន្និដ្ឋានលើចំណុចនេះថា ភស្តុតាងនៅចំពោះមុខបង្ហាញថា មន្ត្រីសាធារណខ្មែររាប់ពាន់នាក់ ត្រូវកាប់សម្លាប់នៅក្នុងទីក្រុងភ្នំពេញក្នុងពេលជម្លៀស ឬនៅពេលពួកគេទៅដល់ភូមិភាគនានារួមទាំង ភូមិភាគនិរតី និងភូមិភាគពិសេស ។ ក្រោយមកសហព្រះរាជអាជ្ញា បានបង្ហាញភស្តុតាងអំពីការកាប់សម្លាប់នៅតាមទីតាំងមួយចំនួន ដូចជាភូមិភាគឧត្តរ ភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល និងភូមិភាគបូព៌ា ។ ការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរទាំងអស់ពុំមែនកើតឡើងនៅពេលជម្លៀសទីក្រុងភ្នំពេញនោះទេ គឺបានកើតឡើងនៅតាមភូមិភាគផ្សេងទៀត ដែលមន្ត្រីសាធារណរដ្ឋខ្មែរ និងយោធាពីមុននោះ ត្រូវបានរកឃើញក្រោយ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ភស្តុតាងបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា មានគោលនយោបាយ ដែលសម្រួលពីមជ្ឈិមក្នុងការធ្វើទុក្ខបុកម្នេញ និងការកាប់សម្លាប់មន្ត្រី លន់ នល់ ពីមុន និងទាហានទូទាំងប្រទេស ។

### ខ) ការសម្លាប់នៅភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៥

សហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានលើទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃថា យ៉ាងហោចណាស់មនុស្សរាប់រយនាក់ ដែលជាទាហាន លន់ នល់ និងអ្នករដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់ ។ ការសម្លាប់កើតឡើងភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាបានកាន់កាប់ខេត្តពោធិ៍សាត់ ។ ការកាប់សម្លាប់បុរសទាំងនេះ ពុំមែនជាហេតុការណ៍ដាច់ដោយឡែក ពុំមែនជាអំពើនៃការសងសឹក ហើយក៏ពុំមែនជាអំពើកើតឡើងដោយមេដឹកនាំភូមិភាគ ធ្វើតាមអំពើចិត្តនោះទេ ។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្លាប់អតីតមន្ត្រី និងទាហានរបបសាធារណរដ្ឋខ្មែរបានក្លាយជាហេតុការណ៍ដែលបានបង្កប់នៅក្នុងគោលនយោបាយទូទាំងប្រទេស ។ វាមានទំនាក់ទំនងទៅនឹងខ្សែសង្វាក់នៃព្រឹត្តិការណ៍នៃការសម្លាប់ដែលទទួលបញ្ជាពីមជ្ឈិមបក្ស ។ ការសម្លាប់មន្ត្រី និងទាហានសាធារណៈរដ្ឋធ្វើឡើងក្រោមបញ្ជារបស់មជ្ឈិមបក្សនៅមុន ក្នុងអំឡុងពេល និងក្រោយឆ្នាំ១៩៧៥ ។ បើទោះបីជាសាក្សីបីនាក់ រួមមាន អ៊ុង ឆាត់, ស៊ឹ អាឡាត់ និង លឹម សាត មិនបានឃើញការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃដោយផ្ទាល់ ប៉ុន្តែបានផ្តល់នូវភស្តុតាងយ៉ាងសំខាន់ ។ លឹម សាត បានផ្តល់សក្ខីកម្មថាខ្លួនជាអ្នកយាមនៅផ្លូវទៅទួលពោធិ៍ជ្រៃ ដែលបានឃើញឡានដឹកទាហាន និងមន្ត្រីនៃសាធារណរដ្ឋខ្មែរ ដែលមានប្រហែល១៥ឡានក្នុងមួយឡានផ្ទុកមនុស្សប្រមាណ៣០នាក់ បានដឹកទៅទួលពោធិ៍ជ្រៃ និងបានសម្លាប់ចោល ។ សាក្សីពុំបានឃើញឡានដឹកមនុស្សត្រឡប់មកវិញទេ ហើយបានស្តាប់ឮការទាក់ទងតាមវិទ្យុថាឲ្យអនុញ្ញាតឡានបន្តទៀត ទៅកាន់ទីតាំងសម្លាប់ ។ អ៊ុង ឆាត់ បានបញ្ជាក់សក្ខីកម្ម ដែលស៊ីសង្វាក់គ្នានឹងអ្នកបើកបរយកទៅសម្លាប់នោះ និងបញ្ជាក់ថា ខ្មែរក្រហមបានបោកបញ្ឆោតអ្នកទាំងនោះថានាំទៅជួបព្រះមហាក្សត្រ ។ សាក្សី ស៊ឹ អាឡាត់ ត្រូវគេប្រាប់ថានាំទៅជួបអង្គការ ប៉ុន្តែដោយសារឡាននោះចង្អៀតពេកទើបខ្លួនមិនបានទៅ ។ បុគ្គលដែលត្រូវសម្លាប់មិនអាចមានលទ្ធភាពការពារខ្លួនទេ ។ សាក្សី លឹម សាត បញ្ជាក់ថា ខ្លួនបានទៅទីនោះមួយថ្ងៃបន្ទាប់ពីថ្ងៃសម្លាប់ឃើញមានការចងដៃជាប់គ្នា ហើយមួយចំណងមាន១៥-២០នាក់ ។ សាក្សីមួយចំនួនបានឃើញសាកសពរលួយនៅទួលពោធិ៍ជ្រៃ និងមានក្លិនស្អុយ ។ ក្រោយមកមានសាក្សី បានឃើញឆ្អឹង និងខោអាវ ដែលបន្សល់ទុកនៅទីនោះ ។ សាក្សីខ្លះនិយាយថា ចំនួនអ្នកស្លាប់នោះប្រហែល២០០-៣០០ ខ្លះថា៥ពាន់នាក់ ខ្លះថាប្រហែល១ម៉ឺននាក់ ។ សាក្សីខ្លះថា មានបឹងធំមួយ ដែលអាចដាក់សាកសពបានរាប់ពាន់នាក់ ។ ចំនួនអ្នកដែលស្លាប់នៅទួលពោធិ៍ជ្រៃ ពុំមានភាពជាក់លាក់ទេ ប៉ុន្តែមានច្រើនជាងរាប់រយនាក់ ។ នៅក្នុងបទសម្ភាសជាវីដេអូរបស់លោក ថេត សម្បត្តិ សាក្សីបានបញ្ជាក់ថា មានប្រហែល១ម៉ឺននាក់ ។ សហព្រះ

រាជអាជ្ញាបានបន្តថា ការសម្លាប់នៅទួលពោធិ៍ជ្រៃ ពុំមែនជាការសងសឹកដោយឡែកដូចអ្វីដែលមេធាវីលើកឡើងនោះទេ ។ វាដូចគ្នានៅទូទាំងប្រទេសចំពោះសេចក្តីសម្រេចដោយមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ស្ថិតនៅពីក្រោយទឹកមុខដ៏ស្រស់ស្រាយរបស់ ប៉ុល ពត ពោលគឺ នួន ជា និង ខៀវ សំផន ដែលខិតខំធ្វើយ៉ាងណា ដើម្បីសម្រេចនូវរបបផ្តាច់ការជាមួយដៃគូឧក្រិដ្ឋរបស់ខ្លួនដោយមានប្រជាជនខ្មែរ គឺជាទាសករ ។ នួន ជា និង ខៀវ សំផន បានសម្រេចនូវគោលការណ៍របស់ខ្លួនដោយមិនបំពេញការងារនេះដោយផ្ទាល់ដៃ ប៉ុន្តែ ប្រគល់ភារកិច្ចនេះទៅកម្មាភិបាលថ្នាក់ក្រោមជាអ្នកប្រព្រឹត្តការងារដ៏ស្មោគគ្រោកនេះជំនួសវិញ ។ អ្នកដែលមិនគោរពតាមបញ្ជាត្រូវប្រឈមមុខនឹងការសម្លាប់ ដូច្នេះ បុគ្គលទាំងពីរនេះត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលកើតចេញពីការសម្រេចរបស់ខ្លួន ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងចំនួនបីចំណុច ដើម្បីឲ្យអង្គជំនុំជម្រះពិចារណាពីទោសកំហុសរបស់ជនជាប់ចោទទាំងពីរ ។ ទី១) ជួរដឹកនាំជាសមូហភាពគោលការណ៍ណែនាំ រចនាសម្ព័ន្ធ និងការទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ទី២) តួនាទី និងអត្តចរិតរបស់ជនជាប់ចោទ ។ ទី៣) ការចូលរួមចំណែករបស់ជនជាប់ចោទនៅក្នុងគោលនយោបាយឧក្រិដ្ឋរួមទាំងឧក្រិដ្ឋកម្ម ដែលចោទប្រកាន់នៅក្នុងការជំនុំជម្រះ ។

### ២) ផែនការឧក្រិដ្ឋកម្ម

#### ក) ជួរដឹកនាំជាសមូហភាព

ភស្តុតាងបានបង្ហាញថា នួន ជា, ខៀវ សំផន, ប៉ុល ពត និង អៀង សារី រស់នៅ និងធ្វើការជាមួយគ្នា ។ មេដឹកនាំទាំងនេះចេញសេចក្តីសម្រេចរួមគ្នាដោយផ្អែកលើមូលដ្ឋានសមូហភាព តាមរយៈរចនាសម្ព័ន្ធបញ្ជា ឋានានុក្រម និងរបបរាយការណ៍ដ៏តឹងរ៉ឹងពីខាងក្រោមទៅខាងលើ ។ ពួកគេអនុវត្តការគ្រប់គ្រងផ្តាច់ការពេញលេញលើកម្ពុជាប្រជាធិបតេយ្យ គ្រប់ភូមិភាគ គ្រប់តំបន់ ក្រសួង កងពលយោធា ដោយសាររាយការណ៍ទៅមជ្ឈិម ។ នៅគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅរបស់ប្រជាជនត្រូវគ្រប់គ្រងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យទាំងការហូបចុក ការងារ អាពាហ៍ពិពាហ៍ ការនិយាយ និងសូម្បីតែជំនឿសាសនា ។ កម្ពុជាប្រជាធិបតេយ្យ ជារដ្ឋទាសករ ហើយចៅហ្វាយនាយនៃរដ្ឋទាសករ គឺមេដឹកនាំទាំងនេះ ។ សហព្រះរាជអាជ្ញា បានបង្ហាញនូវភស្តុតាងជាឯកសារទង់បដិវត្ត និងសក្ខីកម្មរបស់សាក្សីមួយចំនួន ដូចជា ស៊ីវហ៊ិន ហេដឌ័រ, សាឡុត បាន, យុន គីម, ស្លួង ស៊ីគឿន និង នង សុផង់ ជាដើម ដែលបញ្ជាក់ពីមជ្ឈិមបក្ស និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងស្ថាប័ននេះ ។ នួន ជា ក៏បានផ្តល់ការណែនាំអំពីការអនុវត្តសហករណ៍ ។ នួន ជា និង ខៀវ សំផន ជាសមាជិកគណៈ



ប្រជាជននៅខេត្តសៀមរាបកំពុងអបអរពិធីខួបជ័យជម្នះលើ

មជ្ឈិម ដែលមានអំណាចពិត និងតួនាទីពិត ។ ភស្តុតាងបង្ហាញថា ខៀវ សំផន គឺជាមេដឹកនាំមួយក្រុមតូច ដែល ប៉ុល ពត និង នួន ជា ជឿទុកចិត្ត ។ នួន ជា អនុញ្ញាតឲ្យ ខៀវ សំផន នៅក្បែរគ្រប់ពេលទាំងអស់ ។ សហព្រះរាជអាជ្ញាបានបន្ថែមថា ខៀវ សំផនព្យាយាមភូតកុហកតុលាការថា ខ្លួនពុំមែនជាមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែនៅក្នុងសក្ខីកម្មរបស់សាក្សី សូ សុជាតិ ប្រពន្ធរបស់ ខៀវ សំផន បានជម្រាបជូនអង្គជំនុំជម្រះថា ខៀវ សំផន និង

មេដឹកនាំកំពូលដ៏ទៃទៀតរបស់បក្សស្ថិតនៅជិតគ្នាជាដរាបនៅក្នុងសង្គ្រាមចន្លោះឆ្នាំ១៩៧២-១៩៧៥ ។ ខៀវ សំផន ក៏បានអះអាងថា ខ្លួនចូលរួមបដិវត្តដោយចៃដន្យតែប៉ុណ្ណោះ និងបន្តបំពាក់ស្លាកខ្លួនឯងថាជាបុគ្គលថ្លៃថ្នូរ និងស្មោះត្រង់ ។ ខៀវ សំផន ស្នើសុំឲ្យតុលាការ និងសាធារណជន ជឿថាខ្លួនចូលរួមជាមួយខ្មែរក្រហមដោយចៃដន្យ ។ ក៏ប៉ុន្តែ ខៀវ សំផន ពុំមែនជាសមាជិកដែលចូលរួមដោយចៃដន្យ ឬពុំមែនជាសមាជិកធ្វើការងារ



របបខ្មែរក្រហម (បណ្ណសារ ៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយស្ងាត់ស្ងៀមនៅក្នុងអង្គការនោះឡើយ ។ អ្វីដែលនាំឲ្យ ខៀវ សំផន រត់ចូលព្រៃម៉ាគី និងទៅរស់នៅលើទឹកដីបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៦៧ ខៀវ សំផន ទំនងជាពេញចិត្តនឹងទីកន្លែងទាំងអស់នោះ ។ ខៀវ សំផន ពុំមែនស្នាក់នៅតែមួយខែ ឬមួយឆ្នាំនោះទេ គឺចូលរួមបម្រើការងារដោយស្ម័គ្រចិត្តក្នុងនាមជាមេដឹកនាំកំពូលមួយរូប ហើយបម្រើជាតំណាងសាធារណជនរបស់បក្សជិត៣០ឆ្នាំ ដើម្បីការពារគោលនយោបាយសម្ងាត់វង្គាល និងរៀបចំរបៀបវារៈរបស់បក្ស ។

### ១) ការបែងចែក និងការអនុវត្តអំណាច

សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មីត បានរំឭកពីទំនាក់ទំនងរវាងមេដឹកនាំទាំងបី គឺ ប៉ុល ពត, នួន ជា និង ខៀវ សំផន ។ នួន ជា និង ប៉ុល ពត ត្រូវគេណែនាំឲ្យស្គាល់គ្នាដោយសមាជិករួមបក្សនៅក្នុងឆ្នាំ១៩៥៥ ។ ពួកគាត់ធ្វើការជាមួយគ្នានៅអំឡុងឆ្នាំ១៩៦០ ក្នុងការរៀបចំលក្ខន្តិកៈបក្ស និងយុទ្ធសាស្ត្របក្ស ។ នៅក្នុងឆ្នាំ១៩៦០ នួន ជា និង ប៉ុល ពត ក្លាយជាមេដឹកនាំកំពូលនៃចលនានោះ ។ ចំណែក ខៀវ សំផន និង ប៉ុល ពត ធ្លាប់ជាមិត្តរួមថ្នាក់ជាមួយគ្នានៅខេត្តក្នុងទសវត្សរ៍ ឆ្នាំ១៩៤០ ។ នួន ជា បានជួប ខៀវ សំផន ដំបូងនៅឆ្នាំ១៩៦៩-៧០ នៅជិតភ្នំឱរ៉ាល់ ពេលដែល ខៀវ សំផន ស្នាក់នៅទីបញ្ជាការ តាម៉ុក បើសិនជាអ្នកទាំងពីរពុំបានជួបគ្នាពីមុននៅក្នុងគណៈកម្មាធិការរបស់បក្សនៅភ្នំពេញទេ ។

នៅក្នុងខែកញ្ញាឆ្នាំ១៩៧០ មេដឹកនាំទាំងបីនាក់នេះចាប់ផ្តើមរស់នៅធ្វើការជាមួយគ្នាក្នុងកន្លែងតែមួយ ហើយទំនាក់ទំនងបានបន្តក្នុងរយៈពេល២៨ឆ្នាំរហូតមក ។ ទីបញ្ជាការថ្មីរបស់បក្សនៅពេលនោះ ស្ថិតនៅស្ទឹងជីនិតហៅថាមន្ទីរស-៧១ ដែលមានប៉ុល ពត, នួន ជា និង ខៀវ សំផន បានរស់នៅក្នុងផ្ទះជិតគ្នា ។ ពួកគេធ្វើការរួមគ្នា ដោយផ្អែកតាមគោលការណ៍ទៀងទាត់ ។ បន្ថែមលើការងារប្រចាំថ្ងៃ អ្នកទាំង៣បានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយមេដឹកនាំបក្សផ្សេងទៀត ដែលបានធ្វើឡើងនៅទីបញ្ជាការ ស-៧១ ។ យ៉ាងហោចណាស់មួយឆ្នាំម្តង ដែលគេធ្វើសេចក្តីសម្រេចសំខាន់ៗ លើនយោបាយបក្សកុម្មុយនីស្តកម្ពុជានិងយុត្តិសាស្ត្រទាក់ទងនឹងការបិទផ្សារសហករណ៍នៅក្នុងតំបន់រំដោះមួយចំនួន ព្រមទាំងយុត្តិសាស្ត្ររបស់បក្សក្នុងការកាន់កាប់ ឬគ្រប់គ្រងមនុស្សដោយបណ្តេញប្រជាជនឲ្យរស់ពីទីក្រុង ។ នៅក្នុងសន្និបាតបក្សលើកទី៣ ដែលបានធ្វើឡើងនៅខែកក្កដា ឬសីហា ឆ្នាំ១៩៧១ ខៀវ សំផន ទទួលស្គាល់ថា ខ្លួនត្រូវចាត់តាំងឲ្យចូលជាសមាជិកត្រៀមរបស់គណៈមជ្ឈិមបក្ស ។ ខៀវ សំផន គឺជាបុគ្គលមួយរូបដែលគាំទ្រនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលបិទផ្សារ និងជម្លៀសប្រជាជន ព្រមទាំងបានចូលទៅក្នុងថ្នាក់ដឹកនាំបក្សកំពូល ។

នៅឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានប្តូរមន្ទីរអចិន្ត្រៃយ៍មកតាំងទីនៅទីក្រុងភ្នំពេញ គឺមន្ទីរក-១ និង ក-៣ ។ មន្ទីរទាំងពីរនេះជាកន្លែងដែល នួន ជា, ខៀវ សំផន, ប៉ុល ពត និង អៀង សារី បន្តរស់នៅ និងធ្វើការជាមួយគ្នាជារៀងរាល់ថ្ងៃពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សក្ខីកម្មពីអ្នកយាម និងនិរសាដែលធ្វើការនៅមន្ទីរក-១ និង ក-៣ ដូចជា អ៊ិន តាំ, ស វី, សូត្រ ទៀង, ពាន យាន, និង ឡេង ឈឿង បានបញ្ជាក់ថា ជនជាប់ចោទបានរស់នៅ និងធ្វើការក្នុងមន្ទីរក-១ និងក-៣ ជាមួយសមាជិកផ្សេងទៀតនៃគណៈមជ្ឈិមបក្ស ។ ខៀវ សំផន ក៏បានទទួលស្គាល់ពីអង្គហេតុនេះនៅក្នុងសក្ខីកម្មរបស់គាត់តាមរយៈបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញាបានដាក់បង្ហាញវីដេអូស្តីអំពីហេតុការណ៍ ដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យបង្ហាញពីភាពជិតស្និត និងទំនាក់ទំនងការងារជាពិសេសរវាង នួន ជា និង ខៀវ សំផន ព្រមទាំងសមាជិកផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍ ។ វីដេអូរៀបរាប់អំពីប្រតិភូមេដឹកនាំបក្សកុម្មុយនីស្តវៀតណាម ដែលមកដល់ព្រលានយន្តហោះពោធិ៍ចិនតុងនៅថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៥ ដែលមានមេដឹកនាំមជ្ឈិមបក្ស ប៉ុល ពត, នួន ជា, វន វ៉េត និងខៀវ សំផន កំពុងស្វាគមន៍យ៉ាងកក់ក្តៅ ។ ព្រះរាជអាជ្ញាបានអះអាងនៅចំពោះមុខអង្គជំនុំជម្រះថា យោងតាមរយៈការបង្ហាញវីដេអូខ្លីៗ បញ្ជាក់ថា នួន ជា និង ខៀវ សំផនពិតជាមានទំនាក់ទំនងជិតស្និតប្រាកដមែន ។ ចំពោះបទសម្ភាសន៍ ជាមួយជនជាប់ចោទទាំងពីរ នួន ជា និង ខៀវ សំផន បានព្យាយាមការពារគ្នាទៅវិញទៅមក ដោយលើកឡើងបដិសេធថា ពុំធ្លាប់ស្គាល់គ្នា និងពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នាទេ ។ នួន ជា, ខៀវ សំផន និង ប៉ុល ពត នៅតែបន្តទំនាក់ទំនងរហូតដល់ក្រោយខែមករា ឆ្នាំ១៩៧៩ នៅក្នុងពេលដែលពួកគេរស់នៅតាមតំបន់ភ្នំនៅតាមព្រំដែនថៃ ដោយបន្តធ្វើការងារជាមួយគ្នាជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមរហូតដល់ថ្ងៃចុងក្រោយនៃចលនាបដិវត្ត ។

## ក) ការអនុវត្តសិទ្ធិអំណាច

ដើម្បីឲ្យយល់ដឹងបានពីការអនុវត្តសិទ្ធិអំណាចរបស់ជនជាប់ចោទទាំងអស់ ត្រូវតែគិតអំពីដំណើរការធ្វើសេចក្តីសម្រេចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តួនាទី និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនេះ ។ គោលការណ៍សំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺប្រជាធិបតេយ្យប្រមូលផ្តុំ និងការសម្រេចចិត្តជាសមូហភាព ។ ការសម្រេចពុំមែនធ្វើឡើងដោយបុគ្គលនោះឡើយ ត្រូវធ្វើជាសមូហភាព ដោយមជ្ឈិមបក្ស និងគណៈកម្មាធិការដឹកនាំដែលនៅក្នុងនោះមានដូចជា នួន ជា និង ខៀវ សំផន បានចូលរួម និងដើរតួនាទីយ៉ាងសំខាន់ ។ តាមរយៈការផ្តល់សក្ខីកម្មរបស់ នួន ជា នៅក្នុងបន្ទប់សវនាការ ជនជាប់ចោទទទួលស្គាល់ថា សេចក្តីសម្រេចត្រូវធ្វើជាសមូហភាពមិនមែនធ្វើជាបុគ្គល ហើយវាជាគោលការណ៍រួម ដែលបក្សត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួន និងត្រូវអនុវត្តនៅគ្រប់កម្រិតទាំងអស់ ។ គោលការណ៍នេះទាមទារឲ្យមានការពិភាក្សា ដែលត្រូវបន្តរហូតដល់ពេលមានការឯកភាពជាឯកច្ឆ័ន្ទ ។ ព្រះរាជអាជ្ញាបានបំភ្លឺថា នេះគឺជាសារៈសំខាន់បំផុតសែហខុក្រិដ្ឋកម្មរួម ។ ព្រះរាជអាជ្ញាបានបន្តថា ខៀវ សំផន ក៏បានទទួលស្គាល់អំពីលក្ខខណ្ឌតម្រូវនៃការធ្វើការសម្រេចជាសមូហភាព និងជាឯកច្ឆ័ន្ទ ដោយថ្នាក់ដឹកនាំបក្សកុម្មុនីស្តកម្ពុជា ។ នៅក្នុងកិច្ចសម្ភាសន៍មួយទាក់ទងនឹងការពិភាក្សាស្តីអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ខៀវ សំផន បានបញ្ជាក់ថា "ប្រសិនបើមានការជំទាស់តែមួយទៅលើការជម្លៀសប្រជាជន ប្រហែលជានៅពេលនោះពុំអាចមានការជម្លៀសប្រជាជនឡើយ" ។ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញថា នួន ជា និង ខៀវ សំផន បានចូលរួមក្នុងនាមជាសមាជិកមជ្ឈិមបក្សនៅក្នុងការសម្រេចជាសមូហភាពទៅលើគោលនយោបាយ និងផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ភស្តុតាងរួមបញ្ចូលចម្លើយរបស់ ខៀវ សំផន និង នួន ជា ដែលបានបង្ហាញពីការគាំទ្រការលើកសរសើរ ព្រមទាំងការយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់ ប៉ុល ពត និងរបស់បក្ស ។ នៅក្នុងសៀវភៅរបស់ ខៀវ សំផន ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងជំហររបស់ខ្ញុំជាបន្តបន្ទាប់" ខៀវ សំផន បានសរសើរការវិភាគបញ្ហារបស់ ប៉ុល ពត ថា "ដំណោះស្រាយ របស់ ប៉ុល ពត ជាទូទៅតែងតែត្រឹមត្រូវ ។ ប៉ុល ពត តំណាងឲ្យអ្នកដឹកនាំប្រវត្តិសាស្ត្រដែលមិនចេះខុស ។ នៅពេលដែលគាត់ធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ" ។

### ឃ) ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ គឺទាក់ទងនឹងរចនាសម្ព័ន្ធរាយការណ៍ និងរចនាសម្ព័ន្ធអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ។ ភស្តុតាងបង្ហាញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល មេដឹកនាំបក្សទទួលនូវរបាយការណ៍បានទៀងទាត់ និងមានភាពលម្អិតពីភូមិភាគ យោធា និងអង្គភាពដទៃទៀត ។ ឯកសារមួយចំនួនធំដែលនៅសេសសល់រហូតដល់ពេលបច្ចុប្បន្ន បានបង្ហាញនូវទិដ្ឋភាពច្បាស់លាស់គឺ ទី១) លក្ខណៈនៃព័ត៌មានដែលមេដឹកនាំបក្សបានទទួលពីមូលដ្ឋាន ។ ទី២) ការគ្រប់គ្រង និងសិទ្ធិអំណាចរបស់មជ្ឈិមបក្សទៅលើអង្គការតាមភូមិភាគ និងយោធា ។ ទី៣) ផែនការខុក្រិដ្ឋកម្ម និងគោលនយោបាយរបស់មជ្ឈិមបក្សដែលត្រូវបានអនុវត្តជាប្រព័ន្ធដោយអង្គការ ។ ផ្អែកតាមភស្តុតាងបានបង្ហាញថា មានប្រព័ន្ធរៀបចំគ្រប់គ្រាន់នៃការរាយការណ៍ ដែលចាប់ផ្តើមតាំងពីដើមទសវត្សរ៍ ១៩៧០ នៅពេលដែលមេដឹកនាំបក្សមានមូលដ្ឋាននៅក្នុងស្នាក់ការស-៧១ នៅស៊ីងជីនិត ។ សាក្សី នង សុផង់ ធ្វើការនៅក្នុងអង្គភាពសារទូរលេខនៅស្នាក់ការបក្សកុម្មុយនីស្តកម្ពុជា នៅឆ្នាំ ១៩៧៣ បានផ្តល់សក្ខីកម្មថា ភូមិភាគ តំបន់ មូលដ្ឋាន និងអង្គភាពកងពលនីមួយៗ តម្រូវឲ្យមានផ្នែកទំនាក់ទំនង និងផ្នែកសារទូរលេខ ។ ទូរលេខដែលទទួលបានពីមូលដ្ឋាន និងសមរភូមិមុខរបាយការណ៍អំពីស្ថានភាពនៅសមរភូមិ និងសារទូរលេខដែលត្រូវបញ្ជូនចេញជាការណែនាំពីអាជ្ញាធរថ្នាក់លើទៅអាជ្ញាធរថ្នាក់ក្រោម ដើម្បីអនុវត្តដោយរួមបញ្ចូលទាំងវិធានការការណែនាំប្រសារាចរសម្រាប់អនុវត្តនៅថ្នាក់មូលដ្ឋាន ។

ខៀវ សំផន អាចទទួលសារលិខិតនៅមន្ទីរ៨៧០ក្នុងនាមជាអ្នកទទួលខុសត្រូវលើមន្ទីរ៨៧០ ក្រោយពេល ឌឿន ត្រូវបានចាប់ខ្លួន ។ សាក្សីពីររូបគឺ ឌុច បានផ្តល់សក្ខីកម្មថា ខៀវ សំផនទទួលលិខិតនៅមន្ទីរ៨៧០ ។ សាក្សី ភី ភួន បានផ្តល់សក្ខីកម្មថា ខ្លួនទទួលការណែនាំពី អៀង សារី ថា ខៀវ សំផន ទទួលបន្ទុកមន្ទីរ ៨៧០ ជំនួស ឌឿន ។ ភស្តុតាងបានបង្ហាញនូវចំណុចសំខាន់ៗ២ គឺ ខៀវ សំផន ទទួលខុសត្រូវមន្ទីរ៨៧០ ជំនួសឌឿន និងការទទួលខុសត្រូវក្នុងការបញ្ជូនសារលិខិតទៅភូមិភាគនានា ។

សហព្រះរាជអាជ្ញា បានលើកឡើងនូវភស្តុតាងដែលជាសារទូរលេខផ្ញើពីភូមិភាគនានា ដើម្បីបង្ហាញពីការយល់ដឹងរបស់ នួន ជា និង ខៀវ សំផន ដែលជាមេដឹកនាំមជ្ឈិមបក្សទៅលើព័ត៌មាននានា ។ សារទូរលេខទាក់ទងនឹងស្ថានភាពនៅតាមតំបន់មូលដ្ឋានស្តីពីសភាពការណ៍ខ្មាំងរួមមានការចាប់ខ្លួន ស្ថានភាពប្រជាជនស្ថានភាពជំរក និងចំណីអាហារ ។ សារទូរលេខជាច្រើនបង្ហាញពីការស្នើសុំយោបល់ពីថ្នាក់ដឹកនាំមជ្ឈិមបក្ស ។ នេះបញ្ជាក់ថា មេដឹកនាំបានឆ្លើយតបនឹងសារទាំងនោះ ដោយយោងទៅលើសក្ខីកម្មរបស់សាក្សីមួយចំនួន រួមមាន សៅ សារុន និង នង សុផង់ ជាដើម ។

បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តអំណាច និងការគ្រប់គ្រងនៅតាមភូមិភាគរដ្ឋបាលនៅក្នុងកម្ពុជាប្រជាធិបតេយ្យតាមរយៈទស្សនាវដ្តីទង់បដិវត្ត ។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តបានបញ្ជាក់ពីការផ្តល់ការណែនាំដល់សមាជិកបក្ស អំពីការអនុវត្តមាគ៌ា និងគោលនយោបាយបក្ស ។ មេដឹកនាំបក្សផប់ផុលលើសមាសភាពខ្មាំង និងផ្តល់ការណែនាំឲ្យកំទេចខ្មាំង ដោយចោទលើការបម្រើដែលពួកគេធ្វើនៅរបបចាស់ និងការជាប់ពាក់ព័ន្ធនឹងបរទេស ។ កម្មាភិបាលមិនធ្វើការងារដោយស្វ័យតនោះទេ គឺតាមរយៈបញ្ជារបស់មជ្ឈិម ដោយសារស្ថាប័ននេះធ្វើការងារជាប្រចាំថ្ងៃ ។ កំណត់ហេតុទស្សនៈកិច្ចរបស់គណៈអចិន្ត្រៃយ៍ និយាយអំពីវិធានការណ៍មួយចំនួននៅក្នុងកាលៈទេសៈជាច្រើន ដែលមជ្ឈិមបក្សបានកំណត់ពីជោគវាសនារបស់បុគ្គលទាំងឡាយ ។ សហព្រះរាជអាជ្ញាបានបង្ហាញពីកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ ដែលបញ្ជាក់ថា នួន ជា និង ខៀវ សំផន បានចូលរួមនៅក្នុងការប្រជុំស្តីពីបញ្ហាសេដ្ឋកិច្ចកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងការចេញសេចក្តីសម្រេចពីការផលិតអំបិល និងការចែកចាយជំនួយរបស់ចិនទៅតាមភូមិភាគ និងនៅទីក្រុង ។ នៅក្នុងកំណត់ហេតុគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៧៦ មេដឹកនាំបក្សមកពីខេត្តសៀមរាប ព្រះវិហារ និងភូមិភាគឧត្តរ បានរាយការណ៍អំពីសភាពការណ៍ខ្មាំង និងបានទទួលការណែនាំពីការចាត់ចែងទៅលើអ្នកដែលត្រូវសង្ស័យនៅភូមិភាគឧត្តរទាំងនោះ ។ ពួកគេទទួលការសួរចម្លើយរួចទុកពួកគេមួយឡែក បន្ទាប់មករាយការណ៍ទៅថ្នាក់លើដោយ

ភ្ជាប់ឯកសារទៅជាមួយ ។ មានតំណាងមកពីមជ្ឈិមបក្សចំនួន៤រូប ដើម្បីចូលរួមនៅក្នុងកិច្ចប្រជុំនោះ រួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន និង ឌឿន ។ នៅក្នុងការប្រជុំរបស់គណៈអចិន្ត្រៃយ៍ធ្វើឡើងនៅល្ងាចថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៧៦ ពាក់ព័ន្ធនឹងការលាលែងរបស់សម្តេច ព្រះនរោត្តម សីហនុ មានការចូលរួមពីសំណាក់ នួន ជា និង ខៀវ សំផន ។ មេដឹកនាំក៏បានសម្រេចថា ទុកឲ្យសម្តេចសីហនុ នៅមានជីវិតក៏ប៉ុន្តែមិនអនុញ្ញាតឲ្យទ្រង់ចាកចេញពីប្រទេសឡើយ ។ ចំពោះកូនចៅរបស់ព្រះអង្គធ្វើយ៉ាងណាព្យាយាមអូសទាញឲ្យវិលត្រឡប់មកក្នុងប្រទេសវិញដើម្បីសម្លាប់ចោល ។ សហព្រះរាជអាជ្ញា ក៏បានដកស្រង់ថា «បញ្ជូនដំណឹងទៅកាន់កូនចៅរបស់សម្តេចឲ្យមកជាបន្ទាន់ ដោយពន្យល់ថា ឲ្យកូនចៅរបស់សម្តេចមកចូលរួមការប្រារព្ធពិធីចូលឆ្នាំ និងពិធីឯករាជ្យ ។ យើងចង់ដោះស្រាយបញ្ហានេះឲ្យបានស្អាត និងជ្រះស្រឡះ ។ យើងត្រូវដោះស្រាយដូច្នេះ ដើម្បីជាប្រយោជន៍បដិវត្តយើង» ។

**ង) ការគ្រប់គ្រងរបស់មជ្ឈិមបក្សលើភូមិភាគ**

ភូមិភាគនីមួយៗមិនត្រូវអនុញ្ញាតឲ្យចូលរួម និងការទាក់ទងដោយផ្ទាល់ជាមួយនឹងភូមិភាគផ្សេងទៀតនោះទេ ក៏ប៉ុន្តែត្រូវតែមានទំនាក់ទំនងដោយផ្ទាល់តាមរយៈមជ្ឈិមវិញ ។ សាក្សី សោ សារុន ដែលជាអតីតលេខាតំបន់១០៥ បានបង្ហាញពីភស្តុតាងស្តីអំពីទំនាក់ទំនងរវាងមជ្ឈិមបក្ស និងអង្គការតំបន់ ។ អំណាចរបស់មជ្ឈិមបក្សបានតម្រូវឲ្យដោះលែង ឬឃុំបុគ្គលមួយចំនួនដែលឃុបឃិតជាមួយ ខ្មាំង ។ មេដឹកនាំមួយចំនួនមកពីភូមិភាគ១០៥ ត្រូវកោះហៅឲ្យមកប្រជុំនៅទីក្រុងភ្នំពេញ ហើយកម្មាភិបាលមួយក្រុមត្រូវបានចាប់ខ្លួន ពេលដែលមកដល់អាកាសយានដ្ឋានពោធិ៍ចិនតុង ។

**៣) តួនាទី និងអត្តចរិតរបស់ជនជាប់ចោទ មុន ក្នុងអំឡុងពេល និងក្រោយឆ្នាំ១៩៧៥**

**ក) តួនាទី និងអត្តចរិតរបស់ នួន ជា**

សហព្រះរាជអាជ្ញា បានបញ្ចេញទស្សនៈទៅលើជនជាប់ចោទ នួន ជា នៅចំពោះមុខអង្គជំនុំជម្រះ ថា នួន ជា គឺជាជនជ្រុលនិយមដែលមានចេតនាកាប់សម្លាប់ខុសច្បាប់ ដើម្បីសម្រេចបាននូវទស្សនៈរបស់ខ្លួន និងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា ក្លាយជាជនជ្រុលនិយមនៅក្នុងឆ្នាំ១៩៧០ នៅពេលដែលគាត់ជាមនុស្សនៅក្នុងលំដាប់ទី២ (ជាបងទី២) នៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ជាមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ។ នួន ជា ជាមនុស្សឃោរឃៅម្នាក់ដែលយល់ថា ចក្រពត្តិនិយមបរទេស សេ.អ៊ី.អា កា.ហ្សេ.បេ និងគិញវៀតណាម បង្កប់នៅគ្រប់ទីកន្លែងទាំងអស់នោះ គឺជាបុរស ។ នួន ជា យល់ថា «សិទ្ធិមនុស្សធំបំផុតសារៈសំខាន់នៃសិទ្ធិមនុស្ស ត្រូវកាន់អាវុធដើម្បីប្រយុទ្ធនឹងខ្មាំង» ។ នួន ជា មានចេតនាសម្លាប់បងប្អូន ដែលចូលរួមបដិវត្តន៍ជាមួយខ្លួនអស់រយៈពេល១៥ឆ្នាំទៀតផង ។ សូម្បីជនជ្រុលនិយម ប៉ុល ពត ក៏គិតថា នួន ជា ជាមនុស្សរឹងមាំខ្លាំងពេកដែរ ។ សហ



នួន ជា ក្នុងបន្ទប់សវនាការ
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះរាជអាជ្ញាបានដកស្រង់ និងដាក់បញ្ចាំងវីដេអូសម្ភាសជាមួយ នួន ជា ដើម្បីបញ្ជាក់ថា នួន ជា ព្យាយាមប្រានចោលការទទួលខុសត្រូវរបស់ខ្លួនចំពោះការសម្លាប់មនុស្ស ការទទួលខុសត្រូវផ្នែកឃោសនា ការទទួលខុសត្រូវលើមន្ទីរសន្តិសុខស-២១ និងថាខ្លួនទទួលខុសត្រូវតែទៅលើការអប់រំ និងសភាតែប៉ុណ្ណោះ ។ ដោយការបដិសេធទៅនឹងការប្រានចោលរបស់ នួន ជា សហព្រះរាជអាជ្ញាបានបង្ហាញឯកសារ និងសក្ខីកម្មរបស់សាក្សីមួយចំនួនដូចជា អ៊ុង រ៉េន និង ប្រាក់ យុត ។ សហព្រះរាជអាជ្ញា បញ្ជាក់ថា

សភាប្រជាជន ដែល នួន ជា បានលើកឡើង គឺជាការកុហក ដោយសារពុំមានស្ថាប័ននីតិប្រតិបត្តិ ណាមួយជាក់លាក់នោះទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិត សភាតំណាងប្រជាជនត្រូវ លើកបង្ហាញនៅក្នុងកំណត់ហេតុអង្គប្រជុំនៅថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ ដែល ខៀវ សំផន បានធ្វើការបកស្រាយអំពីការបោះឆ្នោតដែលទើបតែប្រព្រឹត្តទៅ ។ ខៀវ សំផន, ប៉ុល ពត និង នួន ជា បានពិភាក្សាអំពីវិធីបញ្ឆោតសាធារណជនអំពីបញ្ហានេះ ។ ខ្លឹមសារអត្ថបទដកស្រង់ដូចតទៅ "ប្រសិនបើគេសួរ យើងត្រូវតែពន្យល់ថា មិនគប្បីសង្ស័យទេ យើងត្រូវតែឲ្យមើលឃើញថា យើងនឹងត្រូវតែបង្ក្រាបពួកគេ



ខៀវ សំផន ក្នុងបន្ទប់សវនាការ
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុន្តែយើងមិនត្រូវលេងសើចអំពីសភានេះទេនៅចំពោះមុខប្រជាជន ដែលធ្វើឲ្យគេដឹងថាយើងបោកបញ្ឆោតគេនោះទេ ។ ហើយ សភារបស់យើង គឺវាគ្មានតម្លៃនោះទេ ។ តាមពិតវានៅតែជាការងាររបស់បក្សយើងដដែល" ។ សហព្រះរាជអាជ្ញាបន្តថា មានភស្តុតាងជាច្រើន ដែលបង្ហាញពីតួនាទីពិតប្រាកដរបស់ នួន ជា នៅបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសវនាការកន្លងមកបានបង្ហាញថា នួន ជា មានការចូលរួមជាមួយយោធា ។ សេចក្តីប្រកាសរបស់ អៀង សារី និង ឌុច ព្រមទាំងមានសាក្សីជាច្រើនទៀតបង្ហាញថា នួន ជា ជាសមាជិកនៃគណៈយោធាបក្ស ។ សារទូរលេខ និងកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ បង្ហាញថា នួន ជា មានការទទួលខុសត្រូវជាទូទៅលើបញ្ហាយោធា និងសន្តិសុខក្នុងឋានៈជាអនុលេខាបក្ស ។ ភស្តុតាងជាច្រើនមិនអាចប្រកែកបានថា នួន ជា មានការទទួលខុសត្រូវលើមន្ទីរសន្តិសុខ ស-២១ នោះគឺជាចម្លើយសារភាពជាច្រើន ដែលមានចំណារផ្ទាល់ពី នួន ជា និងបានបញ្ជូនទៅ"បងនួន (នួន ជា)" ។ ចំណែកសក្ខីកម្ម សួត្រ ទៀង ជាអង្គរក្ស និងជានីសាររបស់ នួន ជា បានបញ្ជាក់ថា គាត់បានយកស្រោមសំបុត្រដែល ឌុច បានផ្ញើទៅជូន នួន ជា ។ នួន ជា ក៏បានទទួលស្គាល់ពីការទទួលខុសត្រូវរបស់ខ្លួន ដោយបានប្រាប់ ថេត សម្បត្តិ ថាខ្លួនបានទទួលខុសត្រូវដោយផ្ទាល់លើមន្ទីរសន្តិសុខស-២១ នៅពេលដែល សុន សេន ត្រូវអគ្គការចាត់តាំងទៅឲ្យសមរភូមិយោធាភូមិភាគបូព៌ា" ។ សហព្រះរាជអាជ្ញា ក៏បានបង្ហាញជូនអង្គជំនុំជម្រះពីតួនាទី និងអត្តចរិករបស់ នួន ជា តាមរយៈបទសម្ភាសន៍របស់ នួន ជា ដែលលើកឡើងថា "នួន ជា ៖ បើទុកពួកហ្នឹងបាត់ប្រទេសជាតិ បាត់ប្រជាជន ស្លាប់ប្រជាជន បាត់ប្រទេសកម្ពុជាគ្មានកម្ពុជាសល់ដល់ឥឡូវទេ បើទុកពួកហ្នឹង ។ អាហ្នឹងសម្លាប់ជាតិ ។ ផ្ទាល់ខ្លួន វាតែងតែមានមនោសញ្ចេតនាខ្លះ ក៏ប៉ុន្តែខ្ញុំបែងចែកផ្ទាល់ខ្លួន ហើយនិងរួមច្បាស់ ។ បើរួម យើងយកផ្ទាល់ខ្លួនជាមនោសញ្ចេតនាធ្លាប់រាប់អានគ្នា ធ្លាប់អីហ្នឹងគ្នា ហើយអាជាតិទាំងមូលតែងយកពីណា? ខ្ញុំយកជាតិហើយ ផ្ទាល់ខ្លួនទុកដោយឡែកសិន ដោះស្រាយសិនទៅ ។ ថេត សម្បត្តិ ៖ អញ្ចឹងអីមានការសោកស្តាយ ចំពោះពួកទាំងនោះទេបាទ? នួន ជា ៖ ខ្ញុំដូចជាគ្មានសោកស្តាយទេ ។ ខ្ញុំសោកស្តាយជាតិខ្ញុំជាង ស្តាយមាគ៌ា ស្តាយគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំស្តាយដែលពួកហ្នឹងមកធ្វើធ្លាក់ហើយ" ។

### ១) តួនាទី និងអត្តចរិតរបស់ ខៀវ សំផន

សហព្រះរាជអាជ្ញាបានបង្ហាញពីអត្តចរិករបស់ ខៀវ សំផន នៅមុន និងក្រោយពេលកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យយល់អំពីការចូលរួមរបស់ ខៀវ សំផន នៅក្នុងគោលនយោបាយឧក្រិដ្ឋ ។ ខៀវ សំផន បានលាក់កំបាំងនូវទីបញ្ជាការបក្សធ្វើការ និងរស់នៅជាមួយ ប៉ុល ពត និង នួន ជា ហើយកាន់អំណាចនានា

នៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចជាន់ខ្ពស់របស់បក្ស និងរដ្ឋាភិបាល ។ ព្រះរាជអាជ្ញាបានបន្តថា ភស្តុតាងបង្ហាញពីរូបភាពអំពីមេដឹកនាំនយោបាយជំនាញ ដែលពូកែបោកបញ្ឆោតមួយរូប ដែលស្រេកឃ្លានចង់បានអំណាច ហើយធ្វើការជាមួយ ប៉ុល ពត និង នួន ជា ដោយយល់ស្រប ទៅលើការប្រើប្រាស់ហឹង្សាក្នុងការសម្រេចអំណាច ។ ខៀវ សំផន អំពាវនាវឲ្យមានការកាប់សម្លាប់ប្រជាជនស្លូតត្រង់ ដែលជឿជាក់ថា ជាការត្រឹមត្រូវចំពោះការកម្ទេចអ្នក ដែលរារាំងបក្សកុម្មុយនីស្តកម្ពុជា ។ ខៀវ សំផន ចូលរួមក្នុងសេចក្តីសម្រេចជម្លៀសទីក្រុង បំបែកគ្រួសារ និងដាក់ប្រជាជនទាំងមូលឲ្យទៅជាទាសករក្នុងលក្ខខណ្ឌមួយអមនុស្សធម៌បំផុត និងបានបំពេញតួនាទីយ៉ាងមានប្រសិទ្ធិភាព ។ សហព្រះរាជអាជ្ញាបន្តថា នៅក្នុងឆ្នាំ១៩៧៥ និង១៩៧៦ ខៀវ សំផន បានប្រានចោលរបាយការណ៍ស្តីពីភាពសាហាវយោរយៅនៅក្នុងប្រទេសកម្ពុជាថា ជាយុទ្ធនាការបន្ទុចឈ្មោះកម្ពុជា ជាការលើកឡើងគ្មានប្រយោជន៍ និងគួរឲ្យរំខាន» ។ ប៉ុន្តែនៅថ្ងៃនេះ ខៀវ សំផន ជម្រាបជូនអង្គជំនុំជម្រះថា ពុំបានដឹងអ្វីទាំងអស់ ។ ក្នុងនាមជាផ្នែកមួយដ៏សំខាន់នៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បានចូលរួមនៅក្នុងការបង្កើតរៀបចំផែនការ និងការតាមដានឧក្រិដ្ឋកម្ម ។ ខៀវ សំផន បានចូលរួមដោយផ្ទាល់ នៅក្នុងអំពើទាសករ កម្មវិធីពលកម្មដោយបង្ខំតាមរយៈការគ្រប់គ្រងរបស់គាត់នៅក្រសួងពាណិជ្ជកម្ម និងឃ្លាំងរដ្ឋ ។ ខៀវ សំផន ដើរតួនាទីផ្ទាល់នៅក្នុងការបង្កើតកម្ពុជាប្រជាធិបតេយ្យ និងជាប្រមុខរដ្ឋព្រមទាំងបានត្រួតត្រាការគ្រប់គ្រងទៅលើការដាក់ឃុំឃាំងនៅក្នុងផ្ទះលើសម្តេច នរោត្តម សីហនុ ក្រោយមក បានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ។ ខៀវ សំផន ជាសមាជិក និងប្រធានមន្ទីរនយោបាយ៨៧០ ដែលជាកន្លែងទទួលខុសត្រូវត្រួតត្រាគ្រប់គ្រងការអនុវត្តគោលនយោបាយមជ្ឈិមបក្ស ។ ដោយផ្អែកលើភស្តុតាងដែលដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ដែលជាកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បានបង្ហាញថា ខៀវ សំផន បានចូលរួម៨៤ភាគរយនៃកិច្ចប្រជុំទាំង អស់នោះ ។ សហព្រះរាជអាជ្ញាបានលើកឡើងពីសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ដែលបង្ហាញអំពីការចូលរួមរបស់គាត់ផ្ទាល់ នៅក្នុងសហឧក្រិដ្ឋកម្មរួម និងការមិនគោរពជីវិតមនុស្ស ។ ការដកស្រង់មានដូចតទៅ «ខៀវ សំផន៖ បាទ សូមត្រូវយល់ថា បើគ្មាន ប៉ុល ពត បើគ្មានខ្មែរក្រហមចាប់ពីការធ្លាក់ពីអំណាចឆ្នាំ១៩៧០ហ្នឹង ប្រទេសកម្ពុជាហ្នឹងប្រហែលជាធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តវៀតណាមបាត់ទៅហើយ ។ អ៊ីចឹងសូមកុំភ្លេចចំណុចនេះឲ្យសោះ ។ អ៊ីចឹងមានន័យថាម៉េច? គឺអត់អីមានន័យថា យ៉ាងម៉េចបើយើងធ្លាក់ទៅក្នុងកណ្តាប់ដៃវៀតណាម? គឺបានន័យថា មិនចាំបាច់ត្រូវការពេលវេលាយូរអីទេ ដើម្បីឲ្យប្រទេសកម្ពុជាបច្ចុប្បន្ននេះក្លាយទៅជាកម្ពុជាក្រោមនោះ ។ អ៊ីចឹងសូមយល់ពីចំណុចនេះ ។ តើនៅកម្ពុជាក្រោមនុងមានប៉ុន្មានលាននាក់? ហើយគេរស់នៅយ៉ាងដូចម្តេចដែររាល់ថ្ងៃនេះ ថាជនជាតិខ្មែរនៅកម្ពុជាក្រោមនោះលោកដឹងទេ? ខ្ញុំសូមប្រាប់លោកថា កម្ពុជាក្រោមហ្នឹងគឺជាមន្ទីរស-២១ដ៏ធំបំផុត ។ បាទ ដូច្នេះបើយើងធៀបមន្ទីរស-២១ដ៏តូចមួយនៅប្រទេសកម្ពុជានេះលោកចង់បំភ្លេចមន្ទីរស-២១ដ៏ធំសម្បើមនៅកម្ពុជាក្រោម ឬក៏យ៉ាងម៉េច?» ។

## ៤) ការសន្និដ្ឋានស្តីពីការទទួលខុសត្រូវ និងការចូលរួមសំខាន់ៗនៅក្នុងផ្នែកឧក្រិដ្ឋកម្មរួម

ជនជាប់ចោទទាំងពីរបានចូលរួមនៅក្នុងកិច្ចប្រជុំនានា ស្តីពីការជម្លៀសប្រជាជន ។ ពេលចាប់ផ្តើមកិច្ចប្រជុំ នួន ជា បានលើកឡើងដោយមានរបៀបវារៈថា យើងនឹងធ្វើការជម្លៀសប្រជាជនមួយរយៈ ដើម្បីវិភាគស្ថានការ និងដើម្បីវិភាគការយល់ឃើញរបស់វៀតណាម ។ ចម្លើយរបស់សាក្សី ភី ភួន ដែលមានវត្តមាននៅក្នុងអង្គប្រជុំ បានបញ្ជាក់ថា កិច្ចប្រជុំនេះប្រើពេលអស់ ២ សប្តាហ៍ និងមានអ្នកចូលរួមតិចជាងសមាជបក្ស ។ ការប្រជុំមានអ្នកចូលរួមពីសំណាក់ នួន ជា និង ខៀវ សំផន និងមេដឹកនាំផ្សេងទៀត ស្តីពីការពិភាក្សាអំពីការឯកភាពលើការជម្លៀស ដែលនៅពេលនោះ នួន ជា បានលើកឡើងថា ការជម្លៀស គឺជាការចាំបាច់ និងមានគោលជំហរគាំទ្រ ។ សាក្សី ភី ភួន បានបន្តទៀតថា ចំណែក ខៀវ សំផន ក៏យល់ស្របចំពោះផែនការនោះដែរ ហើយអង្គប្រជុំទាំងមូលបានទះដៃឯកភាពលើគំនិតនោះ ។ ការផ្តល់សក្ខីកម្មនេះគឺស៊ីសង្វាក់គ្នានឹងប្រភពភស្តុតាងផ្សេង និងមានភាពស៊ីសង្វាក់គ្នានឹងសក្ខីកម្មរបស់ ស្ួង ស៊ីគឿន និង អឹម សែម ដែលធ្វើដំណើរចេញ

ក្រៅ និងនៅប្រទេសកម្ពុជាជាមួយ ខៀវ សំផន។ ការប្រជុំបានបញ្ជាក់ពីការចូលរួមរបស់មេដឹកនាំ នៅក្នុងការបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសភ្នំពេញ។ វាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម ដើម្បីប្រព្រឹត្តលើប្រជាជនកម្ពុជា ជាឧបករណ៍ ក្នុងការដាក់ប្រជាជនឲ្យទៅជាទាសករ ដោយការគាបសង្កត់តាមសហករណ៍ ពលកម្មដោយបង្ខំ ធ្វើការពុំមានបង់ប្រាក់ នៅក្នុងលក្ខខណ្ឌអមនុស្សធម៌ ថែមទាំងបដិសេធនូវសេចក្តីត្រូវការរបស់ប្រជាជន និងសិទ្ធិជាមូលដ្ឋាន។

សហព្រះរាជអាជ្ញា បានទាញហេតុផលផ្លូវច្បាប់ជម្រាបជូនអង្គជំនុំជម្រះថា នួន ជា និង ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកលើប្រជាជនកម្ពុជា តាមរយៈការរៀបចំផែនការបញ្ជាការជម្លៀសដោយបង្ខំមកលើប្រជាជនរាប់លាននាក់ឲ្យចេញពីលំនៅដ្ឋានស្របច្បាប់របស់ពួកគេនៅក្នុងទីក្រុងភ្នំពេញ ដោយគ្មានមូលដ្ឋានស្របច្បាប់។ ជាពិសេស ពុំមានការអនុញ្ញាតឲ្យពួកគេត្រឡប់មកលំនៅដ្ឋានរបស់ខ្លួនជារៀងរហូតក្នុងពេលបុគ្គលទាំងពីរនេះនៅកាន់អំណាច។ លក្ខខណ្ឌដែលបានដាក់មកលើប្រជាជននៅក្នុងការជម្លៀស គឺជាអំពើមួយអមនុស្សធម៌ប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ វាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបញ្ជូនប្រជាជនរាប់លាននាក់ទៅទីជនបទដែលក្តៅហែង ហើយឲ្យពួកគេដើរអស់រយៈពេលជាច្រើនថ្ងៃ ច្រើនសប្តាហ៍ ពេលខ្លះរហូតដល់ច្រើនខែ ដោយពុំមានការរៀបចំធ្វើដំណើរ និងផ្តល់ម្ហូបអាហារ ទឹក ឬខាងជំនួយពេទ្យ។ ជនជាប់ចោទបានដឹងយ៉ាងច្បាស់អំពីលក្ខខណ្ឌអមនុស្សធម៌ ដែលត្រូវបានជម្លៀសបញ្ជូនចេញពីទីក្រុងទៅកាន់ទីជនបទ។ ការជម្លៀសបានធ្វើឡើង នៅពេលដែល នួន ជា និង ខៀវ សំផន កំពុងតែធ្វើដំណើរពីឧត្តុង្គទៅភ្នំពេញ។ បុគ្គលទាំងពីរបានឃើញដោយផ្ទាល់ភ្នែកនូវការជម្លៀសដោយបង្ខំ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទទួលស្គាល់ការដឹងឮអំពីការស្លាប់រាប់សែននាក់។ ខៀវ សំផន បានប្រាប់ចៅក្រមស៊ើបអង្កេតថា គាត់បានដឹងអំពីលទ្ធភាព ដែលអាចមានការស្លាប់ក្នុងទ្រង់ទ្រាយធំក្នុងការជម្លៀសដោយបង្ខំថា «ពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុងភ្នំពេញ ខ្ញុំយល់ឃើញយ៉ាងច្បាស់ថា ប្រជាជនអាចទំនងនឹងដួលនៅតាមផ្លូវ»។ នួន ជា បានទទួលស្គាល់ថា ដួរដឹកនាំនយោបាយបញ្ជាឲ្យកម្មាភិបាលដឹកនាំសាធារណរដ្ឋខ្មែរកំពូល។

នួន ជា និង ខៀវ សំផន មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបទឧក្រិដ្ឋទាំងអស់ ដែលចោទប្រកាន់៖ ទី១) ការជម្លៀសដោយបង្ខំប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលចាប់ផ្តើមឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទី២) ការកាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ទី៣) ការជម្លៀសលើកទី២ ដែលចាប់ផ្តើមឡើងនៅខែកញ្ញា ឆ្នាំ១៩៧៥។ នួន ជា និង ខៀវ សំផន មានការទទួលខុសត្រូវនៅក្នុងបទឧក្រិដ្ឋទាំងអស់នេះ ដោយសារខ្លួនមានសមាជិក និងការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ ដែលមានសមាជិករាប់បញ្ចូលទាំង ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, អៀង សារី និងសមាជិកផ្សេងទៀតនៃមជ្ឈិមបក្ស លេខាភូមិភាគបក្សកុម្មុយនីស្តកម្ពុជា មេបញ្ជាការនៃកងពលបក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃសហឧក្រិដ្ឋកម្មរួម។ ភស្តុតាងបង្ហាញថា នួន ជា និង ខៀវ សំផន មានចេតនាគ្រប់បទឧក្រិដ្ឋទាំងអស់ដែលចោទប្រកាន់។ ជនជាប់ចោទបានអនុវត្តដោយមានការរៀបរយតាមលំដាប់លំដោយ រចនាសម្ព័ន្ធអំណាច និងដឹកនាំដោយមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ បទឧក្រិដ្ឋទាំងអស់នេះប្រព្រឹត្តនៅក្នុងបរិបទជាប្រព័ន្ធវាយប្រហារជាទូទៅ ប្រឆាំងនឹងប្រជាជនក្រុង ព្រមទាំងគម្រង់យកប្រជាជនស៊ីវិលក្រុងថាជាខ្មាំងរបស់ខ្លួន។ សកម្មភាពសំខាន់ៗក្នុងការបង្កើតឲ្យមានការចូលរួមទៅក្នុងសហឧក្រិដ្ឋកម្មមានដូចតទៅ៖

១-ការចូលរួមក្នុងការបង្កើត និងការអនុវត្តនូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីសំដៅយកខ្មាំងដែលគេសង្ស័យរួមមាន សាធារណរដ្ឋខ្មែរ ដែលទទួលការចាប់ឃុំឃាំង ការធ្វើទារុណកម្ម ហើយនឹងការសម្លាប់ក្រៅផ្លូវច្បាប់។

២-ការចូលរួមនៅក្នុងសេចក្តីសម្រេចជាសមូហភាពរបស់មជ្ឈិមបក្ស ដើម្បីជម្លៀសប្រជាជន ដោយបង្ខំចេញពីភ្នំពេញ នៅក្នុងកិច្ចប្រជុំនៅខែមិថុនា ឆ្នាំ១៩៧៤ និងខែមេសា ឆ្នាំ១៩៧៥។

៣-ចេញនូវការណែនាំដល់កងពលខ្មែរក្រហមទាំងអស់ ដើម្បីឲ្យជម្លៀសទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ នៅក្នុងកិច្ចប្រជុំ។

៤-ការបញ្ជា ការណែនាំ ការបង្រៀននូវកម្មាភិបាលបក្ស

កុម្មុយនីស្តកម្ពុជា និងពួកយោធាឲ្យប្រព្រឹត្តបទឧក្រិដ្ឋរាប់បញ្ចូលទាំងការជម្លៀសប្រជាជនចេញពីទីក្រុង ការដាក់ជនស៊ីវិលឲ្យទៅជាទាសករ និងស្វែងរកសម្លាប់អ្នកដែលគេយល់ថាជាខ្មាំង ។

៥-លើកទឹកចិត្ត និងយល់ស្របលើការប្រព្រឹត្តឧក្រិដ្ឋកម្មនៅតាមរយៈការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា រៀនទង់បដិវត្ត សេចក្តីណែនាំផ្សេងៗ ។

៦-លើកទឹកចិត្ត និងផ្តល់ការគាំទ្រការប្រព្រឹត្តបទឧក្រិដ្ឋកម្មតាមរយៈបទសុន្ទរកថា និងសេចក្តីប្រកាសសាធារណៈ ។ ប្រកាសឲ្យមានការសម្លាប់ខ្មាំង ការប្រើនូវរបបទាសកម្ម និងពលកម្មដោយបង្ខំ ។

៧-ការតាមដានការឃ្លាំមើលនៅលើកម្មាភិបាលស៊ីវិលយោធាទាំងអស់ដែលពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ ក្នុងរយៈកាលរបបប្រជុំជាទៀងទាត់នៅក្នុងការរាយការណ៍ទៅមជ្ឈិមបក្ស និងពិនិត្យមើលរបាយការណ៍លម្អិតមកពីភូមិភាគ និងស្ថាប័នស្វ័យត ។

៨-ការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចរបស់មជ្ឈិមបក្សរវាងខែឧសភា និងខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីបន្តការដាក់ឲ្យទៅជាទាសករ និងប្រជាជនជាយក្រុង ហើយការប្រើអំពើអមនុស្សធម៌ ។ ជាពិសេស បញ្ជូនប្រជាជន៥សែននាក់ពីភូមិភាគផ្សេងៗទៅភូមិភាគពាយ័ព្យ និងទៅភូមិភាគឧត្តរ ។

៩-សម្របសម្រួល និងការតាមដានការជម្លៀសដោយបង្ខំលើកទី២ ។

១០-ការប្រកាន់នូវប្រព័ន្ធ ការដាក់ឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្ស ការជម្លៀសដោយបង្ខំ កំណត់ដោយខ្មាំងរហូតដល់ចុងបញ្ចប់ដែលចែងនៅក្នុងដីការដំណោះស្រាយ ។

១១-ការហាមឃាត់មិនឲ្យប្រជាជនដែលដាក់ទាសករមិនឲ្យត្រឡប់មកផ្ទះវិញ ។

១២-ការប្រកាសដោយខ្វែងបន្ទំដែលរៀបចំដើម្បីលាក់លៀមបទឧក្រិដ្ឋ ដើម្បីឲ្យខ្លួនលាក់កំបាំងក្នុងឋានៈជាចារីនៃបទឧក្រិដ្ឋ ។

## ៥) ការកំណត់ទោស

សហព្រះរាជអាជ្ញាជាតិ ជា លាង បានធ្វើការសន្និដ្ឋានចុងក្រោយស្តីពីការទទួលខុសត្រូវរបស់ជនជាប់ចោទទៅលើបទឧក្រិដ្ឋកម្មពាក់ព័ន្ធទៅនឹងរឿងរ៉ាវជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ និងដំណាក់កាលទី២ និងទីកន្លែងសម្លាប់នៅទួលពោធិ៍ជ្រៃ ។ ការកើតឡើងទាំងនេះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ ការជម្លៀស និងការបាត់ខ្លួនដោយបង្ខំ ។ សហព្រះរាជអាជ្ញាយល់ឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ដែលបានប្រព្រឹត្តឡើងស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះរឿងក្តី០០២/០១ ។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ជាអ្នកដាក់ចេញនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយគោលនយោបាយទាំង៥ នោះរួមមាន ៖ ទី១) ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ។ ទី២) ការបង្កើត និងការទាញយកផលប្រយោជន៍តាមរយៈសហករណ៍ និងតាមការដ្ឋាន ។ ទី៣) អប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងដែលត្រូវរកឃើញទាំងនៅក្នុង និងក្រៅជួរបក្ស ។ ទី៤) ការចេញនូវវិធានការ ជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានាដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតរដ្ឋការនានានៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ។ ទី៥) ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ។ ក្នុងចំណោមបទឧក្រិដ្ឋទាំង៥ខាងលើមានគោលនយោបាយចំនួន២ត្រូវអនុវត្តបានសម្រេច គឺការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់មន្ត្រីរដ្ឋការស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ ។ សហព្រះរាជអាជ្ញាយល់ឃើញថា តាមរយៈឯកសារភស្តុតាង ដូចជាតេឡេក្រាម វីដេអូ សក្ខីកម្មសាក្សី និងអ្នកជំនាញបានបង្ហាញច្បាស់ថា ជនជាប់ចោទទាំងពីរនាក់ពិតជាបានដឹង និងបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលផែនការនេះបានបណ្តាលឲ្យប្រជាជនរាប់លាននាក់ស្លាប់ក្នុងរបប៣ឆ្នាំ៨ខែ២០ថ្ងៃ ។ ព្រះរាជអាជ្ញាមិនជ្រើសរើសយកវិធី

សម្លាប់ ដើម្បីយកមកធ្វើការដាក់ទណ្ឌកម្មចំពោះជនជាប់ចោទ នួន ជា និង ខៀវ សំផន ឡើយ ។ សហព្រះរាជអាជ្ញា ក៏ពុំបានស្នើសុំឲ្យអង្គជំនុំជម្រះផ្ដោលទោសជនជាប់ចោទ និងក្រុមគ្រួសារទាំងមូលរបស់ពួកគេ ដោយការបណ្ដេញចេញពីលំនៅដ្ឋាន ឬទង្វើអមនុស្សធម៌ផ្សេងៗដែលជនជាប់ចោទ និងបក្សពួកខ្លួនបានប្រព្រឹត្តមកលើជនរងគ្រោះក្នុងរបបខ្មែរក្រហមនោះទេ ។ ព្រះរាជអាជ្ញាបានបន្តទៀតថា ក្នុងនាមប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ព្រះរាជអាជ្ញាមើលឃើញការផ្ដល់យុត្តិធម៌ពីអង្គជំនុំជម្រះដល់ជនរងគ្រោះទាំងអស់ដែលបានស្លាប់បាត់បង់ជីវិតដល់សព្វថ្ងៃ ។ ជនរងគ្រោះបានហែលកាត់របបដ៏សែនឃោរឃៅ ក្រោមការដឹកនាំរបស់ជនជាប់ចោទទាំងពីរនាក់នេះ និងក្រោមការដឹកនាំរបស់មេដឹកនាំបក្សផ្សេងៗទៀត ។

ជនជាប់ចោទ នួន ជា និង ខៀវ សំផន ពុំបានសម្ដែងការសោកស្ដាយ ឬវិប្បដិសារីចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យទេ ។ ជនជាប់ចោទទាំងពីរ ពុំបានសហការជាមួយតុលាការ ដើម្បីបង្ហាញការពិត និងផ្ដល់ភាពយុត្តិធម៌ជូនជនរងគ្រោះឡើយ ។ ប៉ុន្តែ ជនជាប់ចោទ នួន ជា បានសម្ដែងនូវការខឹងសម្បាតាមរយៈការប្រើពាក្យសម្ដី "កុំយកឈើពុកមកឆ្លាក់ជាព្រះ" នៅក្នុងការជំនុំជម្រះស្ដាប់សក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ចំណែកជនជាប់ចោទ ខៀវ សំផន បាននិយាយថា "អ្វីដែលបានកន្លងផុតហើយ ទុកឲ្យកន្លងផុតទៅចុះ" ។ សហព្រះរាជអាជ្ញាបន្ថែមថា ជនជាប់ចោទ នួន ជា មិនទទួលស្គាល់ឯកសារភស្ដុតាងដែលអង្គជំនុំជម្រះសាលាដំបូងដាក់ពិភាក្សាដេញដោលទេ ។ ខៀវ សំផន បានប្រកែកចោលនូវការទទួលស្គាល់ទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗ ដូចជា ប៉ុល ពត និង នួន ជា ។ នៅក្នុងស្ថានភាពនេះ សហព្រះរាជអាជ្ញាពុំបានរកឃើញនូវមូលដ្ឋានណាមួយ ដើម្បីបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំងពីរនាក់នេះឡើយ ។

អ្វីដែលជនរងគ្រោះបានទទួលរងទុក្ខវេទនាឥតគណនាដោយរបបខ្មែរក្រហម មនុស្សទាំងអស់គ្នា រួមទាំងសហគមន៍អន្តរជាតិ ទន្ទឹងរង់ចាំអស់រយៈពេល៣៨ឆ្នាំមកហើយ ។ ដូច្នេះ ផ្អែកលើភស្ដុតាងដែលមានគ្រប់គ្រាន់ចំពោះមុខអង្គជំនុំជម្រះ និងយោងតាមខ្លឹមសារនៃមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្ដន្ទាទោស នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត ។



នួន ជា (ទីបួនរាប់ពីឆ្វេង) និង ខៀវ សំផន (ឆ្វេងខាងមុខ) ទទួលស្វាគមន៍ព្រះអង្គម្ចាស់ សុផានុវង្ស ពេលទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សេចក្តីថ្លែងការសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ ក្រុមមេធាវីការពារក្តី នួន ជា

ក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់សំណុំរឿងលើសំណុំរឿង០០២/០១ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងភាពមិនអាចទទួលយកបាន ឬភាពអយុត្តិធម៌នៃដំណើរការជំនុំជម្រះសេចក្តីលើជនជាប់ចោទ នួន ជា ។ ក្រៅពីនេះមេធាវីលើកឡើងអំពីតួនាទី និងការទទួលខុសត្រូវរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីការពារក្តីបានឆ្លើយតបផងដែរ ចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ ។ នៅក្នុងអំឡុងពេលសវនាការនេះដែរ នួន ជា ដែលធ្លាប់បានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរជាយូរមកហើយនោះ បានធ្វើសេចក្តីសន្និដ្ឋានដាច់ដោយឡែកមួយ ដោយឆ្លើយតបស្ទើរតែទាំងអស់នូវអង្គហេតុដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ។

## ១) ភាពអយុត្តិធម៌នៃការជំនុំជម្រះ

ទាក់ទងនឹងប្រធានបទនេះ មេធាវីបានលើកឡើងថា ភាពមិនប្រក្រតីនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត និងជំនុំជម្រះសេចក្តីកើតមានជាញឹកញាប់ ដែលធ្វើឲ្យមេធាវីការពារក្តីមានការលំបាកក្នុងការអនុវត្តការងាររបស់ខ្លួន ។ ក្រៅពីនេះមានការជ្រៀតជ្រែកពីរាជរដ្ឋាភិបាលកម្ពុជាទៅលើដំណើរការជំនុំជម្រះ ។ មេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេត និងចៅក្រមជំនុំជម្រះពុំបានធ្វើសេចក្តីសម្រេចឲ្យបានត្រឹមត្រូវ ។ នេះជាហេតុនាំឲ្យភាគីមួយចំនួន និងសាធារណជនមិនមានការចាប់អារម្មណ៍ចំពោះកិច្ចដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះ ។ ដូច្នេះអង្គជំនុំជម្រះបានបរាជ័យក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា និងចំពោះ នួន ជា ។ មេធាវីលើកឡើងទៀតថា តុលាការត្រូវបានបង្កើតឡើងគ្រាន់តែដើម្បីដាក់ទោសចំពោះជនដែលត្រូវបានគេសម្រេចរួចហើយ តាំងពីមិនទាន់មានអគាររបស់អង្គជំនុំជម្រះមកម្ល៉េះ ។

មេធាវីអះអាងថា តុលាការទទួលរងការជ្រៀតជ្រែកពីរាជរដ្ឋាភិបាលកម្ពុជា ដូច្នេះធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យរបស់តុលាការ ។ ការជ្រៀតជ្រែកនេះធ្វើឡើងដោយថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួនដូចជា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្តេច ហេង សំរិន សម្តេច ជា ស៊ីម និងមេដឹកនាំមួយចំនួនទៀត ដែលធ្លាប់បានចូលរួមអនុវត្តគោលនយោបាយដែលតុលាការកំពុងយកមកចោទប្រកាន់ នួន ជា ។ ហេង សំរិន ជាបុគ្គលម្នាក់ដែលបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ គាត់ចូលមកដល់ វិមានឯករាជ្យនៅភ្នំពេញនៅម៉ោង ៩ព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ហេង សំរិន មានតួនាទីជាអនុមេបញ្ជាការកងពលនៅភូមិភាគបូព៌ា ។ ចំណែកលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំទាស់ដោយចំហរ មិនឲ្យមានការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ ។ ក្នុងករណីដែលពុំបានដឹងច្បាស់អំពីការទទួលខុសត្រូវរបស់បុគ្គលដែលមានឈ្មោះនៅក្នុងសំណុំរឿងទាំងពីរនេះទេ តុលាការក៏មិនបានដឹងច្បាស់អំពីការទទួលខុសត្រូវរបស់ នួន ជា ព្រោះវាទាក់ទងទៅនឹងសិទ្ធិអំណាច និងការរាយការណ៍ទៅឲ្យ នួន ជា ។

មេធាវីបន្ថែមទៀតថា តុលាការក៏មានការបរាជ័យធ្ងន់ធ្ងរដែរសម្រាប់ធានាសិទ្ធិរបស់ នួន ជា ក្នុងការការពារខ្លួនតាមរយៈការពិនិត្យមើលភស្តុតាងលម្អិត ដែលត្រូវបានប្រើប្រាស់ដើម្បីចោទប្រកាន់ ។ ក្នុងអំឡុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរពុំបានផ្តោតការយកចិត្តទុកដាក់ទៅលើការស្វែងរកការពិតនោះទេ ។ ចៅក្រមស៊ើបអង្កេតប្រមូលយកតែភស្តុតាងដាក់បន្ទុក ហើយគោលបំណងនៃការស៊ើបអង្កេតនេះគ្រាន់តែដើម្បីចោទប្រកាន់តែប៉ុណ្ណោះ ។ ការស៊ើបអង្កេតត្រូវបានធ្វើជាសម្ងាត់ ដែលការអនុវត្តនេះ គឺខុសពីប្រព័ន្ធស៊ីវិលឡ ហើយមេធាវីការពារក្តីត្រូវបានដកចេញពីការស៊ើបអង្កេត ដែលកត្តានេះមិនអនុវត្តចំពោះសហព្រះរាជអាជ្ញាឡើយ ។ ចំពោះវិធីសាស្ត្រនៃការស៊ើបអង្កេត ចៅក្រម

ពិនិត្យមើលតែសំបកក្រៅនៃចម្លើយសាក្សី ហើយមិនបានសួរដេញដោលអំពីភាពអាចទុកចិត្តបានរបស់សាក្សីនោះទេ ។ កំណត់ហេតុជាច្រើនបានបង្ហាញពីភាពមិនប្រក្រតីនៃកិច្ចស៊ើបសួរ ។ សហចៅក្រមស៊ើបសួរមិនបានអនុវត្តការងាររបស់ខ្លួនក្នុងនាមជាអ្នកស៊ើបសួរដើម្បីស្វែងរកការពិតនោះទេ ហើយរកតែភស្តុតាងដាក់បន្ទុក ។ ដីកាដំណោះស្រាយមិនបានដាក់បញ្ចូលនូវភស្តុតាងដោះបន្ទុកដែលត្រូវបានរកឃើញ ។ ជាក់ស្តែងដីកានេះពុំបានដាក់បញ្ចូលនូវសក្ខីកម្មរបស់ ហេង សំរិន ដែលថា នួន ជា មិនចង់ឲ្យមានការសម្លាប់ទាហាន លន់ នល់ ។ មេធាវីលើកឡើងថា ដើម្បីឲ្យការជំនុំជម្រះមានយុត្តិធម៌នោះ ការស៊ើបអង្កេតត្រូវមានអព្យាក្រិតមិនលម្អៀង ។ ដូច្នេះការណ៍ដែលការស៊ើបអង្កេតមានវិការៈបែបនេះនាំឲ្យ នួន ជា រងផលប៉ះពាល់យ៉ាងខ្លាំង ។

មេធាវីអះអាងទៀតថា ក្នុងអំឡុងពេលជំនុំជម្រះសេចក្តី អង្គជំនុំជម្រះបានធ្វើសេចក្តីដោយពុំត្រឹមត្រូវ ដែលករណីនេះបានកើតមានជាញឹកញាប់ ។ អង្គជំនុំជម្រះមិនបានចាត់វិធានការទប់ស្កាត់ការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលមកលើតុលាការ ។ អង្គជំនុំជម្រះបានកោះហៅ ហេង សំរិន ដែលជាសាក្សីសំខាន់ម្នាក់ក្នុងការដោះបន្ទុក នួន ជា ពាក់ព័ន្ធនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ សាក្សីសំខាន់ទៀតដូចជា ជា ស៊ីម និង អ៊ុក ប៊ុនឈឿន ដែលផ្តល់សក្ខីកម្មស៊ីសង្វាក់នឹង ហេង សំរិន ដែលកត្តានេះបានធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ នួន ជា ក្នុងទទួលបានការកាត់ក្តីដោយយុត្តិធម៌ ។ ជាញឹកញាប់ អង្គជំនុំជម្រះបានកាត់ផ្តាច់ខយោសនស័ព្ទរបស់មេធាវីការពារក្តី ដោយមិនអើពើនឹងអង្គហេតុដែលមេធាវីចង់សួរដេញដោល ។ លើសពីនេះទៀត មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារផ្សេងៗ ដើម្បីសួរដេញ និងកំណត់អំពីភាពអាចជឿជាក់លើសក្ខីកម្មរបស់សាក្សីបានឡើយ ។ មេធាវីលើកឡើងទៀតថា អង្គជំនុំជម្រះបានទទួលយកឯកសារកំណត់ហេតុរាប់ពាន់ដោយមិនកោះហៅសាក្សីដែលផ្តល់ចម្លើយទាំងនោះមកសួរដេញដោល ។ បញ្ហាធ្ងន់ធ្ងរបំផុតនោះគឺពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ ស៊ីវ ហេងឌ័រ ។ ស៊ីវ ហេងឌ័រ ជាសាក្សីពិសេសមួយដែលបាននិពន្ធសៀវភៅមួយមានចំណងជើងថា «បុគ្គល៧រូបដែលត្រូវចោទប្រកាន់» ហើយបានចូលបម្រើការងារនៅការិយាល័យសហព្រះរាជអាជ្ញា ដែលបានចូលរួមសរសេរដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ។ បន្ទាប់មក ស៊ីវ ហេងឌ័រ ត្រូវបានជ្រើសរើសឲ្យមកបម្រើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបានជួយសរសេរដីកាដំណោះស្រាយ ដែលចោទប្រកាន់ នួន ជា ។

ទាក់ទងនឹងការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលដែរ មេធាវី វិចទ័រ កូប៉េ អះអាងថា បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ។ មន្ត្រីរបស់រាជរដ្ឋាភិបាលបានរារាំងមិនឲ្យអតីតសម្តេច ព្រះនរោត្តម សីហនុ និងមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតមកផ្តល់សក្ខីកម្មនៅតុលាការ ។ ការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជាបានធ្វើចៅក្រមអានសឺម៉េត លាលែងពីដំណែង និងមានការព្រួយបារម្ភពីប្រទេសម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិ ។ លោកនាយក រដ្ឋមន្ត្រី ហ៊ុន សែន និង មន្ត្រីជាន់ខ្ពស់មួយចំនួនរបស់រដ្ឋាភិបាលកម្ពុជាបានធ្វើសន្និសីទសារព័ត៌មាន ដែលធ្វើឲ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ នួន ជា ។ ការថ្លែងទាំងនោះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ដែលត្រូវបានកំណត់ថា ពុំមានទោសដរាបណាមិនទាន់មានការសម្រេចពីតុលាការ ។

នៅចុងក្រោយនៃសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងភាពអយុត្តិធម៌នៃការជំនុំជម្រះសេចក្តីនេះ មេធាវី វិចទ័រ កូប៉េ បានលើកឡើងថា ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ជាពិសេសព្រះរាជអាជ្ញាអន្តរជាតិ គឺជាការវាយប្រហារទៅលើលទ្ធិកុម្មុយនីស្ត និងអត្ថប្រយោជន៍នៃលទ្ធិកុម្មុយនីស្តតែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាមិនបានបង្ហាញពីចេតនារបស់ នួន ជា ក្នុងការសម្លាប់ទាហាន លន់ នល់ ឬសម្លាប់ប្រជាជនទេ ។ ផ្ទុយទៅវិញបានព្យាយាមបង្ហាញថាចលនារបស់បក្សកុម្មុយនីស្តខុសច្បាប់ ។ មេធាវីអះអាងថា សហព្រះរាជអាជ្ញាបានលើកឡើងអំពីអ្នកឈ្នះ និងអ្នកចាញ់ ហើយរូបគាត់គាំទ្រចំពោះការលើកឡើងនេះ ព្រោះសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តរបស់អាមេរិកជាអ្នកឈ្នះ ។ អាមេរិកបានឈ្នះសង្គ្រាមនោគមន៍វិជ្ជាប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត ។ ចំណែកអ្នកឈ្នះទី ២ ជារាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន ដែលធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាដួលរលំនៅឆ្នាំ១៩៩៨ ។ ដូច្នេះ ដើម្បីធានានូវប្រវត្តិ

សាស្ត្រនៅកម្ពុជា ត្រូវដាក់ទោសទៅលើលទ្ធិកុម្មុយនីស្តកម្ពុជាឲ្យបានខ្លាំងបំផុត ។ មេធាវីអះអាងទៀតថា“ មេដឹកនាំកម្ពុជា រដ្ឋាភិបាលកម្ពុជា ការដាក់ទោសលើកុម្មុយនីស្តខ្មែរ គឺអាចជាយុត្តិកម្មឲ្យគេមានអំណាចដោយធម្មានុរូប” ។ មេធាវីបានលើកយកការកត់សម្គាល់របស់ចៅក្រមនៅតុលាការតូក្យូ ដែលថាការជំនុំជម្រះអាចបញ្ជាក់ពីគំនិតនៃការសងសឹក ។ រដ្ឋដែលទទួលបានជ័យជម្នះអាចបញ្ជូនយុត្តាធិការរបស់ខ្លួនទៅលើបុគ្គល ដែលរំលោភលើច្បាប់សង្គ្រាម ។ ក្នុងករណីនេះ ការតែងតាំងចៅក្រមឲ្យធ្វើការជំនុំជម្រះសេចក្តីធ្វើឲ្យមានមន្ទិលសង្ស័យជាខ្លាំង ពោលគឺសម្រាប់តែអ្នកឈ្នះប៉ុណ្ណោះ ។ ហេតុការណ៍ទាំងនេះក៏អាចកើតមាននៅអង្គជំនុំជម្រះវិសាមញ្ញដែរ ។ មេធាវី វិចទ័រ កូប៉េ អះអាងថា “ភាពចម្រុះនៃអង្គជំនុំជម្រះ គឺឆ្លុះបញ្ចាំងពីភាគអ្នកឈ្នះទាំងស្រុង ។ មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ក្លាយទៅជាមេដឹកនាំបក្សប្រជាជនកម្ពុជា ដែលមានឥទ្ធិពលទៅលើភាគីចៅក្រមមួយចំនួនដូចជាប្រជាជាតិនៅសហរដ្ឋអាមេរិក បារាំង ហើយនិងអ្នកសម្ព័ន្ធមិត្តជិតស្និតនោះដែរ” ។ ទាំងនេះគឺជាយុត្តិធម៌សម្រាប់អ្នកឈ្នះ ។

### ២) តួនាទី និងការទទួលខុសត្រូវរបស់ នួន ជា

#### ក) មូលហេតុដែល នួន ជា ចូលធ្វើបដិវត្ត

មេធាវី សុន អរុណ បានលើកឡើងថា នួន ជា បានសម្រេចចូលរួមក្នុងចលនាបដិវត្តន៍ដោយសារការធ្វើអាណានិគមនិយមបារាំង ការជិះជាន់ពីសំណាក់អ្នកមានអំណាចមកលើប្រជាជនក្រីក្រ និងការឈ្លានពានពីប្រទេសជិតខាង ដែលរួមមាន វៀតណាម និងថៃ ។ នៅក្នុងសម័យក្រោមអាណានិគមនិយមបារាំង និងសង្គមរាស្ត្រនិយមបារាំង ប្រជាជនស្លូតត្រង់ត្រូវបានជិះជាន់កេងប្រវ័ញ្ច និងធ្វើបាប ។ នួន ជា យល់ថា ស្ថានភាពទាំងនេះ ត្រូវតែផ្លាស់ប្តូរ ហើយមានតែកុម្មុយនីស្តប៉ុណ្ណោះដែលអាចដោះស្រាយបញ្ហាទាំងនេះបាន ។ អស់រយៈពេលជាងពីរទសវត្សរ៍រដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រើហិង្សា បែបយោធាសេដ្ឋកិច្ច និងនយោបាយយ៉ាងលើសលុប ប្រឆាំងនឹងប្រទេសកុម្មុយនីស្ត ។ រហូតមកដល់ឆ្នាំ ១៩៧៣ សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកអស់២,៧៥៦,៩៤១ តោន មកលើប្រទេសកម្ពុជា ។ សមាជិកបក្សកុម្មុយនីស្តកម្ពុជាបានបាត់បង់ជីវិតប្រមាណមួយម៉ឺនប្រាំមួយពាន់នាក់ ។ នួន ជា យល់ឃើញថា របបកុម្មុយនីស្តជាផ្លូវទៅកាន់ សេរីភាពតាមរយៈរបបនេះអាចផ្តល់តាមតម្រូវការរបស់ប្រជាជន ។ ការនាំយករបបកុម្មុយនីស្តមកឲ្យប្រជាជនកម្ពុជាសង្ឃឹមថា នឹងលុបបំបាត់ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច ដែលមិនយុត្តិធម៌ ដើម្បីធ្វើឲ្យមានសមភាពនៅក្នុងសង្គម ។ នួន ជា យល់ឃើញទៀតថា សង្គមកម្ពុជាជាសង្គមពាក់កណ្តាលអាណានិគម និងពាក់កណ្តាលស័ក្តិភូមិ ។ ដូច្នេះ ការធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ដើម្បីបំបាត់ធាតុទាំងពីរនេះ និងដើម្បីប្រឆាំងនឹងវណ្ណៈមូលធននិយម ។



វ៉ិចទ័រ កូប៉េ និង នួន ជា ក្នុងសាលសវនាកា

មេធាវី សុន អរុណ អះអាងថា បក្សកុម្មុយនីស្តកម្ពុជាពុំដែលមានគោលបំណងកសាងសង្គម និយមតាមរយៈការប្រើអំពើហិង្សាឡើយ ។ បន្ថែមលើនេះទៀត នួន ជា ពុំត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មនោះទេ ប៉ុន្តែត្រូវបានកាត់ទោសទៅលើរបបកុម្មុយនីស្ត ជំនឿ និងអ្វីដែល នួន ជា មិនបានប្រព្រឹត្ត ។ បក្សកុម្មុយនីស្តកម្ពុជាមិនដែលមានគំនុំជាមួយប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀតឡើយ ។

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា ជាមនុស្សសាហាវ ដែលមានបំណងចង់ឲ្យប្រទេស

កម្ពុជាក្លាយទៅជារដ្ឋទាសករ មេធាវី សុន អរុណ បញ្ជាក់ថា ជាការចោទប្រកាន់ពុំត្រឹមត្រូវ ។ មេធាវីអះអាងថា នួន ជា ជាមនុស្សស្រឡាញ់ប្រជាជន និងប្រទេសជាតិ ។ នួន ជា មិនដែលចង់ក្លាយជាអ្នកមាន និងចង់បានបុណ្យស័ក្តិឡើយ ។ ពាក់ព័ន្ធនឹងការចោទប្រកាន់នេះដែរ មេធាវី វិចទ័រ កូប៉េ បញ្ជាក់ថា សហព្រះរាជអាជ្ញាបានប្រើពាក្យនេះដោយពឹងផ្អែកលើសក្ខីកម្មរបស់លោក ហ្វីលីព ហ្សូត ដែលគ្រាន់តែជាអ្នកកាសែត ហើយទើបចូលមកប្រទេសកម្ពុជា ២០ឆ្នាំក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងមិនចេះ



រ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភាសាខ្មែរ ។ ដូច្នេះមិនអាចជឿជាក់បានឡើយ ។ នួន ជា ពុំដែលមានចេតនាណាមួយដាក់ប្រទេសខ្លួនឲ្យក្លាយជារដ្ឋទាសភាពឡើយ ។ គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកសាងសង្គមនិយមមួយដែលប្រជាជនមានស្មើភាពគ្នា ។

### ១) តួនាទីរបស់ នួន ជា

### ១.១) ជាអនុលេខាបក្ស

មេធាវី សុន អរុណ លើកឡើងថា តួនាទីសំខាន់របស់ នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺអប់រំនយោបាយ ដោយទទួលបន្ទុកផ្សព្វផ្សាយអំពីគោលនយោបាយរបស់បក្ស ទៅដល់សមាជិក ។ ប៉ុន្តែមិនមានតួនាទីក្នុងការកំណត់គោលនយោបាយរបស់បក្សឡើយ ។ ការចោទប្រកាន់ថា នួន ជា បានចងសម្ព័ន្ធជាមួយកម្មាភិបាលភូមិភាគមួយចំនួន ដើម្បីប្រឆាំងនឹងកម្មាភិបាលនៅក្នុងភូមិមួយចំនួនទៀត ក៏ពុំត្រឹមត្រូវដែរ ។ នួន ជា បានទទួលកិត្តិស័ព្ទនៅក្នុងគណៈអចិន្ត្រៃយ៍ថា ជាអ្នកសម្របសម្រួល ផ្សះផ្សាសន្តិភាពជាមួយបុគ្គលដែលមានទំនាស់ជាមួយគ្នា ។

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាង នួន ជា និងវៀតណាម មេធាវី សុន អរុណ អះអាងថា លោក ហ្វីលីព ហ្សូត បានសន្និដ្ឋានមិនត្រឹមត្រូវអំពីមូលដ្ឋានគ្រឹះនៃមនោគមន៍វិជ្ជា ឬការបែកចេញរបស់មេដឹកនាំបក្សកុម្មុនីស្តកម្ពុជាពីប្រទេសវៀតណាម ។ នួន ជា មិនដែលអាក់អន់ចិត្តអំពីការផ្តល់តួនាទីតូចតាចក្នុងអំឡុងពេលរៀននៅប្រទេសវៀតណាមឡើយ ។ ផ្ទុយទៅវិញ នួន ជា បានស្វាគមន៍ការចូលរួមរបស់វៀតណាម និងមើលឃើញថា វៀតណាមជាសមមិត្តរួមអាវុធដែលវាយសត្រូវតែមួយ ។ ទោះបីជាយ៉ាងណា នួន ជា មិនភ្លេចពីមហិច្ឆតារបស់វៀតណាមក្នុងការគ្រប់គ្រងប្រទេសកម្ពុជានោះទេ ។ សម្តេច ព្រះនរោត្តម សីហនុ ក៏ធ្លាប់បញ្ជាក់ដែរថា ក្រោយពេលសង្គ្រាមចប់ ការរួបរួមកម្លាំងរបស់វៀតណាមទាំងនឹងនាំឲ្យកម្លាំងគ្រប់គ្រងទៅលើប្រទេសជិតខាង ។ ក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ វៀតណាម នៅតែអះអាងថា ខ្លួនគ្រប់គ្រងលើចលនាបក្សកុម្មុយនីស្តកម្ពុជា និងទឹកដីប្រទេសកម្ពុជា ។ នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល នួន ជា មានតួនាទីជាអ្នកសម្របសម្រួលជាមួយវៀតណាម ក្នុងការដោះស្រាយទំនាស់អំពីព្រំដែន និងការបញ្ជាទ័ព ។

### ១.២) តួនាទីក្នុងការតែងតាំង

ទាក់ទងនឹងតួនាទីរបស់ នួន ជា ដែរ មេធាវី សុន អរុណ ច្រានចោលការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា មានតួនាទីតែងតាំង ដកហូត ដាក់ពិន័យ កម្មាភិបាលនៅក្នុងជួរបក្ស ។ មេធាវីអះអាងថា សហព្រះរាជអាជ្ញាពុំបានផ្តល់ភស្តុតាងគាំទ្របន្តិចណាឡើយ ។ សហព្រះរាជអាជ្ញាបានពឹងផ្អែកទៅលើសក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច, នង សុផង និង សាឡុត បាន ដែលមិនអាចជឿជាក់បាន ព្រោះសាក្សីទាំងនោះពុំបានដឹងដោយផ្ទាល់ ។ ក្រៅពីនេះ សហព្រះរាជអាជ្ញាពុំបានបង្ហាញឯកសារណា

មួយដែលបញ្ជាក់ថា នួន ជា បានតែងតាំងកម្មាភិបាលនៅក្នុងជួរបក្សដែរ ។

### ១.៣) ការគ្រប់គ្រងក្រសួងនានា

មេធាវី សុន អរុណ យល់ស្របនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា គ្រប់គ្រងក្រសួងអប់រំ ប៉ុន្តែប្រានចោលដែលថា នួន ជា គ្រប់គ្រងក្រសួងសង្គមកិច្ច ក្រសួងឃោសនាការណ៍ ។ មេធាវីអះអាងថា សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ ដោយគ្រាន់តែពឹងផ្អែកទៅលើសក្ខីកម្មមួយចំនួនដែលមិនអាចជឿជាក់បាន ។ ចំពោះសក្ខីកម្មរបស់ អៀង ធីរិទ្ធ ដែល ថា នួន ជា បានបញ្ជាឲ្យចាប់មនុស្សនៅក្រសួងសង្គមកិច្ច ក៏ពុំអាចជឿជាក់បានដែរ ព្រោះ អៀង ធីរិទ្ធ បានផ្តល់សក្ខីកម្មក្នុងអំឡុងពេលមានសតិមិនល្អ ។ ទោះបីជាយ៉ាងណា មេធាវីយល់ស្របនឹងការលើកឡើងរបស់ នួន ជា ដែលថា គាត់ធ្លាប់បានធ្វើសេចក្តីសម្រេចជាច្រើនអំពីខ្លឹមសារនៃឯកសារអប់រំនយោបាយនៅក្នុងក្រសួងនានា ។

### ១.៤) ជានាយករដ្ឋមន្ត្រីស្តីទី

មេធាវី សុន អរុណ ប្រានចោលនូវការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា នួន ជា ធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ១៩៧៦-១៩៧៧ ដោយអះអាងថាគ្រាន់ជាការស្មានតែប៉ុណ្ណោះ ។ នួន ជា ពុំដែលបានទទួលស្គាល់អំពីតួនាទីនេះឡើយ ។ ឯកសារចំនួនពីរដែលសហព្រះរាជអាជ្ញបានយកមកគាំទ្រការចោទប្រកាន់ គឺមិនភាពស៊ីសង្វាក់គ្នា និងមិនអាចទុកចិត្តបាន ។ ឯកសារទាំងពីរនេះនិយាយពីការថ្លែងសុន្ទរកថារបស់ នួន ជា ក្នុងនាមជានាយករដ្ឋមន្ត្រីស្តីទីក្នុងខែមករា ឆ្នាំ១៩៧៧ ។ ឯកសារទាំងពីរនេះផ្សាយចេញពីវិទ្យុតែមួយ ពេលផ្សាយតែមួយ ប៉ុន្តែខ្លឹមសារខុសគ្នា ។

### ១.៥) ផ្នែកយោធា និងសន្តិសុខ

មេធាវី សុន អរុណ ក៏បានបដិសេធចោលចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា ទទួលបន្ទុកផ្នែកយោធា និងសន្តិសុខ ។ មេធាវីអះអាងថា សហព្រះអាជ្ញាពុំបានបង្ហាញ ភស្តុតាងអ្វីទាំងអស់ និងបានប្រើវិប្រែងបំផ្លើសដើម្បីឲ្យយល់ខុសទៅលើភស្តុតាង ។ ភស្តុតាងទាំងនោះ មិនមានភាពស៊ីសង្វាក់ និងមានភាពផ្ទុយគ្នា ។ មេធាវីបានយោងទៅលើសក្ខីកម្មរបស់ ហ្វីលីព ហ្សុត ដែលបញ្ជាក់ថា "ខ្ញុំមិនបានគិតថា នួន ជា មានតួនាទីជាយោធាទេ ។ [...] នួន ជា មិនមែនជាផ្នែកមួយរបស់គណៈកម្មាធិការយោធាទេ" ។ មេធាវីលើកឡើងថា ក្នុងរយៈពេលជិត ៤ឆ្នាំ នៃរបបកម្ពុជាប្រជាធិបតេយ្យ សហព្រះរាជអាជ្ញាអាចរកបានឯកសារសារទូរលេខចំនួន៦ ប៉ុណ្ណោះដែលបញ្ជូនមក នួន ជា ពាក់ព័ន្ធនឹងកិច្ចការយោធា ។ សារទូរលេខទាំង ៦នេះត្រូវបានបញ្ជូនឲ្យ នួន ជា ដោយកម្មាភិបាលយោធាម្នាក់ឈ្មោះ ឌឹម នៅកងពលធំលេខ១៦៤ ។ ប៉ុន្តែ នួន ជា ពុំបានចាំសារទូរលេខទាំងនេះឡើយ ។

### ១.៦) តួនាទីនៅមន្ទីរសន្តិសុខ ស-២១

មេធាវីបានប្រានចោលទាំងស្រុងចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា ទទួលខុសត្រូវមន្ទីរស-២១ បន្ទាប់ពី សុន សេន ត្រូវបានបញ្ជូនទៅសមរភូមិមុខ ។ មេធាវីអះអាងថា សហព្រះរាជអាជ្ញាពុំមានភស្តុតាងណាមួយឡើយក្រៅពីសក្ខីកម្មរបស់ ឌុច ដែលថា នួន ជា ទទួលបន្ទុកមន្ទីរ ស-២១ ។ មេធាវីស្នើឲ្យអង្គជំនុំជម្រះប្រានចោលនូវសក្ខីកម្មរបស់ ឌុច ដោយផ្តល់ហេតុផលថា មិនអាចជឿជាក់បាន និងអាចធ្វើឲ្យអង្គជំនុំជម្រះមានការភាន់ច្រឡំ ។ បន្ថែមលើនេះទៀត មេធាវីបញ្ជាក់ថា អង្គហេតុទាក់ទងនឹងមន្ទីរស-២១ ពុំត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ដើម្បីជំនុំជម្រះឡើយ ។ ទោះបីអង្គហេតុនេះត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ក៏សហព្រះរាជអាជ្ញាបានបង្ហាញតិចតួចបំផុតក្នុងការចោទប្រកាន់ នួន ជា ។ មេធាវី សុន អរុណ បានលើកឡើងថា នៅក្នុងសំណុំរឿងមានចម្លើយសារភាពចំនួន៨១៨៩ ប៉ុន្តែមានចម្លើយសារភាពចំនួនតែ២៥ប៉ុណ្ណោះ ដែលសហព្រះរាជអាជ្ញាបានអះអាងថា នួន ជា បានឃើញ ។ មេធាវីអះអាងទៀតថា បើយោងលើសក្ខីកម្មរបស់ សួត ឡើង ដែលជានិសាររបស់ នួន ជា បានបញ្ជាក់ថា នួន ជា បានទទួលចម្លើយសារភាពចំនួន ៥ ប៉ុណ្ណោះពីមន្ទីរស-២១ ។ ទោះបីជាយ៉ាងណា មេធាវីនៅតែស្នើសុំអង្គជំនុំជម្រះបដិសេធចោលនូវសក្ខីកម្មរបស់ សួត ឡើង ដែលថាបានបញ្ជូនចម្លើយសារភាពឲ្យ នួន ជា ។ បន្ថែមលើនេះទៀត

មេធាវី សុន អារុណ សុំអង្គជំនុំជម្រះបដិសេធចោលនូវសក្ខីកម្មរបស់ ឌុច ដែលអះអាងបានរាយការណ៍ នួន ជា ។ សក្ខីកម្មរបស់ ឌុច មិនអាចជឿបានឡើយ ព្រោះជានិច្ចជាកាល ឌុច តែងមានបំណងគេចពីការទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មដែលបានកើតនៅមន្ទីរស-២១ ។

មេធាវីអះអាងទៀតថា សហព្រះរាជអាជ្ញាមិនអាចបង្ហាញឲ្យបានច្បាស់លាស់ថា នួន ជា ទទួលខុសត្រូវមន្ទីរស-២១ឡើយ ។ មេធាវីបានច្រានចោលការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលថា នួន ជា បានប្រាប់ ថេត សម្បត្តិ ថា គាត់បានទទួលចម្លើយសារភាពជាច្រើន និងធ្លាប់ទទួលខុសត្រូវលើមន្ទីរស-២១ ។ មេធាវីបញ្ជាក់ថា នៅក្នុងខ្សែអាត់ថតសម្លេងនៃកិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ រាប់ម៉ោងពុំបានបង្ហាញថា នួន ជា ធ្លាប់ទទួលខុសត្រូវលើមន្ទីរស-២១ ឬជាមេរបស់ ឌុច ឡើយ ។

### ខ.៧) ការគ្រប់គ្រងទៅលើភូមិភាគ និងតំបន់ស្វយ័ត

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា នួន ជា បានតាមដាន និងដឹកនាំការអនុវត្តមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទៅដល់ ភូមិភាគ តំបន់ស្វយ័ត និងអង្គការទាំងអស់របស់បក្ស មេធាវី សុន អរុណ បញ្ជាក់ថា នួន ជា មិនបានបដិសេធនោះទេ ហើយបានទទួលស្គាល់ថា គោលនយោបាយទាំងនោះត្រូវបានអនុវត្តនៅតាមភូមិភាគ ។ នួន ជា ក៏បានទទួលស្គាល់ដែរថា គណៈចិន្ត្រៃយ៍បានតាមដានការអនុវត្តគោលនយោបាយទាំងនោះ ។ ទោះបីជាយ៉ាងណា មេធាវីនៅតែអះអាងថា នួន ជា ពុំមានសមត្ថភាពដឹកនាំការអនុវត្តគោលនយោបាយទាំងនោះឡើយ ។ នួន ជា អាចបំពេញការងារទាំងនោះគឺអាស្រ័យលើកិច្ចសហប្រតិបត្តិការរបស់កម្មាភិបាលនៅតាមភូមិភាគ ។ មេធាវីបានច្រានចោលដែរនូវការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលថា នួន ជា បានគ្រប់គ្រងតាមភូមិភាគតាមរយៈការហៅកម្មាភិបាលភូមិភាគមកប្រជុំនៅទីក្រុងភ្នំពេញ តាមរយៈការទទួលសារទូរលេខ និងរបាយការណ៍ និងតាមរយៈការចុះទៅធ្វើទស្សនកិច្ចនៅតាមបណ្តាខេត្ត ។ ការចោទប្រកាន់ទាំងនេះ មិនមានលក្ខណៈពេញលេញ និងធ្វើឲ្យភាន់ច្រឡំ ។ សហព្រះរាជអាជ្ញពុំបានបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ឲ្យផុតពីវិមតិសង្ស័យ ដែលអាចបញ្ជាក់ថា នួន ជា បានទទួលខុសត្រូវតាមភូមិភាគ និងតំបន់ឡើយ ។ ចុងក្រោយមេធាវី សុន អរុណ ស្នើឲ្យអង្គជំនុំជម្រះបដិសេធនូវការចោទប្រកាន់ទាំងនេះចោល ។

### គ) ការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការរបប លន់ នល់

### គ.១) ចេតនារបស់ថ្នាក់ដឹកនាំ

មេធាវី វិចទ័រ កូប៉េ បានអះអាងថា ពុំមានភស្តុតាងណាមួយដែលបង្ហាញថា ថ្នាក់មជ្ឈិមមានគោលនយោបាយសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ឡើយ ។ ដូច្នេះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តមានគោលនយោបាយសម្លាប់អតីតទាហាន តាំងពីមុនឆ្នាំ១៩៧៥មកនោះ គឺជាការមិនពិត ។

ទាក់ទងនឹងចេតនាក្នុងការសម្លាប់ទាហាន លន់ នល់ មេធាវីការពារក្តីអន្តរជាតិ វិចទ័រ កូប៉េ បានលើកយកសក្ខីកម្មរបស់ ភី ភួន, ហេង សំរិន និង អ៊ុក ប៊ុនឈឿន ដែលបញ្ជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពុំមានគោលនយោបាយក្នុងការសម្លាប់ទាហានទាំងនោះឡើយ ។ ភី ភួន ដែលជាកងការពាររបស់ ប៉ុល ពត បានបញ្ជាក់ថា នៅមុនពេលវាយចូលទីក្រុងភ្នំពេញ ប៉ុល ពត បានណែនាំមិនឲ្យ សម្លាប់ទាហាន លន់ នល់ ណាដែលបានលើកទង់ជ័យសរសុំចុះចាញ់នោះទេ ។ សក្ខីកម្មនេះស្របគ្នានឹងសក្ខីកម្មរបស់ នួន ជា ដែលបានផ្តល់បទសម្ភាសន៍ជូន ថេត សម្បត្តិ ថាថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ពុំដែលមានចេតនាសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃឡើយ ព្រោះអ្នកទាំងនោះជាប្រជាជនធម្មតា ។ មេធាវីកូបប៉េ បានអះអាងថា មានសាក្សីជាច្រើនដែលដឹងច្បាស់អំពីភាពគ្មានចេតនារបស់ថ្នាក់ដឹកនាំបក្ស ក្នុងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនេះ ប៉ុន្តែអ្នកទាំងនោះមិនព្រមមកបង្ហាញមុខដើម្បីផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះឡើយ ដូចជាលោក ហេង សំរិន និង អ៊ុក ប៊ុនឈឿនជាដើម ។ដូច្នេះ វត្តមានរបស់អ្នកទាំងនោះ ជាពិសេសវត្តមានរបស់ ហេង សំរិន នៅចំពោះមុខអង្គជំនុំជម្រះ គឺជាលក្ខខណ្ឌអប្បរមា ដែលមិនអាចចចារបានដើម្បីធានាដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ ។ មេធាវី កូប៉េ បានអះអាងថា សក្ខីកម្មរបស់ ហេង សំរិន មានសារៈសំខាន់បំផុតសម្រាប់ នួន ជា ។ ដូច្នេះ ការដែលមិនសម្រេចកោះហៅ ហេង

សំរិន ឲ្យមកផ្តល់សក្ខីកម្ម គឺពុំមានហេតុផលអ្វី ក្រៅពីមានការជ្រៀតជ្រែកឬការមិនមានភាពឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជាឡើយ ។

### ក.២) គោលនយោបាយ

### ចេតនាការសម្លាប់មុនខែមេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថាបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយសម្លាប់អតីតទាហាន លន់ នល់ ចាប់តាំងពីមុនខែមេសា ឆ្នាំ១៩៧៥ មកនោះ មេធាវី វិចទ័រ កូប៉េ អះអាងថា សហព្រះរាជអាជ្ញាពុំបានបង្ហាញឲ្យហួសពីវិមតិសង្ស័យឡើយ ។ មេធាវីការពារក្តីអះអាងថា សហព្រះរាជអាជ្ញាបានពឹងផ្អែកតែទៅលើសក្ខីកម្មរបស់ ស៊ីវ ហេងឌ័រ យកមកចោទប្រកាន់អំពីការសម្លាប់ទាហាន លន់ នល់ នៅក្រុងឧដុង្គ ។ ស៊ីវ ហេងឌ័រ បានបញ្ជាក់ថា គាត់ពុំបានដឹងថា ទាហាន លន់ នល់ ត្រូវបានគេសម្លាប់ភ្លាមៗឡើយ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងឧដុង្គក្នុងអំឡុងឆ្នាំ១៩៧៤ ។ ទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅខេត្តកំពង់ចាម មេធាវីអះអាងថា ព្រះរាជអាជ្ញា ពឹងផ្អែកលើសាក្សី៨រូប ដែលលើកឡើងពីការជម្លៀសប្រជាជននៅខេត្តកំពង់ចាម ។ ប៉ុន្តែសាក្សី ៧រូប ក្នុងចំណោមនោះ មិនបានលើកឡើងពីការសម្លាប់ទាហាន លន់ នល់ ឡើយ ។ មានតែសាក្សី ស៊ីវ ហេងឌ័រ ប៉ុណ្ណោះ ដែលលើកឡើងពីការសម្លាប់ទាហាន លន់ នល់ ។ ប៉ុន្តែ ស៊ីវ ហេងឌ័រ ពុំបានដឹងច្បាស់អំពីការសម្លាប់នោះឡើយ ព្រោះគាត់បានទៅដល់ខេត្តកំពង់ចាម នៅក្រោយពេលមានការជម្លៀស ។ ចំពោះការសម្លាប់មនុស្សនៅមន្ទីរម-១៣ វិញ មេធាវីអះអាងថា ជនរងគ្រោះដែលស្លាប់នៅទីនោះ គឺពុំមែនសុទ្ធតែទាហាន លន់ នល់ ដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាឡើយ ។ អ្នកទាំងនោះមានទាំងប្រជាជនធម្មតា និងគិញដែលខ្មែរក្រហមចាប់ខ្លួនបាន ។ ចំពោះសក្ខីកម្មរបស់សាក្សីម្នាក់ដែលបានបញ្ជាក់ថា មេឃុំដែលបម្រើការងារនៅក្នុងរបប លន់ នល់ ត្រូវបានសម្លាប់ចោលភ្លាមៗ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ គឺពុំអាចទទួលយកបានឡើយ ព្រោះសាក្សីនោះមិនត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ចុងក្រោយ ឆ្លើយតបនឹងការចោទប្រកាន់ថា មានការសម្លាប់ ប្រជាជនខ្មែរវៀតមិញ មេធាវី វិចទ័រ កូប៉េ បានអះអាងថា សាក្សី ឈូក រីន និងសាក្សី នូ ម៉ៅ ដែលបានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងបញ្ហានេះ គឺពុំអាចជឿជាក់បានឡើយ ព្រោះសាក្សីទាំងពីររូបនេះពុំបានដឹងដោយផ្ទាល់អំពីការចាប់ខ្លួន និងសម្លាប់ប្រជាជនទាំងនោះឡើយ ។ មេធាវីបានអះអាងបន្ថែមថា បក្សកុម្មុយនីស្តកម្ពុជាពុំមានហេតុផលអ្វីត្រូវសម្លាប់ប្រជាជនទាំងនោះទេ ព្រោះអ្នកទាំងនោះមានទស្សនៈកុម្មុយនីស្តដូចគ្នា ហើយពុំមានភស្តុតាងណា ដែលបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនវៀតមិញ ទាំងនោះមានការបែកបាក់គ្នាដែរ ។ ចុងក្រោយមេធាវី វិចទ័រ កូប៉េ សន្និដ្ឋាន ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជា មានគោលនយោបាយសម្លាប់ ទាហាន និងមន្ត្រីនៃរបប លន់ នល់ មុនឆ្នាំ១៩៧៥ ឡើយ ។

### ចេតនាសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថាបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយសម្លាប់អតីតទាហាន និងមន្ត្រីរបប លន់ នល់ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ មេធាវី វិចទ័រ អះអាងថា ជាការចោទប្រកាន់មិនត្រឹមត្រូវ ។ មេធាវីបានលើកឡើងនូវសក្ខីកម្មរបស់ ភី ភួន ដែលបញ្ជាក់ថា ប៉ុល ពត បានណែនាំមិនឲ្យសម្លាប់អតីតទាហាន លន់ នល់ ឡើយក្រោយពេលទាហានទាំងនោះ ទម្លាក់អាវុធ និងលើកទង់ជ័យស សូមចុះចាញ់ ។ មេធាវីក៏បានយោងទៅលើការលើកឡើងដែរនូវសក្ខីកម្មរបស់សាក្សីមួយចំនួនទៀតដែលថា នៅក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៥ ទាហាន លន់ នល់ មួយចំនួនត្រូវបានដោះលែង ។ ទាក់ទងនឹងសាក្សី ប៉េជុយ ជីពសែ និងសាក្សី ឡេវ ឡាំ ដែលបានផ្តល់សក្ខីយ៉ាងច្រើនពាក់ព័ន្ធនឹងការសម្លាប់អតីតទាហាន លន់ នល់ មេធាវីអះអាងថា សាក្សីទាំងនោះមិនអាចជឿជាក់បានឡើយ ព្រោះសាក្សីទាំងនោះបានផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ មិនស៊ីសង្វាក់ជាមួយសក្ខីកម្មដែលបានផ្តល់ជូនចៅក្រមស៊ើបអង្កេត ។ មេធាវីបានបន្ថែមទៀតថា អង្គជំនុំជម្រះបានសម្រេចទទួលយកចម្លើយរបស់សាក្សីជាច្រើន ដោយពុំបានកោះហៅសាក្សីទាំងនោះឲ្យមកផ្តល់សក្ខីកម្ម ដែលការធ្វើបែបនេះពុំដែលធ្លាប់មានអនុវត្តនៅតុលាការអន្តរជាតិ ផ្សេងៗ

ទៀតឡើយ ។ អ្វីដែលសំខាន់នោះ គឺក្រុមមេធាវីការពារក្តីពុំបាន សួរដេញដោលអំពីភាពអាចទុកចិត្តបានទៅលើសាក្សីទាំងនោះ ។

ក្រៅពីបដិសេធនូវសក្ខីកម្មរបស់សាក្សីទាំងនេះ មេធាវី វិចទ័រ បានឆ្លើយតបទៅនឹងឯកសារមួយចំនួនទៀត ដែលសហព្រះរាជអាជ្ញាបានដាក់ ។ ឯកសារដែលមេធាវីបានយោងទៅរកនោះ ជាឯកសារបញ្ជាឲ្យសម្លាប់អ្នកទោសចំនួន ១៧នាក់ ដែលបានចេញដោយកម្មាភិបាលម្នាក់ឈ្មោះ ពិន ។ មេធាវីអះអាងថា ពិន ពុំបានបញ្ជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តណាម្នាក់ជាអ្នកបញ្ជាឲ្យសម្លាប់អ្នកទោសទាំងនោះឡើយ គឺគ្រាន់តែបញ្ជាក់ថា បញ្ជាចេញមកពីបក្ស ។ ដូច្នេះការប្រើពាក្យនេះ ពុំមានន័យទាំងអស់ក្នុងការចោទប្រកាន់ទៅលើថ្នាក់ដឹកនាំណាម្នាក់ឡើយ ។ ឯកសារមួយទៀត ជារបាយការណ៍ព័ត៌មានរបស់ទីភ្នាក់ងារសារព័ត៌មានបារាំង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៦ ។ ឯកសារនេះបញ្ជាក់ថា អតីតឧត្តមសេនីយ៍នៃរបប លន់ នល់ ចំនួន៥៨រូប ត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ មេធាវីអះអាងថា ឯកសារនេះមិនអាចទុកចិត្តបានឡើយ ដូច្នេះត្រូវប្រានចោលទាំងស្រុង ។ នៅក្នុងឯកសារព័ត៌មាននេះបានបញ្ជាក់ថា បញ្ជីឈ្មោះឧត្តមសេនីយ៍ដែលត្រូវបានសម្លាប់ទាំងនោះ ត្រូវបានបញ្ជូនទៅរដ្ឋាភិបាលបស្ចិមប្រទេស ដែលកត្តានេះធ្វើឲ្យកាន់តែមិនអាចជឿជាក់បាន ព្រោះពុំមានហេតុផលណាដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវប្រកាសអំពីការកាប់សម្លាប់របស់ខ្លួនឲ្យពិភពលោកដឹងនោះទេ ។ មេធាវី វិចទ័រ កូប៉េ ក៏បានបដិសេធចោលដែរចំពោះសក្ខីកម្មរបស់សាក្សី ស៊ុម ជា និងសាក្សីផ្សេងៗទៀតដែលបញ្ជាក់ថា ទាហាន លន់ នល់ ត្រូវបានសម្លាប់ចោលនៅជិតស្ពានជ្រោយចង្វារ និងទាហានជាច្រើនទៀតត្រូវបានដឹកចេញពីទីក្រុងភ្នំពេញជាច្រើនឡាន ។ មេធាវីអះអាងថា សាក្សីទាំងនោះពុំបានឃើញហេតុការណ៍ទាំងនោះដោយផ្ទាល់ឡើយ ។

ចុងក្រោយមេធាវី វិចទ័រ កូប៉េ សន្និដ្ឋានថា សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងសូម្បីតែបន្តិចបន្តួចថា មានសមាជិកណាម្នាក់របស់មជ្ឈិមបក្ស បានអនុម័ត ឬមានចេតនាសម្លាប់ ឬមានគោលនយោបាយក្នុងការសម្លាប់ទាហាន លន់ នល់ ជាប្រព័ន្ធឡើយ ។ ជាងនេះទៅទៀតសហព្រះរាជអាជ្ញា ក៏ពុំបានបង្ហាញភស្តុតាងថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយសម្លាប់អតីតទាហាន លន់ នល់ និងប្រជាជនសាមញ្ញ បានចូលជាធរមាននៅមុនឆ្នាំ១៩៧៥ ឬក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ ដូច្នេះ ពិតប្រាកដណាស់ដែលថា បក្សកុម្មុយនីស្តកម្ពុជាពុំមាន



ប្រជាជនកម្ពុជាដែលត្រូវបានជម្លៀសដោយខ្មែរក្រហម ទៅកាន់តំបន់ផ្សេងៗ បានវិលត្រឡប់មកលំនៅដ្ឋានវិញ
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

គោលនយោបាយនេះ ។ មេធាវី វិចទ័រ កូប៉េ នៅតែយោងទៅលើសក្ខីកម្មរបស់ ហេង សំរិន ដែលបញ្ជាក់ថា នួន ជា បានណែនាំនៅក្នុងកិច្ចប្រជុំថា មិនឲ្យសម្លាប់ទាហាន និងមន្ត្រីរបប លន់ នល់ ។ មេធាវីអះអាងថា ហេង សំរិន និង ជា ស៊ីម ជាសមាជិកជាន់ខ្ពស់នៅក្នុងជួរកងទ័ពភូមិភាគបូព៌ា ។ នៅភូមិភាគបូព៌ា ហេង សំរិន មានឋានៈជាអនុលេខាកងពល ដែលស្ថិតនៅក្រោមតែមនុស្សពីរនាក់ប៉ុណ្ណោះ គឺ សោ ភឹម និងប្រធានកងពល ។ ប៉ុន្តែអ្នកទាំងពីរនេះពុំដែលបានដឹងអំពីគោលនយោបាយនៃការសម្លាប់ទាហាន លន់ នល់ ឡើយ ។ មេធាវីធ្វើការសន្និដ្ឋានថា ប្រសិនបើមានគោលនយោបាយសម្លាប់អតីតទាហាន លន់ នល់ នោះ ហេង សំរិន និង ជា ស៊ីម ពិតជាបានដឹងពុំខាន ។ ទោះបីជាយ៉ាងណាមេធាវី វិចទ័រ កូប៉េ បានទទួលស្គាល់ថា “ប្រសិនបើមានគោលនយោបាយនោះមែនអាចនឹងមានតែនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ទេ ។ ហើយអាចនឹងកំណត់យកតែមន្ត្រីទាហានជាន់ខ្ពស់ និងមន្ត្រីស៊ីវិលជាន់ខ្ពស់ៗតែប៉ុណ្ណោះ” ។

## ការសម្លាប់នៅភូមិភាគផ្សេងៗ ក្រៅពីទីក្រុងភ្នំពេញ

ទាក់ទងនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា ក្រៅពីការសម្លាប់អតីតទាហាន លន់ នល់ នៅក្នុងទីក្រុងភ្នំពេញ មានការកាប់សម្លាប់ទាហាន លន់ នល់ នៅតាមភូមិភាគផ្សេងៗទៀតនោះ មេធាវីអះអាងសហព្រះរាជអាជ្ញាពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ ។ មេធាវីបានលើកឡើងថា មជ្ឈិមបក្សពុំមានគោលនយោបាយកាប់សម្លាប់ទាហាន លន់ នល់ នៅតាមភូមិភាគផ្សេងៗទៀត ដូចជា ភូមិភាគបូព៌ា ភូមិភាគកណ្តាល ភូមិភាគឧត្តរ និងភូមិភាគពិសេស ដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាឡើយ ។ មេធាវីបានអះអាងថា សហព្រះរាជអាជ្ញាបានលើកយកតែសក្ខីកម្មរបស់សាក្សីចំនួន១០ និងឯកសារតែ២ប៉ុណ្ណោះ មកធ្វើការគាំទ្រក្នុងការចោទប្រកាន់ថា មានការសម្លាប់ទាហាន លន់ នល់ នៅក្នុងភូមិភាគទាំង៤នេះ ។ ក្នុងចំណោមសាក្សីនោះ មានសាក្សីមួយចំនួនពុំបានដឹង ឬឃើញដោយផ្ទាល់អំពីការសម្លាប់ទាហាន លន់ នល់ ឡើយ ដោយគ្រាន់តែឮតាមពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ ហើយសាក្សីមួយចំនួនទៀត ផ្តល់សក្ខីកម្មពាក់ព័ន្ធតែការសម្លាប់មនុស្សនៅភូមិភាគផ្សេងៗ ទៀត ដោយពុំជាប់ពាក់ព័ន្ធនឹងការសម្លាប់អតីតទាហាន លន់ នល់ នៅក្នុងភូមិទាំង៤នេះឡើយ ។

## ការសម្លាប់នៅទួលពោធិ៍ជ្រៃ

ក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ មេធាវី វិចទ័រ កូប៉េ បានព្យាយាមលើកឡើង ៣ចំណុចសំខាន់ ។ ទី១) មេធាវីបានព្យាយាមបង្ហាញថា ភស្តុតាងដែលសហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះដើម្បីគាំទ្រដល់ការចោទប្រកាន់ គឺនៅមានកម្រិត និងមិនអាចធ្វើឲ្យហួសពីវិមតិសង្ស័យឡើយ ។ ជាងនេះទៅទៀត ភស្តុតាងទាំងនោះពុំមានភាពស៊ីសង្វាក់ និងអាចជឿទុកចិត្តបាន ។ ទី២) មេធាវីព្យាយាមបង្ហាញថា ទោះបីភស្តុ-តាងទាំងនោះអាចត្រូវបានសម្រេចថាមានភាពអាចជឿជាក់បាន ឬហួសពីវិមតិសង្ស័យក៏ដោយ ក៏ពុំមានការជាប់ពាក់ព័ន្ធជាមួយនឹង នួន ជា ដែរ ។ ទី៣) មេធាវីបានព្យាយាមបង្ហាញថា ការកាប់សម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ គឺជាការសម្រេចរបស់កម្មាភិបាលថ្នាក់ក្រោម ដែលអាចធ្វើឡើងដោយសារគំនុំសងសឹក ។

ដូចគ្នានឹងការលើកឡើងមុនៗដែរ មេធាវី វិចទ័រ កូប៉េ បានអះអាងថា សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ និងហួសពីវិមតិសង្ស័យឡើយពាក់ព័ន្ធនឹងចោទប្រកាន់អំពីការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ មេធាវីបន្ថែមទៀតថា ទោះបីសហព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងមួយចំនួនក៏ដោយ ប៉ុន្តែភស្តុតាងទាំងនោះនៅមានកម្រិត និងមិនស៊ីសង្វាក់គ្នា ដែលអាចជឿជាក់បានឡើយ ។ មេធាវីបានលើកឡើងថា ក្នុងអំឡុងពេលស៊ើបសួរសហចៅក្រមស៊ើបអង្កេតរកឃើញ កម្ទេចកម្ទីខោអាវ សំបកគ្រាប់កាំភ្លើង ឆ្អឹងសាកសពមនុស្សបន្តិចបន្តួចតែប៉ុណ្ណោះ ដែលពុំអាចសន្និដ្ឋានថាមានការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំនៅទីនោះឡើយ ។ ចំពោះចំនួនជនរងគ្រោះដែលស្លាប់នៅទីនោះ ក៏ពុំមានភាពច្បាស់លាស់ ហើយគ្មានជនរងគ្រោះណាម្នាក់ត្រូវបានកំណត់អត្តសញ្ញាណនោះទេ ។ បន្ថែមលើនេះទៀត មេធាវី វិចទ័រ កូប៉េ បានច្រានចោលនូវសក្ខីកម្មរបស់ អ៊ុង ឆាត់ និង ស៊ឹម អាឡាត់ ដែលបានផ្តល់សក្ខីកម្ម

ថា ទាហាន លន់ នល់ ជាច្រើនឡាន ត្រូវបានដឹកយកទៅសម្លាប់ នៅទួលពោធិ៍ជ្រៃ ដោយអះអាងថា សក្ខីកម្មរបស់អ្នកទាំងនោះ ពុំមានភាពស៊ីសង្វាក់គ្នា ដូច្នេះមិនអាចជឿជាក់បាន ។ ក្រៅពីនេះ ពុំមានសាក្សីណាម្នាក់បានឃើញដោយផ្ទាល់អំពីការសម្លាប់ទា-ហាន លន់ នល់ នៅទួលពោធិ៍ជ្រៃឡើយ ។ មេធាវី វិចទ័រ កូប៉េ អះអាងថា មានភស្តុតែមួយគត់ គឺខ្សែភាពយន្តដែលមានចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" ។ ភស្តុតាងនេះនិយាយលម្អិតអំពីការការសម្លាប់មនុស្សនៅទីនោះ ប៉ុន្តែអង្គជំនុំជម្រះពុំបានកោះហៅម្ចាស់ផលិតករឲ្យមកផ្តល់សក្ខីកម្មឡើយ ។

មេធាវី វិចទ័រ កូប៉េ បានអះអាងទៀតថា ទោះបីជារកឃើញថា ពិតជាមានការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃក៏ដោយ ប៉ុន្តែការសម្លាប់ទាហានទាំងនោះពុំមានការជាប់ពាក់ព័ន្ធនឹង នួន ជា នោះទេ ។ នួន ជា ពុំបានដឹង ឬទទួលខុសត្រូវចំពោះការសម្លាប់ទាហាន លន់ នល់ នៅទីនោះឡើយ ។ អ្វីដែលសំខាន់នោះ សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងដែលបញ្ជាក់ថា ការសម្លាប់ទាហានទាំងនោះ គឺចេញមកពីបញ្ជារបស់មជ្ឈិម ។

ផ្ទុយទៅវិញ មេធាវី វិចទ័រ កូប៉េ បានទម្លាក់ការទទួលខុសត្រូវចំពោះការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ទៅលើកម្មាភិបាលថ្នាក់ក្រោម ដែលក្នុងនោះមាន រស់ ញឹម ដែលជាប្រធានភូមិភាគពាយ័ព្យ ជាអ្នកទទួលខុសត្រូវ ។ មេធាវីបានអះអាងថា រស់ ញឹម បានបំពេញការងារដោយឯករាជ្យ ហើយបានចូលដៃជាមួយ សោ ភឹម ដើម្បីប្រឆាំងនឹង នួន ជា និង ប៉ុល ពត ។ អ្នកទាំងពីរនេះ បានបំភ្លៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយយកទៅអនុវត្តនៅភូមិភាគរបស់ខ្លួន (ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ) ដើម្បីយកប្រយោជន៍ផ្ទាល់ខ្លួន ។ បន្ថែមលើនេះទៀត សោ ភឹម និង រស់ ញឹម បានរៀបចំផែនការណ៍ដើម្បីប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ។ ដើម្បីគាំទ្រនូវការលើកឡើងរបស់គាត់ ដែលថាកម្មាភិបាលភូមិភាគបានអនុវត្តការងារដោយឯករាជ្យ មេធាវីបានលើកយកសម្តីរបស់ អៀង សារី ដែលបានបញ្ជាក់ប្រាប់លោក ហ្វីលីព ហ្សុត ថា "សូម្បី ប៉ុល ពត និង នួន ជា ខ្លួនឯងហ្នឹងក៏ មិនហ៊ានទៅទីនោះម្នាក់ឯងផងដែរ គាត់ខ្លាចតាភឹម ។ ដូច្នេះនៅភូមិភាគហ្នឹង ប្រសិនបើ សោ ភឹម ចង់សម្លាប់នរណាម្នាក់ ក៏ចង់ធ្វើអ្វីមួយ គាត់មិនចាំបាច់ស្នើសុំសួរទៅខាងលើនោះទេ ។ អង្គការគឺអ៊ីចឹង ភូមិភាគនីមួយៗគឺឯករាជ្យ ។ ដូច្នេះយើងអាចនិយាយថា ពួកគេសម្លាប់តាមចិត្តចង់របស់ពួកគេ ហើយធ្វើតាមចិត្តរបស់ពួកគេ" ។

### ៣) ការជម្លៀសប្រជាជន

#### ក) ការជម្លៀសប្រជាជនដំណាក់កាលទី១

ឆ្លើយតបទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មេធាវី សុន អរុណ អះអាងថា ការជម្លៀសនេះ ជាកញ្ចប់មួយដែលទាក់ទងទៅនឹងផែនការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ។ មេធាវីលើកឡើងថា នៅឆ្នាំ១៩៧៥ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ប្រជាជនខ្មែរបានរត់ចោលផ្ទះសំបែង បង្កើតឲ្យមានគ្រោះទុរភិក្ស ខ្វះស្រូវអង្ករសម្រាប់បរិភោគ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ បក្សកុម្មុយនីស្តកម្ពុជាមានផែនការណ៍កសាងហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលដំណាំឡើងវិញ ។ ដូច្នេះការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាប់ពាក់ព័ន្ធទៅនឹងផែនការកសាងប្រទេសជាតិ ។ មេធាវីអះអាងថា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ការបន្តបំលាស់ទីប្រជាជនពីកន្លែងមួយ ទៅកន្លែងមួយទៀត គឺទទួលបានការគាំទ្រពីអង្គការអន្តរជាតិធំៗដូចជាធនាគារពិភពលោក និងអង្គការសហប្រជាជាតិ ។ ធនាគារពិភពលោកនៅតែបន្តគាំទ្រការអនុវត្តគម្រោងផ្សេងៗទៀត ទោះបីជាមានការជម្លៀសប្រជាជនរាប់សែននាក់ចេញពីតំបន់ ដែលរងការប៉ះពាល់ក៏ដោយ គឺក្នុងគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ជាក់ស្តែង នៅចន្លោះឆ្នាំ១៩៨១ដល់១៩៩៤ ធនាគារពិភពលោកគាំទ្រការអនុវត្តគម្រោងធំៗ ដែលបានបណ្តាលឲ្យមានការបំលាស់ទីប្រជាជនជាច្រើន ។

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា "ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ យកទៅដាក់តាមសហករណ៍ គឺដើម្បីដាក់ទណ្ឌកម្មប្រជាជនដែលរស់នៅក្នុងទីក្រុង" មេធាវី សុន អរុណ អះអាងថា ការដែលសហព្រះរាជអាជ្ញាលើកឡើងចំណុចនេះ គឺក្នុងគោលបំណងបង្ហាញថា ប្រជាជនដែល

រស់នៅក្នុងទីក្រុងភ្នំពេញជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សហព្រះរាជអាជ្ញាបានយោងតែការលើកឡើងរបស់អ្នកសិក្សាស្រាវជ្រាវបរទេស ដែលមិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះ សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ និងហួសពីវិមតិសង្ស័យឡើយ ។ មេធាវី សុន អរុណ បានយោងទៅលើសក្ខីកម្មរបស់ ឈូក រីន ដោយអះអាងថា ឈូក រីន ផ្តល់សក្ខីកម្មថាប្រជាជននៅទីក្រុងភ្នំពេញមិនត្រូវបានចាត់ទុកជាសត្រូវ ហើយក៏ពុំដែលបានទទួលការណែនាំណាមួយថា ប្រជាជនទាំងនោះគឺជាសត្រូវដែរ ។ លើសពីនេះទៀត ប្រជាជនទាំងនោះពុំបានប្រព្រឹត្តដូចគ្នាទៅនឹងសត្រូវរបស់បក្សកុម្មុនីស្តកម្ពុជាដែរ ។

មេធាវី សុន អរុណ បានអះអាងទៀតថា ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ គឺដើម្បីដោះស្រាយបញ្ហាកង្វះខាតស្បៀងអាហារ ប្រេងឥន្ធនៈ ដែលប្រជាជនរស់នៅក្នុងទីក្រុងភ្នំពេញកំពុងជួបវិបត្តិយ៉ាងខ្លាំង ។ វិបត្តិទាំងនោះបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ ។ ប្រជាជនដែលរស់នៅក្នុងទីក្រុងមួយចំនួនបានស្លាប់ដោយសារអត់អាហារ ។ដូច្នេះ បើមិនជម្លៀសចេញពីទីក្រុងភ្នំពេញប្រជាជនទាំងនោះនឹងស្លាប់កាន់តែច្រើន ។ ចុង ក្រោយ មេធាវី សុន អរុណ អះអាងថា យោធាខ្មែរក្រហមដែលចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយជម្លៀសប្រជាជនចេញពីទីក្រុងនោះ ធ្វើតាមបញ្ជារបស់ថ្នាក់ដឹកនាំភូមិភាគ មិនមែនធ្វើតាមបញ្ជារបស់ នួន ជា ឬមេដឹកនាំថ្នាក់មជ្ឈិមផ្សេងៗទៀតឡើយ ។ នៅក្នុងអំឡុងពេលជម្លៀសនោះទៀតសោត ក៏ពុំមានការប្រើអំពើហិង្សានោះដែរ ។ ជាក់ស្តែងសហចៅក្រមស៊ើបអង្កេតធ្លាប់បានធ្វើការសន្និដ្ឋានថា “សាក្សីភាគច្រើនបាននិយាយថា គ្មានអំពើហិង្សាណាមួយនៅក្នុងផ្នែកនៃទាហានកុម្មុយនីស្តកម្ពុជាទេក្នុងអំឡុងពេលជម្លៀស” ។

## ១) ការជម្លៀសប្រជាជននៅដំណាក់កាលទី២

មេធាវី សុន អរុណ អះអាងថា ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា ការជម្លៀសប្រជាជនដំណាក់កាលទី២ ធ្វើឡើងតាមការបញ្ជារបស់ នួន ជា និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ជាការចោទប្រកាន់ពុំត្រឹមត្រូវ ។ សហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងឲ្យផុតពីវិមតិសង្ស័យ ចំពោះអង្គហេតុដែលចោទប្រកាន់ចំពោះ នួន ជា ។ មេធាវីអះអាងថា នួន ជា ពុំបានចេញសេចក្តីសម្រេច ឬចេញបញ្ជាណាមួយទាក់ទងនឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២ឡើយ ហើយទើបតែបាន



ពីឆ្វេងទៅស្តាំ : វ៉ន វ៉េត, អៀង សារី, នួន ជា, ប៉ុល ពត, សោ ភឹម ក្នុងពិធីអន្តមីទីញរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដឹងអំពីការជម្លៀសនេះនៅពេលក្រោយប៉ុណ្ណោះ ។ នួន ជា បានទទួលស្គាល់ការទទួលខុសត្រូវសម្រាប់ការជម្លៀសប្រជាជនដំណាក់កាលទី១ ដែលជាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីកន្លែងផ្សេងៗទៀត ។ ដូច្នេះ បើ នួន ជា ពិតជាមានផែនការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២មែននោះ នួន ជា នឹងសារភាពទទួលស្គាល់ដូចការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយមិនខ្លាចទទួលខុសត្រូវឡើយ ។ មេធាវីអះអាងថា ការសម្រេចជម្លៀសប្រជាជននៅដំណាក់កាលទី២ ធ្វើឡើងដោយប្រធានភូមិ ដែលអនុវត្តការងាររបស់ខ្លួនដោយឯករាជ្យ និងមិនមានបញ្ជាពីថ្នាក់មជ្ឈិមនោះទេ ។

មេធាវី សុន អរុណ បានអះអាងទៀតថា ការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី២នេះ ត្រូវបានធ្វើឡើងដោយបង្ខំនោះឡើយ ។ ក្នុងការគាំទ្រនូវអំណះអំណាងនេះ មេធាវីបានលើកយកសក្ខីកម្មរបស់ ឡាយ ប៊ុនទី ដែលបានបញ្ជាក់ថា គាត់មានការសប្បាយរីករាយនៅពេលដឹងថាគាត់នឹងបានទៅភូមិភាគពាយ័ព្យ ព្រោះនៅទីនោះជាកន្លែងសំបូរស្រូវអង្ករ ។ គួរបញ្ជាក់ថា មេធាវីពុំបានដកស្រង់សក្ខីកម្មរបស់ ឡាយ ប៊ុនទី ឲ្យបានពេញលេញនោះទេ ព្រោះ ឡាយ ប៊ុនទី បានផ្តល់សក្ខីកម្មទៀតថា ពេលទៅដល់ភូមិភាគពាយ័ព្យ ស្ថានភាពរស់នៅរឹតតែអាក្រក់ថែមទៀត ។ មេធាវី សុន អរុណ ក៏បានឆ្លើយតបដែរនូវការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដែលថា ការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២នេះ ត្រូវបានធ្វើឡើងដោយមានការរើសអើងផ្នែកនយោបាយ ធ្វើទុក្ខបុកម្នេញបាត់ខ្លួនដោយបង្ខំ បំលាស់ទីដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ហើយក្រុមមនុស្សមួយចំនួនត្រូវបានកំណត់មុខសញ្ញាដើម្បីសម្លាប់ចោល ។ មេធាវីបានអះអាងថា ការចោទប្រកាន់ទាំងនេះធ្វើឡើងដោយពុំត្រឹមត្រូវ ហើយសហព្រះរាជអាជ្ញាពុំបានបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ក្នុងការគាំទ្រចំពោះការចោទប្រកាន់ទាំងនេះឡើយ ។ មេធាវីបញ្ជាក់ថា ប្រជាជនទាំងនោះទទួលរងលក្ខខណ្ឌដូចៗគ្នាក្នុងអំឡុងពេលជម្លៀសដោយគ្មានការរើសអើងឡើយ ។ សាក្សីដែលសហព្រះរាជអាជ្ញាបានយោងទៅរកដើម្បីគាំទ្រការចោទប្រកាន់របស់ខ្លួន មានមួយចំនួនពុំបានផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុទាំងនេះឡើយ ហើយមួយចំនួនទៀតពុំបានដឹងហេតុការណ៍ទាំងនោះដោយផ្ទាល់នោះទេ ។ ទោះបីដូច្នេះក្តីពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា នួន ជា មានការជាប់ពាក់ព័ន្ធទៅនឹងបទក្រិដ្ឋទាំងអស់នេះដែរ ។ ចុងក្រោយ មេធាវី សុន អរុណ ស្នើសុំអង្គជំនុំជម្រះច្រានចោលការចោទប្រកាន់ទាំងនេះ ។

## ៤) សេចក្តីថ្លែងរបស់ នួន ជា

បន្ទាប់ពីក្រុមសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០១ ចប់សព្វគ្រប់ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ដែលជាថ្ងៃចុងក្រោយបង្អស់នៃសវនាការអង្គជំនុំជម្រះបានអនុញ្ញាតឲ្យ នួន ជា ធ្វើសេចក្តីសន្និដ្ឋានឆ្លើយទាំងអស់ចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន នួន ជា បានចំណាយពេលអស់ប្រមាណមួយម៉ោងកន្លះ ដោយអានទាំងស្រុងទៅលើឯកសារដែលត្រូវបានរៀបចំទុកជាមុន ។ នៅក្នុងសេចក្តីសន្និដ្ឋាននោះ នួន ជា បានលើកឡើងអំពីតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបដិសេធចោលនូវតួនាទីជាច្រើន ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ។ បន្ថែមលើនេះ នួន ជា បានចោទប្រកាន់អំពីភាពមិនប្រក្រតី និងភាពអយុត្តិធម៌ ដែលបានកើតឡើងនៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះសេចក្តីរបស់អង្គជំនុំជម្រះ ។ ខាងក្រោមនេះជាសេចក្តីសន្និដ្ឋានទាំងស្រុងរបស់ នួន ជា ដែលបានធ្វើជាសាធារណៈនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ៖

«សូមក្រាបថ្វាយបង្គំព្រះថេរា នុថេរៈដែលគង់នៅទីនេះ និងនៅគ្រប់វត្ត ។ សូមគោរពបងប្អូន ជនរួមជាតិជាទីស្នេហា ។ សូមគោរពតុលាការ ។ មកដល់ពេលនេះ សវនាការបានប្រព្រឹត្តទៅអស់រយៈពេលជាង២ឆ្នាំមកហើយ ដើម្បីសម្រេចអំពីជោគវាសនារបស់ខ្ញុំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ក្នុងអំឡុងពេលនេះ គឺជាចន្លោះពេលមួយដែលទាក់ទងនឹងការបំពេញការងារស្មើរតែមួយជីវិតរបស់ខ្ញុំ ក្នុងបុព្វហេតុបម្រើប្រទេសជាតិ និងប្រជាជនជាទីស្នេហារបស់ខ្ញុំផងដែរ ។ ទាក់ទង

ទៅនឹងសវនាការនេះ បើទោះបីជាខ្ញុំមិនបានចូលរួមដោយផ្ទាល់ ដោយសារសុខភាពរបស់ខ្ញុំមិនសូវល្អក្តី ក៏ខ្ញុំបានតាមដានស្តាប់ ដោយយកចិត្តទុកដាក់នូវការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ និងការសួរដេញដោលសាក្សីទាំងឡាយ នៅពេលសវនាការ ពីបន្ទប់ឃុំឃាំងនៅក្រោមសាលជំនុំជម្រះជាបន្តបន្ទាប់ ។ តាមរយៈសវនាការនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើស ដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់នោះទេ ។ និយាយឲ្យខ្លីទៅ គឺខ្ញុំមិនមានទោសអ្វីទាក់ទងនឹងការចោទប្រកាន់ដូចដែលបានលើកឡើងនោះទេ ។ សូមគោរពតុលាការ! នៅពេលខ្ញុំនិយាយបែបនេះ ប្រហែលជាអាចមានអ្នកខ្លះ ដែលមិនទាន់បានយល់អំពីច្បាប់ ឬមានគំនិតលម្អៀង អាចសើចចំអកឡកឡឺយឲ្យខ្ញុំ ។ តែនេះមិនមែនជាអ្វីទេ នៅពេលខ្ញុំជម្រាបជូននៅពេលបន្តិចទៀតនេះ ទើបអស់លោកបានដឹងច្បាស់ថា អ្វីដែលខ្ញុំនិយាយ គឺសុទ្ធសឹងតែជាការពិត ។ តាមផ្លូវច្បាប់ គោលបំណងនៃការបង្កើតតុលាការនេះ គឺមានទិសដៅនិងតួនាទី ដើម្បីស្វែងរកការពិតនិងយុត្តិធម៌ឲ្យខ្ញុំ និងជនរងគ្រោះ តាមរយៈភស្តុតាងរឹងមាំ ស្របច្បាប់ និងអាចឲ្យជឿបាន ។ ផ្ទុយទៅវិញ មកដល់ពេលនេះ លោក លោកស្រីសហព្រះរាជអាជ្ញា មិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបំពេញធាតុផ្សំបទល្មើសដែលបានចោទប្រកាន់ដាក់បន្ទុកមកលើរូបខ្ញុំ ហើយសិទ្ធិស្របច្បាប់របស់ខ្ញុំមួយចំនួនក៏មិនបានធានាត្រឹមត្រូវនៅក្នុងតុលាការនេះផងដែរ ។ ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីឲ្យបានឆាប់រហ័ស សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ សិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិផ្សេងៗទៀត ដែលធានាដោយច្បាប់ជាតិ និងអន្តរជាតិ ។ ម្យ៉ាងវិញទៀត ចំណុចសង្ស័យជាច្រើនទាក់ទងនឹងភស្តុតាងក៏មិនទាន់បានលាតត្រដាងឲ្យបានច្បាស់លាស់នៅចំពោះមុខតុលាការ ដូចជាឯកសារដើម និងសក្ខីកម្មរបស់សាក្សីសំខាន់ៗដែលជួយដល់ខ្ញុំ ។ ដូចលោក លោកស្រីចៅក្រមបានជ្រាប់ស្រាប់ហើយ ចំណុចទាំងអស់នេះ លោកមេធាវីរបស់ខ្ញុំ បានបញ្ជាក់ជូនអង្គសវនាការយ៉ាងច្បាស់ និងមានមូលដ្ឋានច្បាប់ត្រឹមត្រូវរួចមកហើយ ។ តែទោះជាយ៉ាងនេះក្តី រូបខ្ញុំផ្ទាល់សូមបញ្ជាក់បន្ថែមនូវចំណុចសំខាន់ៗមួយចំនួនទៀត សម្រាប់ជាមូលដ្ឋានផ្តល់ជូនលោក លោកស្រីចៅក្រមជ្រាប់ឲ្យកាន់តែច្បាស់ចំពោះភាពគ្មានទោស និងសុចរិតភាពរបស់ខ្ញុំពាក់ព័ន្ធនឹងបទចោទប្រកាន់មកលើខ្ញុំ ។ ខ្ញុំសម្អាងបែបនេះដោយផ្អែកលើមូលដ្ឋាន ៣យ៉ាងសំខាន់គឺ ៖

### ក) ការគ្មានអំណាចគ្រប់គ្រង និងគ្មានអំណាចទប់ស្កាត់

សូមគោរពតុលាការ និងបងប្អូនជនរួមជាតិជាទីស្នេហា! កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅនេះ ខ្ញុំបានជម្រាបជូនអង្គសវនាការម្តងរួចមក ហើយថា ខ្ញុំមិនមានអំណាចអ្វី និងមិនជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលកើតមានឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានតួនាទីតែ ៣ប៉ុណ្ណោះគឺ ៖

### ក.១) ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា

នៅក្នុងមុខងារនេះ ខ្ញុំមានតួនាទីជាអ្នកឃោសនាអប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស ។ ចំពោះខ្លឹមសារនៃការឃោសនាអប់រំ ខ្ញុំមិនដែលឃោសនាអប់រំឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ ដូចជាប្រើអំណាចអាជ្ញា ឬមានអកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ ។ ខ្ញុំបានអប់រំឲ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជាចេះគោរពប្រជាជន ស្រឡាញ់ប្រជាជន បម្រើប្រជាជន និងប្រទេសជាតិរបស់ខ្លួន ។ ខ្ញុំមិនដែលអប់រំ ឬណែនាំសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ឲ្យធ្វើបាបកាប់សម្លាប់អង្កត់អាហារប្រជាជន ឬប្រល័យពូជសាសន៍ណាម្តងទេ ។ ខ្ញុំតែងតែលើកយកគោលការសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជា មកបង្រៀន និងអប់រំ ដល់សមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងទិសដៅធ្វើយ៉ាងណាឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តកម្ពុជាទាំងអស់អនុវត្តការងារ និងបម្រើប្រជាជនឲ្យបានល្អប្រសើរ ។ ជាពិសេស ខ្ញុំបានលើកយកគោលការណ៍ ដែលមានចែងនៅក្នុងមាត្រា ២នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីអប់រំឲ្យសមាជិកបក្សទាំងអស់យល់ជ្រួតជ្រាបកាន់តែច្បាស់អំពីភារកិច្ចរបស់សមាជិកបក្សក្នុងការចូលរួមក្នុងសកម្មភាពសង្គម ។ មាត្រា២ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា "បក្សជនគ្រប់រូបសុទ្ធតែមានភារកិច្ចដូចតទៅ ៖

១) ភារកិច្ចក្នុងមហាជនគឺ ឃោសនា អប់រំមហាជនអំពីនយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្ស ហើយប្រឡូកចុះជិតស្និតជាមួយមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ។ ត្រូវទទួលខុសត្រូវខ្ពស់ ចំពោះមហាជន បម្រើមហាជនអស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ ។ រាបសារនឹងមហាជន ហើយខំរៀនសូត្រពីមហាជន ។

២) បំផុសបំផុលចលនាមហាជន ពិសេសមហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ឲ្យក្តៅគគុក និងជាប់ជានិច្ចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសដៅបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម ។

៣) ភារកិច្ចផ្ទៃក្នុងគឺ ខិតខំថែរក្សា ពង្រឹង ពង្រីក សាមគ្គីភាពផ្ទៃក្នុងបក្សឲ្យបានល្អជាប់ជានិច្ចដាច់ខាត ។ ផ្អែកលើគោលការណ៍នេះ វាបញ្ជាក់យ៉ាងច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជា មានបំណងឲ្យសមាជិករបស់ខ្លួនមានស្មារតីទទួលខុសត្រូវខ្ពស់ ចុះជាប់ជាមួយប្រជាជន ធ្វើល្អជាមួយប្រជាជនយកចិត្តទុកដាក់ជាមួយប្រជាជន និងរៀនសូត្រពីប្រជាជន ។ ជាពិសេស លើកទឹកចិត្តកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា និងប្រជាជនឲ្យមានគំនិតស្នេហាជាតិ និងការពារមាតុភូមិ ។ ទន្ទឹមនឹងនេះខ្ញុំ តែងតែអប់រំឲ្យសមាជិកបក្សទាំងអស់ កុំប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំពុករលួយ និងកុំលែងល្បែងស៊ីសង ។ល ។ ជាពិសេសឲ្យចេះសាមគ្គីគ្នា ទាំងក្នុងជួរបក្ស និងមហាជន ។

អ្វីៗដែលខ្ញុំបានលើកឡើងខាងលើនេះ គឺជាឧទាហរណ៍មួយដែលបញ្ជាក់ពីកិច្ចការរបស់ខ្ញុំបានធ្វើក្នុងតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ និយាយឲ្យខ្លីទៅអ្វីដែលខ្ញុំបានអប់រំ និងបង្រៀនដល់សមាជិកបក្ស និងកងទ័ពនោះ គឺជាការបណ្តុះពុទ្ធិ ឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តកម្ពុជា ត្រូវមានឆន្ទៈស្នេហាជាតិ ការពារជាតិ និងស្រឡាញ់ប្រជាជន និងសាមគ្គីភាពផ្ទៃក្នុងល្អ ក្នុងទិសដៅការពារ និងកសាងប្រទេសជាតិមួយឲ្យបានរីកចំរើនរុងរឿង និងឯករាជ្យពិតប្រាកដ ហើយមិនអនុញ្ញាតឲ្យប្រទេសណាមួយ ធំក្តី តូចក្តី ជិតក្តី ឆ្ងាយក្តី ឈ្លានពាន និងធ្វើអាណានិគមមកលើប្រទេសកម្ពុជាបានជាដាច់ខាត ។

ការកម្ចាត់ខ្មាំងឈ្លានពាន វាជាតួនាទីរបស់កងទ័ពប្រជាជនបដិវត្តកម្ពុជាក្នុងការការពារជាតិមាតុភូមិ ។ រួមជាមួយនេះ ការពង្រឹងសន្តិសុខ និងស្ថេរភាពនយោបាយផ្ទៃក្នុង ត្រូវអនុវត្តឲ្យបានល្អប្រសើរ ទើបបដិវត្តមានការរីកចម្រើនរុងរឿង ។ តាមទស្សនៈទូទៅ ប្រការនេះវាមិនខុសគ្នាទៅនឹងថ្នាក់ដឹកនាំគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ដែលត្រូវតែមានតួនាទីបែបនេះ ដើម្បីការពារសន្តិសុខ និងប្រទេសជាតិរបស់ខ្លួន ។ ប្រទេសនានានៅលើពិភពលោក តែងតែមានច្បាប់ដើម្បីបម្រើនយោបាយ និងគ្រប់គ្រងប្រទេសរបស់គេ ។ ប្រសិនបើជនណាម្នាក់រំលោភច្បាប់ជននោះនឹងត្រូវទទួលទោសតាមច្បាប់នៃប្រទេសនោះ ។

**ក.២) ជាអនុប្រធានគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម (បច្ចុប្បន្នបក្សកុម្មុយនីស្តវៀតណាម)**

ចំពោះកិច្ចការទំនាក់ទំនងជាមួយប្រទេស និងប្រជាជនវៀតណាម គឺមានមកជាយូរយាណាស់មកហើយ ។ តែចាប់តាំងពីមានចលនា និងការកកើតបក្សកុម្មុយនីស្តកម្ពុជា ការទំនាក់ទំនងជាមួយវៀតណាមកាន់តែបានពង្រឹងថែមទៀត ដោយមានការចាត់តាំងជាគណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាម តាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់ភូមិភាគ ។ គណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាមថ្នាក់មជ្ឈិមមាន ប៉ុល ពត ជាប្រធាន ហើយខ្ញុំជាអនុប្រធានគណៈកម្មាធិការនេះ ។ តែដោយ ប៉ុល ពត មានកិច្ចការច្រើនដូច្នោះហើយ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានតែងតាំងខ្ញុំជាអនុ ប្រធានឲ្យទទួលខុសត្រូវកិច្ចការនេះជំនួស ប៉ុល ពត ។ នៅក្នុងឱកាសនោះហើយ ដែលខ្ញុំបានជួបប្រជុំជាមួយបក្សកុម្មុយនីស្តវៀតណាមជាញឹកញាប់ ។ ចាប់តាំងពីខ្ញុំទទួលកិច្ចការនេះ ខ្ញុំបានដឹងពីកលល្បិច និងកិច្ចការសម្ងាត់ជាច្រើនរបស់ប្រទេសវៀតណាម ដែលមានមកលើប្រទេសកម្ពុជាយើង ។ ខ្ញុំចាំបានថា នៅពេលខ្ញុំចូលបម្រើចលនាបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៥០ គឺមានវត្តមានកងទ័ពវៀតណាម (វៀតកុង) នៅទូទាំងប្រទេសកម្ពុជារួចជាស្រេចទៅហើយ ។ សមាសភាពនេះបានបង្កប់ខ្លួននៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ទាំងនៅក្នុងជួរកងទ័ពប្រជាជនបដិវត្តកម្ពុជា ក្នុងថ្នាក់ដឹកនាំស៊ីវិលកម្ពុជា និងក្នុងប្រជាជនកម្ពុជា ។

ខ្ញុំចាំបានថា នៅពេលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូង គឺមិនទាន់មានការិយាល័យ ឬទីបញ្ជាការទេ ។ បក្សកុម្មុយនីស្តកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាមទាំងស្រុង ។ តែនៅឆ្នាំ១៩៦៤ ប៉ុល ពត បានរំដោះបក្សចេញពីការគ្រប់គ្រងផ្តាច់ផ្តែងពីវៀតណាម ។ ប៉ុល ពត និងសមាជិកមជ្ឈិមបក្សមួយចំនួន បានទៅកសាងមូលដ្ឋានបង្អែករបស់ខ្លួន ដែលមានឈ្មោះថា “មន្ទីរ១០០” ។ ក្រោយមកមន្ទីរនេះបានចល័តទៅខេត្តរតនៈគិរី ។ ពេលនោះការិយាល័យនោះមិនទាន់មានសេរីភាពពេញលេញទេ ។ វៀតណាមដែលមានមូលដ្ឋានសឹកនៅភូមិភាគ៥នៃប្រទេសវៀតណាម បានខំរកគ្រប់វិធីដើម្បីក្តោបក្តាប់បក្សកុម្មុយនីស្តកម្ពុជាគ្រប់ពេលវេលា ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា ។

នៅទសវត្សរ៍ឆ្នាំ១៩៦០ វៀតណាមខាងជើងបានប្រើប្រាស់ប្រទេសកម្ពុជា ធ្វើជាមូលដ្ឋានសឹក ដើម្បីវាយប្រយុទ្ធជាមួយវៀតណាមខាងត្បូង (ធៀវគី) ។ នៅពេលជាមួយគ្នានេះដែរ ចលនាបក្សកុម្មុយនីសកម្ពុជា បានរីកដុះដាលយ៉ាងរហ័សបន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមសីហនុ ចេញពីដំណែង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលធ្វើឡើងដោយចក្រពត្តិអាមេរិក និងបនក្បត់ជាតិ លន់ នល់, សិរិមតៈ និង សឺង ង៉ុកថាញ់ ។ នៅពេលនេះហើយ កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ត្រូវបានបង្កើតឡើង ហើយរីកចម្រើនធំធាត់យ៉ាងឆាប់រហ័ស ។ នៅពេលនោះដែរ វៀតណាមបានជ្រើសរើសខ្មែរមួយចំនួនប្រហែលបីពាន់នាក់ឲ្យទៅរៀនសូត្រ និងទទួលការបំពាក់បំប៉នទាំងផ្នែកបច្ចេកទេស នយោបាយ និងសតិអារម្មណ៍ នៅប្រទេសវៀតណាមខាងជើង ។ នៅពេលពួកគេត្រឡប់មកប្រទេសកម្ពុជាវិញ នៅពាក់កណ្តាលឆ្នាំ១៩៧៣ អ្នកទាំងនោះត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ។

និយាយជារួម វៀតណាមខំប្រើគ្រប់ល្បិចកល ដើម្បីគ្រប់គ្រងចលនាបក្សកុម្មុយនីស្តកម្ពុជា ទាំងផ្នែកយោធា នយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល។ តែទោះជាយ៉ាងនេះក្តី អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មើលឃើញថា បក្សកុម្មុយនីស្តវៀតណាមធ្វើបែបនេះ គឺមិនសមស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ ។ នៅដើមឆ្នាំ១៩៧៣ ដោយការខិតខំតស៊ូរើបម្រាស់រំដោះខ្លួនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្ស និងដោយសង្គ្រាមនៅវៀតណាមខាងត្បូងកាន់តែប្រយុទ្ធសន្ធោរសន្ធៅ កងទ័ពវៀតណាមបានបន្ធូរចិត្តបន្ធូរដៃគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធ និងរដ្ឋអំណាចកម្ពុជា ហើយដកខ្លួនទៅប្រយុទ្ធជាមួយវៀតណាមខាងត្បូង ។ ពេលនោះហើយជាឱកាសមួយ ធ្វើឲ្យកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និង



គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងសម័យតស៊ូក្នុងទសវត្សរ៍
(បណ្ណសារ ៖ មជ្ឈម

បក្សកុម្មុយនីសកម្ពុជាកាន់តែមានឯករាជ្យភាព និងកម្លាំងរឹងមាំបន្ថែមទៀត ។ ខណៈនោះបក្សកុម្មុយនីស្តកម្ពុជាក្រោមការខិតខំរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្សបានអនុវត្តនូវគោលការណ៍ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា បានជ័យជម្នះលើរបប លន់ នល់ ហើយប្រហែលជាពីរអាទិត្យក្រោយមកវៀតណាមខាងត្បូង ក៏ត្រូវបានរំដោះផងដែរ ។

ទាក់ទងនឹងមហាជ័យជម្នះនេះ គឺប្រជាជនកម្ពុជា និងកងទ័ព ប្រជាជនបដិវត្តន៍កម្ពុជា បានរំដោះទីក្រុងភ្នំពេញដោយខ្លួនឯង ហើយបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាមានឯករាជ្យពេញលេញក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន ។ បើទោះជាបក្សកុម្មុយនីស្តវៀតណាមប្រកាសថា កងទ័ពវៀតណាមបានដក ឬឈប់គ្រប់គ្រងដោយផ្ទាល់លើចលនាបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងឆ្នាំ១៩៧៣ យ៉ាងណាក៏ដោយ តែការពិតកងកម្លាំងវៀតណាម និងភ្នាក់ងារសម្ងាត់របស់វៀតណាមជាច្រើន ដែលបានជ្រៀតចូលក្នុងជួរបក្ស



...៦០ រូបអនុស្សាវរីយ៍ពីឆ្វេងទៅស្តាំ នួន ជា, ប៉ុល ពត និង សោ ភឹម (...ណ្ឌលឯកសារកម្ពុជា)

និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាជាយូរមកហើយ នៅតាមមូលដ្ឋាននានាទូទាំងប្រទេសកម្ពុជា មិនបានត្រឡប់ទៅប្រទេសវៀតណាមវិញទេ ។ ពួកគេ បាននៅធ្វើការតាមរូបភាពចំហរខ្លះ និងសម្ងាត់ខ្លះជាមួយអនិកជនវៀតណាម និងប្រជាជនកម្ពុជា ។ ប្រការនេះ ដំបូងឡើយយើងពុំបានយល់ដឹងស៊ីជម្រៅចំពោះកលល្បិចរបស់វៀតណាមនោះទេ ។ ក្រោយមកយើងបានដឹងច្បាស់ពីឧបាយកលទាំងនោះ តាមរយៈភស្តុតាង៤យ៉ាងគឺ៖ ១) មានរបាយការណ៍ថា ប្រជាជនកម្ពុជា ត្រូវបានគេបង្អត់បាយ និងធ្វើការជាទម្ងន់នៅតាមមូលដ្ឋាន ។ ២) ប្រជាជនកម្ពុជាត្រូវបានគេសម្លាប់ ។ ៣) កម្មាភិបាលថ្នាក់ក្រោម មិនបានរាយការណ៍អំពីស្ថានភាពទាំងអស់នោះជូនថ្នាក់លើ និង៤) កងទ័ពរបស់យើងមួយចំនួនបានបង្កអរិភាព និងចុះចូលជាមួយវៀតណាម ជាពិសេសនៅភូមិភាគបូព៌ា ។ ទាំងអស់នោះហើយបង្ហាញយ៉ាងច្បាស់ថា វៀតណាមបានបង្កប់ភ្នាក់ងារសម្ងាត់របស់គេ នៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងគោលបំណងបំផ្លិចបំផ្លាញបដិវត្តកម្ពុជាសម្លាប់ប្រជាជន និងលេបយកទឹកដីនៃប្រទេសកម្ពុជា ដែលវៀតណាមមានមហិច្ឆតាជាយូរមកហើយ ។ ជាក់ស្តែងណាស់ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៤ វៀតណាមបានឈ្លានពានប្រទេសកម្ពុជានៅពេលដែលវៀតណាមបានកម្ទេចមូលដ្ឋានគ្រឹះរបស់បដិវត្តន៍កម្ពុជានៅតាមមូលដ្ឋានស្ទើរតែទាំងអស់ តាមរយៈការបង្អត់អាហារ ការកាប់សម្លាប់ប្រជាជន និងការបង្កើតឲ្យមានភាពមិនទុកចិត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ប្រទេសវៀតណាមបានគ្រប់គ្រងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១ នៅពេលប្រទេសកម្ពុជា មានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។ អំពើបង្អត់អាហារ និងការកាប់សម្លាប់ប្រជាជនកម្ពុជាទាំងអស់នោះ វាផ្ទុយស្រឡះពីទស្សនៈ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ផ្អែកលើមូលដ្ឋាននេះ ខ្ញុំសន្និដ្ឋានបានថា អំពើទាំងអស់នោះគឺជាអំពើរបស់បក្សកុម្មុយនីស្តវៀតណាមយ៉ាងពិតប្រាកដ ។

ខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាមានការឈឺចាប់ណាស់ នៅពេលដែលខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាបានដឹងថា បក្សកុម្មុយនីស្តកម្ពុជាចាញ់ល្បិចកលវៀតណាម ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លួនស្លាប់ ហើយប្រទេសជាតិធ្លាក់ចូលទៅក្នុងភាពអន្តរាយបែបនេះ ។ តែវាហាក់ដូចជាហួសពេលក្នុងការស្តារឡើងវិញទៅហើយ ។ នៅពេលប្រទេសវៀតណាមឈ្លានពានប្រទេសកម្ពុជា កិច្ចការទូតរវាងប្រទេសទាំងពីរត្រូវបានកាត់ផ្តាច់ ។ កិច្ចការការពារជាតិ និងការបញ្ជាកម្លាំងប្រយុទ្ធ បានធ្លាក់ទាំងស្រុងទៅលើ សុន សេន ដែលជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ។ ពេលនោះហើយ ដែលតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការទំនាក់ទំនង

ជាមួយគណបក្សពលករវៀតណាម (គណបក្សកុម្មុយនីស្តវៀតណាម) ត្រូវបានបញ្ចប់ទាំងស្រុង ។

### ក.៣) ជាប្រធានសភាតំណាងប្រជាជនកម្ពុជា

គោរពតុលាការ! ក្រោយពេលរំដោះនៅថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំត្រូវបានជ្រើសឲ្យធ្វើជាប្រធានសភាតំណាងប្រជាជនកម្ពុជា ។ តាមផ្លូវច្បាប់ នៅក្នុងតួនាទីនេះ ខ្ញុំទទួលខុសត្រូវក្នុងការអនុម័តច្បាប់ ។ នៅពេលនោះ ដោយសារប្រទេសកម្ពុជាទើបតែចប់សង្រ្គាម ហើយក៏មានសង្រ្គាមបន្តជាមួយវៀតណាមទៀតនោះ ក្នុងរយៈពេលខ្លីបែបនេះ យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើច្បាប់ច្រើននោះទេ ។ ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិស្ថិតនៅក្នុងស្ថានភាពបែបនេះ កិច្ចការច្បាប់គឺមិនមែនជាកិច្ចការជាអាទិភាពនោះដែរ ។ តាមទ្រឹស្តីនៃរបបកុម្មុយនីស្ត ការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាប្រទេសកុម្មុយនីស្តផ្សេងៗទៀតដែរ គឺមានបក្សដឹកនាំ និងរដ្ឋគ្រប់គ្រងប្រទេស ។ ក្នុងន័យនេះ បក្សផ្តល់ជាគោលការណ៍សម្រាប់ដឹកនាំចំណែករដ្ឋវិញ គឺសំដៅទៅលើរដ្ឋាភិបាល ឬនីតិប្រតិបត្តិ ដែលជាអ្នកមានអំណាចគ្រប់គ្រងប្រទេសទាំងមូល ។ និយាយឲ្យចំទៅមានតែរដ្ឋាភិបាលទេ ដែលមានអំណាចពេញលេញ ក្នុងការបញ្ជា ឬអនុវត្តរាល់សកម្មភាពការងារទាំងឡាយក្នុងការគ្រប់គ្រងប្រទេស ។ នៅក្នុងសម័យកាលនោះ បើទោះបីជាមានការបែងចែកអំណាចជាពាគឺ នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ ដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏វាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ។ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ មិនបានដំណើរការពេញលេញទេ ។ ជាក់ស្តែង មានតែនីតិប្រតិបត្តិទេ ដែលបានដំណើរការងារពេញលេញ ហើយ ប៉ុល ពត បានទទួលតំណែងជានាយករដ្ឋមន្ត្រី ។ ដូច្នោះហើយ ប៉ុល ពត មានអំណាចជារួមក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស ទាំងនៅក្នុងជួរបក្ស និងនៅក្នុងរដ្ឋាភិបាល ដោយសារគាត់ជាលេខាបក្ស និងជានាយករដ្ឋមន្ត្រី ។ នៅក្នុងតួនាទីនេះ គ្មាននរណាម្នាក់អាចជំនួសគាត់បានឡើយ ។ ផ្អែកលើមូលដ្ឋាននេះ បញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានអំណាចអ្វីបន្តិចក្នុងការគ្រប់គ្រង និងប្រតិបត្តិការងារនៃនីតិប្រតិបត្តិឡើយ ។

### ក.៤) ការចោទប្រកាន់ចំពោះមុខតំណែងផ្សេងៗទៀត

ខ្ញុំសូមបញ្ជាក់ថា ក្រៅពីតួនាទីខាងលើ ខ្ញុំមិនដែលបានទទួលតួនាទីអ្វីទៀតទេ ។ ខ្ញុំមានចម្ងល់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទី ជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១ ។ ការចោទប្រកាន់បែបនេះ បើទោះជាមានចេតនា ឬអចេតនាក៏ដោយ វាជាការនិយាយខុសពីការពិតទាំងស្រុង ហើយពុំមាន ភស្តុតាងជាក់លាក់ផងដែរ ។ ប៉ុល ពត គាត់មានឧបនាយករដ្ឋមន្ត្រីរបស់គាត់ គឺលោក អៀង សារី លោក សុន សេន និងលោក វ៉ន វ៉េត ។ ដូចនេះ វាគ្មានហេតុផលអ្វីដែល ប៉ុល ពត តែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទី ក្រៅពីឧបនាយករដ្ឋមន្ត្រីរបស់គាត់នោះទេ ។ ជាការពិតណាស់ គាត់មិនអាចតែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៅពេលគាត់អវត្តមានពីប្រទេសនោះទេ ពីព្រោះខ្ញុំមិនមែនតួនាទីណាមួយក្នុងអំណាចនីតិប្រតិបត្តិទាល់តែសោះ ។ ប្រសិនបើគាត់ធ្វើបែបនេះ វាជាអំពើខុសច្បាប់របស់បក្ស ។

ចំពោះការចោទថា ខ្ញុំធ្វើជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងជាប់ទាក់ទងទៅនឹងការគ្រប់គ្រងមន្ទីរស-២១ នោះក៏ជារឿងមិនពិតដែរ ។ ជាការពិតណាស់ ខ្ញុំមិនដែលបានធ្វើកិច្ចការទាំងនេះទេ កិច្ចការទាំងអស់នោះ លោក សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់ ។ ខ្ញុំមិនដែលបានដួប មិនដែលគ្រប់គ្រង ឬមិនបានបញ្ជាឌុច ឲ្យធ្វើបាប ឬសម្លាប់មនុស្សនោះទេ ។ អស់លោកគួរតែជ្រាបហើយសារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការផ្ទាល់របស់ខ្លួននោះទេ ។ ដូច្នេះ គ្មានហេតុផលអ្វីដែលឌុច ស្តាប់ខ្ញុំនោះទេ ។ និយាយដោយត្រង់ទៅ ខ្ញុំទើបតែឮឈ្មោះ ឌុច នៅក្រោយឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ សម្តីរបស់ ឌុច ដែលបានចោទខ្ញុំថា បានគ្រប់គ្រងមន្ទីរស-២១នោះ គឺគាត់គ្រាន់តែចង់គេចពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ និងមានបំណងចង់ឲ្យខ្ញុំទទួលទោសអស់មួយជីវិតដូចគាត់ដែរ ដោយសារ សុន សេន បានស្លាប់ ហើយ ឌុច ត្រូវបានតុលាការផ្តន្ទាទោសអស់មួយជីវិតទៅហើយ ។ មនុស្សដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ មិនដែលនិយាយការពិតនោះទេ ដោយសារ

គាត់មានកំហឹងពេញខ្លួន និងអស់សង្ឃឹមក្នុងជីវិត ។ នេះគឺជាហេតុផលជាក់លាក់ ដែលគាត់ឆ្លើយទម្លាក់កំហុសមកលើខ្ញុំ ។

និយាយជារួមចំណុចទាំងនេះ មេធាវីរបស់ខ្ញុំបានបញ្ជាក់ជូនលោក លោកស្រីចៅក្រមច្បាស់លាស់រួចមកហើយថា ខ្ញុំមិនបានបំពេញកិច្ចការនេះទាល់តែសោះ ហើយក៏គ្មានឯកសារណាមួយជាក់លាក់បញ្ជាក់ពីរឿងនេះដែរ ។ ផ្អែកលើមូលដ្ឋានទាំងអស់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំគ្មានអំណាច និងមិនមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំង ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ ។ ដូច្នេះ តើមានហេតុផលអ្វីដែលខ្ញុំអាចបញ្ជា បញ្ចុះបញ្ចូល ឬទប់ស្កាត់មិនឲ្យជនល្មើសប្រព្រឹត្តបទល្មើសបាននៅក្នុងសម័យនោះ? សូមលោក លោកស្រី ចៅក្រមពិចារណា!

ខ្ញុំសូមអះអាងយ៉ាងឱឡារិកថា អ្វីដែលខ្ញុំបានចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមានបំណងចង់រំដោះប្រទេសជាតិពីអាណានិគមនិយមបារាំង និងការពារទឹកដី ការឈ្លានពានពីប្រទេសជិតខាង ដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយ ។ ខ្ញុំស្រឡាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានបំណង និងចេតនាណាមួយធ្វើបាប កាប់សម្លាប់ ឬប្រល័យពូជសាសន៍ឯងនោះទាល់តែសោះ ។

### ១) ការគ្មានភស្តុតាងគ្រប់គ្រាន់នៅក្នុងបទចោទ

### ១.១) ការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

ករណីនេះខ្ញុំសូមបញ្ជាក់ដោយស្មោះត្រង់ថា ខ្ញុំមិនដែលបានដឹងថាអតីតទាហាន លន់ នល់ ត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃទេ ។ ក្រោយពេលរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បើតាមខ្ញុំដឹងបក្សកុម្មុយនីស្តកម្ពុជាមិនដែលបានបង្កើតគោលនយោបាយឲ្យកងកម្លាំងរបស់ខ្លួនកាប់សម្លាប់អតីតទាហាន លន់ នល់ ឬប្រជាជនទេ ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះឈ្លើយសឹក គឺសណ្តោសប្រណី និងលើកលែងទោសពីព្រោះអ្នកទាំងនោះត្រូវគេចាប់បង្ខំមកឲ្យធ្វើទាហានសម្រាប់ មកប្រយុទ្ធស្លាប់ជំនួសគេ ហើយពួកគេជាកូនចៅរបស់ប្រជាជននៅក្នុងមូលដ្ឋាន រំដោះរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាគោលការណ៍ការធ្វើបដិវត្តន៍គឺប្រមូលកម្លាំង ។ បើយើងសម្លាប់អ្នកទាំងនោះដូចការចោទប្រកាន់ គឺខុសពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយរុញច្រានឪពុកម្តាយ បងប្អូនរបស់ពួកគេឲ្យទៅនៅជាមួយខ្មាំង បន្ថែមកម្លាំងឲ្យខ្មាំង ឬឲ្យគេងាកមកប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជាវិញទេ ។ តែទោះជាមានការកាប់សម្លាប់អតីតទាហាន លន់ នល់ ពិតមែន ក៏នេះគឺជាការសម្រេចចិត្តរបស់មន្ត្រីថ្នាក់ក្រោម ដែលបានប្រព្រឹត្តអំពើខុសឆ្គង ធ្វើតាមទំនើងចិត្តរបស់ខ្លួន ឬប្រហែលជាមានបំណងសងសឹក និងការគុំគួនគ្នានៅពេលធ្វើសង្គ្រាម ។ ទាក់ទងនឹងករណីនេះ មានសាក្សីមួយចំនួនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការថា ទាហានខ្មែរក្រហមប្រមូលអតីតទាហាន លន់ នល់ មកជួបប្រជុំនៅសាលាខេត្តពោធិ៍សាត់ប្រហែលជាមួយអាទិត្យក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ។ សាក្សីទាំងនោះផ្តល់សក្ខីផ្ទុយគ្នា សូម្បីតែចម្លើយរបស់គាត់ទៅចៅក្រមស៊ើបសួរ និងនៅសវនាការក៏ខុសគ្នាដែរ ។ ដូចជាសាក្សីឈ្មោះ លឹម សាត បានផ្តល់ចម្លើយទៅចៅក្រមស៊ើបសួរថា ទាហាន លន់ នល់ ដែលចូលរួមប្រជុំនៅសាលាខេត្តពោធិ៍សាត់ និងក្រោយមកត្រូវយកទៅសម្លាប់ មានចំនួនប្រហែលបីពាន់នាក់ ។ អ្នកទាំងនោះ ត្រូវបានដឹកតាមឡានចំនួន ២០ ទៅ ៣០ ឡាន ហើយក្នុងមួយឡានដាក់មនុស្សប្រហែល ៣០ នាក់ ។ នៅពេលសវនាការសាក្សី លឹម សាត ឆ្លើយថា ទាហាន លន់ នល់ នោះ មានចំនួនពីរពាន់នាក់ខ្វះបន្តិចបន្តួចប៉ុណ្ណោះ ដឹកតាមឡានពី ១០ ទៅ ១៥ ឡាន ។ សាក្សីឈ្មោះ អ៊ុង ឆាត់ បានឆ្លើយនៅក្នុងសវនាការថា ទាហាន លន់ នល់ ដែលប្រជុំនៅសាលាខេត្តពោធិ៍សាត់ មានចំនួន២០០នាក់ ក្រោយមកថាមានចំនួនពី១០០ ទៅ ១៥០ នាក់ទៅវិញ ហើយខ្សែវីដេអូរបស់ ថេត សម្បត្តិ ដែលមានចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" មានសាក្សីថា ទាហាន លន់ នល់ ដែលត្រូវយកទៅសម្លាប់នោះ មានចំនួនប្រហែល១ម៉ឺននាក់ ។ លើសពីនេះ មានសាក្សីខ្លះទៀតឆ្លើយថា គេបានលួចចូលទៅមើល ហើយឃើញខ្មោចនៅពេញវាលដោយគ្មានសម្លៀកបំពាក់យោធា ឬសាក់កាដូយោធាទេ ។ តែសាក្សីខ្លះអះអាងថា មានសាក់កាដូនៅទីនោះច្រើនណាស់ ។ សូមសាធារណជន លោក លោកស្រី ចៅក្រម និងដាក់ចម្ងល់បន្តិចមើល! នៅក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះ តើមានហេតុផលអ្វីដែលប្រជាជនទាំងនោះ ប្រថុយនឹងគ្រោះថ្នាក់ដល់ជីវិតសុខចិត្តលួចចូលទៅមើលសាកសពទាំងនោះ ។ ប្រសិន

បើមានសម្លាប់មនុស្សមែននោះ ខ្ញុំជឿថាកន្លែងនោះជា តំបន់គ្រោះថ្នាក់ មនុស្សយើងធម្មតាមិនហានទៅទីនោះទេ ។ នៅពេលចៅក្រមស្តាប់ចម្លើយសាក្សីទាំងនោះ តើសាក្សីទាំងអស់នោះគួរជឿ និងយកជាសក្ខីកម្មត្រឹមត្រូវបានឬទេ? ចម្លើយគឺថា មិនអាចឲ្យជឿ និងយកជាការណ៍បាននោះទេ ដោយសារសក្ខីកម្មរបស់សាក្សីទាំងអស់នោះ ពោរពេញទៅដោយចំណុចមន្ទិលសង្ស័យ និងភូតកុហក ។ ខ្ញុំសួរថានៅពេលនោះ ក្នុងនាមជាអ្នកដឹកនាំម្នាក់ តើមានពេលវេលាឯណាសម្រាប់គិតគូរពីបញ្ហានេះ? ពួកយើងមានកិច្ចការរួមសំខាន់ៗ និងបន្ទាន់ជាច្រើននៅទីក្រុងភ្នំពេញ ជាពិសេសនៅអំឡុងពេល ២ ឬ៣ខែដំបូង ។ បញ្ហាសំខាន់គឺ ដោះស្រាយជីវភាពរបស់ប្រជាជន និងការពារជាតិឲ្យផុតពីការប៉ុនប៉ងគ្រប់គ្រងពីបក្សកុម្មុយនីស្តវៀតណាម និងពីគូបដិបក្ខ ។

លើសពីនេះទៀត ខ្ញុំសូមឆ្លើយតបចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា បក្សកុម្មុយនីស្តកម្ពុជា បានប្រើប្រាស់ហិង្សាបដិវត្តតាំងពីមុនឆ្នាំ១៩៧៥ ។ ការអះអាងនេះវាហាក់ដូចជាមើលព្រឹត្តិការណ៍ប្រទេសកម្ពុជាតែជ្រុងម្ខាង ឯជ្រុងម្ខាងទៀត ធ្វើជាមិនដឹង និងឃើញ ឬធ្វើមិនឮ ។ បើនិយាយភាសានៅក្នុងតុលាការវិញ គេថា យុត្តិធម៌សម្រាប់តែអ្នកឈ្នះ ។ សូមកុំភ្លេចថា មុនពេលសម្រេចចិត្តតស៊ូដោយអាវុធក្នុងបុព្វហេតុរំដោះប្រទេសជាតិ សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនជាច្រើនរូប ត្រូវបានគេលួចសម្លាប់ ចាប់ខ្លួន ធ្វើទារុណកម្មដោយគ្មានហេតុផល និងបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ ព្រឹត្តិការណ៍នោះប្រជាពលរដ្ឋគ្រប់រូប គួរតែនៅចងចាំនៅឡើយ ។ អំពើហិង្សាទាំងនោះ បានកើតមានគ្រប់ជំនាន់ក្នុងសង្គមខ្មែរ ហើយជនរងគ្រោះនៃព្រឹត្តិការណ៍ទាំងនោះ សុទ្ធសឹងជាកសិករក្រីក្រ និងជនស្លូតត្រង់ ។

ខ្ញុំសូមចាប់ផ្តើមពីសម័យអាណានិគមនិយមបារាំង ។ បារាំងបានធ្វើអាណានិគម មកលើប្រទេសកម្ពុជាអស់រយៈពេលជិតមួយសតវត្សរ៍ ។ អ្នកកាន់អំណាចនាសម័យនោះ បានប្រើហិង្សាដោយតាមចាប់ខ្លួន និងកាប់សម្លាប់ប្រជាជនកសិករដែលគ្មានអាវុធ នៅភូមិក្រាំងលាវ ក្នុងខេត្តកំពង់ឆ្នាំង ដែលពួកគាត់ពុំមានលទ្ធភាពបង់ពន្ធដា ត្រូវបង្ខំចិត្តតវ៉ា និងទាមទារយុត្តិធម៌ ។ ចុងក្រោយអ្នកចាញ់គឺកសិករក្រីក្រ ហើយភូមិរបស់ពួកគាត់ត្រូវបានគេប្តូរឈ្មោះទៅជាភូមិតិរច្ឆាន ។ តើនេះមិនមែនជាហិង្សាទេឬ?

នៅសម័យសង្គមរាស្ត្រនិយម ពួកអ្នកមានអំណាច បានទៅឈូសឆាយ ផ្ទះសម្បែង ស្រែចម្ការរបស់កសិករនៅសំឡូត ។ល ។ ពួកគេបានរំលោភបំពានយកដីពីប្រជាកសិករ ដែលធ្លាប់បានរស់នៅទីនោះតកូន តចៅរាប់ជំនាន់មកហើយនោះ ។ នៅពេលដែលប្រជាជនតវ៉ាដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគាត់ ទាហានបានបាញ់សម្លាប់ប្រជាជនដែលគ្មានអាវុធយ៉ាងរង្គាល ទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី ។ ឈឺចាប់ជាងនេះ ពួកគេតាមកាប់សម្លាប់ប្រជាជនជាច្រើនទៀត ដែលហេតុធ្វើឲ្យប្រជាជនមានការភ័យខ្លាច និងរត់ចូលព្រៃ ។ តែអ្នកមានអំណាចបានចោទប្រកាន់ប្រជាជនម្ចាស់ទឹកម្ចាស់ដីទាំងនោះថា ជាខ្មែរក្រហម ។ តើនេះមិនមែនជាការបង្កើតហិង្សា និងធ្វើឲ្យឈឺចាប់ទេឬ?

នៅក្នុងសម័យ លន់ នល់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក ពួកទាហាន លន់ នល់ បានរំលោភស្រ្តីប្លន់យកទ្រព្យសម្បត្តិ កាប់សម្លាប់ប្រជាជននៅគ្រប់ទីកន្លែង និងកាត់ក្បាលមនុស្សដោតតាមរបងផ្ទះ ដោយគ្រាន់តែសង្ស័យថា ប្រឆាំងនឹងរបបរបស់ខ្លួន និងយកលេសថា ប្រជាជនរងគ្រោះទាំងនោះជាខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ពួក លន់ នល់ បានប្រព្រឹត្តិជាប្រព័ន្ធនូវអំពើរំលោភស្រ្តីភេទ ប្លន់ទ្រព្យសម្បត្តិ ជម្លៀសដោយហិង្សាចេញពីផ្ទះសម្បែង កាប់សម្លាប់យ៉ាងរង្គាលលើអនិកជនវៀតណាមនៅគ្រប់ទីកន្លែង ។ លើសពីនេះ អាមេរិកផ្ទាល់បានទម្លាក់គ្រាប់បែកជាច្រើនតោន មកលើភូមិករផ្ទះសម្បែង វត្តអារាម ស្រែចម្ការរបស់កសិករកម្ពុជា សម្លាប់ជនស៊ីវិល មានទាំងកុមារ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ និងជនពិការអស់រាប់ម៉ឺននាក់ ។ តើនេះមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេឬ?

នៅក្នុងឆ្នាំ១៩៧៩ វៀតណាមបានចូលឈ្លានពាន និងកាន់កាប់ប្រទេសកម្ពុជា ហើយនៅឆ្នាំបន្តបន្ទាប់មក ពួកគេបានបាញ់ផ្លោងដាក់ជំរុំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ធ្វើឲ្យឆេះលំនៅដ្ឋាន ទ្រព្យសម្បត្តិ បាត់បង់ជីវិតមនុស្សរាប់សិបនាក់ ក្នុងនោះមានទាំងកុមារ ស្ត្រីភេទ មនុស្សចាស់ជរា និងជនពិការផង

ដែរ ។ លើសពីនេះ ពួកគេបានរៀបចំ “ផែនការក-៥” ដោយចាប់បង្ខំប្រជាជនស៊ីវិលឲ្យចូលព្រៃ ជញ្ជូនគ្រាប់រំសេវ ជីកលានដ្ឋាន ដើម្បីការពារអំណាចដែលបានមកពីការឈ្លានពាន ដែលបណ្តាលឲ្យប្រជាជនស្លាប់អស់រាប់ម៉ឺននាក់ ។ តើទាំងនេះ មិនមែនជាឧក្រិដ្ឋកម្មទេឬ? មិនមែនជាផែនការសម្លាប់មនុស្សទេឬ?

នៅក្នុងឆ្នាំ១៩៩៧ គេបានប្រយុទ្ធគ្នាក្នុងទីក្រុងភ្នំពេញ ដើម្បីដណ្តើមអំណាចគ្នា បណ្តាលឲ្យឆេះផ្ទះសម្បែង ទ្រព្យសម្បត្តិរបស់ប្រជាជន ស្លាប់ជនស៊ីវិល ហើយឈ្លើយសឹកមួយចំនួនរបស់ទាហានហ៊ុនសិនប៊ិច ត្រូវបានគេបាញ់សម្លាប់ក្រោយពេលពួកគេចុះចាញ់ ។


កងចល័តយុវជនកំពុងលើកទំនប់ក្នុងរបបខ្មែរក្រហមនៅតំបន់ជើងឯក ជាយទីក្រុងភ្នំពេញ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឧទាហរណ៍ លោក ហ៊ូ សុក ត្រូវបានគេសម្លាប់នៅក្នុងបរិវេណក្រសួងមហាផ្ទៃ នៅពេលចាប់បានជាចំណាប់ខ្មាំង ។ តើនេះមិនមែនជាហិង្សា ឬបទល្មើសឧក្រិដ្ឋទេឬ? តើព្រឹត្តិការណ៍ទាំងអស់ដែលខ្ញុំបានលើកឡើងនេះ មិនមែនជាហិង្សា ឬឧក្រិដ្ឋកម្ម ជាអំពើអមនុស្សធម៌ទេឬ?

ទាំងអស់នេះអាចជាសក្ខីភាព អាចជាសក្ខីភាពមួយ សម្រាប់ធ្វើការប្រៀបធៀប ទៅនឹងស្ថានភាពនៃបក្សកុម្មុយនីស្តកម្ពុជា ។ ប្រសិនបើចោទប្រកាន់ថា មុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានប្រើហិង្សាចុះហេតុអ្វីសហព្រះរាជអាជ្ញាមិនព្រមផ្តល់សច្ចភាពបន្តិចបន្តួច ដោយគ្រាន់តែលើកពីអំពើខុះស្រាលៗ ដែលភាគីម្ខាងទៀតបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។ ខ្ញុំមើលឃើញថា សហព្រះរាជអាជ្ញាបានខិតខំលើកយកការកាប់សម្លាប់គ្នាទៅវិញទៅមកក្នុងដំណាក់កាលធ្វើសង្គ្រាម មកភ្ជាប់ជាមួយព្រឹត្តិការណ៍កាប់សម្លាប់ក្រោយបញ្ចប់សង្គ្រាមភ្លាមៗ ដើម្បីបង្ហាញអង្គជំនុំជម្រះថា នេះជាផែនការ ធ្វើឡើងជាប្រព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ការភ្ជាប់ស្ថានភាពបែបនេះ មិនយុត្តិធម៌ទេ ដោយហេតុផល បើចាត់ទុកការកាប់សម្លាប់គ្នាក្នុងពេលធ្វើសង្គ្រាមថាជាផែនការធ្វើឡើងជាប្រព័ន្ធ ហេតុអ្វីមិនចោទប្រកាន់លើគូបដិបក្ខម្ខាងទៀតនៃសង្គ្រាមផងទៅ? ជាការពិតណាស់ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផែនការធ្វើសង្គ្រាម ដើម្បីរំដោះប្រទេសជាតិពីភាពអន្តរាយ ។ យុទ្ធសាស្ត្រប្រយុទ្ធសម្រាប់សត្រូវ ពិតជាត្រូវបានប្រើប្រាស់ ដើម្បីទទួលបានជ័យជម្នះ ។ ការធ្វើបែបនេះ ខ្ញុំគិតថាវាមិនមែនជាការខុសច្បាប់ទេ ។ ប្រជាជននៃប្រទេសជាច្រើននៅលើពិភពលោក បានវាយប្រយុទ្ធគ្នាប្រឆាំងនឹងរដ្ឋាភិបាលរបស់ខ្លួនសម្រាប់បុព្វហេតុអ្វីមួយដែលគេគិតថា អ្វីដែលកើតឡើងមកលើពួកគេ ជាការមិនត្រឹមត្រូវ និងទាមទារឲ្យមានការផ្លាស់ប្តូរ ។ ជាពិសេស ការទាមទារសិទ្ធិ ស្វ័យសម្រេចទៅលើជោគវាសនា

ប្រទេសជាតិខ្លួន ។ ខ្ញុំសូមផ្តល់ឧទាហរណ៍ខ្លះៗ ដូចជា ប្រទេសសិរីលង្កា ប្រទេសស៊ីរី ប្រទេសលីប៊ី ប្រទេសវៀតណាម និងប្រទេសអ៊ីរ៉ាក់ ។ល ។ ប្រទេសទាំងអស់នោះសុទ្ធតែធ្លាប់ប្រយុទ្ធគ្នា ។ នៅពេលប្រយុទ្ធបែបនេះ ក្រុមមនុស្សទាំងនោះ សុទ្ធសឹងតែមានផែនការ ដើម្បីកម្ទេចសត្រូវរបស់ខ្លួនទៅវិញទៅមក ។ ប្រសិនបើតុលាការចាត់ទុកថា ការធ្វើផែនការប្រយុទ្ធនៅពេលធ្វើសង្គ្រាមរបស់ភាគីដើម្បីទទួលជ័យជម្នះ ជាចេតនាប្រព្រឹត្តបទល្មើសដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់មែននោះ ម៉្លេះសមមេដឹកនាំនៃប្រទេសទាំងអស់នោះ មិនថា រាជរដ្ឋាភិបាល ឬក្រុមប្រឆាំងទេ ត្រូវតែយកមកកាត់ទោសដូចគ្នា ជាពិសេស សហរដ្ឋអាមេរិក វៀតណាម រួមទាំងមេដឹកនាំខ្មែរដទៃទៀតផង ។ កុំយកតែខ្លួនក្រពើមកកាត់ទោស តែក្បាល និងកន្ទុយ ទុកនៅដោយឡែករួចពីសំណាញ់ច្បាប់ ។ នេះជារឿងអយុត្តិធម៌ណាស់ចំពោះរូបខ្ញុំ ។ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមញែកឲ្យដាច់ពីគ្នា រវាងផែនការវាយរំដោះទឹកដីទៅនឹងផែនការសម្លាប់មនុស្សនៅក្រោយសង្គ្រាម ។ ចំណុចទាំងពីរនេះ មានភាពខុសគ្នាស្រឡះ ផែនការប្រយុទ្ធគ្នា ឬកម្ទេចសត្រូវ ត្រូវបានបញ្ចប់នៅពេលបញ្ចប់សង្គ្រាម ។ ចំណែកចេតនាសម្លាប់មនុស្ស វាជាដំណាក់កាលថ្មីនៃអ្នកកាន់អំណាច នៅពេលដែលពួកគេបានទទួលមុខដំណែងក្នុងការគ្រប់គ្រងប្រទេស ។ ម្យ៉ាងវិញទៀត ខ្ញុំចាំបានថា តុលាការនេះបានកំណត់វិសាលភាពនៃការកាត់ទោសចំពោះតែអំពើទាំងឡាយណាដែលកើតឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ប៉ុណ្ណោះ ។ បើទោះជាខ្ញុំមិនចេះច្បាប់ក៏ដោយ ក៏ខ្ញុំយល់ថា ការអះអាងរបស់លោក លោកស្រីសហព្រះរាជអាជ្ញា អំពីសកម្មភាពរបស់ខ្ញុំនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពិតជាអំណះអំណាងខុសច្បាប់ និងគ្មានតម្លៃតាមផ្លូវច្បាប់ ។ ជារួម ការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញា ពីអំពើហិង្សាបដិវត្តន៍នៅមុនថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ ដើម្បីធ្វើជាមូលដ្ឋានច្បាប់សម្រាប់បន្ត្រប់ធាតុផ្សំនៃបទល្មើស ក្នុងគោលបំណងដាក់ទោសចំពោះរូបខ្ញុំនោះ គឺពិតជាមិនត្រឹមត្រូវទេ ។ សូមលោក លោកស្រីចៅក្រមបដិសេធចោលចំពោះការអះអាងនេះ ។

### ១.(២) ការជម្លៀសប្រជាជន

ដូចខ្ញុំបានជម្រាបជូនអង្គសវនាការរួចមកហើយកាលពីប៉ុន្មានឆ្នាំមុននេះ ក្រោយថ្ងៃរំដោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥



ប្រជាជនត្រឡប់ទៅលំនៅដ្ឋានវិញក្រោយរបបខ្មែរក្រហមដួលរលំ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនទាំងអស់ដែលបានរស់នៅក្នុងទីក្រុងនានា ត្រូវបានជម្លៀសចេញពីទីក្រុងពិតមែន ។ តែការជម្លៀសនេះ មិនមែនជាការជម្លៀសដោយបន្ទំនោះទេ ។ មានហេតុផលពីរយ៉ាងដែលថ្នាក់ដឹកនាំបានបន្ទំចិត្តខ្លួនឯងធ្វើសេចក្តីសម្រេចបែបនេះ ។

ហេតុផលទី១ ៖ គឺដោយសារមានការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុងក្រោយរដ្ឋាភិបាល លន់ នល់ បានទទួលបរាជ័យ ។ ចំណុចនេះ វាជាមូលហេតុដែលធ្វើឲ្យថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋខ្មែរជឿបានថា នឹងមានយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាជាថ្មីទៀតនៅតាមក្រុងនានា ជាពិសេស នៅទីក្រុងភ្នំពេញ ព្រោះសហរដ្ឋអាមេរិកធ្លាប់ទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាជាច្រើនតោនកន្លងមកហើយ ។

ហេតុផលទី២ ៖ គឺថា ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាង ៥ឆ្នាំមកហើយ ។ តាមរយៈសង្គ្រាមនេះ ប្រទេសកម្ពុជាបានជួបប្រទះបញ្ហាប្រឈមជាច្រើន រួមទាំងស្បៀងអាហារផងដែរ ។ ករណីស្បៀងអាហារវាជាបញ្ហាមួយសំខាន់ ដែលត្រូវដោះស្រាយជាបន្ទាន់ ព្រោះវាទាក់ទងនឹងអាយុជីវិតរបស់ប្រជាជន ។ នៅពេលនោះ ប្រទេសកម្ពុជាក៏មិនមានជំនួយពីបរទេសដែរ ។ ស្ថិតនៅក្នុងកាលៈទេសៈបន្ទាន់បែបនេះ ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំផែនការជម្លៀសប្រជាជនឲ្យទៅតាមតំបន់ និងខេត្តណាដែលមានធនធានសេដ្ឋកិច្ច ស្រូវ អង្ករ អាចចិញ្ចឹមប្រជាជនបាន និងទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯង សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ និងកសាងប្រទេសជាតិ ។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គណៈអចិន្ត្រៃយ៍បានសម្រេចឲ្យមជ្ឈិមបក្សកោះប្រជុំ ដើម្បីរៀបចំផែនការជម្លៀស ។ គ្រប់លេខាភូមិភាគដែលជាសមាជិកគណៈមជ្ឈិមបក្ស បានចូលរួមកិច្ចប្រជុំនេះ ។ ពេលនោះ ខ្ញុំចាំបានថា គ្រាន់តែភូមិភាគពាយ័ព្យបានធានាទទួលយកប្រជាជនចំនួន ១លាន ៥សែននាក់ ហើយភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគកណ្តាល បានធានាទទួលយកប្រជាជនដែលនៅសេសសល់ ។ ក្នុងផែនការនោះ គឺឲ្យភូមិភាគនីមួយៗមានស្វ័យភាពក្នុងការជួយសម្រួលគ្នាទៅវិញទៅមកទាក់ទងនឹងការជម្លៀសនេះ និងត្រូវណែនាំដល់សហករណ៍ឲ្យខិតខំដោះស្រាយជីវភាពប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយកុំឲ្យមានការរើសអើងចំពោះប្រជាជនទាំងនោះផងដែរ ។

ទោះជាមានហេតុផលទាំងពីរនេះក្តី ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ គ្មានប្រើអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ ។ ប្រការនេះត្រូវបានអនុវត្តតាមរយៈការពន្យល់ប្រជាជនឲ្យបានដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង ។ នៅពេលនោះ ប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និងតម្រូវការចាំបាច់របស់ប្រទេសជាតិ ជាពិសេសប្រជាជនបានគាំទ្រ និងស្រឡាញ់បដិវត្តន៍ ។ ដូច្នេះហើយ ប្រជាជនបានចាកចេញពីទីក្រុងជាបណ្តើរៗតាមការអំពាវនាវ និងការពន្យល់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ទាក់ទងនឹងចំណុចនេះ ខ្ញុំសូមបំភ្លឺចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ លោក លោកស្រីសហព្រះរាជអាជ្ញាបានចោទប្រកាន់ចំពោះការហ៊ុំព័ទ្ធទីក្រុងភ្នំពេញ ដែលបណ្តាលឲ្យមានវិបត្តិស្បៀងអាហារ និងការបាញ់ផ្លោងចូលក្នុងទីក្រុង ទីតាំងជាមូលដ្ឋានបង្អែករបស់ លន់ នល់ ក្នុងទីក្រុងភ្នំពេញ ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាថា នេះជាអំពើអមនុស្សធម៌ ។ ចុះសហព្រះរាជអាជ្ញាធ្លាប់បានគិតទេ ថា ពួក លន់ នល់ បានបាញ់ផ្លោងដោយកាំភ្លើងធំដែលសហរដ្ឋអាមេរិកផ្តល់ឲ្យអស់រាប់លានគ្រាប់ និងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកច្រើនជាងកន្លះលានតោន បំផ្លាញផ្ទះសម្បែង វត្តអារាម ទ្រព្យសម្បត្តិ ស្រែចម្ការ សត្វពាហនៈរបស់ប្រជាជន ។ ជាពិសេស បណ្តាលឲ្យស្លាប់មនុស្សរាប់សិបម៉ឺននាក់ មានទាំងចាស់ជរា ទាំងកុមារ ទាំងស្ត្រីភេទ តើនេះមិនមែនជាអំពើអមនុស្សធម៌ ឬជាឧក្រិដ្ឋកម្មទេ ឬ? គ្រាប់បែករបស់សហរដ្ឋអាមេរិកដែលបានទម្លាក់មកលើប្រទេសកម្ពុជាមានចំនួនច្រើនជាង ៣ដងនៃគ្រាប់បែកដែលសហរដ្ឋអាមេរិកបានទម្លាក់លើប្រទេសជប៉ុន ក្នុងសង្គ្រាមលោកលើកទី២ ។

លើសពីនេះ បក្សកុម្មុយនីស្តកម្ពុជាមិនបានចាត់ទុកប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ជាខ្មាំងដូចការចោទប្រកាន់របស់

សហព្រះរាជអាជ្ញាទេ ។ ផ្ទុយទៅវិញ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញទាំងនេះ ភាគច្រើនជាកម្មករ កសិករ អនុធន បញ្ញាជន និងបុគ្គលស្នេហាជាតិ ដែលបក្សកុម្មុយនីស្តកម្ពុជា ត្រូវប្រមូល និងចាត់ទុកជាកម្លាំងមួយដ៏សំខាន់ ដើម្បីចូលរួមធ្វើបដិវត្តន៍ ។

ចំពោះករណីដែលលោក លោកស្រីសហព្រះរាជអាជ្ញាលើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យជារដ្ឋទាសករ ។ នេះវាជារឿងមួយមិនអាចទទួលយកបានទេ ។ ខ្ញុំសូមជម្រាបជូនបងប្អូនជនរួមជាតិថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនតស៊ូរំដោះប្រទេសកម្ពុជាក្នុងគោលបំណងដាក់ប្រជាជនកម្ពុជាជាទាសករ ដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ។ ផ្ទុយទៅវិញ បក្សកុម្មុយនីស្តកម្ពុជាបានរំដោះប្រជាជនកម្ពុជាពីទាសភាព ។ យើងទាំងអស់គ្នាគួរតែបានដឹងរួចមកហើយថា នៅមុនថ្ងៃរំដោះ១៧ មេសា ឆ្នាំ ១៩៧៥ ប្រជាកសិករកម្ពុជាភាគច្រើនមានភាពក្រីក្រខ្វះមុខខ្វះក្រោយ និងជួបប្រទះការលំបាកយ៉ាងខ្លាំងនៅក្នុងជីវភាពរស់នៅរបស់ពួកគេ ។ រដ្ឋអំណាច លន់ នល់ មិនបានផ្តល់សេវាកម្មសាធារណៈ និងគិតគូរពីសុខមាលភាពសង្គមដល់ប្រជាជនក្រីក្រនោះទេ ។ អំពើពុករលួយ និងភាពអយុត្តិធម៌ បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ។ ដោយសារហេតុផលនេះ ប្រជាកសិករកាន់តែក្រទៅៗ ពួកគាត់តែងតែខ្ចីបុល ពីនាយទុន ដើម្បីទ្រទ្រង់ជីវភាពព្យាបាលជំងឺ ឬបង់ពន្ធដារ ។ នៅពេលនោះហើយ ពួកនាយទុនបានឆ្លៀតពេលដែលប្រជាជនមានទុក្ខលំបាកបានធ្វើទុក្ខបុកម្នេញ និងទារការប្រាក់គាត់ តាមទំនើងចិត្តរហូតដល់យកការប្រាក់ចំនួន ៥០ភាគរយក្នុង១ខែក៏មាន ។ ដោយការប្រាក់ខ្ពស់ហួសហេតុនាំឲ្យប្រជាជនទាំងនោះគ្មានលទ្ធភាពសងបំណុល ហើយត្រូវបានម្ចាស់បំណុលរឹបអូសយកដីស្រែចម្ការ និងផ្ទះសម្បែងអស់ ។ នៅពេលអស់ដីស្រែ ចម្ការ និងផ្ទះសម្បែង ប្រជាជនទាំងនោះ ត្រូវបង្ខំចិត្តស៊ីឈ្នួលគេ ឬត្រូវបានចាប់បង្ខំឲ្យធ្វើជាខ្ញុំកញ្ជះគេ ដើម្បីកាត់បំណុលដែលសងមិនចេះអស់នេះ ។ មានករណីជាច្រើន ដែលពួកគាត់ត្រូវបង្ខំចិត្តលក់កូនឲ្យធ្វើជាខ្ញុំគេ តកូន តចៅ វេទនមិនរួច ហើយក្លាយជាទាសកររបស់គេ ដោយលក់កម្លាំងដូរបាយតែមួយចំអែតក្រពះតែប៉ុណ្ណោះ ។ ការកេងប្រវ័ញ្ច និងភាពក្រីក្ររកទីបំផុតគ្មានរបស់ប្រជាកសិករនេះ ជាបុព្វហេតុមួយក្នុងបុព្វហេតុជាច្រើនទៀតដែលបក្សកុម្មុយនីស្តកម្ពុជារំដោះប្រទេសជាតិ និងប្រជាជន ចេញពីទាសភាព ។ ការកេងប្រវ័ញ្ច ការជិះជាន់ និងការឈ្លានពានរបស់បរទេស ដោយកសាងប្រទេសកម្ពុជាមួយដែលប្រជាជនរស់នៅដោយស្មើភាព និងប្រជាជន ជាម្ចាស់ប្រទេសពិតប្រាកដក្នុងគោលជំហរ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។ គ្មានគោលនយោបាយ ឬផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាណាមួយដែលកំណត់ឲ្យដាក់ប្រជាជនជាទាសករ តាមរយៈការបង្អត់អាហារ ការបង្ខំឲ្យធ្វើការ ឬការសម្លាប់ឡើយ ។ ផ្ទុយទៅវិញ នៅពាក់កណ្តាលឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំ និងអនុម័តគម្រោង ផែនការ៤ឆ្នាំ សម្រាប់កសាងសង្គមនិយមគ្រប់ផ្នែក ។ មាគ៌ា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាគឺ លើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ផែនការនេះបានកំណត់ថា របបអាហាររបស់ប្រជាជនម្នាក់ៗចំនួន ១៣ថាំង ឬ៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ។ ដូច្នេះប្រជាជនហូបគ្រប់គ្រាន់សម្រាប់ពី៣ពេល ទៅ៤ពេលក្នុងមួយថ្ងៃ ។ ចំពោះម្ហូប គឺ២មុខ មានសម្លរទឹក និងសម្លរគោក ។ លើសពីនេះ បានសម្រេចបន្ថែមលើរបបអាហារ នូវចំណី និងបង្អែមផ្សេងៗ ដោយផ្តល់ឲ្យ៣ថ្ងៃម្តង ក្នុងឆ្នាំ១៩៧៧ ។ ២ថ្ងៃម្តងៗ ក្នុងឆ្នាំ១៩៧៨ ហើយ១ថ្ងៃម្តង ចាប់ពីឆ្នាំ១៩៧៩ តទៅ ។ ចំពោះការងារវិញ គឺឲ្យប្រជាជនធ្វើការងារ៨ម៉ោងក្នុង១ថ្ងៃ និងឲ្យឈប់សម្រាក៣ថ្ងៃក្នុងមួយខែ ។ នារីមានផ្ទៃពោះនិងឆ្លងទន្លេ ឲ្យឈប់សម្រាក២ខែ ។ អ្នកជំងឺឲ្យឈប់សម្រាកតាមជាក់ស្តែង ។ លើសពីនេះ យើងបានរៀបចំបង្កើនគ្រឿងចក្រឲ្យកាន់តែច្រើន សម្រាប់សម្រាលទម្ងន់ការងារដោយកម្លាំងកាយផ្ទាល់របស់ប្រជាជន ។ នេះបង្ហាញថា គោលជំហរបក្សកុម្មុយនីស្តកម្ពុជាមិនបានបង្ខំឲ្យប្រជាជន ធ្វើការយ៉ាងធ្ងន់ធ្ងរនោះឡើយ ។ ខ្ញុំនៅចាំបានថា មានថ្ងៃមួយ ខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តសៀមរាប កាត់តាមខេត្តកំពង់ធំ នៅពេលយប់ ។ ខ្ញុំបានឃើញប្រជាជនដើរទៅកាន់វាលស្រែ ពេលខ្ញុំសួរកម្មាភិបាលគ្រប់គ្រងមូលដ្ឋាននោះ គេឆ្លើយប្រាប់ខ្ញុំថា ប្រជាជនមានស្មារតីប្តេជ្ញាចិត្តខ្ពស់ ស្ម័គ្រចិត្តធ្វើការបន្ថែម ។ ក្រោយឆ្នាំ ១៩៧៩ ទើបខ្ញុំបានដឹងថា កម្មាភិបាលមូលដ្ឋាននោះបានកុហក

ខ្ញុំ ។ លើសពីនេះ យើងបានគ្រោងការចំណាយសម្រាប់ថ្នាំពេទ្យរយៈពេល៤ឆ្នាំ សរុប ៣៥លាន២សែន៧ម៉ឺនដុល្លារ ។ សម្រាប់សម្លៀកបំពាក់រយៈពេល៤ឆ្នាំ សរុប៦៦លាន២សែន៧ម៉ឺនដុល្លារ ។ សម្រាប់ផ្ទះសម្បែង អនាម័យ វប្បធម៌ រយៈពេល ៤ឆ្នាំ សរុប៨០លាន២សែន៣ម៉ឺនដុល្លារ ។ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ចេញនូវផែនការនេះយ៉ាងជាក់លាក់ និងច្បាស់លាស់សម្រាប់ឲ្យភូមិភាគ និងតំបន់ស្វយ័តនីមួយៗអនុវត្ត ។

ចំពោះការកាប់សម្លាប់ ក៏មិនមែនជាផែនការ ឬគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ បក្សកុម្មុយនីស្តកម្ពុជាមានផែនការបង្កើនប្រជាជន មិនមែនកាត់បន្ថយចំនួនប្រជាជននោះឡើយ ។ ប៉ុន្តែគួរឲ្យសោកស្តាយដែលភូមិភាគ និងតំបន់ស្វយ័តខ្លះមិនបានអនុវត្តតាមការសម្រេចរបស់គណៈអចិន្ត្រៃយ៍ ។ មកដល់ពេលនេះ ខ្ញុំអាចសរុប និងឆ្លើយតបនឹងចម្ងល់របស់តុលាការ និងជាពិសេសជនរួមជាតិរបស់ខ្ញុំឲ្យបានជ្រាបថា វិនាសកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមូលហេតុដូចខាងក្រោម ៖

ទី១) អ្នកដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជាជ្រើសរើសកម្មាភិបាលមួយចំនួនខុស ដោយអ្នកខ្លះក្បត់ អ្នកខ្លះក្តាប់មិនបានពីមាគ៌ារបស់បក្ស ហើយអ្នកដឹកនាំរវល់តែកិច្ចការ នៅទីក្រុងភ្នំពេញ មិនសូវបានចុះទៅតាមសហករណ៍ឲ្យបានជាប់លាប់ ។

ទី២) មានមេដឹកនាំភូមិភាគ តំបន់ស្វយ័ត និងកម្មាភិបាលមួយចំនួនជាភ្នាក់ងាររបស់វៀតណាម និងអាមេរិក ដែលក្បត់បដិវត្តន៍ ។ ពួកគេបានធ្វើសកម្មភាពបំផ្លិចបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជា និងប្រទេសកម្ពុជា ។ ពួកនេះមិនបានធ្វើតាមផែនការ និងគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជាទេ ។ បែរជានាំគ្នាកាប់សម្លាប់ និងធ្វើបាបប្រជាជន ដោយការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំង តាមទំនើងចិត្តរបស់ខ្លួន ហើយលាក់បាំង និងរាយការណ៍ភូតកុហកមកមជ្ឈិមបក្ស ។ ពួកគេធ្វើគ្រប់វិធី ដើម្បីធ្វើឲ្យប្រជាជនមានសតិអារម្មណ៍ថ្នាំងថ្នាក់ងាកមកប្រឆាំងនឹងបដិវត្តន៍ បណ្តាលឲ្យបក្សកុម្មុយនីស្តកម្ពុជាចុះខ្សោយ ហើយសត្រូវបរទេសយកលេសថាមករំដោះប្រជាជនកម្ពុជា ដើម្បីឲ្យការឈ្លានពានរបស់គេក្លាយជាអំពើស្របច្បាប់ ។ ជាក់ស្តែង មេភូមិភាគបូព៌ាបានបង្អត់បាយប្រជាជនតែបែរជាលួចដឹកស្រូវចេញទៅប្រទេសវៀតណាមទៅវិញ ។ ក្រុមនេះអាចចាត់ទុកថា ជាពួកដុតឲ្យខ្លោចរោចឲ្យឆៅ ។ ពួកដុតឲ្យខ្លោច គឺពួកធ្វើឲ្យលើសហួសហេតុពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ពួករោចឲ្យឆៅ គឺពួកគេមិនធ្វើអ្វីទាំងអស់ មិនខ្វល់អ្វីទាំងអស់ ហើយកម្មាភិបាលថ្នាក់ក្រោមធ្វើតាមអំពើចិត្ត ។

ទី៣) មានកម្មាភិបាលភូមិភាគ តំបន់ស្វយ័ត ស្រុក និងសហករណ៍មួយ ចំនួនធំក្តាប់មិនបានពីមាគ៌ា ផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្រុមនេះមិនបានរាយការណ៍ពីការលំបាក និងការខ្វះខាតរបស់ប្រជាជន ឬបើបានជារាយការណ៍វិញ គេរាយការណ៍បំផ្លើសពីភាពជោគជ័យក្នុងការដឹកនាំមូលដ្ឋានរបស់ខ្លួន មកមជ្ឈិមបក្សជាថ្នូរនឹងស្នាដៃ ។ ដើម្បីឲ្យបានសម្រេចដូចរបាយការណ៍ ពួកគេបានបង្ខិតបង្ខំឲ្យប្រជាជនឲ្យធ្វើការហួសកម្លាំង កាត់បន្ថយរបបអាហារ និងកាប់សម្លាប់តាមតែចិត្តរបស់ខ្លួន ។

សរុបមក បក្សកុម្មុយនីស្តកម្ពុជាមានហេតុផលច្បាស់លាស់ចំពោះការជម្លៀសប្រជាជន ក្នុងគោលដៅដើម្បីធានានូវសុវត្ថិភាពរបស់ប្រជាជន និងរំដោះប្រជាជនចេញពីទាសភាព និងអំពើអយុត្តិធម៌ ។ វាមិនមែនជាការដាក់ប្រជាជនជាទាសករនោះទេ ។

## ក) ភាពយុត្តិធម៌នៅពេលកាត់សេចក្តីនេះ

គោរពតុលាការ! តាមការសង្កេតរបស់ខ្ញុំនៅក្នុងសវនាការនេះ សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ខ្ញុំត្រូវបានរំលោភបំពាន ។ តាមពិតទៅខ្ញុំមិនគួរនិយាយថា ការកាត់សេចក្តីនេះមានភាពអយុត្តិធម៌នោះទេ ពីព្រោះខ្ញុំកំពុងតែសុំតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំ ។ ប្រសិនបើចៅក្រមខឹងខ្ញុំ ដោយសារតែខ្ញុំរិះគន់នោះ ភាពអយុត្តិធម៌ពិតជាកើតមានឡើងចំពោះខ្ញុំជាមិនខាន ។ តែបើខ្ញុំមិននិយាយអំពីការរំលោភបំពាននោះទេ ឱកាសនៃការរកយុត្តិធម៌ឲ្យខ្ញុំនោះ វារិតតែគ្មានទាល់តែសោះ ពីព្រោះសិទ្ធិទាំងអស់នោះជាមូលដ្ឋានគ្រឹះនៃការរកយុត្តិធម៌ឲ្យខ្ញុំ ។ ទាក់ទងនឹងករណីនេះ ខ្ញុំបានតាមដាន និងសង្កេតដោយយកចិត្តទុកដាក់បំផុតហើយឃើញថា មានសិទ្ធិច្រើនណាស់ត្រូវបានរំលោភបំពាន ។

១) ភាពមិនស្មើគ្នានៃការប្រមូលភស្តុតាង ៖ នៅពេលដំណើរ

ការរឿងក្តី មេធាវីរបស់ខ្ញុំ មិនត្រូវបានអនុញ្ញាតឲ្យចុះស៊ើបអង្កេតដើម្បីប្រមូលភស្តុតាងយកមកការពារខ្ញុំនោះទេ ។ ចំណែកសហព្រះរាជអាជ្ញាវិញ មានឱកាសគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតសួរសាក្សីតាំងពីដំបូង ។ ចំពោះមេធាវីការពារខ្ញុំវិញ មិនត្រូវបានអនុញ្ញាតឲ្យស្វែងរកសាក្សីផ្សេងក្រៅពីបញ្ជីសាក្សីដែលចៅក្រមស៊ើបអង្កេតផ្តល់ឲ្យនោះទេ ។ ការធ្វើបែបនេះ វាហាក់ដូចជាចងដៃមេធាវី និងកម្រិតសិទ្ធិមេធាវីរបស់ខ្ញុំ ក្នុងការប្រមូលភស្តុតាងមកការពារខ្ញុំ ហើយផ្តល់ឱកាសឲ្យភាគីម្ខាងទៀតវ៉ៃខ្ញុំតាមចិត្ត ។ នេះធ្វើឲ្យប៉ះពាល់យ៉ាង ខ្លាំងដល់ការការពាររបស់មេធាវី និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំ ។

(២) មិនបានកោះហៅសាក្សីសំខាន់មកបំភ្លឺនៅចំពោះមុខតុលាការ ៖ ករណីនេះ មេធាវីរបស់ខ្ញុំបានស្នើសុំជាច្រើនដងឲ្យតុលាការកោះហៅសាក្សីសំខាន់ៗមួយចំនួន ឲ្យចូលមកបំភ្លឺនៅចំពោះមុខតុលាការ ដូចជាសាក្សីអត្តចរិក និងសាក្សីទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ តែតុលាការបានបដិសេធ ។ ការសម្រេចនេះ បានធ្វើឲ្យប៉ះពាល់ដល់ការស្វែងរកការពិត និងត្រឹមត្រូវចំពោះរឿងក្តី ។

(៣) មានភាពលម្អៀងក្នុងការសាកសួរសាក្សីនៅចំពោះមុខតុលាការ ៖ ការសួរសាក្សីជាផ្នែកមួយដ៏សំខាន់សម្រាប់ស្វែងរកការពិត និងភាពមិនច្បាស់លាស់របស់សាក្សី ដែលផ្អែកលើលទ្ធផលនៃសក្ខីកម្មនេះ ចៅក្រមអាចសម្រេចក្តីប្រកបដោយយុត្តិធម៌ ។ ចំពោះសវនាការនេះ ខ្ញុំមើលឃើញថា ចៅក្រមមិនបានពិចារណាឲ្យបានដិតដល់អំពីបញ្ហានេះទេ ។ នៅពេលព្រះរាជអាជ្ញាសួរសាក្សី ចៅក្រមតែងតែផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាសួររហូត កម្រនឹងមានការរំខានណាស់ បើទោះជាមានការជំទាស់ពីមេធាវីការពារក៏ដោយ ។ ចំពោះមេធាវីការពារវិញ មិនមានឱកាសដូចនេះទេ ។ មេធាវីការពារ ត្រូវបានរំខានគ្រប់ពេលវេលាតាមការជំទាស់របស់សហព្រះរាជអាជ្ញា ហើយចៅក្រមតែងតែផ្តល់ឲ្យព្រះរាជអាជ្ញាធ្វើបែបនេះ ។ មានពេលខ្លះ នៅពេលមេធាវីការពារធ្វើការតវ៉ា ក៏មានការព្រមានពីប្រធានសវនាការជាដើម ។ ដោយមើលឃើញពីភាពអយុត្តិធម៌បែបនេះ ទាំងរូបខ្ញុំ ក៏ដូចជាលោក ខៀវ សំផន បានសម្រេចចិត្តឈប់ផ្តល់សក្ខីកម្មជូនតុលាការ ពីព្រោះយើងយល់ថា បើទោះជាយើងផ្តល់ចម្លើយជូនចៅក្រម ក៏វាមិនមានន័យអ្វីដែរ ដោយហេតុថាចៅក្រមមានភាពលម្អៀង ហើយអ្វីដែលអនុវត្តនៅចំពោះមុខតុលាការនោះ វាគ្រាន់តែជាការបង្គ្រប់នីតិវិធី ឬបំពេញទម្រង់ឲ្យល្អមើលតែប៉ុណ្ណោះ ។

សរុបសេចក្តីមក ដោយផ្អែកលើមូលដ្ឋានទាំងបីដែលខ្ញុំបានបញ្ជាក់ជូនខាងលើនេះ វាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ខ្ញុំមិនបានធ្វើផែនការប្រព្រឹត្តបទល្មើស ខ្ញុំមិនបានជួយឧបត្ថម្ភ ឬលើកទឹកចិត្តឲ្យជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើស ។ បើទោះជាខ្ញុំមានតួនាទី ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា ខ្ញុំមិនបានដឹងអំពីការប្រព្រឹត្តបទល្មើសនៅតាមមូលដ្ឋាននោះទេ ។ ទើបតែនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបខ្ញុំបានដឹងអំពីអំពើក្បត់របស់មេដឹកនាំនៅតាមភូមិភាគតំបន់មូលដ្ឋានខ្លះ ដែលមានបំណងបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ហើយនៅពេលនោះ ខ្ញុំពិតជាគ្មានអំណាចក្នុងការទប់ស្កាត់អំពើក្បត់ទាំងនោះបានឡើយ ពីព្រោះខ្ញុំពុំមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំងយោធា ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ ។ ប្រសិនបើក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្ញុំពិតជាមានអំណាចដឹកនាំ ឬបានប្រព្រឹត្តដូចការចោទប្រកាន់នៅពេលនេះ ប្រាកដជាតុលាការដែលបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៥ ពិតជាកាត់ទោសខ្ញុំដូចជា ប៉ុល ពត និង អៀង សារី ទៅហើយ ពីព្រោះពេលនោះភស្តុតាងនៃឧក្រិដ្ឋកម្មនៅបន្សល់ទុកថ្មីៗនៅឡើយ មិនបាច់រង់ចាំពេល ៣៨ឆ្នាំ ដើម្បីកាត់ទោសខ្ញុំទេ ។ តែដោយសារដឹងថាខ្ញុំគ្មានអំណាចអ្វី និងមិនបានប្រព្រឹត្ត ។ ទោះបីជាយ៉ាងណា ខ្ញុំនៅនៅតែសម្តែងនូវការសោកស្តាយជាទីបំផុត និងសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរងគ្រោះទាំងអស់ និងប្រជាជនកម្ពុជាទាំងមូលដែលបានទទួលរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាការពិត សម្រាប់ប្រវត្តិសាស្ត្រ ទាំងគោលនយោបាយ ទាំងមាគ៌ា និងទាំងផែនការរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតឡើងក្នុងគោលបំណងតែមួយគត់ គឺរំដោះប្រទេសជាតិ និងប្រជាជន ឲ្យរួចផុតពីអាណានិគមនិយមចក្រពត្តិនិយម និងការជិះជាន់កេងប្រវ័ញ្ច ភាពក្រីក្ររកទីបំផុត គ្មានការជ្រៀតជ្រែក និងការឈ្លានពានពីប្រទេសជិតខាងពិសេស

ពីប្រទេសវៀតណាម ។ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយដាក់លាក់ គ្មានការភូតភរ គឺកសាងប្រទេសមួយស្មើភាពគ្នា និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដ ក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។ ចលនាបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើង មិនមែនដើម្បីកាប់សម្លាប់ប្រជាជន និងបំផ្លាញប្រទេសជាតិនោះឡើយ ។ ខ្ញុំពិតជាមានការសោកស្តាយ ចំពោះការលះបង់សឹងតែមួយជីវិតរបស់ខ្ញុំក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ មនសិការរបស់ខ្ញុំ សេចក្តីសង្ឃឹមរបស់ខ្ញុំ និងសេចក្តីប្រាថ្នារបស់ខ្ញុំ ត្រូវបានបំផ្លាញដោយពួកក្បត់ចលនា ដែលធ្វើឲ្យប្រជាជនរបស់ខ្ញុំត្រូវបានកាប់សម្លាប់ និងរងទុក្ខវេទនា ។ ប្រទេសជាតិរបស់ខ្ញុំត្រូវបែកបាក់ ។ ទោះបីជាសោកនាដកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបង្កឡើងដោយជនក្បត់ចលនាក៏ដោយ ក៏ក្នុងនាមខ្ញុំជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាដែលមានភារកិច្ចឃោសនាអប់រំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមសុំទោសជាសាធារណៈចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូល ហើយនៅតែប្រកាន់ជំហរទទួលខុសត្រូវលើផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានដិតដល់ និងមិនបានគ្រប់ជ្រុងជ្រោយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនដែលរងគ្រោះដោយគ្រប់យថាហេតុទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សរុបឲ្យខ្លី តាមពន្លឺនៃសវនាការនេះ ខ្ញុំឃើញច្បាស់ថា យុត្តិធម៌អាចប្រែប្រួល ទៅតាមកាលៈទេសៈ តែសច្ចៈធម៌ជាអមតៈមិនប្រែប្រួលជាដាច់ខាត ។ ពពកខ្មៅមិនអាចបិទបាំងពន្លឺព្រះអាទិត្យបានទេ ។ យ៉ាងណាមិញ មនុស្សអគតិ អសីលធម៌ មិនអាចភូតភរកុហក និងបិទបាំងភ្នែកប្រជាជន និងមហាជន មិនឲ្យមើលឃើញនូវសច្ចៈធម៌ នៃការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា និងការឧបត្ថម្ភគាំទ្ររបស់ប្រជាជន ស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោកបានឡើយ ។ អាស្រ័យហេតុនេះ ដោយផ្អែកលើភស្តុតាង និងហេតុផលទាំងអស់ខាងលើនេះ និងជាពិសេសសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំ ខ្ញុំសូមសំណូមពរតុលាការមេត្តាសម្រេចឲ្យខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងសំណុំរឿងនេះ និងសូមដោះលែងខ្ញុំឲ្យមានសេរីភាពវិញទៅតាមផ្លូវច្បាប់ ។ សូមអរគុណ! សូមអរគុណលោកប្រធាន» ។



យោធាខ្មែរក្រហមក្នុងពិធីបុណ្យខួបថ្ងៃបង្កើតកងទ័ពបដិវត្តន៍កម្ពុជា នៅពហុកីឡាដ្ឋានជាតិ អូឡាំពិក
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន

បន្ទាប់ពីមេធាវីការពារក្ដី នួន ជា បានបញ្ចប់ការធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញ ដោលរយៈពេលពីថ្ងៃរួចមក អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្ដី ខៀវ សំផន ដើម្បីធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ។

មេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន គឺ មេធាវី អាកទួរ វែកគែន បានឡើងថ្លែងដំបូងដោយកត់សម្គាល់ទាក់ទងនឹងសេចក្ដីថ្លែងការណ៍របស់ក្រុមមេធាវីការពារក្ដី នួន ជា ហើយចាត់ទុកការលើកឡើងរបស់ក្រុមមេធាវីការពារក្ដី នួន ជា ថាពោរពេញទៅដោយទេពកោសល្យ និងគាំទ្រ ចំពោះអំណះអំណាងទាំងអស់នោះ ។ បន្ទាប់មកមេធាវី វែកគែន ជម្រាបជូនអង្គជំនុំជម្រះថា លោកនឹងចាប់ផ្ដើមដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយផ្ដោតសំខាន់លើវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង បន្ទាប់មកនឹងលើកឡើងអំពីបញ្ហាភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។

## ១) បញ្ហាវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង

ចំពោះចំណុចវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង មេធាវី អាកទួរ វែកគែន បានថ្លែងរៀបរាប់ដោយរំឭកឡើងវិញអំពីប្រវត្តិនីតិវិធីចាប់តាំងពីការចាប់ផ្ដើមសំណុំរឿង០០២ រហូតដល់ ពេលដែលអង្គជំនុំជម្រះសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ជាផ្នែកតូចៗ ។ មេធាវីបានអះអាងថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះ បានអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចលើកយកអង្គហេតុ ដែលចោទប្រកាន់ទាក់ទងនឹងការជម្លៀសប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ រួមជាមួយនឹងការសម្លាប់អតីតមន្ត្រីរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិសាត់មកជំនុំជម្រះ ដោយពុំចាំបាច់ជំនុំជម្រះលើអង្គហេតុទាំងមូលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវី វែកគែន បានលើកឡើងទៀតថា អង្គជំនុំជម្រះធ្លាប់បានជូនដំណឹងដល់ភាគីមិនឲ្យលើកឡើងអំពីអ្វីដែលស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុដែលបានកំណត់ដោយអង្គជំនុំជម្រះទេ ។ ប៉ុន្តែ នៅក្នុងសវនាការកន្លងមក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញអាចផ្ដល់សក្ខីកម្មទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ដែលចេញក្រៅពីអង្គហេតុដែលអង្គជំនុំជម្រះខ្លួនឯង ធ្លាប់បានកំណត់ដោយសារហេតុផលផ្សេងៗ ។ មេធាវីអះអាងទៀតថា វិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងនេះ មានការកែប្រែ ទៅតាមតែការយល់ឃើញរបស់អង្គជំនុំជម្រះ ដែលអាចនឹងរំលោភបំពានលើគោលការណ៍កាត់សេចក្ដីដោយយុត្តិធម៌ ដោយសារតែជនជាប់ចោទពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំក្នុងការការពារខ្លួនពីការចោទប្រកាន់ប៉ុណ្ណោះ ។

មេធាវី វែកគែន បានចោទប្រកាន់សហព្រះរាជអាជ្ញាថា បានស្នើសុំអង្គជំនុំជម្រះឲ្យផ្អែកលើអង្គហេតុ ដែលស្ថិតក្រៅវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង ដើម្បីចេញសេចក្ដីសម្រេច ប្រកាសពិរុទ្ធភាព និងកាត់ទោស ខៀវ សំផន ឲ្យជាប់គុកមួយជីវិត ។ ម្យ៉ាងវិញទៀត ចំពោះការចោទ ប្រកាន់របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដែលថា ខៀវ សំផន បានចូលរួមក្នុងគោលបំណងដាក់ប្រជាជនទាំងអស់ឲ្យក្លាយជាទាសករនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មេធាវី វែកគែន បានឆ្លើយតបថា នេះគឺគ្រាន់តែជាយុទ្ធសាស្ត្ររបស់សហព្រះរាជអាជ្ញា ដើម្បីបន្ថយនូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងភស្តុតាងប៉ុណ្ណោះ ។ ដើម្បីចោទប្រកាន់ពីការដាក់កម្ពុជាឲ្យក្លាយជារដ្ឋទាសករ សហព្រះរាជអាជ្ញាចាំបាច់ត្រូវបានបង្ហាញរាល់ភស្តុតាងដែលទាក់ទងនឹងគោលនយោបាយឧក្រិដ្ឋកម្មទាំងអស់ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ និងត្រូវតែបង្ហាញថា គោលនយោបាយទាំងនោះ មានគោលដៅតែមួយគត់ គឺធ្វើយ៉ាងណាសម្រេចឲ្យបានលទ្ធផលតាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួន ។ ឧទាហរណ៍ ដូចជា ការអនុវត្តគោលនយោបាយទាក់ទងនឹងការជម្លៀសប្រជាជន ការបង្កើតសហ

ករណ៍ ការដ្ឋានការងារ ការអប់រំសមាសភាពថ្មី ការសម្លាប់ខ្មាំងទាំងក្នុង និងក្រៅជួរបក្ស ការកំណត់គោលដៅចំពោះបុគ្គលជាក់លាក់ ដូចជា អតីតមន្ត្រីសាធារណរដ្ឋខ្មែរ ជនជាតិចាម ពុទ្ធសាសនិក និងជនជាតិវៀតណាម និងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាដើម ។ ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានលើកឡើងអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋកម្មទាំងនេះទេ តែបែរជាលើកឡើងពីការអនុវត្តគោលនយោបាយឧក្រិដ្ឋកម្ម ដែលពុំមែនជាកម្មវត្ថុនៃការជំនុំជម្រះក្ដីទៅវិញ ។ មេធាវី វែកគែន បានអះអាងបន្ថែមទៀតថា សហព្រះរាជអាជ្ញាបានលើកឡើងនូវអង្គហេតុជាច្រើន ដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទី១ ដោយព្យាយាមបំភ្លេចដីកាបំបែកកិច្ចដំណើរការនីតិវិធីដែលធ្វើឡើងដោយអង្គជំនុំជម្រះ ។

មេធាវី វែកគែន ឆ្លើយតបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិ ជា លាង ដែលអះអាងនៅក្នុងសំណើសុំចុងក្រោយថា សហព្រះរាជអាជ្ញានឹងពុំស្នើសុំអង្គជំនុំជម្រះឲ្យហែកដើងកូនរបស់ ខៀវ សំផន នៅចំពោះមុខគាត់ មិនសុំឲ្យតុលាការដាក់គាត់ឲ្យក្លាយជាទាសករ មិនសុំឲ្យតុលាការបង្អត់អាហារគាត់ តែគ្រាន់តែសុំឲ្យអង្គជំនុំជម្រះសម្រេចដាក់គុកអស់មួយជីវិត ។ ការលើកឡើងបែបនេះ មេធាវី វែកគែន យល់ថា សហព្រះរាជអាជ្ញាពុំមែនចាត់ទុក ខៀវ សំផន ជាជនជាប់ចោទ ដែលមាន សិទ្ធិក្នុងការពារខ្លួនទេ ប៉ុន្តែសហព្រះរាជអាជ្ញាបានចាត់ទុក ខៀវ សំផន ថាជាបិសាចតែម្ដង ។ ប៉ុន្តែ សំណើបែបនេះមិនអាចធ្វើឲ្យចៅក្រមដែលមានវិជ្ជាជីវៈយល់ស្របតាមនោះទេ ចៅក្រមជាអ្នកស្វែងរកយុត្តិធម៌ និងត្រូវបំពេញការតព្វកិច្ចយ៉ាងធំធេង ដែលត្រូវកាត់សេចក្ដីលើព្រឹត្តិការណ៍ ដែលមានការចោទប្រកាន់ថាបានធ្វើឲ្យមានមនុស្សស្លាប់ជាច្រើន ។ ចៅក្រមមិនអាច មិនគោរពវិធានច្បាប់ទាំងឡាយដែលបានចែង ហើយផាកទោសសម្រេចសេចក្ដីដោយគ្រាន់តែយោងលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងមតិសាធារណជន ដែលមានបុរេវិនិច្ឆ័យចំពោះជនជាប់ចោទទេ ។ ចៅក្រមត្រូវយកច្បាប់ជាធំ បើច្បាប់កាន់តែរឹងមាំក្មេងជំនាន់ក្រោយនឹងគោរព ហើយយុត្តិធម៌នឹងក្លាយជាគំរូនៅថ្ងៃក្រោយ ។ មេធាវី វែកគែន បានលើកយកសម្ដីរបស់សហព្រះរាជអាជ្ញាដែលបាននិយាយថា "យើងត្រូវការការផ្សះផ្សាជាតិ" ហើយបានចោទជាសំណួរថា តើការផ្សះផ្សាជាតិចាំបាច់ត្រូវតែអង្គុយនៅលើច្បាប់ឬយ៉ាងណា? មេធាវីរូបនេះបានបន្តអះអាងទៀតថា សហព្រះរាជអាជ្ញាបានស្នើសុំចៅក្រមកាត់ទោស ខៀវ សំផន ចំពោះការដាក់ឲ្យប្រជាជនក្លាយទៅជាទាសករ ប៉ុន្តែឧក្រិដ្ឋកម្មដែលថា ដាក់មនុស្សឲ្យក្លាយជាទាសករ ពុំមានពាក្យបណ្ដឹងដែលប្ដឹងមកអង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មនេះទេ ។ ចំពោះការចោទប្រកាន់ ខៀវ សំផន ថា បង្កើតឲ្យមានសហករណ៍ មន្ទីរឃុំឃាំង កន្លែងអប់រំ ការប្រព្រឹត្តិឧក្រិដ្ឋកម្ម លើជនជាតិចាម វៀតណាម លើអ្នកកាន់ព្រះពុទ្ធសាសនា និងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ មេធាវីអះអាងថា ពុំដែលលើកយកមកនិយាយនៅចំពោះមុខអង្គជំនុំជម្រះទេ ហើយហេតុអ្វីបានជាសហព្រះរាជអាជ្ញា ទើបតែលើកយកចំណុចទាំងអស់នេះ មករៀបរាប់នៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់ខ្លួនទៅវិញ ។ ការធ្វើដូច្នេះ គឺដើម្បីបោកបញ្ឆោតចៅក្រម ឬយ៉ាងណា?

បន្ទាប់មក មេធាវី វែកគែន បានធ្វើការកត់សម្គាល់ពាក់ព័ន្ធនឹងនីតិវិធីក្នុងការដាក់សារណា សន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលដោយអះអាងថា ជនជាប់ចោទ និងមេធាវីការពារក្ដីជនជាប់ចោទ គួរតែមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យមើលសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ដើម្បីអាចធ្វើការឆ្លើយតបដោយប្រសិទ្ធិភាព ។ ប៉ុន្តែដោយសារការអនុវត្ត នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវឲ្យកំណត់ថ្ងៃដាក់សារណារបស់ភាគីទាំងអស់ ដូច្នេះទាំងសហព្រះរាជអាជ្ញា ទាំងមេធាវីការពារក្ដី ទាំងដើមបណ្ដឹងរដ្ឋប្បវេណី ដាក់សារណារបស់ខ្លួននៅថ្ងៃតែមួយ គឺថ្ងៃចុងក្រោយនៃកាលបរិច្ឆេទដែលអង្គជំនុំជម្រះកំណត់ឲ្យដាក់សារណា ។ ដោយសារមូលហេតុនេះ មេធាវី វែកគែន អះអាងថា កូនក្ដីរបស់ខ្លួន គឺជនជាប់ចោទ ខៀវ សំផន ពុំមានឱកាសពិនិត្យមើលសារណារបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបឡើយ ដោយសារម្យ៉ាង ខៀវ សំផន ពុំចេះភាសាអង់គ្លេស ព្រោះសារណានោះពុំទាន់ត្រូវបានបកប្រែជាភាសាខ្មែរ និងម្យ៉ាងទៀត ខៀវ សំផន ត្រូវរង់ចាំស្ដាប់ការអានរបស់សហព្រះរាជអាជ្ញារហូតដល់នាទីចុងក្រោយ នៅក្នុង

សវនាការ ដើម្បីយល់ពីអំណះអំណាងរបស់សហព្រះរាជអាជ្ញា ហើយត្រៀមឆ្លើយតបចំពោះអំណះអំណាងទាំងនោះ ។

មេធាវី វ៉េកគែន បានចោទប្រកាន់អង្គជំនុំជម្រះថា បានដាក់បន្ថែមឯកសារភស្តុតាងរាប់ពាន់ ក្រោយពេលសវនាការវគ្គដំបូងបានបិទបញ្ចប់ទៅហើយ កាលពីខែសីហា ឆ្នាំ២០១៣ ដែលនេះជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានព័ត៌មានអំពីការចោទប្រកាន់ សិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួន និងសិទ្ធិទទួលបានការកាត់ក្តីស្មើភាពគ្នាចំពោះមុខច្បាប់ ។ បន្ថែមពីលើនេះ មេធាវីការពារក្តីឲ្យ ខៀវ សំផន ក៏ពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើល និងពិភាក្សាអំពីតម្លៃជាភស្តុតាងនៃឯកសារដែលអង្គជំនុំជម្រះនឹងយកមកជំនុំជម្រះលើកូនក្តីរបស់ខ្លួនដែរ ។

មេធាវី វ៉េកគែន បានអះអាងថា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាលើកនិយាយអំពីអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយទាំងមូលតែម្តង សូម្បីបុគ្គលដែលអង្គជំនុំជម្រះកោះហៅមកផ្តល់សក្ខីកម្មកាលពីខែវិច្ឆិកា ឆ្នាំ២០១១ ក៏បានថ្លែងរៀបរាប់អំពីរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលដែរ ។ ជាងនេះទៅទៀតថា នៅក្នុងអំឡុងពេលនៃការអានសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សា ដេញដោលសហព្រះរាជអាជ្ញាបានធ្វើឲ្យសាធារណជនទូទៅគិតថា អង្គជំនុំជម្រះកំពុងកាត់សេចក្តីលើរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ ចំណែកឯអ្នកកាសែតបានចុះផ្សាយថា មានមនុស្សស្លាប់រាប់លាននាក់នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ។ មេធាវីបានរិះគន់តុលាការថា ជារោងល្ខោនដែលត្រូវបានរៀបចំយ៉ាងស្អាតដើម្បីទទួលអ្នកការទូតពីប្រទេសម្ចាស់ជំនួយ ព្រោះថា អ្នកការទូតទាំងអស់នោះពុំដែលចាប់អារម្មណ៍នឹងនីតិវិធីជំនុំជម្រះទេ ។ ភ្លាមៗ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានផ្អាក និងណែនាំឲ្យមេធាវី វ៉េកគែន ត្រូវចៀសវាងការលើកឡើងទាំងឡាយណា ដែលប៉ះពាល់ដល់ភាគីដទៃទៀត ឬការលើកឡើងដែលមិនពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ។ លោកចៅក្រម បានស្នើឲ្យមេធាវីត្រូវប្រកាន់ខ្ជាប់អាកប្បកិរិយា និងពាក្យសម្តីសមរម្យ គោរពចំពោះអង្គជំនុំជម្រះ គោរពភាគីដទៃផ្សេងទៀត គោរពសាធារណជន និងគោរពក្រមសីលធម៌វិជ្ជាជីវៈ ។ ប៉ុន្តែ មេធាវី វ៉េកគែន ហាក់បីដូចជាពុំយល់ស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះទេ ហើយបានឆ្លើយតបនឹងការកត់សម្គាល់របស់អង្គជំនុំជម្រះថា មេធាវីការពារក្តីពុំបានរំលោភបំពានលើភាគីណាមួយ ឬរំលោភក្រមសីលធម៌វិជ្ជាជីវៈក្រៅពីការពារកូនក្តីរបស់ខ្លួនទេ ។ មេធាវី វ៉េកគែន បានលើកឡើងទៀតថា នៅពេលដែលមេធាវីការពារក្តី នួន ជា គឺលោក វិចទ័រ កូបប៉េ ថ្លែងថា *“គាត់ទុកចិត្តចំពោះចៅក្រមអន្តរជាតិ ជាងចៅក្រមជាតិ”* អង្គជំនុំជម្រះពុំបានកាត់ផ្តាច់ មេធាវី នួន ជា ទេ ។ នៅពេលចូលដល់ចំណុចនេះ មេធាវី វ៉េកគែន បានឆ្លៀតឱកាសបង្ហាញពីការយល់ឃើញចំពោះការលើកឡើងរបស់មេធាវី នួន ជា ថា សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំគាំទ្រចំពោះការលើកឡើងនេះទាំងស្រុងទេ ពីព្រោះក្រុមមេធាវី ខៀវ សំផន គិតថា ចៅក្រមខ្មែរក៏អាចធ្វើដូចចៅក្រមបរទេសបានដែរ ហើយមេធាវី ខៀវ សំផន ទុកចិត្តលើចៅក្រមជាតិទាំងអស់ ទោះបីជា មានសមាសភាពអ្វីក៏ដោយ ។



នួន ជា (ទីបួនរាប់ពីឆ្វេង) និង ខៀវ សំផន (ឆ្វេងខាងមុខ) ទទួល
ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ (បណ្ណស

### ៧) បញ្ហាភស្តុតាងនៅក្នុងសំណុំរឿង

ពាក់ព័ន្ធនឹងបញ្ហាភស្តុតាង មេធាវី វ៉េកកែន បានកត់សម្គាល់ថា ភស្តុតាងដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ដើម្បីចោទប្រកាន់ ខៀវ សំផន សុទ្ធតែជាឯកសារដែលមិនអាចជឿជាក់បាន ។ ចំពោះភស្តុតាងផ្សេងទៀត ដូចជា សក្ខីកម្មរបស់សាក្សីដែលចូលផ្តល់នៅចំពោះមុខអង្គជំនុំជម្រះ ពុំត្រូវបានប្រើប្រាស់ច្រើនដូចអ្វីដែលសាក្សីទាំងនោះបានបង្ហាញជូនអង្គជំនុំជម្រះទេ ហើយមានពេលខ្លះ សហព្រះរាជអាជ្ញាបានកែប្រែ ឬបំភ្លៃសម្តី


ស្វាគមន៍ព្រះអង្គម្ចាស់ សុជានុវង្ស ពេលទស្សនកិច្ចនៅប្រទេសកម្ពុជា
ារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់សាក្សីទាំងនោះថែមទៀត ។

ចំពោះឯកសារភស្តុតាង មេធាវី វ៉េកកែន បានអះអាងថា ឯកសារដែលសហព្រះរាជអាជ្ញា ប្រើប្រាស់ដើម្បីចោទប្រកាន់ជនជាប់ចោទ មានឯកសារដើមចំនួន២តែប៉ុណ្ណោះ ក្រៅពីនោះសុទ្ធសឹងជាឯកសារថតចម្លង ឬឯកសារស្កេន ។ លោកមេធាវីបន្តថា ចាប់តាំងពីលោកចូលការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន រយៈពេលជិត២ឆ្នាំមកនេះ លោកពុំដែលឃើញឯកសារដើមនៅក្នុងសំណុំរឿងទេ គឺមានតែឯកសារថតចម្លង ដែលមេធាវីការពារក្តីចាត់ទុកថា ជាឯកសារដែលពុំមានភាពគួរឲ្យជឿជាក់បាន ។ មេធាវីបានលើកឡើងទៀតថា សហព្រះរាជអាជ្ញាបានប្រើប្រាស់យ៉ាងច្រើននូវកំណត់ហេតុស្តាប់ចម្លើយរបស់សាស្ត្រាចារ្យ បេន ឃៀរនិន ប៉ុន្តែអង្គជំនុំជម្រះធ្លាប់បានសម្រេចហើយថា សក្ខីកម្មរបស់ សាស្ត្រាចារ្យ បេន ឃៀរនិន ពុំមានតម្លៃជាភស្តុតាងឡើយ ដោយសារតែលោកសាស្ត្រាចារ្យបានបដិសេធពុំចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះ សហព្រះរាជអាជ្ញាហាក់ដូចជាបានបំភ្លេចសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើតម្លៃជាភស្តុតាងរបស់សាស្ត្រាចារ្យ ឃៀរនិន ។

មេធាវី វ៉េកកែន បានលើកឡើងបន្ថែមទាក់ទងនឹងខ្សែសង្វាក់ក្នុងការរក្សាទុកឯកសារថា នៅអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកគ្រប់គ្រង អង្គការដែលមានប្រភពឯកសារយ៉ាងសំខាន់ទាក់ទងនឹងភស្តុតាងដែលមាននៅក្នុងសំណុំរឿង លោកបានបដិសេធមិនបង្ហើបប្រាប់ពីទីកន្លែងតម្កល់ទុកឯកសារដើមជូនអង្គជំនុំជម្រះទេ ។ ដូច្នេះ ទាំងអង្គជំនុំជម្រះ និងភាគីទាំងអស់ អាចប្រើប្រាស់បានត្រឹមតែឯកសារថតចម្លងតែប៉ុណ្ណោះ ។ ហេតុនេះមេធាវីការពារក្តីមានសិទ្ធិក្នុងការព្រួយបារម្ភអំពីតម្លៃជាភស្តុតាងនៃឯកសារដែលត្រូវបានលើកយកមកពិភាក្សានៅក្នុងសំណុំរឿង ដោយសារខ្សែសង្វាក់នៃការថែរក្សាឯកសារដើមទាំងនោះ ត្រូវបានរក្សាការសម្ងាត់ ។

មុនពេលបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋាន មេធាវី អាកទួរ វ៉េកកែន បានអះអាងថា អង្គជំនុំជម្រះនៅទីនេះ ពុំមែនបង្កើតឡើងដើម្បីផ្សះផ្សាជាតិទេ ប៉ុន្តែបង្កើតឡើងដើម្បីផ្តល់យុត្តិធម៌ ដោយអនុលោមទៅតាមវិធានច្បាប់ ដោយផ្អែកលើភស្តុតាងរឹងមាំ និងមិនអាចប្រកែកបាន ។

បន្ទាប់ពី មេធាវី វ៉េកកែន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន មួយរូបទៀត គឺមេធាវី អង់តា ហ្គីសសេ ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ។ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ មេធាវី ហ្គីសសេ បានផ្តោតជាសំខាន់លើបរិបទ ប្រវត្តិសាស្ត្រ សង្គ្រាមត្រជាក់ និងការ

ទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា មុនពេលឈានដល់របបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក មេធាវី បានលើកឡើងអំពីមូលហេតុដែលនាំឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី២ និងឆ្លើយតបចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាចំពោះជនជាប់ចោទ ខៀវ សំផន ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ។

## ៣) ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា

មេធាវី អង់តា ហ៊្គីសសេ បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានថា សង្គ្រាមត្រជាក់ គឺជាដើមហេតុនៃសោកនាដកម្មនៃប្រទេសកម្ពុជា ហើយចាំបាច់ត្រូវតែនាំយកប្រធានាធិបតីរបស់សហរដ្ឋអាមេរិក មកជំនុំជម្រះដូចគ្នានេះដែរ ព្រោះថាសហរដ្ឋអាមេរិកជាអ្នកបង្កើតឲ្យមានសង្គ្រាម និងមានការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា ។ មេធាវី ហ៊្គីសសេ បន្តថា បើយោងតាមការផ្តល់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញនៅអំឡុងពេលសវនាការបានបង្ហាញថា នៅចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥ មានប្រជាជនប្រមាណ២លាន ៥សែននាក់ បានរត់ភៀសខ្លួនចូលមកទីក្រុងភ្នំពេញដោយសារតែខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ មេធាវីអះអាងទៀតថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានបំផ្លិចបំផ្លាញស្រែចម្ការ និងទន្និផលកសិកម្មយ៉ាងធ្ងន់ធ្ងរ ហើយបើមើលលើបរិបទនៃប្រវត្តិសាស្ត្រកម្ពុជានៅពេលនោះ ឃើញថា ចាប់ពីឆ្នាំ១៩៧៥ទៅ ប្រទេសកម្ពុជាពុំមានអ្វីៗទាំងអស់ ។ ប៉ុន្តែ សហព្រះរាជអាជ្ញាពុំបានលើកឡើងអំពីចំណុចទាំងអស់នេះនៅក្នុងការធ្វើសេចក្តីសន្និដ្ឋាន បញ្ចប់កិច្ចពិភាក្សាដេញដោលទេ ។ មេធាវីបន្តថា ទំហំនៃការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជានៅពេលនោះ គឺមានទំហំបីដងធំជាងការទម្លាក់គ្រាប់បែកនៅប្រទេសជប៉ុនក្នុងអំឡុងសង្គ្រាមលោកលើកទី២ទៅទៀត ។ ស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជានៅពេលនោះរឹតតែដុនដាប ដោយសារសត្វចិញ្ចឹម និងដំណាំ៧៥ភាគរយ ត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម ដោយប្រជាជនចាប់ផ្តើមខ្វះខាតស្បៀងអាហារដើម្បីបរិភោគ ។ មេធាវី ហ៊្គីសសេ បន្ថែមថា ស្ថានភាពទាំងអស់នេះពុំមែនកើតឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទេ គឺកើតឡើងមុនពេលខ្មែរក្រហមចូលកាន់អំណាចទៅទៀត ។

## ៤) ចម្លើយតបចំពោះការចោទប្រកាន់ទាក់ទងនឹងការជម្លៀសប្រជាជន

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាលើជនជាប់ចោទ ខៀវ សំផន ទាក់ទងនឹងការបញ្ជាឲ្យមានការជម្លៀសប្រជាជន មេធាវី អង់តា ហ៊្គីសសេ បានអះអាងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺស្ថិតក្រោមការទទួលខុសត្រូវរបស់ភូមិភាគ ហើយការជមៀសនេះទៀតសោត ក៏ពុំមានការឯកភាពគ្នាដែរ ។ មេធាវីបានលើកយកសក្ខីកម្មរបស់អ្នកជំនាញ ហ្វីលីព ស្ហតុ ដែលបានលើកឡើងថា “បក្សកុម្មុយនីស្តកម្ពុជា បើមើលពីក្រៅហាក់ដូចជាមានឯកភាពគ្នា ប៉ុន្តែយោធាដែលកាន់អំណាចមិនមានឯកភាពគ្នាទេ” ។

មេធាវី ហ៊្គីសសេ បានបញ្ជាក់ថា ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ គឺមានធាតុផ្សំតិចតួចបំផុត ដោយសារតែពុំមានកាលបរិច្ឆេទ និងចំនួនប្រជាជនរងគ្រោះច្បាស់លាស់ ។ ឯកសារសំខាន់ពីរ ដែលសហព្រះរាជអាជ្ញាផ្អែកលើ ដើម្បីចោទប្រកាន់ពីការជម្លៀសប្រជាជនដំណាក់កាលទី២នេះ ។ ឯកសារទី១ គឺកំណត់ហេតុនៃទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍នៅក្នុងភូមិភាគឦសាននៅថ្ងៃទី ២០-២៤ ខែសីហា ឆ្នាំ១៩៧៥ ។ ឯកសារទី២ គឺឯកសារដែលមានចំណងជើងថា “ការពិនិត្យមើល ការក្តាប់ និងការអនុវត្តគោលនយោបាយនៃការកសាងសេដ្ឋកិច្ច និងកសាងប្រទេសក្នុងគ្រប់វិស័យ” ។ ប៉ុន្តែ នៅក្នុងឯកសារទាំងពីរ ដែលសហព្រះរាជអាជ្ញាបានលើកឡើងដើម្បីចោទប្រកាន់ពីការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២នេះ ពុំមាននិយាយថា ខៀវ សំផន បានធ្វើបទអន្តរាគមន៍ទេ ហើយ ខៀវ សំផន នៅពេលនោះក៏កំពុងតែធ្វើទស្សនកិច្ចនៅបរទេស ។ ដូច្នេះ ខៀវ សំផន ពុំបានចូលរួមសម្រេចឲ្យមានការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី២ ដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវី ហ៊្គីសសេ បានទទួលស្គាល់ថា ការជម្លៀសប្រជាជនដំណាក់កាលទី២ ពិតជាត្រូវបានធ្វើឡើងប្រាកដ

មែន ប៉ុន្តែការសម្រេចជម្លៀសប្រជាជនលើកទី២នោះ គឺធ្វើឡើងដោយសារស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកំពុងមានការខ្វះខាតស្បៀងអាហារ ពុំមែនធ្វើឡើងក្នុងគោលបំណងឧក្រិដ្ឋដូចការលើកឡើងរបស់សហព្រះរាជអាជ្ញាឡើយ ។

មេធាវី អង់តា ហ្គីសសេ បានសន្និដ្ឋានជារួមថា ការជម្លៀសប្រជាជនទាំងដំណាក់កាលទី១ និងដំណាក់កាលទី២ មិនមែនជាចេតនាអាក្រក់ទេ ប៉ុន្តែជាវិធានការមួយដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានាពេលនោះ ។

### ៥) ចម្លើយតបចំពោះការចោទប្រកាន់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអំពីការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តលើប្រជាជនថ្មី មេធាវី ហ្គីសសេ បានបញ្ជាក់ថាការចោទប្រកាន់នេះ គឺជាការចោទប្រកាន់ពុំត្រឹមត្រូវ ពីព្រោះបក្សកុម្មុយនីស្តកម្ពុជាពុំមានគោលនយោបាយ ធ្វើបាបប្រជាជនថ្មីដូចជាការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ។ ទោះបីជាយ៉ាងណា មេធាវី ហ្គីសសេ បានទទួលស្គាល់ថា ពិតជាមានការប្រព្រឹត្តអំពើអមនុស្សធម៌លើប្រជាជនថ្មីប្រាកដមែន ប៉ុន្តែ អំពើដែលប្រព្រឹត្តឡើងទាំងអស់នោះ ធ្វើឡើងដោយកម្មាភិបាលថ្នាក់មូលដ្ឋានតែប៉ុណ្ណោះ ពុំមែនធ្វើតាមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ ការអះអាងដូច្នេះ ដោយសារមេធាវី ហ្គីសសេ យល់ថានៅតាមមូលដ្ឋានមានការស្អប់ខ្ពើមគ្នាពីសំណាក់ប្រជាជនចាស់ទៅលើប្រជាជនថ្មី ។ ដូច្នេះ ការព្យាយាមរបស់សហព្រះរាជអាជ្ញាក្នុងការផ្សារភ្ជាប់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាមួយការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម គឺជារឿងពុំត្រឹមត្រូវ ។ ទំនួលខុសត្រូវគឺត្រូវតែជាបន្ទុករបស់កម្មាភិបាលថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើទាំងនេះ ដោយផ្ទាល់ ប៉ុន្តែការលើកឡើងបែបនេះ សហព្រះរាជអាជ្ញាពុំចង់បានឡើយ ព្រោះបើកាលណានិយាយអំពីទំនួលខុសត្រូវរបស់កម្មាភិបាលថ្នាក់ក្រោម វានឹងធ្វើឲ្យការចោទប្រកាន់ចំពោះការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួមចាប់ផ្តើមចុះខ្សោយ ។

បន្ទាប់ពីមេធាវី ហ្គីសសេ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារក្តី ខៀវ សំផន មួយរូបផ្សេងទៀត គឺលោកមេធាវី គង់ សំអុន ដើម្បីឡើងថ្លែងសន្និដ្ឋានអំពីអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ។

មេធាវី គង់ សំអុន បានចាប់ផ្តើមដំបូងដោយលើកឡើងពីអត្តចរិត និងប្រវត្តិតួនាទីរបស់ ខៀវ សំផន នៅមុនឆ្នាំ១៩៧៥ និងបានអះអាងថា ការដឹងអំពីតួនាទីពិតប្រាកដរបស់ ខៀវ សំផន គឺជាកត្តាសំខាន់សម្រាប់កំណត់ អំពីមូលដ្ឋានគតិយុត្តិក្នុងការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនាពេលខាងមុខ ។ មេធាវីបានសង្កត់ធ្ងន់ថា នៅក្នុងអំឡុងពេលដែលអង្គហេតុកើតឡើង ខៀវ សំផន ពុំមានតួនាទីដូចជាការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ហើយថា ការចោទប្រកាន់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ចាំបាច់ទាមទារឲ្យមានការបង្ហាញពីសំណាក់សហព្រះរាជអាជ្ញាអំពីអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មច្បាស់លាស់ ដែលជនជាប់ចោទបានដឹងអំពីផែនការនោះ ហើយជនជាប់ចោទបានចូលរួមយ៉ាងជាក់ច្បាស់តែម្តង ។ ដូច្នេះ គប្បីពិនិត្យមើលថា តើជនជាប់ចោទ ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងក្របខ័ណ្ឌនៃការចូលរួមរបស់ខ្លួនក្នុងបដិវត្តន៍សង្គមនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? មេធាវី សំអុន បានបន្តថា ខៀវ សំផន មិនអាចទទួលខុសត្រូវរាល់អំពើទាំងអស់ដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

### ៦) អត្តចរិតរបស់ ខៀវ សំផន

បន្ទាប់មក មេធាវី គង់ សំអុន ចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន ដោយលើកយកសក្ខីកម្មរបស់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលធ្លាប់បានចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដែលលើកឡើងពីភាពស្អាតស្អំ សុភាពរាបសារ និងទឹកចិត្តស្មោះត្រង់របស់ ខៀវ សំផន នៅក្នុងកាតព្វកិច្ចដើម្បីប្រទេសកម្ពុជា ។ មេធាវីបន្តថា ពាក្យដែលអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ប្រើប្រាស់ដើម្បីរាប់រៀបពីអត្តចរិតរបស់ ខៀវ សំផន មានដូចជា បញ្ញាវន្ត យុត្តិធម៌ និងស្អាតស្អំ ជាដើម ។

ឆ្លើយតបចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការចាប់ផ្តើមនៃនិន្នាការនយោបាយរបស់ ខៀវ សំផន មេធាវី គង់ សំអុន បានបញ្ជាក់ថា សហព្រះរាជអាជ្ញាហាក់បីដូចជា

ចាត់ទុកការរាប់អានមជ្ឈដ្ឋានកុម្មុយនីស្តនៅទសវត្សរ៍៥០ និង៦០ របស់ ខៀវ សំផន ថា ជាអំពើឧក្រិដ្ឋរួចស្រេចទៅហើយ ។ ប៉ុន្តែ ខៀវ សំផន ធ្លាប់បានឆ្លើយតបចំពោះចំណុចនេះរួចហើយថា "ជាការពិតណាស់ ខ្ញុំក៏បានចាប់អារម្មណ៍ពីលទ្ធិកុម្មុយនីស្ត ហើយខ្ញុំក៏បានសិក្សាអំពីទ្រឹស្តីកុម្មុយនីស្តដែរ ។ ចុះយ៉ាងម៉េច! នៅថ្ងៃនេះ អស់លោកអស់សំណើចពេបជ្រាយ ប៉ុន្តែខ្ញុំត្រូវរំឭកលោកថា នាពេលនោះ កុម្មុយនីស្ត គឺជាចលនាមួយដែលផ្តល់សេចក្តីសង្ឃឹមដល់យុវជនរាប់លាននាក់នៅលើសាកលលោកទាំងមូល" ។ មេធាវី សំអុន បានអះអាងថា ការបញ្ជាក់របស់ ខៀវ សំផន នៅត្រង់ចំណុចនេះ គឺចង់បង្ហាញថា ការសម្រេចចិត្តចូលរួមបក្សកុម្មុយនីស្តបារាំងនៅពេលនោះ គឺជារឿងត្រឹមត្រូវ ដើម្បីឲ្យមានការផ្លាស់ប្តូរណាមួយដែលអាចផ្តល់បទពិសោធន៍ល្អដល់ប្រទេសកម្ពុជា និងដើម្បីស្វែងរកការអភិវឌ្ឍ ជីវភាពរបស់ប្រជាពលរដ្ឋ សេដ្ឋកិច្ចជាតិ និងសមភាពនៅក្នុងសង្គម ។

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលអះអាងថា ខៀវ សំផន បានប្រើប្រាស់អត្ថន័យក្នុងនិក្ខេបបទរបស់ខ្លួន យកទៅអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មេធាវី គង់ សំអុន បានបញ្ជាក់ថា និក្ខេបបទរបស់ ខៀវ សំផន មិនបានតម្រូវឲ្យលុបបំបាត់ការប្រើប្រាស់លុយ ហើយក៏មិនបានស្នើឲ្យលុបបំបាត់កម្មសិទ្ធិឯកជន និងទីក្រុងដែរ ។ ដូច្នេះរបបកម្ពុជាប្រជាធិបតេយ្យពុំបានប្រើប្រាស់និក្ខេបបទរបស់ ខៀវ សំផន យកមកអនុវត្តនៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជាតិនៅសម័យនោះទេ ។ បើតាម ខៀវ សំផន ចាំបាច់ត្រូវមានការអភិវឌ្ឍឧស្សាហកម្ម ដើម្បីលើកតម្លៃផលិតកម្មក្នុងស្រុក និងលើកស្ទួយដល់សេដ្ឋកិច្ចក្នុងស្រុក ។ មេធាវី សំអុន បានលើកយកសម្តីរបស់អ្នកជំនាញ ហ៊ីលីព ស្ប៉ត ដែលបានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា ខៀវ សំផន បានប្រឆាំង នឹងការលុបបំបាត់រូបិយប័ណ្ណនៅក្នុងរបបកម្ពុជប្រជាធិបតេយ្យ ។

មេធាវី សំអុន បានបន្តទៀតថា នៅក្រោយពេលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ខៀវ សំផន បានបង្កើតកាសែតឯករាជ្យមួយដែលបានទិតៀនយ៉ាងសុភាពរាបសា ដោយភាពក្លាហានចំពោះអំពើអយុត្តិធម៌នៅក្នុងសង្គមនៃរបបរបស់សម្តេចព្រះនរោត្តម សីហនុ ។ ប៉ុន្តែ ខៀវ សំផន ត្រូវបាននគរបាលរបស់សម្តេច សីហនុ ធ្វើឲ្យអាម៉ាស់ជាសាធារណៈ និងក្រោយមកត្រូវបានចាប់ដាក់គុក ដោយពុំមានការជំនុំជម្រះ ។ បន្ទាប់មកទៀតកាសែតឡបសែរវ៉ាទ័រ របស់ ខៀវ សំផន ក៏ត្រូវ បានហាមឃាត់មិនឲ្យចេញផ្សាយ ។ ប៉ុន្តែ ខៀវ សំផន នៅតែបន្តរស់នៅទីក្រុងភ្នំពេញព្យាយាមបន្តឆន្ទៈក្នុងការកែប្រែប្រទេសកម្ពុជាប្រកបដោយសន្តិវិធី ។ មេធាវីបន្តថា ក្រោយពីការចូលប្រឡូកក្នុងនយោបាយចំនួនពីរលើក ខៀវ សំផន បានកាន់កាប់មុខងារជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម ក្នុងរាជរដ្ឋាភិបាលរបស់សម្តេចព្រះ នរោត្តម សីហនុ និងបានជំទាស់រាល់អំពើពុករលួយ ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៦៦ មក សម្តេចព្រះនរោត្តម សីហនុ ពុំអាចគ្រប់គ្រងលើស្ថានភាពនយោបាយចំពោះមុខអ្នកស្តាំនិយមតឹងរឹង ដែលដឹកនាំដោយនាយករដ្ឋមន្ត្រីរបស់ទ្រង់ គឺលោក លន់ នល់ ។ បន្ទាប់ពីការប៉ះបោររបស់កសិករនៅសំឡូតក្នុងឆ្នាំ១៩៦៧ សម្តេចព្រះនរោត្តម សីហនុ បានចោទប្រកាន់ ខៀវ សំផន ថាជាអ្នកចូលរួមចំណែកក្នុងចលនានោះ ហើយប្រកាសចាប់ខ្លួន ខៀវ សំផន និងជូនរង្វាន់ដល់អ្នកណា ដែលអាចចាប់ខ្លួន ខៀវ សំផន បានថែមទៀតផង ។ មេធាវី សំអុន បានពន្យល់ថា នៅចំពោះមុខ ការគំរាមនេះហើយដែល ខៀវ សំផន យល់ថាអាចនឹងប៉ះពាល់ដល់អាយុជីវិតរបស់ខ្លួន ហេតុនេះ ចាំបាច់ត្រូវតែរត់គេចខ្លួនចេញពីទីក្រុងភ្នំពេញ ។ មេធាវីបន្តថា អ្នកជំនាញ និងសាក្សីមួយចំនួនយល់ឃើញថា ការរត់គេចខ្លួនរបស់ ខៀវ សំផន នៅពេលនោះ គឺដើម្បីគេចចេញពីការតាមចាប់ខ្លួនពីសំណាក់សម្តេចព្រះ នរោត្តម សីហនុ ។

មេធាវី គង់ សំអុន អះអាងថា ខៀវ សំផន ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានទេ ហើយបក្សកុម្មុយនីស្តកម្ពុជាមិនអាចទុកចិត្ត និងប្រគល់តំណែងសំខាន់ណាមួយពិតប្រាកដឲ្យ ខៀវ សំផន ដែរ ។ មេធាវីបន្តថា រយៈពេល២ឆ្នាំបន្ទាប់ពីរត់ចូលទៅរស់នៅក្នុងព្រៃម៉ាគី គឺនៅក្នុងឆ្នាំ១៩៦៩ ទើប ខៀវ សំផន ត្រូវបានអនុញ្ញាតឲ្យចូលជាសមាជិកបក្ស ។ នៅអំឡុងពេលនោះ ខៀវ សំផន ត្រូវសម្ងំលាក់ខ្លួនក្នុងជីវភាពមួយស្ងប់ស្ងាត់នៅតាមជនបទ ដោយពុំមានការងារធ្វើ ត្រូវចល័តពីភូមិមួយទៅភូមិមួយទៀត ។ ខៀវ សំផន កាន់តែពិបាកចិត្តនៅពេលដែលចលនាបដិវត្តមិនទុកចិត្តចំពោះបញ្ញាជន

គហបតីថ្នាក់ទាប ។

មេធាវីបានធ្វើការសន្និដ្ឋានថា បើពិនិត្យមើលលើការបង្ហាញរបស់សាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឲ្យឃើញថា ខៀវ សំផន មានអត្តចរិតស្លូតបូត សុភាពរាបសា ស្រឡាញ់យុត្តិធម៌ និងការរីកចម្រើនដែលផ្តល់នូវសុខុមាលភាព និងការអភិវឌ្ឍដល់សង្គម ។

**៧) តួនាទីរបស់ ខៀវ សំផន**

**ក) តួនាទីនៅចន្លោះពីឆ្នាំ១៩៧០ រហូតដល់១៩៧៥**

ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥ មេធាវី គង់ សំអុន បានអះអាងថា នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិ ខៀវ សំផន មានតំណែងខ្ពស់ ប៉ុន្តែពុំមានអំណាចអ្វី ឡើយ ។ មេធាវីបានលើកយកសម្តីរបស់ ខៀវ សំផន ដែលនិយាយថា "ហេតុអ្វីបានជាខ្ញុំដែលមើល ពីក្រៅមកឃើញថាកាន់តំណែងខ្ពស់ ហើយបែរជាមិនបានចូលរួមក្នុងការសម្រេចអ្វីធំដុំនៅក្នុងកិច្ចការរបស់បក្ស ឬកិច្ចការរបស់ប្រទេសនោះ? គឺដោយសារ ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាចាត់ទុក ខ្ញុំជាបញ្ញាជនរត់មករស់នៅជាមួយបក្សកុម្មុយនីស្តកម្ពុជា មិនមែនជាមនុស្សរបស់បក្សទេ ។ នេះជាការពិតនៅមុនឆ្នាំ១៩៧៥ ហើយនៅថ្ងៃតៗមកក្រោយទៀតក៏នៅតែយ៉ាងនេះ" ។ មេធាវី សំអុន បានអះអាងថែមទៀតថា បក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមនិយាយពីការចូលរួមរបស់ ខៀវ សំផន នៅក្នុង រចនាសម្ព័ន្ធបក្ស ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៥ តែប៉ុណ្ណោះ ។ នៅក្រោយរដ្ឋប្រហារ ប៉ុល ពត និង សម្តេច សីហនុ នៅទីក្រុងប៉េកាំង ដូចគ្នា ។ សម្ព័ន្ធភាពរវាងអ្នកទាំងពីរក៏បានចាប់ផ្តើមឡើង ។ មេធាវីបន្តថា នៅពេលនោះ ប៉ុល ពត មើលឃើញភ្លាមៗនូវអត្ថប្រយោជន៍ក្នុងការពង្រីកចលនាបដិវត្តន៍ដោយយក ខៀវ សំផន ធ្វើជាអ្នកទាក់ទងជាមួយនឹងសម្តេច សីហនុ។ នៅពេលនោះ ខៀវ សំផន បានទទួលដំណឹងថា គាត់ត្រូវបានប្រគល់ជូននូវឋានន្តរស័ក្តិជាផ្លូវការយ៉ាងមហាអធិអធមក្នុងអង្គភាពផ្សេងៗនៃរណសិរ្សរបស់សម្តេច សីហនុ និងខ្មែរក្រហមនៅកណ្តាលព្រៃ ។ មេធាវី សំអុន អះអាងថា ការទទួលយកតំណែងនេះ ដោយសារ ខៀវ សំផន ចង់ឲ្យមានការរួបរួមកម្លាំងជាតិក្រោយពីជួបវិបត្តិសង្គ្រាមធ្ងន់ធ្ងរដោយសារតែប្រទេសធំៗច្បាំងគ្នា ។ ខៀវ សំផន ធ្លាប់បានអះអាងថា "ក្រោយពេលរដ្ឋប្រហារ ខ្ញុំគ្រាន់តែចង់ឲ្យកម្លាំងជាតិ ទាំងអស់រួបរួមគ្នាសាមគ្គីតស៊ូ ។ ដល់ក្រោយរដ្ឋប្រហារមក សង្គ្រាមវៀតណាម វាហូរចូល



កម្មាភិបាលខ្មែរក្រហមកំពុងហូបបាយជុំគ្នាក្នុងកំឡុងពិធីបុណ្យខួបបក្ស (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកក្នុងដី យើងមហាយក្សទាំងអស់ដែលគេច្បាំងគ្នានៅវៀតណាមខាងត្បូង ក្រោយរដ្ឋប្រហារ គេមកច្បាំងគ្នា នៅក្នុងទឹកដីយើង នៅលើជាតិយើង» ។ មេធាវីរូបនេះបានបន្ថែមថា ការជ្រៀតចូលនៃកងទ័ពបរទេស មកប្រយុទ្ធគ្នានៅលើទឹកដីកម្ពុជា បានធ្វើឲ្យទ្រង់ទ្រាយនៃសង្គ្រាមកាន់តែធំឡើង ហើយបានទាញភាគីកម្ពុជាដែលកំពុងតែច្បាំងគ្នាឲ្យធ្លាក់ចូលក្នុងសង្គ្រាមដែរ ។ ហេតុដូច្នេះ ការទទួលតំណែងក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជារបស់ ខៀវ សំផន គឺដើម្បីការពារបូរណភាព និងឯករាជ្យជាតិនៃកម្ពុជាក្នុងនាមជាជនស្នេហាជាតិ ដែលជាការសម្រេចចិត្តដ៏ត្រឹមត្រូវ ។ មេធាវី គង់ សំអុន បានសង្កត់ធ្ងន់ថា ប្រសិនបើពុំមាន ខៀវ សំផន ធ្វើជាស្ពានទេ បក្សកុម្មុយ នីស្តកម្ពុជា និងសម្តេច សីហនុ មិនអាចរួបរួមគ្នាបានទេ ។ ហេតុនេះ ខៀវ សំផន ក៏ចេញមុខជាអ្នកដឹកនាំសំខាន់មួយនៃកម្លាំងតស៊ូនៅក្នុងប្រទេស ទោះបីជាមានការទើសទាល់ខ្លាំងចំពោះតំណែងខ្យល់នោះក៏ដោយ ។ តាមការពិត ខៀវ សំផន គ្មានការទទួលខុសត្រូវខាងយោធា ឬខាងនយោបាយឡើយ ព្រោះរាជរដ្ឋាភិបាលរួបរួមជាតិ គ្រាន់តែជារដ្ឋាភិបាលគ្មានអំណាចមួយប៉ុណ្ណោះ ចំណែកឯអំណាចពិតប្រាកដ ស្ថិតនៅក្នុងដៃរបស់គណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ហើយអំណាចនេះនៅតែបន្តស្ថិតនៅបែបនេះរហូតដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម ។ ខៀវ សំផន ពុំមានសមត្ថភាពខាងយុទ្ធសាស្ត្រយោធា ឬខាងបញ្ជាទ័ពទេ ។ បើយោងតាមអ្នកជំនាញ និងសាក្សី ដែលដឹងពីឋានានុក្រមយោធា បានលើកឡើងថា សុន សេន និង ប៉ុល ពត ជាអ្នកទទួលខុសត្រូវខាងកងទ័ពមិនមែន ខៀវ សំផន ទេ ។

ចុងក្រោយមេធាវី គង់ សំអុន បានធ្វើការសន្និដ្ឋានថា គ្មានឯកសារ ឬសក្ខីកម្មណាមួយ ដែលអាចបញ្ជាក់បានថា ខៀវ សំផន បានចូលរួមធ្វើសេចក្តីសម្រេចចិត្តក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជនដំណាក់កាលទី២ ដែលជាបទល្មើសស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង០០២/០១ទេ ។

បន្ទាប់ពីមេធាវី គង់ សំអុន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវី អាកតួរ វែរកែន សារជាថ្មីម្តងទៀត ដើម្បីឆ្លើយតបនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងទ្រឹស្តីនៃ«សំណាញ់ដែក» ។ នៅក្នុងបរិបទនេះ ពាក្យថាទ្រឹស្តី «សំណាញ់ដែក» ដែលសហព្រះរាជអាជ្ញា បានប្រើប្រាស់ដើម្បីចោទប្រកាន់លើជនជាប់ចោទ សំដៅលើការដាក់ប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសឯកោ ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងពិភពលោក ដោយពុំព្រមទទួលជំនួយផ្សេងៗពីអន្តរជាតិ ដែលជាហេតុធ្វើឲ្យប្រជាជនជួបប្រទះទុក្ខវេទនាហួសប្រមាណ ។ ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញានេះ មេធាវី វែរកែន បានអះអាងថា ការកសាងប្រទេសមួយពីចំណុចសូន្យ មិនអាចធ្វើបានក្នុងរយៈពេលមួយថ្ងៃទេ និងបានបន្ថែមថា តាមការពិត ខ្មែរក្រហមពុំបានផ្តាច់ទំនាក់ទំនងជាមួយនឹងពិភពលោកទេ ។ ខ្មែរក្រហមនៅតែមានទំនាក់ទំនងជាមួយក្រុមប្រទេសកុម្មុយនីស្ត និងប្រទេសមិនចូលបក្សសម្ព័ន្ធ ។ មានគណៈប្រតិភូបរទេសមួយចំនួនមិនធ្វើទស្សនកិច្ចនៅកម្ពុជា ឧទាហរណ៍ជាក់ស្តែង ដូចជា ទស្សនកិច្ចនៅកម្ពុជារបស់គណៈប្រតិភូវៀតណាម កូរ៉េខាងជើង យូហ្គោស្លាវី ឡាវ អាល់បានី ចិន ប៉ាឡេស្ទីន សំប៊ី ស៊ុយអែត ទុយនីស៊ី អាហ្វ្រិកនីស្ថាន សេណេហ្គាល់ ម៉ូរីតានី យូហ្គោស្លាវី វៀតណាម កូរ៉េ ម៉ាលីតង់សានី ដាណឺម៉ាក ហ្វាំឡង់ ភូមា អាល់ហ្សេរី ជាដើម ។

មេធាវី វែរកែន បានរិះគន់ការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលនិយាយថា នៅពេលដែលប្រទេសមួយបដិសេធមិនព្រមទទួលជំនួយពីសហរដ្ឋអាមេរិក ជាភស្តុតាងបង្ហាញថាប្រទេសនោះកំពុងតែក្លាយជាប្រទេសបិសាច ។ មេធាវីបានចោទជាសំណួរថា តើពិតទេដែរថា របបកម្ពុជាប្រជាធិបតេយ្យបានបដិសេធរាល់ជំនួយបរទេសទាំងអស់ ដើម្បីឃុំខ្លួននៅក្នុងរបបឧក្រិដ្ឋ និងផ្តាច់ការ? បើតាមឧទាហរណ៍ខាងលើប្រទេសកម្ពុជាពិតជាបានទទួលជំនួយពីបរទេស មិនដូចជាការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ។

ចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាថា របបកម្ពុជាប្រជាធិបតេយ្យបានដាក់ប្រទេសកម្ពុជាឲ្យទៅជារដ្ឋទាសករ ជាការលើកឡើងដែលមានលក្ខណៈជានយោបាយជាជាងលក្ខណៈច្បាប់ ។ ការចោទប្រកាន់ ខៀវ សំផន ថាបានចូលរួមក្នុងការធ្វើឲ្យកម្ពុជាក្លាយជារដ្ឋទាសករ ជាការចោទប្រកាន់ដែលពុំមានអំណះ

អំណាងច្បាស់លាស់ ។ ម្យ៉ាងវិញទៀត ៩០ភាគរយនៃអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលលើកអំពីការពាក់ព័ន្ធនឹងការចូលរួមចំណែក និងចេតនារបស់ ខៀវ សំផន សុទ្ធតែស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូង ។

### ១) តួនាទី ខៀវ សំផន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

បន្ទាប់ពីមេធាវី វ៉េកកែន អង្គជំនុំជម្រះបានបន្តប្រគល់វេទិកាជូនមេធាវី អង់តា ហ្គីសសេ សាជាថ្មីទៀត ដើម្បីធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងការចូលរួមរបស់ ខៀវ សំផន ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ មេធាវី ហ្គីសសេ បានអះអាងថា ខៀវ សំផន ពុំបានចូលរួមធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ដោយសារតែសេចក្តីសម្រេចនេះ ធ្វើឡើងជាសម្ងាត់ ហើយពុំបានប្រើប្រាស់ពាក្យថាជម្លៀសប្រជាជនទេ គឺប្រើពាក្យថា វាយផ្តាច់ព្រ័ត្រ ។ បន្ថែមពីលើនេះ ពុំមានសក្ខីកម្មរបស់សាក្សីណាមួយដែលអាចបញ្ជាក់បានថា ខៀវ សំផន បានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ។

ឆ្លើយតបនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំផន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសទាក់ទងនឹងការបង្រៀនក្នុងវគ្គសិក្សារៀនសូត្រ ការថ្លែងសុន្ទរកថា តួនាទីក្នុងក្រសួងពាណិជ្ជកម្ម និងតួនាទីនៅក្នុងមន្ទីរ៨៧០ មេធាវី ហ្គីសសេ បានបញ្ជាក់ថា ការចោទប្រកាន់នេះ គឺពុំស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះដំណាក់កាលដំបូងទេ ។ មេធាវីបន្តថា សវនាការដំណាក់កាលដំបូងកំណត់ត្រឹមវិសាលភាពនៃអង្គហេតុពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទី១ និងដំណាក់កាលទី២ រួមនឹងការសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ ដែលមានកាលបរិច្ឆេទមុនឆ្នាំ ១៩៧៦ រីឯការចោទប្រកាន់របស់សហព្រះរាជអាជ្ញាចំពោះតួនាទីរបស់ ខៀវ សំផន ក្នុងការបង្រៀនក្នុងវគ្គសិក្សារៀនសូត្រ តួនាទីក្នុងក្រសួងពាណិជ្ជកម្ម និងតួនាទីនៅមន្ទីរ៨៧០ សុទ្ធតែជាអង្គហេតុក្រោយឆ្នាំ១៩៧៦ ។ ដូច្នេះ សហព្រះរាជអាជ្ញាពុំអាចលើកឡើងអំពីចំណុចនេះនៅក្នុងសវនាការដំណាក់ដំបូងនេះបានទេ ។ ម្យ៉ាងវិញទៀត ភស្តុតាងដែលសហព្រះរាជអាជ្ញាប្រើប្រាស់ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួនចំពោះការចោទប្រកាន់លើចំណុចទាំងនេះ ពុំមានធាតុផ្សំណាមួយដែលបង្ហាញពីចេតនាឧក្រិដ្ឋ ឬការជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយ ខៀវ សំផន ទេ ។ មេធាវី ហ្គីសសេ បានលើកយកឯកសារជាច្រើន រួមជាមួយនឹងសក្ខីកម្មរបស់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបង្ហាញថា សក្ខីកម្មរបស់អ្នកទាំងនោះដែលលើកឡើងអំពីតួនាទីរបស់ ខៀវ សំផន ពុំមានភាពច្បាស់លាស់គួរឲ្យជឿជាក់ មានភាពច្របូកច្របល់ និងពុំមានភាពស៊ីសង្វាក់គ្នា ។

មុនពេលបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល មេធាវី អង់តា ហ្គីសសេ បានស្នើសុំឲ្យអង្គជំនុំជម្រះដោះលែង ខៀវ សំផន ឲ្យមានសេរីភាពឡើងវិញ ដោយសំអាងថា ខៀវ សំផន ពុំបានចូលរួមនៅក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការសម្លាប់អតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២ទេ ។ រីឯ តំណែង និងតួនាទីដែល ខៀវ សំផន មាននៅមុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គ្រាន់តែជាតំណែងដែលមានលក្ខណៈឧបកិច្ច ឬមានតែតួនាទី ប៉ុន្តែពុំមានអំណាច ។

### ៨) ចម្លើយតបចំពោះការចោទប្រកាន់លើការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

ឆ្លើយតបចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃថា ជាការប្រព្រឹត្តឡើងក្រោមគោលនយោបាយលុបបំបាត់អតីតអ្នករដ្ឋការនៃរបប លន់ នល់ និងជាគោលនយោបាយបង្កើតឲ្យមានការវាយប្រហារមានលក្ខណៈជាទូទៅ និងជាប្រព័ន្ធ មេធាវី វ៉េកកែន បានអះអាងថា ការចោទប្រកាន់នេះជាការចោទប្រកាន់ដែលពុំសមស្រប ។ ម្យ៉ាងវិញទៀត សាក្សីដែលចូលមកផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុនេះ សុទ្ធតែផ្តល់ចម្លើយដែលមានលក្ខណៈមិនស៊ីសង្វាក់គ្នា និងពុំសូវមានភាពគួរឲ្យជឿជាក់បាន ។ សហព្រះរាជអាជ្ញា ពុំបានបង្ហាញភស្តុតាងគ្រប់គ្រាន់ ពុំមានឯកសារ ឬយោបល់របស់អ្នកជំនាញ ដែលអាចយកមកធ្វើជាមូលដ្ឋានបានទេ ។ មេធាវី

បន្តថា ដើម្បីអាចដឹងអំពីអត្ថិភាពនៃអង្គហេតុចាំបាច់ត្រូវតែដឹងអំពីខ្សែសង្វាក់នៃការចេញបញ្ជា ថាតើនរណាខ្លះបានចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនោះ ។

មេធាវី វែកគែន អះអាងថា ឯកសារផ្សេងៗពាក់ព័ន្ធនឹងប្រធានបទមហាជនក្បត់ទាំង៧ មិនមែនជាភស្តុតាងបង្ហាញអំពីចេតនារបស់ ខៀវ សំផន ក្នុងការសហការដើម្បីវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ សំដៅលើអតីតមន្ត្រីរដ្ឋការ លន់ នល់ ទេ ។ ប៉ុន្តែការសម្លាប់អតីតទាហានរដ្ឋការ លន់ នល់ អាចបណ្តាលមកពីការបានឆ្លើយតបរួចទៅហើយនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ដែលដាក់ជូនអង្គជំនុំជម្រះ ។ ចំពោះចំណុចដែលក្រុមមេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅត្រង់ការលើកឡើងថា ក្រុមមេធាវីការពារក្តី ខៀវ សំផន បានប្រើប្រាស់បញ្ហាសេដ្ឋកិច្ច និងបញ្ហាយោធា ដើម្បីយកមកធ្វើយុត្តិកម្ម (ការធ្វើឲ្យក្លាយទៅជារឿងត្រឹមត្រូវ) ចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ឆ្លើយតបនឹងការអះអាងដូច្នេះ ក្រុមមេធាវីការពារក្តី



ខៀវ សំផន (ស្តាំ) និង អៀង សារី (រូបកណ្តាល) កំពុងនាំគណៈប្រតិភូ ឡាវ ដឹកនាំដោយព្រះអង្គម្ចាស់ សុផានុវង្ស ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ទៅពិនិត្យមើលការដ្ឋានសំណង់ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

គុំកួនរបស់ប្រជាជននៅតាមមូលដ្ឋាន និងស្អប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនៅក្នុងរដ្ឋការ លន់ នល់ ។

### ៩) ការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា

សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំបានឆ្លើយតបច្រើនចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទេ ដោយអះអាងថា ដោយសារតែចម្លើយតបរបស់សហព្រះរាជអាជ្ញានៅតែលើកឡើងអំពីអង្គហេតុដោយពុំមានភាពជាប់ទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូង និងចំណុចផ្សេងទៀត ក្រុមមេធាវី ខៀវ សំផន ខៀវ សំផន បានពន្យល់ទៅវិញថា សូម្បីតែសហចៅក្រមស៊ើបអង្កេតក៏មិនបានបដិសេធបញ្ហាទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច យោធា និងសុខាភិបាល នៅមុនពេលនៃរបបខ្មែរក្រហមដែរ ។ ដើម្បីដឹងអំពីចេតនារបស់ ខៀវ សំផន ចាំបាច់ត្រូវតែដឹងអំពីស្ថានភាពទាំងនេះ ។ ពុំមែនត្រូវរកចម្លើយថា ហេតុអ្វី ខៀវ សំផន សម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ព្រោះ ខៀវ សំផន មិនបានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនទេ ។

ចំពោះការសម្រេចជម្លៀសប្រជាជនដំណាក់កាលទី២ មាន

ភស្តុតាងដែលមិនអាចប្រកែកបាន ដែលថា ខៀវ សំផន កំពុងនៅបរទេស នៅពេលដែលមានការជម្លៀសប្រជាជនក្នុងដំណាក់កាលទី២នេះ ហើយសូម្បីសហព្រះរាជអាជ្ញាក៏ពុំបានជំទាស់ចំពោះចំណុចនេះដែរ ។

ពាក់ព័ន្ធនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអំពីសហឧក្រិដ្ឋកម្មរួម មេធាវី វែកគែន អះអាងថា ចំពោះសំណើរបស់សហព្រះរាជអាជ្ញាសូមឲ្យអង្គជំនុំជម្រះអនុវត្តលក្ខណៈវិនិច្ឆ័យនៃទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមដោយចាត់ប្រទេសកម្ពុជានៅពេលនោះជាជំរំប្រមូលផ្តុំគឺជាសំណើសុំដែលមិនអាចអនុវត្តបានពីព្រោះអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះ ពុំជាប់ពាក់ព័ន្ធនឹងជំរំប្រមូលផ្តុំ ។

បន្ទាប់ពីមេធាវី អាក់ទូរ វែកគែន បញ្ចប់ការឆ្លើយតបនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានប្រគល់វេទិកាជូនជនជាប់ចោទ ខៀវ សំផន ដើម្បីឡើងថ្លែងកត់សម្គាល់អំពីអ្វីដែលជនជាប់ចោទមានបំណងចង់បង្ហាញនៅមុនពេលអង្គជំនុំជម្រះបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។

## ១០) សេចក្តីថ្លែងរបស់ ខៀវ សំផន

សូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ ដែលគង់នៅតាមវត្តអារាមនានាទូទាំងប្រទេស ។ សូមគោរពបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា ។ សូមគោរពដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមទាំងអស់ ។ សូមគោរព លោកមេធាវី អស់លោក លោកស្រីមេធាវីទាំងអស់ ។ សូមគោរពសហព្រះរាជអាជ្ញា ។

ក្នុងរយៈប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានស្តាប់ច្បាស់អំពីអត្ថាធិប្បាយ... 

ក្នុងរយៈប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានស្តាប់ច្បាស់អំពីអន្តរាគមន៍របស់ភាគីនានា ហើយជាពិសេស អន្តរាគមន៍របស់អ្នកដែលបន្ទោសខ្ញុំ ថាខ្ញុំបាននិយាយតិចតួចពេកក្នុងរឿងក្តីរបស់ខ្ញុំនេះ ។ ក៏ប៉ុន្តែ ព្រមជាមួយគ្នានេះ ដែលបានប្រើប្រាស់អ្វីដែលខ្ញុំបាននិយាយបន្តិចបន្តួចនោះ មកចោទលើរូបខ្ញុំទៅវិញ ។ ហេតុនេះ បើទោះជាខ្ញុំនិយាយពន្យល់ ដោយបដិសេធមិនព្រមទទួលការចោទប្រកាន់របស់អស់លោក ក៏អស់លោកនៅតែបន្ទោស ខ្ញុំតែបើខ្ញុំនៅស្ងៀម ក៏អស់លោកនៅតែចោទប្រកាន់ខ្ញុំដដែល ។ ខ្ញុំមិនដែលប្រាថ្នា ឬក៏បានសម្រេចជម្លៀសប្រជាជនអ្វីទាល់តែសោះ ហើយខ្ញុំក៏មិនដែលប្រាថ្នា ឬសម្រេចឲ្យមានការកាប់សម្លាប់អ្វីទាល់តែសោះ ។ ជំនឿខាងនយោបាយរបស់ខ្ញុំ អ្វីដែលខ្ញុំបានខិតខំធ្វើសកម្មភាពជាហូរហែរកន្លងមកនេះ គឺដើម្បីការពារអ្នកទន់ខ្សោយ គឺដើម្បីឲ្យគេគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ហើយដើម្បីជាតិយើង កម្ពុជាយើង មានភាពរឹងមាំ និងឯករាជ្យបរិបូរណ៍ ។ បាទ! ពិតណាស់ ភាពអយុត្តិធម៌ក្នុងសង្គម ធ្វើឲ្យខ្ញុំមិនពេញចិត្តទាល់តែសោះ តែវាមិនដល់ថ្នាក់ថា ខ្ញុំចង់ឲ្យអ្នកដទៃទទួលភាពអយុត្តិធម៌វិញនោះឡើយ ។ ឧត្តមគតិរបស់ខ្ញុំ គឺជាតិឯករាជ្យភាព និងប្រជាជនរស់នៅបានធូរធារ និងសប្បុរសប្បាយ និងទទួលបាននូវកត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ដូចគេឯងឡើងវិញ ។ ក៏ប៉ុន្តែពេលដែលខ្ញុំបានឮអ្វីដែលចោទប្រកាន់ដល់រូបខ្ញុំ និងរបៀបនៃការចោទប្រកាន់នៅទីនេះ ហើយពេលដែលខ្ញុំ មើលឃើញថាអ្នកដែលនឹងត្រូវចូលរួមសម្រេចលើរឿងក្តីរបស់ខ្ញុំនេះបានបដិសេធមិនព្រមពិចារណាដល់សភាពការណ៍ជាក់ស្តែងនៅសម័យកាលនោះ ដោយមើលមកខ្ញុំថា ខ្ញុំជាព្រាយបិសាចនោះ ខ្ញុំលែងចង់និយាយស្តីអីទៀតហើយ ។ បាទ! កាលពីសម័យរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ខ្ញុំប្រាថ្នាចង់ឲ្យខ្មែរក្រហម និងសម្តេចសីហនុ ទទួលបានជ័យជម្នះក្នុងសង្គ្រាម ហើយខ្ញុំបានចូលរួមជាមួយពួកគេ ។ ក្រោយពីការលាលែងរបស់ សម្តេច សីហនុពីតំណែងប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ខ្ញុំបានជឿថា មានការកសាងប្រទេសឲ្យបានរីកចម្រើន ។ អស់លោកអ្នកទាំងអស់គ្នាដែលនៅទីនេះ អស់លោកហាក់ដូចជាជឿជាក់ថា ខ្ញុំខុស ព្រោះអស់លោកទាំងអស់គ្នាជឿថា ខ្ញុំគួរតែបានប្រមាណមើលឃើញអំពីអ្វី ដែលបានកើតឡើងនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយខ្ញុំគួរតែឈប់ចូលរួម ឬក៏រត់គេចខ្លួនចេញពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែខ្ញុំនៅបន្តទៅទៀត លោក ក៏ចោទថាខ្ញុំជាពិរុទ្ធជន បើទោះជាខ្ញុំអាចនិយាយបកស្រាយ និងព្យាយាមពន្យល់យ៉ាងណាក៏ដោយ ។ តាមអស់លោក ខ្ញុំគួរតែទុកឲ្យ លន់ នល់ បន្តសកម្មភាពរបស់គេ ខ្ញុំមិនគប្បីតបតនឹងសកម្មភាពរបស់ លន់ នល់ ឡើយ ឬក៏នៅពេលទទួលបានជ័យជម្នះលើសង្គ្រាម លន់ នល់ និងពួកអាមេរិកហើយ ខ្ញុំត្រូវតែដឹងជាមុនថា នយោបាយ និងឧត្តមគតិរបស់ខ្ញុំ នឹងមិនត្រូវបានអនុវត្តន៍នោះទេ តែវានឹងត្រូវ

បង្វែរតាមទិសផ្ទុយពីនេះទៅវិញ ។ ដោយខ្មែរក្រហមដែលគេមានអំណាច គេបានអនុវត្តន៍វិធានការតឹងរឹងនោះ ។ ខ្ញុំមិនបានឃើញរឿងរ៉ាវ ដែលអាចកើតឡើងនៅថ្ងៃក្រោយនោះទេ ហើយខ្ញុំក៏មិនមានអំណាចអ្វីដាក់កំហិតឲ្យគេកែប្រែនោះដែរ ។ អ្នកខ្លះថាខ្ញុំជាជនកំសាក ឯខ្ញុំ ខ្ញុំមិនមែនជាអ្នកមានអំណាចអ្វី ហើយខ្ញុំក៏មិនខ្វល់អ្វីពីរឿងអត់អំណាចនេះដែរ ។ នេះប្រហែលជាទោសកំហុសរបស់ខ្ញុំ ព្រោះថាក្នុងពេលតៗមក ខ្ញុំក៏ស្ថិតនៅក្បែរៗអ្នកមានអំណាចផងដែរ តែខ្ញុំមិនអំណាចដូចគេនោះទេ តែអស់លោកជឿជាក់ថាខ្ញុំមានអំណាច ដូច្នេះហើយបានជាថ្ងៃនេះ ខ្ញុំត្រូវបានគេចាប់ខ្លួនយកមកកន្លែងនេះ ។ នៅថ្ងៃនេះ វាងាយស្រួលណាស់ដែលនិយាយថា ខ្ញុំគួរតែដឹងរឿងរ៉ាវ និងយល់រឿងរ៉ាវទាំងអស់ ហើយ ដូច្នេះខ្ញុំអាចកែប្រែសភាពការណ៍បានទាំងអស់ ។ តើទាំងអស់គ្នាយល់ថា ខ្ញុំមិនបានព្យាយាមរកយល់ឬ? តើទាំងអស់គ្នាពិតជាយល់ឃើញថា នេះជាអ្វីដែលខ្ញុំចង់បាន សម្រាប់ប្រជាជនរបស់ខ្ញុំឬ? កាលពីនៅយុវវ័យ ខ្ញុំបានខិតខំទៅតាមលទ្ធភាព និងមធ្យោបាយរបស់ខ្ញុំ ក្នុងគោលបំណងចង់កែប្រែរបបអយុត្តិធម៌ ក្រោយមកខ្ញុំក៏ត្រូវបង្ខំចិត្តរត់គេចខ្លួន ខ្ញុំបានរួចជីវិត ដោយសារតែខ្ញុំរត់ចូលព្រៃ ។ បន្ទាប់មកទៀត នៅពេលដែលខ្ញុំគិតថា មានមនុស្សគេអាចបំពេញកិច្ចការបានប្រសើរជាងខ្ញុំ ដើម្បីផលប្រយោជន៍ប្រជាជន និងជាតិរបស់ខ្ញុំ ខ្ញុំក៏ប្រាថ្នាចង់ឲ្យអ្នកទាំងនោះទទួលបានជ័យជម្នះ ហើយខ្ញុំក៏បានផ្តល់ដល់ពួកគេនូវការឧបត្ថម្ភដ៏តិចតួចស្តួចស្តើងតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន ពីព្រោះខ្ញុំជឿជាក់ទៅលើគម្រោងបដិវត្តន៍របស់គេនោះថា នឹងនាំឲ្យសង្គមបានប្រសើរជាងមុន ជាតិខ្ញុំបានរស់គង់វង្ស ទោះណាប្រទេសខ្ញុំត្រូវទទួលរងគ្រោះដោយសង្គ្រាមមហាវិនាសសកម្ម ហើយត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទី រហូតដល់នាំឲ្យមានគ្រោះអាសន្នទុរ្ភិក្ស ថែមទៀតផងក៏ដោយ ។ ផ្ទុយស្រឡះពីការដែលបានលើកឡើងនៅក្នុងសវនាការនេះ ខ្ញុំមិនដែលបានចូលរួមធ្វើផែនការ ដែលនាំបង្កឲ្យមានទុក្ខវេទនាទាល់តែសោះ គឺមិនដែលទាល់តែសោះ មិនដែលទាល់តែសោះ ។ ដូចដែលខ្ញុំបានព្យាយាមនិយាយជម្រាបទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលបានឡើងមកនិយាយ នៅក្នុងសវនាការនេះដូច្នោះដែរ គឺថា ខ្ញុំមិនដែលគិតថា ចង់ឲ្យរឿងទាំងនេះកើតឡើងទាល់តែសោះ នេះគឺជារឿងតែមួយគត់ ដែលខ្ញុំអាចនិយាយនៅថ្ងៃនេះ ។ នេះជាការពិត ប៉ុន្តែគ្មាននរណាចង់ស្តាប់ខ្ញុំឡើយ ។ នៅចំពោះមុខការមិនរវល់អើពើដល់ការខិតខំពន្យល់របស់ខ្ញុំចំពោះមុខលក្ខខណ្ឌដំណើរការនៅតុលាការនេះ ខ្ញុំមានអារម្មណ៍ថា ទោះបីខ្ញុំខំនិយាយពន្យល់យ៉ាងណាក៏ដោយ ក៏គេនៅតែមិនយកចិត្តទុកដាក់ស្តាប់ខ្ញុំឡើយ ។ ផ្ទុយទៅវិញ ខ្ញុំមានអារម្មណ៍ថា ពេលណាខ្ញុំនិយាយ គេរឹងតែចងកំហឹងនឹងខ្ញុំកាន់តែខ្លាំងឡើងទៅទៀត ។ ដូច្នេះខ្ញុំគិតថា ខ្ញុំមិនបាច់ឆោតល្ងង់ទៅនិយាយពន្យល់អ្នកមិនដែលចង់ស្តាប់ខ្ញុំនោះទេ ។ ខ្លួនខ្ញុំក៏ខ្ញុំសោកស្តាយណាស់ដែរ ដោយខំជឿយ៉ាងខ្លាំងពីដំបូងថា តុលាការនេះអាចជាឱកាសសម្រាប់រូបខ្ញុំក្នុងការពន្យល់ ក៏ប៉ុន្តែគ្រប់គ្នាចង់បានតែម្យ៉ាងគត់ពីខ្ញុំ គឺការសារភាពសុទ្ធសាធទៅតាមអ្វីដែលគេចោទមកលើខ្ញុំ ឯការចោទប្រកាន់នេះទៀត ក៏ជាការចោទប្រកាន់លើអំពើដែលខ្ញុំមិនបានប្រព្រឹត្តទាល់តែសោះ ។ ដោយហេតុថា ខ្ញុំមិនបានដឹងព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់ ណាមួយខ្ញុំគ្មានហេតុផលអ្វីទៅលន់តួចំពោះការបង្ខំដាច់ណាត់មកលើខ្ញុំនេះដែរ ។ ខ្ញុំយល់ថា ការនៅស្ងៀមមិននិយាយស្តីរបស់ខ្ញុំ វាស្របនឹងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្ញុំជាង ។ ហើយខ្ញុំទុកលទ្ធភាព ជូនអស់លោក លោកស្រីចៅក្រមវិនិច្ឆ័យរូបខ្ញុំទៅចុះ ។ មេធាវីទាំងអស់របស់ខ្ញុំ និងក្រុមការងាររបស់ខ្ញុំ បានការពារខ្ញុំយ៉ាងរឹងមាំ យ៉ាងខ្លាំងក្លា និងប្រកបដោយការជឿជាក់ ហើយខ្ញុំសូមអរគុណដល់អ្នកទាំងអស់គ្នា ទោះបីលទ្ធផលវាទៅជាយ៉ាងណាក៏ដោយ ។ ខ្ញុំសង្ឃឹមជឿជាក់ថា ទោះជាយ៉ាងណាក្តី អស់លោក លោកស្រី នឹងស្វែងរកយុត្តិធម៌ ។ សូមអរគុណ ។

បន្ទាប់ពីការស្តាប់សេចក្តីថ្លែងការបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីទាំងអស់ និងការស្តាប់សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ ។ គួរបញ្ជាក់ថា សំណុំរឿង០០២ នៅពុំទាន់បានបិទបញ្ចប់ទាំងស្រុងនោះទេ ។ សាលក្រមនៃសំណុំរឿង ០០២/០១ អាចនឹងចេញនៅក្នុងឆមាសទីមួយនៃឆ្នាំ២០១៤ ។ ចំពោះការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ អង្គជំនុំជម្រះសាលាដំបូងពុំទាន់ជូនដំណឹងនៅឡើយទេ ។

## ពន្យល់ពាក្យសំខាន់ៗ

**១**-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញា ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរ ចំពោះករណីបទល្មើសណាមួយ និងធ្វើការចោទប្រកាន់ ។

**២**-ដីកាសន្និដ្ឋានស្ថាពរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើដីកាដំណោះស្រាយចំពោះសំណុំរឿងណាមួយ ។

**៣**-ដីកាដំណោះស្រាយ ៖ សំដៅទៅលើដីកាចុងក្រោយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ការស៊ើបសួរដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ dccam@online.com.kh

គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*Bereau of Democracy, Human Rights, and Labor,*

*U.S. Department of State*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យច័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ទូន ឡៃហុល**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

